ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

## របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

**ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**

**កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**

# ព្រះរាជក្រម

នស/រកម/០៦២៥/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៣ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើ
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
# របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១ .-**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ៧ រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២៥

ពរស. ៧៥០៦. ៧៤៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# បុព្វកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍ក្រោមម្លប់នៃសុខសន្តិភាពនៅទូទាំងប្រទេស ដែលសម្រេចបានតាមរយៈ **នយោបាយឈ្នះ ឈ្នះ** របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបានកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍជាតិ ដោយសម្រេចបានសមិទ្ធផលធំៗជាច្រើនលើគ្រប់វិស័យ និងបានឈានដល់ការសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។ ជាការពិត សមិទ្ធផលនិងវឌ្ឍនភាពគួរជាទីមោទនៈទាំងនេះ កើតចេញពីជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណនិងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល របស់រាជរដ្ឋាភិបាលកម្ពុជា។

មូលដ្ឋានគ្រឹះដ៏រឹងមាំនៃការអភិវឌ្ឍជាតិ ការរក្សាបាននូវចីរភាពនៃសុខសន្តិភាព និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ជាប្រចាំឱ្យកាន់តែមុតស្រួច បានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ចនិងការវិនិយោគ ដែលជាប្រភពនៃការបង្កើតការងារសម្រាប់ប្រជាជននិងជាចលករជំរុញសេដ្ឋកិច្ចឱ្យសម្រេចបានកំណើនខ្ពស់ក្នុងអត្រាប្រចាំឆ្នាំជាមធ្យម៧% ក្នុងរយៈពេលពីរទសវត្សរ៍មុនវិបត្តិសកលកូវីដ-១៩។ ការណ៍នេះបានផ្តល់កាលានុវត្តភាព ក្នុងការបង្កើនការវិនិយោគសាធារណៈ ការអភិវឌ្ឍធនធានមនុស្សនិងមូលធនមនុស្ស កិច្ចគាំពារសង្គមរឹងមាំ ការកាត់បន្ថយភាពក្រីក្រ និងវិសមភាពជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់។

ផ្អែកលើបទពិសោធ សមិទ្ធផលដែលទទួលបានក្នុងរយៈពេល២៥ឆ្នាំកន្លងទៅ និងការពិនិត្យវាយតម្លៃនិន្នាការតំបន់និងសកល ក៏ដូចជាការសម្លឹងទៅមុខសម្រាប់រយៈពេល២៥ឆ្នាំ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ** ដើម្បី**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចរយៈពេលវែង និងត្រូវអនុវត្តជា៥ដំណាក់កាល។ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** គឺជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីអនុវត្តសម្រាប់រយៈពេល៥ឆ្នាំ សំដៅការពារ ថែរក្សា និងពូនជ្រំសមិទ្ធផលជាតិ ដើម្បីបន្តលើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែតបន្ថែមមួយកម្រិតថ្មីទៀត ជំរុញសន្ទុះកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅដល់ការសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់ ប្រកបដោយអរិយធម៌ថ្កុំថ្កើងរុងរឿង។

**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលរួមគ្នាបំពេញតួនាទីជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលបានកំណត់សកម្មភាពអាទិភាពនិងសូចនាករគន្លឹះច្បាស់លាស់ សំដៅសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ ពង្រឹងឯករាជ្យភាព និងភាពម្ចាស់ការលើខ្លួនឯង

ដើម្បីនាំនាវាកម្ពុជាឱ្យចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួចជាស្ថាពរនៅឆ្នាំ២០២៩ ដោយរលូននិងប្រកបដោយចលនការ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គឺជាផែនទីបង្ហាញផ្លូវដល់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ និងជាឧបករណ៍សម្រាប់អនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងវិធានការគន្លឹះទាំង៥** ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ធានានូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំនិងកំណត់នូវសកម្មភាពអាទិភាព កម្មវិធី គម្រោងតាមវិស័យ និងសូចនាករសមិទ្ធកម្មគន្លឹះនានា សម្រាប់តម្រង់ទិសនិងបង្កភាពងាយស្រួលដល់គ្រប់តួអង្គពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដ៏មានសារៈសំខាន់នេះ ដោយមានបញ្ចូលនូវយន្តការជំរុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ។

ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ ខិតខំរួមគ្នាជាកម្លាំងរួមតែមួយ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ឱ្យសម្រេចជោគជ័យតាមទិសដៅអភិវឌ្ឍន៍ជាតិឱ្យខាងតែបាន ក្នុងស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្មបំផុត ស្របតាមអភិក្រម **«ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»** និងតាមការចង្អុលបង្ហាញដោយសកម្មភាពអាទិភាព កម្មវិធី គម្រោងតាមវិស័យ និងសូចនាករសមិទ្ធកម្មគន្លឹះនានា ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រនេះ ដើម្បីសម្រេចទិសដៅដែលបានកំណត់ និងបំពេញបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងជំរុញសម្ទុះការអភិវឌ្ឍជាតិ ប្រកបដោយបរិយាបន្ន សមធម៌ ភាពធន់ និងចីរភាព។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការនិងជាប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមទាំងវិស័យឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានដឹកនាំនិងចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនេះ។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិទាំងអស់ ដែលបានជួយគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ និងរួមចំណែកដល់ការសម្រេចបានវឌ្ឍនភាពនិងជោគជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

ថ្ងៃ ច័ន្ទ ៦រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៥

**ហ៊ុន ម៉ាណែត**

# មាតិកា


**បុព្វកថា** ....................................................................................................... i

**សេចក្តីផ្តើម** ....................................................................................................... ១

**ជំពូកទី១ សមិទ្ធផលនិងបញ្ហាប្រឈមក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣** ....................................................... ៤

**១.១- សមិទ្ធផលចម្បងៗនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣** ....................................... ៤

១.១.១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ ....................................... ៤

១.១.២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ....................................... ១០

១.១.៣- ការអភិវឌ្ឍធនធានមនុស្ស ....................................... ១៥

១.១.៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច ....................................... ២១

១.១.៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ ....................................... ២៨

១.១.៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន ....................................... ៣០

**១.២- សមិទ្ធផលចម្បងៗក្នុងឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា** .......... ៣៨

**១.៣- បញ្ហាប្រឈមក្នុងការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣** ....................................... ៤៣

**ជំពូកទី២ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា** ....................................... ៤៨

**២.១- សមិទ្ធផលឆ្នាំ២០១៩-២០២៣** ....................................... ៤៨

២.១.១- ស្ថានភាពនៃកំណើនសេដ្ឋកិច្ច ....................................... ៤៨

២.១.២- ស្ថានភាពនៃការវិនិយោគ ....................................... ៥០

២.១.៣- ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ....................................... ៥១

២.១.៤- ស្ថានភាពបំណុលសាធារណៈ ....................................... ៥៣

២.១.៥- អតិផរណានិងអត្រាប្តូរប្រាក់ ....................................... ៥៤

២.១.៦- ស្ថានភាពរូបិយវត្ថុ ....................................... ៥៤

២.១.៧- ស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ....................................... ៥៥

២.១.៨- ជញ្ជីងទូទាត់កម្ពុជា ....................................... ៥៧

២.១.៩- ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងភាពក្រីក្រ ....................................... ៥៩

**២.២- បញ្ហាប្រឈមនិងកាលានុវត្តភាព** ....................................... ៦០

២.២.១- បញ្ហាប្រឈម ....................................... ៦០

២.២.២- កាលានុវត្តភាព ....................................... ៦១

**២.៣- ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនិងគោលដៅកំណើនសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា** ........ ៦២

២.៣.១- គោលដៅនៃកំណើនសេដ្ឋកិច្ចតាមវិស័យ ........................................................ ៦២
២.៣.២- ចំហាក(សេណារីយ៉ូ)ម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅមុខ ............................................ ៦៤
**២.៤- គោលដៅយុទ្ធសាស្ត្រនិងគោលនយោបាយអាទិភាពសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា.......... ៦៦**
២.៤.១- គោលដៅយុទ្ធសាស្ត្រ................................................................................ ៦៦
២.៤.២- គោលនយោបាយអាទិភាព ........................................................................ ៦៧
២.៤.៣- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ............................................ ៦៨
២.៤.៤- ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ ........................................................ ៧០
២.៤.៥- ក្របខ័ណ្ឌគោលនយោបាយទាក់ទាញវិនិយោគ ............................................ ៧១

**ជំពូកទី៣ គោលនយោបាយនិងសកម្មភាពអាទិភាព សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ........................................................ ៧៣**

**៣.១- ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ........................................................ ៧៣**
៣.១.១- ការពង្រឹងនិងការកែទម្រង់ស្ថាប័ន.......................................................... ៧៣
៣.១.២- ការលើកកម្ពស់សមត្ថភាពធនធានមនុស្សនិងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ........................................................ ៧៧
៣.១.៣- ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ .................. ៧៩
៣.១.៤- ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌ .................... ៨១
៣.១.៥- ការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច.............................................. ៨៥
**៣.២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ........................................ ៨៨**
៣.២.១- ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ .... ៨៨
៣.២.២-ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងឈ្លាសវៃ ...... ៩៣
៣.២.៣-ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................ ៩៤
៣.២.៤-ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ននិងស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ........................................................ ៩៧
៣.២.៥-ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងសកលលោក ...................... ៩៩
**៣.៣- ការអភិវឌ្ឍមូលធនមនុស្ស.......................................................................... ១០៣**
៣.៣.១-ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.................... ១០៣
៣.៣.២-ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ........................................................ ១០៦
៣.៣.៣-ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន........................................ ១០៧
៣.៣.៤-ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង .............................................. ១១០
៣.៣.៥-ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន........................................................ ១១៥

**៣.៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង ..... ១១៩**
៣.៤.១- ការអភិវឌ្ឍវិស័យគន្លឹះនិងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច ..... ១១៩
៣.៤.២-ការលើកកម្ពស់ការតភ្ជាប់និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូននិងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល ..... ១២៤
៣.៤.៣-ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ ..... ១៣១
៣.៤.៤- ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក ..... ១៣៣
៣.៤.៥-ការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាននិងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ..... ១៣៥
**៣.៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ ..... ១៣៨**
៣.៥.១- ការអភិវឌ្ឍទីផ្សារការងារ ..... ១៣៨
៣.៥.២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ..... ១៤១
៣.៥.៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន ..... ១៤៤
៣.៥.៤- ការពង្រឹងការប្រកួតប្រជែង ..... ១៤៥
៣.៥.៥- ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ..... ១៤៧
**៣.៦- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ..... ១៥២**
៣.៦.១- ការធ្វើសុកបរម្មូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ ..... ១៥២
៣.៦.២-ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព ..... ១៥៦
៣.៦.៣-ការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ ..... ១៦៤
៣.៦.៤- ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម ..... ១៦៨
៣.៦.៥-ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ..... ១៧២
**៣.៧- ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ..... ១៧៤**
៣.៧.១- ការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល ..... ១៧៤
៣.៧.២- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងប្រព័ន្ធនវានុវត្តន៍ឌីជីថល ..... ១៧៧
៣.៧.៣- ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ..... ១៧៩
៣.៧.៤- ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល ..... ១៨១
៣.៧.៥- ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ..... ១៨២

**ជំពូកទី៤ តម្រូវការធនធានហិរញ្ញវត្ថុនិងការកំណត់កម្មវិធីចំណាយ............ ១៨៦**

៤.១- តម្រូវការវិនិយោគសរុប ........................................................................ ១៨៦

៤.២- តម្រូវការវិនិយោគសាធារណៈ .................................................................. ១៨៧

៤.៣- ប្រភពហិរញ្ញប្បទានសក្តានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ ................. ១៨៧

**ជំពូកទី៥ យន្តការអនុវត្ត តាមដានត្រួតពិនិត្យ វាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ........................................................................ ១៩០**

៥.១- យន្តការដឹកនាំសម្របសម្រួល.................................................................. ១៩០

៥.២- យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ..................................................... ១៩១

៥.៣- ការរៀបចំរបាយការណ៍............................................................................ ១៩៣

៥.៤- ការគ្រប់គ្រងហានិភ័យ ............................................................................ ១៩៤

**សេចក្តីសន្និដ្ឋាន............................................................................................ ១៩៦**

ឧបសម្ព័ន្ធទី១ តារាងសូចនាករសមិទ្ធកម្មសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ............................ ១៩៧

ឧបសម្ព័ន្ធទី២ ពាក្យបំពេញ ........................................................................ ២០៤

# សេចក្តីផ្តើម

ក្នុងដំណើរដ៏វែងឆ្ងាយនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច កម្ពុជាបានឆ្លងកាត់បរិការណ៍សេដ្ឋកិច្ច សង្គម នយោបាយ និងប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនិងជាច្រើនដំណាក់កាល។ តាមរយៈ **នយោបាយឈ្នះ ឈ្នះ** របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានិងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាជម្នះបានទាំងស្រុងពីការអូសបន្លាយជម្លោះផ្ទៃក្នុងជិតបីទសវត្ស ព្រមទាំងទទួលបាននូវសុខសន្តិភាពពេញលេញ ការឯកភាពជាតិ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មាននីតិរដ្ឋនិងស្ថិរភាពនយោបាយ សម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ។ ទោះបីត្រូវប្រឈមនឹងឥទ្ធិពលពីការប្រែប្រួលនៃបរិការណ៍សកល ដូចជាបញ្ហាប្រឈមខាងសេដ្ឋកិច្ចសកល ការរាតត្បាតនៃជំងឺកូវីដ-១៩ ការប្រកួតប្រជែងលើភូមិសាស្ត្រនយោបាយ និងជម្លោះនិងសង្គ្រាមតាមតំបន់មួយចំនួននៅក្នុងសកលលោក រាជរដ្ឋាភិបាលនៅតែអាចសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើន ក្នុងការកសាងសង្គមជាតិ ដោយរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ ក្នុងរយៈពេលជាងពីរទសវត្សរហូតដល់ការរីករាលដាលនៃជំងឺសកលកូវីដ-១៩ រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព ព្រមទាំងបានលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាជនប្រកបដោយបរិយាបន្ន។ ឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំនេះ សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញ ដោយមានកំណើនវិជ្ជមានចាប់ពីឆ្នាំ២០២១ និងបន្តរក្សាបានកំណើនវិជ្ជមានក្នុងបណ្តាឆ្នាំបន្តបន្ទាប់។

ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តនូវ «**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**» ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម សេដ្ឋកិច្ច ក្នុងនីតិកាលទី៧ នៃរដ្ឋសភា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលមានឋានានុក្រមទី៣ នៅក្នុងឯកសារក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ជាតិ បន្ទាប់ពី**កម្មវិធីនយោបាយ**និង**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** គឺជាផែនការចង្អុលបង្ហាញរយៈពេលមធ្យម ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ និង ជាឧបករណ៍គោលនយោបាយចម្បងក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្ររួមរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដូចបានកំណត់នៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះបំប្លែងការតម្រង់ទិសគោលនយោបាយយុទ្ធសាស្ត្រធំៗ ដែលមានចែងនៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ឱ្យក្លាយជាសកម្មភាពដែលអាចអនុវត្តបាន និងមានចរិតជាការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដាក់ចេញនូវវិធានការសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយជាលក្ខណៈវិស័យនិងអន្តរវិស័យ ដែលជាមគ្គុទ្ទេសក៍សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដោយតម្រឹមតម្រង់ជាមួយនឹងគោលដៅយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍជាតិ និងធានាថាបាវចនាទាំង៥ របស់**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ គឺកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ត្រូវបានយកមកគិតគូរ

ដោះស្រាយជាប្រព័ន្ធ ដើម្បីឆ្ពោះទៅដល់គោលដៅចុងក្រោយបង្អស់នៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច គឺការលើកកម្ពស់សុខុមាលភាពសេដ្ឋកិច្ចនិងសង្គមរបស់ប្រជាជន។

ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ផ្ដល់នូវក្របខ័ណ្ឌរួមមួយសម្រាប់ការធ្វើអាទិភាវូបនីយកម្ម និងការកៀរគរធនធានក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីធ្វើហិរញ្ញប្បទានដល់ការអនុវត្តវិធានការ សកម្មភាព កម្មវិធី និងគម្រោងនានា ដោយបន្ស៊ីការប្រើប្រាស់ធនធានជាមួយនឹងអាទិភាពជាតិ កំណត់នូវយន្តការតាមដានត្រួតពិនិត្យវឌ្ឍនភាពធៀបនឹងសូចនាករនិងចំណុចដៅ ដែលជាមូលដ្ឋានសម្រាប់ការកែតម្រូវអាទិភាព និងការបែងចែកធនធាន ដោយផ្អែកលើភស្តុតាង និងសម្រាប់ការលើកកម្ពស់គណនេយ្យភាព និងគិតគូរដាក់បញ្ចូលការចូលរួមរបស់កម្ពុជាក្នុងការអនុវត្តបណ្ដារបៀបវារៈអភិវឌ្ឍសកល។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏បានគិតគូរលើនិន្នាការតំបន់និងសកល ដែលជាកាលានុវត្តភាព ហានិភ័យ និងបញ្ហាប្រឈមដែលអាចមានកម្មវិបាកលើកម្ពុជា តាមរយៈការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច ដែលកើតឡើងពីការប្រណាំងប្រជែងឥទ្ធិពលរបស់ប្រទេសមហាអំណាច និងទំនោរទៅរកការកើនឡើងនៃការគាំពារនិយម ការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ជាពិសេសឌីជីថលូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ ដែលអាចមានកម្មវិបាកលើដំណើរនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

ជាមួយការគិតគូរជម្នះនូវបញ្ហាប្រឈម ហានិភ័យ និងនិន្នាការសកលចម្បងៗដែលអាចមានកម្មវិបាកអវិជ្ជមានមកលើកម្ពុជា ក៏ដូចជាការត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយតបទាន់ពេល និងកាលានុវត្តភាពនានាដែលអាចចាប់យកបាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះផ្ដោតជាចម្បងលើគោលដៅអាទិភាពសំខាន់ៗ និងការតម្រង់ទិសលើការកំណត់សកម្មភាពអាទិភាព វិធានការ កម្មវិធី និងគម្រោងតាមវិស័យរបស់ក្រសួង ស្ថាប័នអនុវត្ត ព្រមទាំងបានរៀបចំយន្តការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងសម្រិតសម្រាំងសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារ បែងចែកផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ធានាបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំឆ្ពោះទៅដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់ ប្រកបដោយអារ្យធម៌រុងរឿង។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ត្រូវបានរៀបចំឡើងដោយចែកចេញជា៥ជំពូក តាមទម្រង់ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**។ ជំពូកទី១ ពិពណ៌នាអំពីសមិទ្ធផលចម្បងៗនៃការអនុវត្ត ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា និងសមិទ្ធផលសំខាន់ៗ ដែលសម្រេចបានតាមរយៈការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងឆ្នាំ២០២៤ និងបញ្ហាប្រឈមចម្បងៗ។ ជំពូកទី២ បង្ហាញអំពីដំណើរវិវឌ្ឍនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេល៥ឆ្នាំកន្លងទៅ និងកំណត់ក្របខ័ណ្ឌទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេល៥ឆ្នាំទៅមុខ តាមរយៈ ការវិភាគនិងការព្យាករ ដោយរំលេចឡើងអំពីកំណើនសេដ្ឋកិច្ច អនិកម្មភាព អតិផរណា

ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និងវិស័យក្រៅប្រទេស។ ជំពូកទី៣ ចង្អុលបង្ហាញនូវបណ្តាវិធានការ សកម្មភាព កម្មវិធី និងគម្រោងអាទិភាពនានារបស់ក្រសួង ស្ថាប័ន ដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ក្នុងនីតិកាលទី៧ នៃរដ្ឋសភា។ ជំពូកទី៤ បង្ហាញអំពីការប៉ាន់ស្មានតម្រូវការធនធានហិរញ្ញវត្ថុសម្រាប់ការ អនុវត្តវិធានការ និងសកម្មភាពទាំងអស់ ដែលបានដាក់ចេញនៅក្នុងផ.យ.អ.ជ. ដោយរំលេចពីតម្រូវការ វិនិយោគសរុប ទាំងពីប្រភពវិស័យសាធារណៈនិងប្រភពវិស័យឯកជន ក៏ដូចជាប្រភពហិរញ្ញប្បទានក្នុង និងក្រៅប្រទេស។ ជំពូកទី៥ រៀបចំយន្តការអនុវត្ត តាមដានត្រួតពិនិត្យ វាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ដើម្បីជានាជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

# ជំពូកទី១
# សមិទ្ធផលនិងបញ្ហាប្រឈម ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗជាច្រើន ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលចង្អុលបង្ហាញដោយ**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ពាក់ព័ន្ធនឹងការបង្កើនល្បឿននៃការកែទម្រង់ស្ថាប័ននិងអភិបាលកិច្ច ការអភិវឌ្ឍធនធានមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។ ជំពូកនេះផ្តោតជាចម្បងលើសមិទ្ធផលធំៗ ដែលរាជរដ្ឋាភិបាលសម្រេចបានពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដោយផ្អែកលើភស្តុតាងជាក់ស្តែង តាមរយៈស្ថិតិដែលទទួលបានពីការធ្វើអង្កេត ជំរឿននិងទិន្នន័យពីគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងសមិទ្ធផលសំខាន់ៗ ដែលសម្រេចបានតាមរយៈការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងឆ្នាំ២០២៤។ ជាមួយគ្នានឹងការសម្រេចបានសមិទ្ធផលចម្បងៗជាច្រើន ការអនុវត្តផ.យ.អ.ជ. ក្នុងនីតិកាលទី៦ នៃរដ្ឋសភា កន្លងទៅនេះ ក៏ជួបនូវបញ្ហាប្រឈមមួយចំនួន ដែលចាំបាច់ត្រូវបន្តដោះស្រាយក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីឈានដល់ការសម្រេចសមិទ្ធផលថ្មីៗបន្ថែមទៀត និងគោលដៅរបស់**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ក៏ដូចជាទិសដៅនៃការអភិវឌ្ឍជាតិ ស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

## ១.១- សមិទ្ធផលចម្បងៗនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣

### ១.១.១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ

#### ការកែទម្រង់និងការលើកកម្ពស់សមត្ថភាពស្ថាប័ន

រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានយកចិត្តទុកដាក់ខ្ពស់លើការកែទម្រង់និងការលើកកម្ពស់សមត្ថភាពស្ថាប័ន ដើម្បីកសាងស្ថាប័នល្អនិងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ដោយការកែទម្រង់និងការលើកកម្ពស់សមត្ថភាពស្ថាប័ន មានលក្ខណៈអន្តរស្ថាប័ន ការងារនេះត្រូវបានចូលរួមអនុវត្តពីគ្រប់ក្រសួង ស្ថាប័ន តាមរយៈការរៀបចំនិងការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាមវិស័យ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការអភិវឌ្ឍធនធានមនុស្ស ស្របតាមស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដោយសម្រេចបានវឌ្ឍនភាពនិងសមិទ្ធផលគួរឱ្យកត់សម្គាល់។

ក្នុងវិស័យការពារជាតិ រាជរដ្ឋាភិបាលបានអនុវត្តផែនការកែទម្រង់យោធា ដោយធ្វើការកែសម្រួលរចនាសម្ព័ន្ធ ការពង្រឹងប្រព័ន្ធគ្រប់គ្រងនិងឋានានុក្រមដឹកនាំបញ្ជា កិច្ចការបទដ្ឋានបច្ចេកទេស កិច្ចការរដ្ឋបាល ការពង្រឹងការងារនីតិកម្មក្នុងការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងការងារនយោបាយការបរទេសយោធា។ កងយោធពលខេមរភូមិន្ទបានបន្តដើរតួនាទីជាកងកម្លាំងស្នូល ក្នុងការថែរក្សា

ការពារសន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងចូលរួមក្នុងបុព្វហេតុនានា សម្រាប់ជាផលប្រយោជន៍រួមក្នុងតំបន់និងសកលលោក តាមរយៈការបំពេញបេសកកម្មប្រតិបត្តិការរក្សាសន្តិភាព ក្រោមឆត្រអង្គការសហប្រជាជាតិ។ កន្លងមក កងយោធពលខេមរភូមិន្ទបានការពារនិងទប់ស្កាត់បានទាន់ពេលនូវរាល់ការប៉ុនប៉ងនិងការបង្កអស្ថិរភាពគ្រប់រូបភាព ព្រមទាំងបានចូលរួមប្រយុទ្ធយ៉ាងពេញលេញ ក្នុងការងារមនុស្សធម៌ ការទប់ស្កាត់និងការប្រឆាំងភេរវកម្ម ការបោសសម្អាតមីន និងកាកសំណល់សង្គ្រាមនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ មជ្ឈមណ្ឌលសម្រាប់យោធិនពិការត្រូវបានបង្កើតឡើង ដើម្បីផ្តល់សេវាកម្មសុខុមាលភាពដល់គ្រួសារកងទ័ពនិងនិវត្តជន ឱ្យបានទូលំទូលាយនិងមានប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ គឺជាផ្នែកមួយដ៏មានសារៈសំខាន់ ក្នុងការជំរុញការផ្តល់សេវាសាធារណៈ ឱ្យកាន់តែប្រសើរនិងមានប្រសិទ្ធភាព ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងគោលដៅប្រែក្លាយរដ្ឋបាលថ្នាក់ក្រោមជាតិទៅជារដ្ឋបាលឯកភាពមួយ ដើម្បីធានាឱ្យមានការឆ្លើយតបទាន់ពេលនិងមានប្រសិទ្ធភាព ស្របតាមសំណូមពរនិងតម្រូវការនៃការអភិវឌ្ឍនៅមូលដ្ឋាន។ រាជរដ្ឋាភិបាលបានរៀបចំកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងារ ការផ្ទេរសិទ្ធិអំណាចនិងមុខងារ ព្រមទាំងបានធ្វើវិមជ្ឈការហិរញ្ញវត្ថុ តាមរយៈការបង្កើនចំណាយកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ទៅនឹងការកសាងសមត្ថភាព ដើម្បីធានាតម្លាភាពនិងគណនេយ្យភាពច្បាស់លាស់និងភាពបត់បែនតាមស្ថានភាពជាក់ស្តែង។

ក្នុងការកែទម្រង់និងការគ្រប់គ្រងក្នុងវិស័យមុខងារសាធារណៈ រាជរដ្ឋាភិបាលបានលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ធ្វើបច្ចុប្បន្នកម្មកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ បង្កើតយន្តការប្រឡងប្រណាំងនិងយន្តការជំរុញការគាំទ្រចលនាប្រឡងប្រណាំង ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាជន ធ្វើការកែទម្រង់ប្រព័ន្ធបៀវត្សដោយដាក់ឱ្យដំណើរការការបើកបៀវត្សតាមប្រព័ន្ធធនាគារទាន់ពេលនិងទៀងទាត់ជារៀងរាល់២សប្តាហ៍ បង្កើនសុវត្ថិភាពក្នុងការបញ្ចូលទិន្នន័យ រៀបចំ បោះពុម្ព និងបានដាក់ឱ្យប្រើប្រាស់អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការប្រភេទថ្មី (Smart Card) ដែលមានមុខងារសម្រាប់ប្រើប្រាស់ក្នុងការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ (ATM) និងជាអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីរាជការផងដែរ ដំឡើងប្រាក់បៀវត្សនិងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីផ្សេងទៀតក្នុងក្របខ័ណ្ឌនៃលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ ដំឡើងជាបន្តបន្ទាប់នូវរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ពិសេសប្រាក់សោធនប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន កាត់បន្ថយគម្លាតរវាងប្រាក់សោធនអប្បបរមានិងអតិបរមា តាមរយៈការដំឡើងប្រាក់សោធនអប្បបរមាប្រចាំខែ ដោះស្រាយបញ្ហាគម្លាតប្រាក់សោធនចាស់និងប្រាក់សោធនថ្មីសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ធានាសង្គតិភាពរវាងប្រាក់សោធនរបស់អតីតមន្ត្រីរាជការ

ស៊ីវិលនិងអតីតយុទ្ធជន។ បន្ថែមលើនេះ រាជរដ្ឋាភិបាលកំពុងជំរុញការអនុវត្តវិធានការគន្លឹះទាំងបីក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ រួមមាន ១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ ប្រសិទ្ធភាព និងបរិយាបន្ន ២) ការលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពការងារប្រកបដោយវិន័យ សីលធម៌ និងវិជ្ជាជីវៈ និង ៣) ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

## ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើភាពស្អាតស្អំនិងគណនេយ្យភាពក្នុងវិស័យសាធារណៈ ដោយអនុវត្តអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** និងប្តេជ្ញាចិត្តលុបបំបាត់អំពើពុករលួយ តាមរយៈការពង្រឹង ការអប់រំ ការបង្ការទប់ស្កាត់ និងការអនុវត្តច្បាប់បង្ក្រាបអំពើពុករលួយដោយកសាងសំណុំរឿងបញ្ជូនទៅតុលាការជាបន្តបន្ទាប់ ការប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់មន្ត្រីរាជការ ការអនុវត្តភារកិច្ចស្របតាមផែនការយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងផែនការសកម្មភាពដែលកំណត់ដោយក្រុមអាស៊ីប៉ាស៊ីហ្វិកប្រឆាំងការសម្អាតប្រាក់ដែលធ្វើឱ្យកម្ពុជាត្រូវបានដកចេញពីបញ្ជីប្រផេះ ការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំប្រធានស្ថាប័នប្រឆាំងអំពើពុករលួយអាស៊ានលើកទី១៨ ដោយជោគជ័យនិងការចូលរួមយ៉ាងសកម្មក្នុងការអនុវត្តយន្តការចុះត្រួតពិនិត្យការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងអំពើពុករលួយដើម្បីជានាឱ្យមានរដ្ឋបាលសាធារណៈស្អាតស្អំនិងរឹងមាំ សម្រាប់ជំរុញការអភិវឌ្ឍ ប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព។

បន្ថែមលើនេះ ការធ្វើអធិការកិច្ចលើគ្រប់វិស័យ ការតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងបទបញ្ជារបស់រាជរដ្ឋាភិបាល ការទទួលការអង្កេតស្រាវជ្រាវនិងដោះស្រាយបណ្តឹង ការអប់រំផ្សព្វផ្សាយច្បាប់ ការកសាងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច និងការពង្រឹងសមត្ថភាពមន្ត្រីត្រូវបានពង្រឹងជាប់ជាប្រចាំដោយទទួលបានវឌ្ឍនភាពជាទីមោទនៈ ស្របតាមចក្ខុវិស័យទាំង៤របស់ក្រសួង គឺ ១) ពង្រឹងសមត្ថភាពស្ថាប័នឱ្យមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ២) កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយមូលធនមនុស្សខ្ពស់ស្របតាមចក្ខុវិស័យនៃការកែទម្រង់រដ្ឋបាលសាធារណៈ ៣) កសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ច និង ៤) ថែរក្សាបរិយាកាសសុខដុមនីយកម្ម ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយឈរលើអភិក្រម **«ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»**។ ជាក់ស្តែង ក្នុងអាណត្តិទី៦កន្លងទៅ ក្រសួងអធិការកិច្ចបានធ្វើអធិការកិច្ចសរុបចំនួន៤ ៨០៤មុខសញ្ញា បានតាមដានការអនុវត្តច្បាប់ចំនួន៣ ៣០៤មុខសញ្ញា និងដោះស្រាយបណ្តឹងសរុប៦៧២បណ្តឹង។ ការអប់រំផ្សព្វផ្សាយច្បាប់ត្រូវបានរៀបចំនៅគ្រប់រាជធានី ខេត្ត ដោយមានអ្នកចូលរួមសរុបចំនួន១៧៤ ២៥២នាក់ និងមន្ត្រីអធិការកិច្ចសរុបចំនួន៧០៧នាក់ ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចនិងជំនាញពាក់ព័ន្ធ។

## ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

ដើម្បីពង្រឹងប្រសិទ្ធភាពការងារ រាជរដ្ឋាភិបាលដោយមានក្រសួងមុខងារសាធារណៈជាសេនាធិការ បានពង្រឹងនិងបណ្តុះបណ្តាលជំនាញបន្ថែមលើមុខជំនាញរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលសាធារណៈ ដល់ថ្នាក់ដឹកនាំសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ កម្មសិក្សាការីនៃវគ្គវិក្រឹតការមន្ត្រីរាជការក្របខ័ណ្ឌថ្មីនិងសិក្ខាកាមនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សរុបចំនួន១០ ៣៥៩នាក់ ក្នុងរយៈពេលនៃការអនុវត្តផែនការពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣។ ជាមួយគ្នានេះ មន្ត្រីរាជការនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សរុបចំនួន៧ ៧៧៦នាក់ បានទទួលការពង្រឹងសមត្ថភាពបន្ថែម តាមរយៈកម្មវិធីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត កម្មវិធីចែករំលែកចំណេះដឹងនិងការចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។

ការគ្រប់គ្រងក្នុងវិស័យមុខងារសាធារណៈត្រូវបានកែលម្អជាលំដាប់ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការឱ្យបានពេញលេញ ការរៀបចំប្រព័ន្ធគ្រប់គ្រងសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិល ប្រព័ន្ធគ្រប់គ្រងការចូលនិវត្តន៍ ប្រព័ន្ធព័ត៌មានមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ប្រាក់ម៉ោងបន្ថែមសម្រាប់មន្ត្រីអប់រំ ប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យានិងគ្រូជាប់កិច្ចសន្យា ប្រព័ន្ធគ្រប់គ្រងចរន្តឯកសារ និងប្រព័ន្ធគ្រប់គ្រងបណ្ណសារដ្ឋានក្រសួងមុខងារសាធារណៈ។ កិច្ចសហប្រតិបត្តិការក្នុងវិស័យមុខងារសាធារណៈទ្វេភាគីក្នុងកម្រិតអន្តរជាតិនិងតំបន់ត្រូវបានពង្រឹង តាមរយៈការចុះអនុស្សរណៈនៃការយោគយល់ជាមួយប្រទេសចិន ថៃ និងកូរ៉េ ព្រមទាំងបន្តកិច្ចសហការជាមួយប្រទេសបារាំង អាល្លឺម៉ង់ អូស្ត្រាលី ជប៉ុន សិង្ហបុរី តួកគី ឥណ្ឌា និងដៃគូអភិវឌ្ឍផ្សេងទៀត។

ក្នុងវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលបានកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ សរុបចំនួន១៣ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគ្រប់គ្រងនិងធានានូវសន្តិសុខនិងស្ថិរភាពសង្គម ក្នុងវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ បានពិនិត្យនិងផ្តល់យោបល់លើជំពូកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់និងបទដ្ឋានគតិយុត្តនានា របស់ក្រសួង ស្ថាប័ន បានជំរុញការអភិវឌ្ឍវិស័យច្បាប់និងយុត្តិធម៌ តាមរយៈការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណវុឌ្ឍិសម្រាប់បម្រើការងារក្នុងវិស័យយុត្តិធម៌ បានរៀបចំសិក្ខាសាលានិងផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌ វិស័យរដ្ឋប្បវេណី ដល់មន្ត្រីអនុវត្តច្បាប់ ចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស បានសហការជាមួយអង្គការជាដៃគូអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិលើគម្រោងកិច្ចសហប្រតិបត្តិការជាច្រើនក្នុងវិស័យយុត្តិធម៌ បានកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានាក្នុងវិស័យយុត្តិធម៌ ដូចជាការសាងសង់អគារសាលាដំបូងខេត្តមួយចំនួន ការិយាល័យសាលាឧទ្ធរណ៍ និងអគាររដ្ឋបាលទីស្តីការក្រសួងយុត្តិធម៌ បានលើកកម្ពស់ និងពង្រឹងជាប្រចាំនូវយន្តការអធិការកិច្ច បានពិនិត្យតាមដានលើ វិន័យការងារ ក្រមសីលធម៌និងសេចក្តីថ្លៃថ្នូរ របស់ចៅក្រមនិងព្រះរាជអាជ្ញានៃអយ្យការអមសាលាជម្រះក្តី បានចាត់ការលើពាក្យបណ្តឹងពាក់ព័ន្ធនឹងវិន័យការងាររបស់ចៅក្រមនិងព្រះរាជអាជ្ញា បានបង្កើត

សេវាយុត្តិធម៌ឱ្យកាន់តែជិតប្រជាពលរដ្ឋ ដោយបានបង្កើតនិងដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ចំនួន៣ និងសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តកែប បានផ្តល់ជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រដែលពុំមានលទ្ធភាពពឹងពាក់មេធាវី បានដោះស្រាយការកកស្ទះសំណុំរឿងដោយជោគជ័យ តាមរយៈការបង្កើតគណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត និងបានរួមចំណែកដោះស្រាយភាពចង្អៀតណែននៅតាមពន្ធនាគារ បានជំរុញយុទ្ធនាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាច្រើនករណី តាមរយៈយន្តការប្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាននិងសហគមន៍ និងបានលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌ ដោយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការផ្សព្វផ្សាយអំពីចំណេះដឹងពាក់ព័ន្ធជាច្រើន ដល់មន្ត្រីអនុវត្តច្បាប់ ចៅក្រម និងព្រះរាជអាជ្ញា ជាពិសេសអនុសញ្ញាCEDAW និងច្បាប់ជាតិពាក់ព័ន្ធនានា រួមទាំងបទប្បញ្ញត្តិទាក់ទងទៅនឹងស្ត្រីនិងកុមារ។

ក្នុងការអនុវត្តកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសម្រាប់លើកកម្ពស់ប្រសិទ្ធភាពការងាររាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរជាទីមោទនៈ តាមរយៈការរៀបចំនិងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីជាតិ ផែនការប្រតិបត្តិ និងឯកសារណែនាំបច្ចេកទេសនានា ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ការបែងចែកមុខងារឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈជាមូលដ្ឋាននិងចាំបាច់នានា ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំរបៀបរបបបំពេញការងារ នីតិវិធីការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលការណ៍រដ្ឋបាលឯកភាព និងគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ដោយមានការចូលរួមពីប្រជាជន ក្នុងកិច្ចដំណើរការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ការដោះស្រាយបញ្ហាប្រឈម និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចំនួនពីរដំណាក់កាល ការបន្តពិនិត្យ និងកែលម្អជាបន្តបន្ទាប់នូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងការបែងចែកមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ដោយធ្វើសមាហរណកម្មមន្ទីរសុខាភិបាល មន្ទីរពេទ្យ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងមណ្ឌលថែទាំកុមាររដ្ឋ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ការរៀបចំប្រព័ន្ធគ្រប់គ្រង អភិវឌ្ឍ និងពង្រឹងសមត្ថភាពធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្តល់សិទ្ធិអំណាចកាន់តែច្រើនទៅឱ្យ

រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន ការធ្វើមជ្ឈការហិរញ្ញវត្ថុ និងការវិភាជន៍ថវិកាកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារក្នុងវិស័យសង្គមកិច្ចឱ្យស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស ការពង្រឹងនិងការពង្រីកយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងការទទួលសេវារដ្ឋបាលចាំបាច់នានា និងការដាក់ឱ្យអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ ជាដើម។

### ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

រាជរដ្ឋាភិបាលបានចាត់ទុកផ្នែកឯកជនជាចលករយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបានខិតខំសម្របសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការបន្តបោះទុនវិនិយោគបន្ថែមទៀតនៅកម្ពុជា។ ដើម្បីជំរុញលើកទឹកចិត្តនិងគាំទ្រដល់ការបណ្តាក់ទុនវិនិយោគ កម្ពុជាបានអនុម័តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២១ ដើម្បីផ្តល់ការលើកទឹកចិត្តពន្ធ រហូតដល់រយៈពេល១៥ឆ្នាំ ព្រមទាំងការផ្តល់ការការពារនិងការថែទាំដល់ការវិនិយោគលើវិស័យនិងសកម្មភាពអាទិភាពចំនួន១៩ចំណុច។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ចនិងវិនិយោគ ដោយបានគិតគូរលើគ្រប់ទិដ្ឋភាពចាប់ទាំងពីការចាប់ផ្តើមធុរកិច្ចនិងវិនិយោគ ការធ្វើប្រតិបត្តិការ រហូតដល់ការបញ្ចប់ធុរកិច្ចនិងវិនិយោគ។ ជាក់ស្តែង នៅឆ្នាំ២០២០ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារអន្តរក្រសួង ក្រោមការសម្របសម្រួលនិងដឹកនាំដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាជិកជាតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីកំណត់វិធានការជំរុញការកែលម្អបរិយាកាសធុរកិច្ចនិងវិនិយោគនៅកម្ពុជា ឱ្យមានភាពគ្រប់ជ្រុងជ្រោយ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីគោលនយោបាយសំខាន់ៗ ដូចជាក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីឆ្នាំ២០២១-២០២៣ ជាដើម។

បន្ថែមលើនេះ រាជរដ្ឋាភិបាល ក៏បានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន តាមរយៈការរៀបចំវេទិកានិងកិច្ចប្រជុំជាមួយវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសនានា ជាពិសេស វេទិការាជរដ្ឋាភិបាលផ្នែកឯកជន ដែលរាជរដ្ឋាភិបាលបានបង្កើតឡើងជាយន្តការសម្រាប់ដោះស្រាយជាប់ជាប្រចាំនូវរាល់បញ្ហាប្រឈមនិងកង្វល់របស់វិស័យឯកជន។ ជាក់ស្តែង រាជរដ្ឋាភិបាលបានរៀបចំវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៨ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ដោយបានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ពាក់ព័ន្ធនឹងការកាត់បន្ថយចំណាយធុរកិច្ច ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ការសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយនិងពន្ធដារ ការចុះអធិការកិច្ចតាមរោងចក្រ និងការកែសម្រួលច្បាប់ការងារ ជាដើម។

## ១.១.២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនាំមុខ សន្តិភាព ស្ថិរភាពនយោបាយ និងសណ្ដាប់ធ្នាប់សាធារណៈ

ក្នុងរយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងសកម្មក្នុងការថែរក្សាសន្តិភាពនិងស្ថិរភាពនយោបាយ បូរណភាពទឹកដី អធិបតេយ្យជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ។ សកម្មភាពទាំងនេះ គឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ធានាបាននូវចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ រាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើនលើការងារខណ្ឌសីមានិងបោះបង្គោលជាមួយប្រទេសជិតខាង និងការងារសាងសង់ផ្លូវក្រវាត់ព្រំដែន រួមមាន ១) ជាមួយប្រទេសវៀតណាម បានធ្វើការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោកបាន៨៤% នៃខ្សែព្រំដែនសរុប ស្មើនឹង២ ០៤៧បង្គោល ២) ជាមួយប្រទេសឡាវ បានចុះត្រួតពិនិត្យខ្សែព្រំដែនរួមគ្នាបានប្រវែងប្រមាណ៤៦៥គ.ម. ស្មើនឹង៨៦% និងបានឯកភាពគ្នាលើខ្សែព្រំដែនប្រមាណ៥៥% នៃខ្សែព្រំដែនសរុបប្រវែងប្រមាណ៥៤០គ.ម. និងបានឯកភាពគ្នាបោះបង្គោលព្រំដែននៅលើដីជាក់ស្តែងបានចំនួន២៥២ទីតាំង ស្មើនឹង២៧២បង្គោល ៣) ជាមួយប្រទេសថៃ បានអនុវត្តការងារស្វែងរុករកទីតាំងពិតប្រាកដនៃបង្គោលព្រំដែនដែលបានបោះដោយគណៈកម្មការបោះបង្គោលព្រំដែនឥណ្ឌូចិន សៀមទាំង៧៤បង្គោល និង៤) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ ក៏ដូចជាការអភិវឌ្ឍតំបន់ព្រំដែន រាជរដ្ឋាភិបាលបានធ្វើការសាងសង់ផ្លូវក្រវាត់ព្រំដែនសរុបប្រវែង១ ៣២០,០១គ.ម.។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានជំរុញនិងពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការបង្ក្រាបបទល្មើសគ្រឿងញៀន ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ សកម្មភាពក្មេងទំនើង ការអនុវត្តច្បាប់ចរាចរណ៍ ការផ្តល់អន្តរាគមន៍ពន្លត់អគ្គិភ័យនិងការសង្គ្រោះជនរងគ្រោះនានា ដើម្បីធានាបាននូវប្រក្រតីភាពនិងភាពសុខសាន្តនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្គម។ ការងារចុះបញ្ជីអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្មត្រូវបានពង្រឹងទាំងក្នុងក្របខ័ណ្ឌនៃការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការផ្តល់សេវាអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានអត្តសញ្ញាណផ្លូវច្បាប់ពេញលេញ និងទទួលបានសេវាជាមូលដ្ឋានចាំបាច់នានាស្របតាមច្បាប់។

ការងារអន្តោប្រវេសន៍ត្រូវបានអនុវត្តនិងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដោយធានាបានយ៉ាងពិតប្រាកដនូវអធិបតេយ្យជាតិ ការទប់ស្កាត់មិនឱ្យកើតមានឡើងនូវអំពើភេរវកម្មនៅក្នុងទឹកដីកម្ពុជា ការលួចលាក់ជ្រកកោនធ្វើសកម្មភាពរបស់អង្គការភេរវកម្មនានា លំហូរជ្រៀតចូលស្នាក់នៅដោយខុសច្បាប់របស់ជនបរទេសអន្តោប្រវេសន៍ ការគ្រប់គ្រងដំណើរចូលចេញប្រទេសឆ្លើយតបជាវិជ្ជមានចំពោះនយោបាយទេសចរណ៍ជាតិ ការវិនិយោគ ពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យការងារ និងវិស័យពាក់ព័ន្ធផ្សេងទៀត។ ការងារគ្រប់គ្រងច្រកទ្វារព្រំដែនត្រូវបានពង្រឹង និងបទល្មើសគ្រឿងញៀនត្រូវបានបង្ក្រាបទាន់ពេលប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៀត ការងារបង្ការ អប់រំ និង ផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ត្រូវបានធ្វើឡើងដើម្បីអប់រំនិងផ្សព្វផ្សាយដល់ប្រជាជន និងបានដាក់ឱ្យដំណើរការ

មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅរាជធានី ខេត្តមួយចំនួន។ ជាមួយគ្នានេះ ការសម្របសម្រួលនិងការសហការជាមួយស្ថាប័ន អង្គភាពអនុវត្តច្បាប់ក្នុងក្របខ័ណ្ឌអន្តរជាតិ ជាពិសេស ជាមួយប្រទេសជិតខាង ត្រូវបានពង្រឹង ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ឈានដល់ការបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន។ បន្ថែមលើនេះ សមត្ថភាព ឆន្ទៈ គុណធម៌ ភាពស្មោះត្រង់ និងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ ត្រូវបានពង្រឹង ស្របតាមទិសស្លោកជាតិ **«បីកុំមួយរាយការណ៍»** គឺ **១-កុំពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង** និងត្រូវរាយការណ៍ផ្តល់ព័ត៌មានដល់សមត្ថកិច្ចគ្រប់ករណីបទល្មើសគ្រឿងញៀន ព្រមទាំងបានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការរៀបចំបង្កើតភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀន។

## បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

រាជរដ្ឋាភិបាលបានបញ្ចេញធនធានហិរញ្ញវត្ថុ ដើម្បី ***ម្ខាង*** គ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ និង***ម្ខាងទៀត*** ជួយស្រោចស្រង់វិស័យឯកជន និងជំរុញសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ចឱ្យមានចលនារស់រវើកឡើងវិញ និងរក្សាលំនឹងជីវភាពរស់នៅរបស់កម្មករនិយោជិត និងប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ តាមរយៈការដាក់ចេញវិធានការអន្តរាគមន៍សង្គម សេដ្ឋកិច្ច ជាបន្តបន្ទាប់ សរុបចំនួន១០ជុំ។ ទោះបីជាមានតម្រូវការចំណាយយ៉ាងច្រើនលើមុខសញ្ញាចាំបាច់និងអាទិភាពនានា រាជរដ្ឋាភិបាលនៅតែអាចមានលទ្ធភាពគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុសាធារណៈបានល្អ ជាពិសេស ធានាបានប្រក្រតីភាពនៃកិច្ចដំណើរការរបស់ក្រសួង ស្ថាប័ន ការបើកផ្តល់ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់បានយ៉ាងទៀងទាត់និងទាន់ពេល និងការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជន។ ជាងនេះទៀត រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយគាំទ្រសំខាន់ៗ ដើម្បីបង្កភាពងាយស្រួលនិងបង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្មនិងវិនិយោគ ជាពិសេសជំរុញការស្តារនិងងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចកម្ពុជា។

ក្នុងគោលបំណងទាក់ទាញវិនិយោគឱ្យកាន់តែច្រើន ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១ ត្រូវបានប្រកាសឱ្យប្រើប្រាស់និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់នេះត្រូវបានដាក់ចេញ ហើយការផ្សព្វផ្សាយនិងទាក់ទាញវិនិយោគ ត្រូវបានលើកកម្ពស់ តាមរយៈវេទិកាសិក្ខាសាលាពាក់ព័ន្ធនានានិងជំនួបពិភាក្សាជាមួយគណៈប្រតិភូវិនិយោគជាតិនិងអន្តរជាតិ។ ជាលទ្ធផល លំហូរវិនិយោគពីបរទេសបានកើនឡើងគួរឱ្យកត់សម្គាល់ទៅក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ចកម្ពុជា។ ជាក់ស្តែង ទោះបីត្រូវរងកម្មវិបាកអវិជ្ជមានពីវិបត្តិនៃជំងឺកូវីដ-១៩ និងសេដ្ឋកិច្ចសកល កម្ពុជាសម្រេចបានទំហំនៃលំហូរវិនិយោគផ្ទាល់ពីបរទេសប្រចាំឆ្នាំ រហូតដល់៣ ៦២៥លានដុល្លារអាម៉េរិកនៅឆ្នាំ២០២០ និង៣ ៤៨៣លានដុល្លារអាម៉េរិកនៅឆ្នាំ២០២១។ ទំហំនេះបានបន្តកើនឡើងជាបន្តបន្ទាប់ដល់ប្រមាណ៣ ៥៧៩លានដុល្លារអាម៉េរិកនៅឆ្នាំ២០២២ និង៣ ៩៥៩លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣។ ទន្ទឹមនេះ តំបន់សេដ្ឋកិច្ចពិសេសកាន់តែច្រើនត្រូវបានបង្កើតឡើង។ ការណ៍នេះបង្ហាញថាកម្ពុជាដែលពីមុនមិនមានអ្នកហ៊ានមកវិនិយោគសូម្បីប្រជាជនកម្ពុជាផ្ទាល់ នៅពេលនេះបានក្លាយជាទីតាំងវិនិយោគពីបរទេសដ៏សំខាន់មួយក្នុងតំបន់។

ក្នុងវិស័យពាណិជ្ជកម្ម រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយអាទិភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងទោះបីជាមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយក៏ដោយ ក៏រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលគួរជាទីមោទនៈ ដូចជាការពង្រឹងការចុះបញ្ជីពាណិជ្ជកម្ម តាមរយៈការដាក់ចេញលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណឱ្យដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាត/អាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក ការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការពង្រឹងកម្មសិទ្ធិបញ្ញាតាមរយៈលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ការបង្ក្រាបការក្លែងបន្លំចំពោះគុណភាពទំនិញនិងសេវា ដើម្បីធានាសុវត្ថិភាពចំណីអាហារ ការពារអ្នកប្រើប្រាស់និងការប្រកួតប្រជែងស្មើភាព ការពង្រឹងយន្តការលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពម្ហូបអាហារជាសាធារណៈ ការសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងជ្រើសរើសសេចក្តីជូនដំណឹងអំពីវិធានអនាម័យនិងភូតគាមអនាម័យពីប្រភពផ្សេងៗ ការចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដាផលិតផលហាឡាលកម្ពុជា ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម ក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ការធ្វើប្រតិភូកម្មការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី(D) សម្រាប់ទំនិញកសិផល ការឱ្យអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន និងគម្រោងចុះបញ្ជីអ្នកនាំចេញសម្រាប់ធ្វើការនាំចេញទៅកាន់សហគមន៍អឺរ៉ុប ប្រទេសស្វីស ណ័រវែស និងប្រទេសតួកគី។

ជាកម្មវិបាក វិស័យពាណិជ្ជកម្ម បាននិងកំពុងដើរតួនាទីសំខាន់ និងជាចន្ទល់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ដោយបានរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន បង្រួមវិសមភាពសេដ្ឋកិច្ចនិងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាថ្មីៗ ព្រមទាំងបានជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាកាន់តែជ្រៅក្នុងសេដ្ឋកិច្ចតំបន់និងអន្តរជាតិ តាមរយៈការធ្វើពិពិធកម្ម ទាំងទីផ្សារសម្រាប់នាំចេញនិងផលិតផលនាំចេញ និងការពង្រឹងការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃតំបន់និងសកល។ ជាក់ស្តែង នៅឆ្នាំ២០១៩ កម្ពុជាបាននាំចេញទំនិញក្នុងតម្លៃ១៤,៧ពាន់លានដុល្លារអាមេរិក ហើយបានកើនដល់២៣,៥ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ដែលមានកំណើនប្រមាណ៥៩% បើធៀបនឹងតម្លៃនាំចេញក្នុងឆ្នាំ២០១៩។ កម្ពុជាបាននាំចូលទំនិញក្នុងតម្លៃ២០,២ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ និង២៤,៤ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ដែលកើនឡើងប្រមាណ២១% បើធៀបនឹងតម្លៃនាំចូលក្នុងឆ្នាំ២០១៩។ ដោយឡែកក្នុងឆ្នាំ២០២២ កម្ពុជាបាននាំចេញទំនិញក្នុងទំហំប្រមាណ៧៩,៣%នៃផ.ស.ស.និងនាំចូលទំនិញក្នុងទំហំ១០៥,៦%នៃផ.ស.ស. ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយមានសេដ្ឋកិច្ចបើកចំហយ៉ាងខ្លាំង។ ទំហំពាណិជ្ជកម្មសរុបពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ សម្រេចបានចំនួន២២០,៦ពាន់លានដុល្លារអាមេរិក ក្នុងនោះការនាំចេញសម្រេចបានប្រមាណ៩៨,៣ពាន់លានដុល្លារអាមេរិក និងការនាំចូលសម្រេចបាន១២២,៣ពាន់លានដុល្លារអាមេរិក។

## ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

ដើម្បីពង្រឹងភាពជាម្ចាស់និងភាពជាដៃគូក្នុងការអភិវឌ្ឍរាជរដ្ឋាភិបាលបានរៀបចំនិងអនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ ក៏ដូចជាការអនុវត្តគោលការណ៍ យន្តការ និងឧបករណ៍ ដើម្បីបន្សុីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយអាទិភាពអភិវឌ្ឍន៍ជាតិនិងការពង្រឹងភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការប្រកបដោយបរិយាបន្ន និងលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ជាមួយនឹងការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្ពុជាស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ បានលើកកម្ពស់តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន យន្តការចាំបាច់នានានិងយន្តការពិគ្រោះយោបល់ភាពជាដៃគូនៅគ្រប់ថ្នាក់ ត្រូវបានដាក់ឱ្យអនុវត្ត ដោយសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ សំដៅលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាបន្ន តាមរយៈការបង្កើតកាលានុវត្តភាពសម្រាប់ដៃគូអភិវឌ្ឍទាំងអស់ ជួបពិភាក្សាជាមួយរាជរដ្ឋាភិបាលលើគ្រប់ទិដ្ឋភាព ទាំងផ្នែកគោលនយោបាយ និងផ្នែកប្រតិបត្តិការ។ ដោយមានកិច្ចខិតខំប្រឹងប្រែងជាប្រចាំទាំងនេះ រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការកៀរគរហិរញ្ញប្បទានសរុបរហូតដល់ប្រមាណ១០ ១០០លានដុល្លារអាមេរិកពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣ ដែលក្នុងនោះ ការផ្ដល់ហិរញ្ញប្បទានសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានការគាំទ្រច្រើនជាងគេប្រមាណ៣៣,៣% នៃហិរញ្ញប្បទានសរុប វិស័យសង្គមកិច្ច២៦,២% វិស័យសេដ្ឋកិច្ចប្រមាណ២២,៨% និងអន្តរវិស័យប្រមាណ១០,៣%។ ហិរញ្ញប្បទានសរុបនេះ មានទំហំលើស ២៣% ធៀបនឹងតម្រូវការធនធានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបានគ្រោងត្រឹម ៨ ១៥៤លានដុល្លារអាមេរិក។

## ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក

ដោយអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបើកចំហ កម្ពុជាបានជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែជ្រៅក្នុងសេដ្ឋកិច្ចតំបន់និងអន្តរជាតិ តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការពង្រឹងការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងខ្សែប្រវាក់ផ្គត់ផ្គង់ និងខ្សែប្រវាក់តម្លៃតំបន់និងសកល កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីមួយចំនួន ដូចជា កម្ពុជា ចិន និងកម្ពុជា កូរ៉េ និងក្នុងក្របខ័ណ្ឌពហុភាគី ដូចជាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប-RCEP) ជាដើម ដែលជាយន្តការដ៏សំខាន់ក្នុងការជំរុញនិងការបង្កើនភាពជាដៃគូយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម និងការវិនិយោគ ដើម្បីធានាបានភាពធន់ បរិយាបន្ន និងចីរភាព។ ជាមួយគ្នានេះ កិច្ចព្រមព្រៀងក្រោមក្របខ័ណ្ឌអាស៊ាននិងអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានអនុវត្ត ដើម្បីចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងធានានូវភាពស្មើភាពជាមួយរដ្ឋជាសមាជិកដទៃទៀត។ យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក/គម្រោង Go4eCAM និងគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច (AIMS) ក៏ត្រូវបានដាក់ឱ្យអនុវត្តផងដែរ។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានសម្របសម្រួលជាមួយភាគីសហរដ្ឋអាម៉េរិក ដើម្បីបន្តឡើងវិញប្រព័ន្ធអនុគ្រោះពន្ធទូទៅ និងបន្តផ្សព្វផ្សាយប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មថ្មីៗជូនដល់វិស័យឯកជន ព្រមទាំងបានរៀបចំនិងដឹកនាំកិច្ចប្រជុំពាក់ព័ន្ធ ដែលគ្របដណ្ដប់លើយុទ្ធសាស្ត្រសំខាន់ចំនួន៤ រួមមានការបង្កើនការតភ្ជាប់លើវិស័យឌីជីថលអាស៊ាន ការគាំពារនិងការជំរុញកំណើនសហគ្រាសធុនតូចនិងមធ្យមអាស៊ាន ការសម្របសម្រួលនិងការសហការកាត់បន្ថយការចំណាយលើការនាំចេញ នាំចូលជាមួយបណ្ដាប្រទេសក្នុងតំបន់អាស៊ាន។ យន្តការជំរុញពាណិជ្ជកម្មជាច្រើនទៀត ត្រូវបានបង្កើតឡើង ដើម្បីបង្កើនការនាំចេញ និងលើកកម្ពស់ការធ្វើសមាហរណកម្ម ដូចជាការអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០១៩-២០២៣ ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសនិងក្រៅប្រទេស ការបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជាក្រៅប្រទេស ការតាមដានពីស្ថានភាពទីផ្សារនិងស្រង់សន្ទស្សន៍ថ្លៃទំនិញចាំបាច់ ការបង្កើតទីផ្សារព្រំដែនកម្ពុជា វៀតណាម ការរៀបចំវេទិកាជំនួបរវាងអ្នកលក់និងអ្នកបញ្ជាទិញ ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិនិងព័ត៌មានពាណិជ្ជកម្ម ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់លើកកម្ពស់ការប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការធ្វើវិសោធនកម្មច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មសុវត្ថិភាពម្ហូបអាហារ ការសិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) ស្ដីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ផែនការយុទ្ធសាស្ត្រស្ដីពីការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ការពង្រឹងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម។

ដោយការជំរុញការធ្វើសមាហរណកម្មនិងពាណិជ្ជកម្មមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងកិច្ចការបរទេសនិងការទូត រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច នយោបាយការបរទេសបុរេសកម្ម និងអនុវត្តគោលដៅយុទ្ធសាស្ត្រស្របតាមទិសស្លោក **«កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅដោយឈរលើមូលដ្ឋានឯករាជ្យ»** ដោយបានខិតខំពង្រឹងនិងពង្រីកទំនាក់ទំនងជាមួយមិត្តចាស់និងថ្មី ប្រកបដោយភាពបត់បែនឆ្លាតវៃ ការពារផលប្រយោជន៍ជាតិ អធិបតេយ្យ បូរណភាពទឹកដី និងសេចក្ដីថ្លៃថ្នូរជាតិ ព្រមទាំងចូលរួមពង្រឹងពហុភាគីនិយមនិងសណ្ដាប់ធ្នាប់ពិភពលោកដោយផ្អែកលើប្រព័ន្ធច្បាប់អន្តរជាតិ។

កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ តាមរយៈការសម្រេចបានសមិទ្ធផលការងារធំៗ ដូចជាការទទួលបានការគាំទ្រកម្ពុជាកាន់តែច្រើននៅក្នុង «កិច្ចសន្ទនាអន្តរសកម្ម ជាមួយអ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា» ការបកស្រាយបំភ្លឺលើការចោទមួលបង្កាច់មានចរិតនយោបាយ ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ ការពង្រឹងទំនាក់ទំនងល្អប្រសើរជាមួយប្រទេសជិតខាង ការផ្លាស់ប្ដូរទស្សនកិច្ចនិងជំនួបទ្វេភាគី ក្នុងកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ សម្រាប់ការផ្លាស់ប្ដូរពាណិជ្ជកម្ម ទេសចរណ៍ និងវិនិយោគ កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអាស៊ីខាងត្បូង អាស៊ីកណ្ដាល តំបន់អូសេអានី ដែលជួយបង្កើនគួរឱ្យកត់សម្គាល់នូវទំហំពាណិជ្ជកម្មទ្វេភាគី ការកែលម្អយ៉ាងខ្លាំងនូវទំនាក់ទំនងរវាងកម្ពុជា ជាមួយបណ្ដា

ប្រទេសបស្ចិមលោក ជោគជ័យនៃការទទួលធ្វើជាប្រធានអាស៊ាន ជាលើកទី៣ ក្នុងប្រវត្តិសាស្ត្រ ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដោយផ្ទាល់ក្រោយវិបត្តិជំងឺកូវីដ-១៩ ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុបលើកទី១៣ ការធ្វើជាសហប្រធាននៃកិច្ចប្រជុំកំពូលពិសេស អាស៊ាន សហរដ្ឋអាមេរិក ការចូលរួមយ៉ាងសកម្មក្នុងយន្តការពហុភាគីដទៃទៀត ដើម្បីចូលរួមជាផ្នែកមួយក្នុងការកសាងសហគមន៍ នៅក្នុងតំបន់និងសកលលោក ប្រកបដោយសន្តិភាព សន្តិសុខនិងវិបុលភាព ការចូលរួមស្វែងរកដំណោះស្រាយបញ្ហាប្រឈម ដូចជាការប្រែប្រួលអាកាសធាតុ ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មឆ្លងដែន ហិរញ្ញប្បទានភេរវកម្មជាដើម ការបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ការប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់សន្តិភាព កិច្ចសហប្រតិបត្តិការល្អ និងការអភិវឌ្ឍ កម្ពុជាត្រូវបានជ្រើសរើសជាអនុប្រធាននៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧៣ និងត្រូវបានជ្រើសរើសជាសមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម នៃអង្គការសហប្រជាជាតិ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងក្របខ័ណ្ឌអាស៊ាននិងជាសមាជិកស្ថាបនិកនៃធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ក្រោមគំនិតផ្តួចផ្តើម«**ខ្សែក្រវាត់មួយ ផ្លូវមួយ**» ព្រមទាំងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាច្រើនទៀត។ បន្ថែមលើនេះ កម្ពុជាទទួលបានជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ និងការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម លើកទី១២។

### ១.១.៣- ការអភិវឌ្ឍធនធានមនុស្ស

#### ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

វិស័យអប់រំត្រូវបានកែទម្រង់ជាប្រចាំ ដើម្បីបង្កើតបរិយាកាសល្អសម្រាប់ការអប់រំប្រកបដោយបរិយាបន្ន សំដៅជំរុញការអភិវឌ្ឍធនធានមនុស្សឱ្យសម្រេចបានមូលធនមនុស្សនិងជំនាញខ្ពស់ សម្រាប់បំពេញតម្រូវការនៃការអភិវឌ្ឍជាតិនិងទីផ្សារការងារ តាមរយៈកម្មវិធីការកែទម្រង់នានា ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ការកែទម្រង់សាលារៀន ការអនុវត្តស្តង់ដាសាលារៀនគំរូ ការបង្កើតសាលារៀនជំនាន់ថ្មី ការពង្រឹងគុណភាពនៃការបង្រៀននិងរៀន ការកែទម្រង់ការប្រឡងជ្រើសរើសគ្រូបង្រៀន ការលើកកម្ពស់សមត្ថភាពនិងអភិបាលកិច្ចល្អនៅតាមគ្រឹះស្ថានសិក្សា ការធ្វើបច្ចុប្បន្នកម្មនៃកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា ការពង្រាយគ្រូបង្រៀន ការកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា ការកែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការកែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ការសាងសង់អគារសិក្សានិងការជួសជុល ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ការលើកកម្ពស់វិស័យកីឡា ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន ការអប់រំបច្ចេកទេស ការរៀបចំគន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា ការបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស និស្សិតក្រីក្រ និងងាយរងគ្រោះនិងការបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង និងសម្រួចជំនាញឯកទេសជាប្រចាំ សំដៅលើកកម្ពស់ភាពប្រកួតប្រជែងនៃកម្លាំងពលកម្ម និងកសាងយុវជនបន្តវេនកម្ពុជាដែលមានសមត្ថភាពដឹកនាំខ្ពស់។

ជោគជ័យនៃការកែទម្រង់វិស័យអប់រំនិងសមិទ្ធផលធំៗនៃវិស័យនេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលឆ្លុះបញ្ចាំងតាមរយៈការទទួលបានពានរង្វាន់អក្ខរកម្មពិភពលោកឆ្នាំ២០២៣ ការវាយតម្លៃជាអន្តរជាតិនូវលទ្ធផលសិក្សារបស់សិស្សកម្ពុជាអាយុ១៥ឆ្នាំនៅឆ្នាំ២០២២លើផ្នែកគណិតវិទ្យា ទទួលបានពិន្ទុមធ្យម៣៣៦(កើនឡើង១១ពិន្ទុ) ផ្នែកអំណានទទួលបានមធ្យម៣២៩ពិន្ទុ(កើនឡើង៨ពិន្ទុ) និងផ្នែកវិទ្យាសាស្ត្រទទួលបានពិន្ទុមធ្យម៣៤៧ពិន្ទុ(កើនឡើង១៧ពិន្ទុ) បើធៀបនឹងលទ្ធផលសិក្សារបស់សិស្សនៅប្រទេសកំពុងអភិវឌ្ឍ(PISA-D) អត្រារួមនៃការសិក្សានៅបឋមសិក្សាបានកើនឡើង១៤,៤ពិន្ទុភាគរយ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិបានកើន១៤,៣ពិន្ទុភាគរយ និងអត្រារួមនៃការសិក្សានៅឧត្តមសិក្សាបានកើនឡើង១១,៥៧ពិន្ទុភាគរយ។

## ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

រាជរដ្ឋាភិបាលបានបន្តជំរុញនិងលើកកម្ពស់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស តាមរយៈការដាក់ចេញនិងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានា ពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការបង្កើនទំហំថវិកាជាតិជាបន្តបន្ទាប់ ដើម្បីធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពង្រឹងគុណភាព និងបង្កើនសមត្ថភាពបណ្តុះបណ្តាលគ្រប់កម្រិតសិក្សា ព្រមទាំងការដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ។ រាជរដ្ឋាភិបាលបានបង្កើនការផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈចំនួន២៧,២ម៉ឺននាក់ និងបន្តជំរុញការអភិវឌ្ឍសមត្ថភាពរបស់កម្លាំងពលកម្ម ដែលនៅក្នុងទីផ្សារការងារនិងត្រៀមចូលទីផ្សារការងារ តាមរយៈការអនុវត្តការហ្វឹកហ្វឺនកូនជាងចំនួន១២,៩ម៉ឺននាក់ បញ្ជូនសិស្សចុះកម្មសិក្សាទស្សនកិច្ចសិក្សាតាមរោងចក្រសហគ្រាសចំនួន២២,៤ម៉ឺននាក់ និងបានធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងការជំរុញការគ្រប់គ្រងនិងអភិវឌ្ឍសមត្ថភាពវិស្វករ។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានពង្រឹងអភិបាលកិច្ចនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការពង្រឹងសមត្ថភាពគណៈគ្រប់គ្រងនិងមន្ត្រីរាជការ ការរៀបចំលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីព្រាងច្បាប់ស្តីពីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការត្រួតពិនិត្យនិងវាយតម្លៃធានាគុណភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងសមត្ថភាពគ្រូបច្ចេកទេស/ឯកទេស និងការបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពបន្ថែមចំនួន៧០គុណវុឌ្ឍិ លើ៤២មុខជំនាញនៃវិស័យអាទិភាពសំខាន់ៗ ដែលធ្វើឱ្យកញ្ចប់គុណវុឌ្ឍិសរុបមានចំនួន១៨៨ លើ៧៦មុខជំនាញ ព្រមទាំងបានបណ្តុះបណ្តាលសមត្ថភាពគ្រូបច្ចេកទេស/ឯកទេសជាប្រចាំ ពង្រឹងតួនាទីវិស័យឯកជនក្នុងការចូលរួមអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន៤ និងអនុស្សរណៈនៃការយោគយល់គ្នារវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាមួយសហគ្រាសគ្រឹះស្ថាន សរុបចំនួន៣២៦ និង ជំរុញការសិក្សាស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យា និងលើកកម្ពស់ការប្រកួតប្រជែងជំនាញថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

## ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

គុណភាពសេវាសុខាភិបាលត្រូវបានកែលម្អនិងអន្តរាគមន៍សុខភាពសាធារណៈត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់ ដែលធ្វើឱ្យកម្ពុជាអាចគ្រប់គ្រងជំងឺកូវីដ-១៩ ដោយជោគជ័យ និងកាត់បន្ថយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ មកលើសុខភាពសាធារណៈឱ្យស្ថិតនៅកម្រិតទាប។ ជាមួយគ្នានេះ សុខភាពប្រជាជនក៏ត្រូវបានលើកកម្ពស់ តាមរយៈគោលនយោបាយពាក់ព័ន្ធនានា ដូចជាការអនុវត្តមូលនិធិសមធម៌សុខាភិបាល របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គោលនយោបាយអាទិភាពស្តីពីរបបសន្តិសុខសង្គម ដូចជាការពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គម របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបវិភាគទានជាកាតព្វកិច្ចនិងស្ម័គ្រចិត្ត ការផ្តល់ប្រាក់ឧបត្ថម្ភដល់សមាជិកបេឡាជាតិសន្តិសុខសង្គមជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ស្ត្រីសម្រាលកូន កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងកំឡុងពេលមានសម្ពាធអតិផរណា។ ប្រជាជនកម្ពុជាដែលត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាលនិងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានកើនឡើងពី៣៥,៧% នៅឆ្នាំ២០១៨ ដល់ប្រមាណ៤១% នៅឆ្នាំ២០២៣។

កម្ពុជាបានលុបបំបាត់និងគ្រប់គ្រងជំងឺឆ្លងជាច្រើន ជាអាទិ៍ជំងឺគ្រុនស្វិតដៃជើង ជំងឺតេតាណូសលើមាតានិងទារក ជំងឺកញ្ជ្រឹល ជំងឺជើងដំរី ជំងឺត្រអកភ្នែក និងប្រេវ៉ាឡង់មេរោគរលាកថ្លើមប្រភេទB លើកុមារអាយុក្រោម៥ឆ្នាំ នៅក្រោម១% អត្រាព្យាបាលជោគជ័យនៃជំងឺរបេងខ្ពស់លើសពី៩០% និងការស្លាប់ដោយសារជំងឺគ្រុនចាញ់បានធ្លាក់ ចុះដល់សូន្យករណីចាប់ពីឆ្នាំ២០២៨ ជាដើម។ បន្ថែមលើនេះ មរណភាពមាតា ទារក និងកុមារ ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ក្នុងនោះអត្រាមរណភាពមាតាបានធ្លាក់ចុះពី១៧០ ក្នុងទារកកើតរស់១០០ ០០០នាក់ នៅឆ្នាំ២០១៤ មកត្រឹម១៥៤នាក់ នៅឆ្នាំ២០២១/២០២២ ខណៈដែលអត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំបានធ្លាក់ចុះពី៣៥ ក្នុង១០០០កំណើតរស់ នៅឆ្នាំ២០១៤ មកនៅត្រឹម១៦ នៅឆ្នាំ២០២១/២០២២ ហើយអត្រាមរណភាពទារកបានធ្លាក់ចុះពី ១៨ ក្នុង១០០០ កំណើតរស់ នៅឆ្នាំ២០១៤ មកត្រឹម៨ នៅឆ្នាំ២០២១/២០២២។

តាមរយៈការសម្របសម្រួលការចូលរួមកិច្ចសហការរវាងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៥ សម្រាប់ការឆ្លើយតបយ៉ាងទូលំទូលាយនិងពហុវិស័យចំពោះមេរោគអេដស៍/ជំងឺអេដស៍ ពិសេសការបង្ការ ការអប់រំសុខភាពបន្តពូជ ការថែទាំព្យាបាល និងការគាំពារសង្គម កម្ពុជាកំពុងឆ្ពោះទៅសម្រេចគោលដៅ៩៥-៩៥-៩៥ ហើយនៅត្រឹមឆ្នាំ២០២៣ ៨៩% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងស្ថានភាពមានមេរោគអេដស៍ ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពមានមេរោគអេដស៍កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាលមានកំហាប់មេរោគអេដស៍ក្នុងឈាមទាបបំផុត(Viral load suppression)។ ជាក់ស្តែង អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនពេញវ័យអាយុ១៥ ដល់៤៩ឆ្នាំ បានថយចុះពី០,៩% ក្នុង

ឆ្នាំ២០១០ មកត្រឹម០,៥% ក្នុងឆ្នាំ២០២៣។ ចំនួនករណីឆ្លងមេរោគអេដស៍ថ្មីបានថយចុះពី២០០០ ក្នុងមួយឆ្នាំក្នុងឆ្នាំ២០១០ មក១២០០ ក្នុងឆ្នាំ២០២៣។ អត្រានៃការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនបានថយចុះពី១៥,២% នៅក្នុងឆ្នាំ២០១៨ ដល់៨% នៅក្នុងឆ្នាំ២០២៣។

វិស័យអាហារូបត្ថម្ភត្រូវបានពង្រឹងនិងលើកកម្ពស់ជាប្រចាំ តាមរយៈយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការធ្វើបរិវត្តកម្មប្រព័ន្ធស្បៀង ដើម្បីឈានទៅបញ្ចប់ភាពអត់ឃ្លាន គោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ការពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារផ្សេងៗទៀតឱ្យបានសមស្របនិងជានាបានគុណភាព សុវត្ថិភាព និងបរិមាណគ្រប់គ្រាន់តាមតម្រូវការ ការបង្កើនការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតបានទូលំទូលាយសម្រាប់លើកកម្ពស់សុខភាពសាធារណៈ និងសុខមាលភាពប្រជាពលរដ្ឋ ស្របតាមលក្ខខណ្ឌគោល៤ គឺ **«គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ»** ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ និងការអនុវត្តវិធានការបញ្ចុះថ្លៃទឹកស្អាតជូនកម្មករកម្មការិនី និងសិស្សនិស្សិតស្នាក់នៅបន្ទប់ជួល សំដៅលើកកម្ពស់អាហារូបត្ថម្ភនិងសុខុមាលភាពរបស់ប្រជាជន។

ជាក់ស្តែង ស្ថិតិអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាបានបង្ហាញថា ភាពក្រិសក្រិនរបស់កុមារអាយុក្រោម៥ឆ្នាំ មានវឌ្ឍនភាពល្អ ដោយបានធ្លាក់ចុះពី៣២% នៅឆ្នាំ២០១៤ មកត្រឹម២២% ក្នុងឆ្នាំ២០២១-២០២២។ អត្រាស្គមស្គាំងរបស់កុមារអាយុក្រោម៥ឆ្នាំមិនមានការប្រែប្រួល គឺស្ថិតក្នុងរង្វង់១០% ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១-២០២២។ ទន្ទឹមនេះ អត្រាកុមារអាយុក្រោម៥ឆ្នាំ ដែលលើសទម្ងន់និងធាត់ជ្រុល បានកើនឡើងពីរដង ពី២%ក្នុងឆ្នាំ២០១៤ ដល់៤%ក្នុងឆ្នាំ២០២១-២០២២។ អត្រានៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់របស់ទារកអាយុពី០-៦ខែ បានថយចុះពី៦៤,៦% នៅឆ្នាំ២០១៤ មកត្រឹម៥១%ក្នុងឆ្នាំ២០២១-២០២២។

## ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

សមភាពយេនឌ័រនិងតួនាទីស្ត្រី ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈការធ្វើស្ថាប័នូបនីយកម្ម ការផ្សព្វផ្សាយទស្សនាទានយេនឌ័រ និងអនុសញ្ញាស៊ីដ និងការបញ្ជ្រាបយេនឌ័រនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងក្រោមជាតិ ដោយបានផ្តល់បរិយាកាសអំណោយផលនិងកាលានុវត្តភាពដល់ស្ត្រីចូលរួមប្រកបដោយសក្តានុពលនៅក្នុងកិច្ចការសង្គម នយោបាយ បរិស្ថាន និងកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ។ ការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចត្រូវបានយកចិត្តទុកដាក់ តាមរយៈការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី ការគាំទ្រស្ត្រីដែលដឹកនាំ និងគ្រប់គ្រងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ជាពិសេសក្នុងវិស័យឌីជីថលនិងសេដ្ឋកិច្ចបៃតង ការលើកកម្ពស់ចំណេះដឹងនិងជំនាញ ព្រមទាំងការអនុវត្តបរិយាបន្នហិរញ្ញវត្ថុនិងឌីជីថល ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី និងសេដ្ឋកិច្ចដែលគិតគូរដល់សុខុមាលភាព ការការពារសិទ្ធិរបស់ស្ត្រី ក្នុងសកម្មភាពសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រព័ន្ធ។ ជាក់ស្តែង កម្លាំងពលកម្មរបស់

ស្ត្រីមានរហូតដល់៨៤% ហើយស្ត្រីចំនួន៦១% ជាម្ចាស់អាជីវកម្មនិងធុរជន ដែលជាអត្រាខ្ពស់នៅក្នុងតំបន់។ បន្ថែមលើនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់បំផុតជាប្រទេសផ្តល់សេរីភាពទូលំទូលាយសម្រាប់ស្ត្រីក្នុងការចាប់ផ្តើមធ្វើអាជីវកម្មនិងធុរកិច្ច ព្រមទាំងទទួលបានតួនាទីកាន់តែច្រើននៅក្នុងសមាសភាពស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់កម្រិត ទាំងនៅក្នុងអង្គនីតិប្បញ្ញត្តិ អង្គនីតិប្រតិបត្តិ និងតុលាការ។

រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តប្រកបដោយជោគជ័យនូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣ និងប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។ ការលើកកម្ពស់ជំនួយផ្នែកច្បាប់ត្រូវបានអនុវត្ត ដើម្បីជួយស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើរំលោភសេពសន្ថវៈនៅទូទាំងរាជធានីខេត្ត។ ផ្អែកលើលទ្ធផលអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាពីសំណាក់ដៃគូស្និទ្ធស្នាលក្នុងមួយជីវិតមានការថយចុះពី២៩% នៅឆ្នាំ២០១៤ មកត្រឹម២១% នៅឆ្នាំ២០២១។

ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈនិងនយោបាយមានការកើនឡើងជាលំដាប់ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំនិងគណៈគ្រប់គ្រងជាស្ត្រី ការរៀបចំវេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច និងការអនុវត្តគោលការណ៍ជ្រើសរើសមន្ត្រីរាជការថ្មីដែលយកចិត្តទុកដាក់លើការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រី ដោយធ្វើឱ្យសមាមាត្រស្ត្រីនៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅក្នុងវិស័យសាធារណៈមានការកើនឡើងជាបន្តបន្ទាប់។ ជាក់ស្តែង មន្ត្រីរាជការជាស្ត្រីបានកើនឡើងពី៤១% នៅឆ្នាំ២០១៨ ដល់៤២% នៅឆ្នាំ២០២៣។ ស្ត្រីជាសមាជិការដ្ឋសភាមានចំនួន១៣,៦០% នៅឆ្នាំ២០២៣។ កម្ពុជាមានស្ត្រី១រូបជាប្រធានរដ្ឋសភានិងស្ត្រី២រូបជាប្រធានគណៈកម្មការជំនាញ។ ស្ត្រីជាសមាជិកាព្រឹទ្ធសភាបានកើនឡើងពី១៤,៧៥% នៅឆ្នាំ១៩៩៩ ដល់១៦,១៣% នៅឆ្នាំ២០១៩ ក្នុងនោះ មានស្ត្រី២រូបជាប្រធានគណៈកម្មការជំនាញ។ បច្ចុប្បន្ន ស្ត្រី៣រូបជារដ្ឋមន្ត្រី ស្ត្រី១រូបជាអគ្គសវនករនិងស្ត្រី១រូបជាអគ្គទេសាភិបាលធនាគារជាតិ។ នៅលើឆាកអន្តរជាតិ បច្ចុប្បន្នកម្ពុជាមានលំដាប់លេខរៀងទី១ ក្នុងសហគមន៍អាស៊ាន និងលំដាប់លេខរៀងទី៩ ក្នុងចំណោមប្រទេសចំនួន១២៣ ដែលបានបញ្ជូនកងទ័ពជាស្ត្រីចូលរួមប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

ក្នុងវិស័យគាំពារសង្គម វិសាលភាពប្រព័ន្ធគាំពារសង្គមត្រូវបានពង្រឹងនិងពង្រីក ដើម្បីរក្សាលំនឹងជីវភាពប្រជាជន តាមរយៈក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម កសាងប្រព័ន្ធគាំពារសង្គមកម្ពុជាដែលរួមមានប្រព័ន្ធជំនួយសង្គមនិងប្រព័ន្ធសន្តិសុខសង្គម ការបង្កើតនូវស្ថាប័ននិយ័តករសន្តិសុខសង្គម និងមូលនិធិជាតិជំនួយសង្គម ការកែសម្រួលមុខងារនិងភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គមឱ្យកាន់តែមានប្រសិទ្ធភាពនិងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងប្រព័ន្ធគាំពារសង្គម ដោយសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់។

រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តកម្មវិធីជំនួយសង្គមសម្រាប់ជាប្រយោជន៍ដល់គ្រួសារក្រីក្រដោយប្រើប្រាស់ថវិការដ្ឋទាំងស្រុង។ ក្នុងឆ្នាំ២០២៣ ប្រព័ន្ធជំនួយសង្គមមានវិសាលភាពគ្របដណ្តប់លើ

ពលរដ្ឋសរុបចំនួន១,២លានគ្រួសារ ដែលមានសមាជិកចំនួនជាង៤,៨លាននាក់(រួមទាំងគ្រួសារងាយរងហានិភ័យ) ស្មើនឹងប្រមាណ២៨% នៃប្រជាជនសរុប ដោយបានចំណាយថវិការដ្ឋប្រមាណ២៣០ប៊ីលានរៀល(សមមូលប្រមាណ៦០លានដុល្លារអាម៉េរិក)ក្នុងឆ្នាំ២០២៣ ក្នុងនោះ កម្មវិធីជាតិជំនួយសង្គមមានចំនួន៤ រួមមាន១) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ ២) កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ៣) កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និង៤) មូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមពលរដ្ឋគោលដៅនានា រួមមានគ្រួសារក្រីក្រ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ អនុភូមិ និងជំនួយការភូមិ កម្មករក្រៅប្រព័ន្ធ អ្នកជាក់ស៊ីក្លូ កីឡាករជម្រើសជាតិ ក្រុមគ្រួសារជនពលីមរណៈ បុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ក្នុងពេលកម្ពុជាជួបគ្រោះអាសន្នកន្លងមក រាជរដ្ឋាភិបាលបានជួយគាំពារពលរដ្ឋ តាមរយៈការដាក់ចេញនូវអន្តរាគមន៍ពិសេសនានា ដើម្បីជួយរក្សាលំនឹងជីវភាព កាត់បន្ថយកម្មវិបាកអវិជ្ជមាន និងស្តារជីវភាពរបស់ពលរដ្ឋប្រកបដោយប្រសិទ្ធភាព តាមរយៈកម្មវិធីជំនួយសង្គមពិសេស ដូចជា ១) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ក្នុងកំឡុងប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានគ្រួសារទទួលផលសរុបប្រមាណ៧០ម៉ឺនគ្រួសារ ឬស្មើនឹង២,៨លាននាក់ ២) កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ទ្រង់ទ្រាយធំ មានគ្រួសារទទួលផលសរុបប្រមាណ១២ម៉ឺនគ្រួសារ ៣) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងកំឡុង មានសម្ពាធអតិផរណា មានគ្រួសារទទួលផលសរុបប្រមាណ៥០ម៉ឺនគ្រួសារ ឬស្មើនឹង១,៨លាននាក់ និង៤) កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ មានគ្រួសារទទួលផលសរុបប្រមាណ១០ម៉ឺនគ្រួសារ ឬស្មើនឹង៣៧ម៉ឺននាក់ ដោយបានចំណាយថវិការដ្ឋបន្ថែមសរុបចំនួន៥,៧ទ្រីលានរៀល (សមមូលប្រមាណ១ ៤២២លានដុល្លារអាម៉េរិក)។

ចំពោះប្រព័ន្ធសន្តិសុខសង្គម រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តរបបសន្តិសុខសង្គម ដែលមានវិសាលភាពកាន់តែទូលំទូលាយស្របទៅតាមការវិវត្តនៃសង្គមសេដ្ឋកិច្ច ដើម្បីជួយគាំទ្រនិងការពារប្រជាជនពីអសន្តិសុខប្រាក់ចំណូល ដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ ការងារ និកម្មភាព និងជរាភាព ដែលមានដូចជា ១) ការបង្កើនសមាជិករបបសន្តិសុខសង្គមផ្នែកហានិភ័យការងារពី១,២លាននាក់ នៅឆ្នាំ២០១៩ មកដល់១,៨លាននាក់ នៅឆ្នាំ២០២៣ ២) ការបង្កើនសមាជិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបកាតព្វកិច្ចដល់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងតាមរបបភាគទានស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និង អ្នកក្នុងបន្ទុកសមាជិកប.ស.ស. ពី១,៥លាននាក់ នៅឆ្នាំ២០១៩ មកដល់២លាននាក់ នៅឆ្នាំ២០២៣ និង ៣) ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនចាប់ពីខែកក្កដា ឆ្នាំ២០២២ ដោយបានចុះបញ្ជីសមាជិកសរុបចំនួន១,៥លាននាក់ គិតត្រឹមឆ្នាំ២០២៣។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តនិងពង្រីកវិសាលភាពនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ សម្រាប់សមាជិកប.ស.ស. ជាស្ត្រី ដែលគិតត្រឹមឆ្នាំ២០២៣ មានស្ត្រីនិងកុមារសរុបប្រមាណ៨៩ម៉ឺននាក់ បានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ។

ជារួម ប្រព័ន្ធគាំពារសង្គមកម្ពុជាមានវិសាលភាពគ្របដណ្តប់ប្រជាពលរដ្ឋជាង៧,៥លាននាក់ ស្មើនឹង៤២% នៃប្រជាជនសរុប។ ការវាយតម្លៃនានាបានបង្ហាញថា ការអនុវត្តគោលនយោបាយជាតិគាំពារសង្គមនាពេលកន្លងមកមានកម្មវិបាកវិជ្ជមានគួរឱ្យកត់សម្គាល់ ទាំងទៅលើការអភិវឌ្ឍមនុស្សនិងសង្គមសេដ្ឋកិច្ច ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជននៅក្នុងទិដ្ឋភាពសន្តិសុខស្បៀង អាហារូបត្ថម្ភ ការអប់រំកុមារ ការសន្សំប្រាក់ ការសងបំណុល ការថែទាំសុខភាព និងការលើកកម្ពស់យេនឌ័រ បន្ថែមលើការជួយជំរុញកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងបង្កើតការងារនិងមុខរបរក្នុងមូលដ្ឋាន។

## ១.១.៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

### ការកែលម្អប្រព័ន្ធឡូជីស្ទិក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូនថាមពល និងឌីជីថល

ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រព័ន្ធឡូជីស្ទិក ប្រព័ន្ធថាមពល និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល ត្រូវបានកែលម្អនិងធ្វើទំនើបកម្មគួរឱ្យកត់សម្គាល់។ វិស័យគមនាគមន៍និងដឹកជញ្ជូនកម្ពុជា ត្រូវបានស្តារនិងស្ថាបនាឡើងវិញ ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេសនិងជាមួយប្រទេសជិតខាង ដែលធានាដល់ការធ្វើដំណើរបានគ្រប់ពេលនិងគ្រប់ទីកន្លែង ជាពិសេសបាននិងកំពុងតែបន្តកសាងនិងកែលម្អជាបន្តបន្ទាប់ ដើម្បីអភិវឌ្ឍប្រព័ន្ធឡូជីស្ទិក និងប្រែក្លាយទៅជាប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយសម្រាប់បម្រើឱ្យការតភ្ជាប់ផ្ទៃក្នុងប្រទេសផង និងពង្រីកសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោកផង។

បច្ចុប្បន្ន កម្ពុជាសម្រេចបានការសាងសង់ផ្លូវជាតិនិងផ្លូវតាមខេត្តដោយក្រាលកៅស៊ូនិងបេតុងគ្រប់ប្រភេទមានប្រវែងសរុប១១ ២៨៥គីឡូម៉ែត្រ ផ្លូវល្បឿនភ្នំពេញ ក្រុងព្រះសីហនុប្រវែង១៨៧,៥គីឡូម៉ែត្រ ស្ពានតូចធំគ្រប់ប្រភេទចំនួន២ ៥៣០ស្ពាន ប្រវែងសរុប៨៦,២គីឡូម៉ែត្រ បណ្តាញផ្លូវនាវាចរណ៍តាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ប្រវែងសរុប១ ៧៥០គីឡូម៉ែត្រ ព្រមទាំងកំពុងបន្តអភិវឌ្ឍ ពង្រីក និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ជាពិសេស គម្រោងផ្លូវនាវាចរណ៍ និងប្រព័ន្ធភស្តុភារកម្ម សម្រាប់ការដឹកជញ្ជូនតភ្ជាប់ពីទន្លេបាសាក់ទៅសមុទ្រខេត្តកែប។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបាននិងកំពុងសិក្សាគម្រោងលើកកម្រិតផ្លូវរថភ្លើងដែលមានស្រាប់ សិក្សាគម្រោងធ្វើទំនើបកម្មបណ្តាញផ្លូវដែកទាំងពីរខ្សែនេះ ភ្នំពេញ ប៉ោយប៉ែត និងភ្នំពេញ ក្រុងព្រះសីហនុ ឱ្យប្រែក្លាយជាប្រព័ន្ធខ្សែផ្លូវរថភ្លើងល្បឿន និងសិក្សាបន្ថែមខ្សែផ្លូវដែកថ្មី(ផ្លូវដែកល្បឿន) ពីភ្នំពេញ សៀមរាប ប៉ោយប៉ែត ខ្សែផ្លូវដែកតភ្ជាប់ភ្នំពេញ ក្រុងបាវិត និងខ្សែផ្លូវដែកថ្មីល្បឿនមួយចំនួនទៀតតភ្ជាប់ជាមួយប្រទេសថៃនិងឡាវ។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់ការសិក្សាពីលទ្ធភាពសាងសង់ផ្លូវដែកទីក្រុងប្រភេទស្វ័យប្រវត្តិគ្មានអ្នកបើកបរ AGT និងផ្លូវដែកទោលកង់កៅស៊ូម៉ូណូរ៉ែល ព្រមទាំងកំពុងសិក្សាលទ្ធភាពសាងសង់ផ្លូវដែកក្រោមដីនៅរាជធានីភ្នំពេញតភ្ជាប់ពីអាកាសយានដ្ឋានថ្មីតេជោក្រុងតាខ្មៅមករាជធានីភ្នំពេញ និងផ្លូវដែកធុនស្រាលតភ្ជាប់ពីអាកាសយានដ្ឋានថ្មីសៀមរាបទៅទីក្រុងសៀមរាប។

ចំពោះការដឹកជញ្ជូនផ្លូវទឹក រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពនូវគម្រោងផ្លូវនាវាចរណ៍ «ព្រែកជីកហ្វូណនតេជោ» តភ្ជាប់ពីទន្លេបាសាក់ទៅសមុទ្រខេត្តកែប បញ្ចប់ការសាងសង់កំពង់ផែទេសចរណ៍កែប កោះទន្សាយនៃខេត្តកែប បានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ បាននិងកំពុងសាងសង់កំពង់ផែបេតុង ផ្លូវបេតុងចេញចូលផែ និងការងារដាក់លូក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានបញ្ចប់ការសាងសង់កំពង់ផែទេសចរណ៍អន្តរជាតិខេត្តកំពត បានបញ្ចប់ការសិក្សាផែនការមេនិងកំពុងសាងសង់ជាជំហានៗ មជ្ឈមណ្ឌលភស្តុភារកម្មនិងកំពង់ផែពហុបំណងឯកជនខេត្តកំពត បានបញ្ចប់ការសិក្សាលើប្លង់បច្ចេកទេសចំពោះការសាងសង់កំពង់ផែផ្ទុកទូខេត្តកំពង់ឆ្នាំង និងការសាងសង់ផែរណបមួយចំនួនរបស់កំពង់ផែស្វយ័តភ្នំពេញនៅទន្លេមេគង្គលើទន្លេមេគង្គក្រោមនិងទន្លេសាប។ បន្ថែមលើនេះ នៅកំពង់ផែក្រុងព្រះសីហនុ រាជរដ្ឋាភិបាលបានសាងសង់ចំណតផែកុងតឺន័របន្ថែមបំពាក់ដោយគ្រឿងចក្របន្ថែមនិងសម្ភារផែផ្សេងៗ សាងសង់ចំណតផែកុងតឺន័រ ពង្រីកចំណតផែកុងតឺន័រទឹកជ្រៅថ្មី ជំហានទី២និងទី៣ ដាក់ឱ្យប្រើប្រាស់ឃ្លាំងCFS នៅតំបន់សេដ្ឋកិច្ចកំពង់ផែក្រុងព្រះសីហនុ និងគ្រឿងចក្រលើកដាក់នៅគែមផែចល័តចំនួន២គ្រឿង។

ហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យអាកាសចរណ៍ស៊ីវិល ត្រូវបានអភិវឌ្ឍនិងកែលម្អ។ ជាក់ស្តែង កម្ពុជាបានសាងសាង់និងស្តារអាកាសយានដ្ឋានក្នុងស្រុក អន្តរជាតិសរុបចំនួន១១កន្លែង រួមមាន ១) អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី គឺ **«អាកាសយានដ្ឋានអន្តរជាតិតេជោ»** ជាអាកាសយានដ្ឋានអន្តរជាតិខ្នាតធំកម្រិតលំដាប់ថ្នាក់4F ២) អាកាសយានដ្ឋានអន្តរជាតិសៀមរាបថ្មី ជាអាកាសយានដ្ឋានអន្តរជាតិកម្រិតលំដាប់ថ្នាក់4E ៣) អាកាសយានដ្ឋានអន្តរជាតិតារាសាគរ ៤) អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ត្រូវបានកែលម្អ ដើម្បីបង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធនិងឋបនីយកណ្ឌសំខាន់ៗ និង ៥) អាកាសយានដ្ឋានបន្ទាប់បន្សំចំនួន៧ ទៀតដែលនឹងសាងសង់និងស្តារ រួមមានអាកាសយានដ្ឋានប៉ោយប៉ែត អាកាសយានដ្ឋានកោះរ៉ុង អាកាសយានដ្ឋានកោះកុង អាកាសយានដ្ឋានមណ្ឌលគិរី អាកាសយានដ្ឋានបាត់ដំបង អាកាសយានដ្ឋានកំពង់ឆ្នាំង អាកាសយានដ្ឋានស្ទឹងត្រែង និងគម្រោងសាងសង់មជ្ឈមណ្ឌលផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍។

ការអភិវឌ្ឍវិស័យអគ្គិសនីសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដើម្បីឈានដល់ការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានតម្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ។ សមត្ថភាពនិងប្រភពនៃការផ្គត់ផ្គង់អគ្គិសនី ត្រូវបានបង្កើនដល់៤ ៦៤៩ មេហ្គាវ៉ាត់ នៅចុងឆ្នាំ២០២៣ ដែលក្នុងនោះមាន៣ ៩៧៧មេហ្គាវ៉ាត់ ស្មើនឹង៨៥,៥៤% ជាប្រភពអគ្គិសនីដែលបានអភិវឌ្ឍ នៅក្នុងស្រុក និង៦៧២មេហ្គាវ៉ាត់ ស្មើនឹង១៤,៤៦% ជាប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង។ ប្រភពអគ្គិសនីដែលបានអភិវឌ្ឍនៅក្នុងស្រុក មានប្រភពអគ្គិសនីដែលប្រើឥន្ធនៈហ្វូស៊ីលចំនួន១ ៧០០មេហ្គាវ៉ាត់ ដែលស្មើនឹង៤២,៧៥% និងមានប្រភពអគ្គិសនីពីប្រភពថាមពលកកើតឡើងវិញចំនួន២ ២៧៧មេហ្គាវ៉ាត់ ស្មើនឹង៥៧,២៥%។ ចំពោះប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី រាជរដ្ឋាភិបាលបានសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីកើនឡើងដល់៣ ៧០៨,៥៦គីឡូម៉ែត្រ និងបានបង្កើនអនុស្ថានីយ៍ឱ្យកើនឡើងដល់៦៨កន្លែង ដែលបានគ្របដណ្តប់គ្រប់រាជធានី ខេត្ត។

ជាមួយគ្នានេះ ប្រព័ន្ធបណ្តាញចែកចាយត្រូវបានអភិវឌ្ឍ ដោយខ្សែបណ្តាញចែកចាយមេបានកើនដល់ ៤៩ ៦៥២គីឡូម៉ែត្រនិងខ្សែបណ្តាញចែកចាយសាធារណៈបានកើនដល់៤៧ ៤១១គីឡូម៉ែត្រ ដែលធ្វើឱ្យការចែកចាយអគ្គិសនីចេញពីប្រព័ន្ធបណ្តាញជាតិបច្ចុប្បន្ន អាចគ្របដណ្តប់លើភូមិប្រមាណ៩៨,៨៧% និងបានភ្ជាប់ឱ្យលំនៅឋានចំនួន៣,៤៦លានផ្ទះ ស្មើនឹង៩៤,០២% នៃចំនួនផ្ទះសរុប។

ក្នុងគោលដៅធានាសន្តិសុខនិងចីរភាពថាមពល ដើម្បីបំពេញតម្រូវការប្រើប្រាស់របស់កម្ពុជាឱ្យបានគ្រប់គ្រាន់នាពេលអនាគត និងចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលបានដាក់ចេញផែនការមេអភិវឌ្ឍវិស័យថាមពលអគ្គិសនីឡើងវិញសម្រាប់ឆ្នាំ ២០២២-២០៤០ ដោយបង្កើនសមាមាត្រនៃប្រភពថាមពលស្អាតក្នុងកម្រិតអតិបរមា និងជាផ្នែកមួយចូលរួមដោះស្រាយគោលដៅបរិស្ថានជាតិ ព្រមទាំងការប្តេជ្ញាចិត្តជាសកលរបស់កម្ពុជា។ ទន្ទឹមនេះ គោលការណ៍សម្រាប់អនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលផ្ទះក៏ត្រូវបានប្រកាសឱ្យអនុវត្ត។ ជាមួយគ្នានេះ កម្មវិធីអនុវត្តគម្រោងអន្តរកាលថាមពលជំហានទី១ ឆ្នាំ២០២៣-២០២៥ បាន និងកំពុងអនុវត្ត ចំណែកកម្មវិធីអនុវត្តគម្រោងអន្តរកាលថាមពលជំហានទី២ ឆ្នាំ២០២៥-២០២៨ ផែនទីបង្ហាញផ្លូវសម្រាប់ការប្រើប្រាស់យានយន្តអគ្គិសនី និងផែនទីបង្ហាញផ្លូវឆ្ពោះទៅអព្យាក្រឹតកាបូននៅឆ្នាំ ២០៥០ បាននិងកំពុងរៀបចំ។

## ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ មានវឌ្ឍនភាពល្អប្រសើរក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។ តាមការចង្អុលបង្ហាញរបស់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកកម្ពុជាត្រូវបានដាក់ចេញឱ្យអនុវត្ត ដើម្បីជំរុញការធ្វើពិពិធកម្ម និងអភិវឌ្ឍវិស័យថ្មីដែលមានតម្លៃបន្ថែមខ្ពស់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា។ បន្ថែមលើនេះ ច្បាប់ថ្មីស្តីពីវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ដែលមានការបើកចំហទូលំទូលាយ ទំនើប និងផ្តល់នូវការលើកទឹកចិត្តជាច្រើន ត្រូវប្រកាសឱ្យអនុវត្ត ដើម្បីទាក់ទាញវិនិយោគមានគុណភាពខ្ពស់នៅក្នុងវិស័យអាទិភាពមួយចំនួន ដូចជាបច្ចេកវិទ្យា រថយន្ត អេឡិចត្រូនិក ថាមពលបៃតង សុខាភិបាល ជាដើម។ តំបន់សេដ្ឋកិច្ចពិសេសកាន់តែច្រើនត្រូវបានបង្កើត ដើម្បីជំរុញនូវការអភិវឌ្ឍចង្កោមឧស្សាហកម្ម (Clusters) និងលើកកម្ពស់ឧស្សាហកម្មប្រតិគមន៍និងអនុគមន៍ (Backward and Forward Linkages)។ ជាមួយគ្នានេះ យន្តការសម្របសម្រួលនិងដោះស្រាយនានាពាក់ព័ន្ធនឹងការវិនិយោគនៅកម្ពុជា ត្រូវបានដាក់ចេញ ដើម្បីពង្រឹងនូវភាពជឿទុកចិត្តនិងទាក់ទាញវិនិយោគឱ្យបានកាន់តែច្រើននៅកម្ពុជា។

ក្នុងវិស័យឧស្សាហកម្ម រោងចក្រសរុបចំនួន២ ១២៥រោងចក្រ ក្នុងនោះរោងចក្របង្កើតថ្មីមានចំនួន១៤៣រោងចក្រ ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីផ្តល់ការងារដល់កម្លាំងពលកម្មសរុបចំនួនរហូតដល់ជាង១លាននាក់។ ជាមួយគ្នានេះ ការងារត្រួតពិនិត្យប្លង់បច្ចេកទេសឧស្សាហកម្មត្រូវបានដាក់ឱ្យអនុវត្ត ការងារគ្រប់គ្រងសុវត្ថិភាពឧស្សាហកម្មត្រូវបានពង្រឹង ការងារបណ្តុះបណ្តាលស្តីពីសុវត្ថិភាព

ឧស្សាហកម្មត្រូវបានផ្តល់ជូនវិស័យឯកជនបានចំនួន២ ៥០៣រោងចក្រ ដែលមានសិក្ខាកាមចូលរួមរហូតដល់ចំនួន១០ ០៩៧នាក់ និងក្របខ័ណ្ឌគោលនយោបាយផលិតភាពសេដ្ឋកិច្ចកម្ពុជាត្រូវបានដាក់ចេញ ដើម្បីបង្កើនផលិតភាពពលកម្ម សំដៅកាត់បន្ថយថ្លៃដើម បង្កើនគុណភាព ប្រសិទ្ធភាពផលិតកម្មនិងភាពប្រកួតប្រជែងរបស់កម្ពុជា។

សមិទ្ធផលជាច្រើនទៀតក្នុងការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ ត្រូវបានសម្រេចក្នុងវិស័យអាទិភាពមួយចំនួន រួមមានវិស័យទេសចរណ៍ វិស័យរ៉ែនិងថាមពល វិស័យពាណិជ្ជកម្ម និងវិស័យវប្បធម៌។ ក្នុងវិស័យទេសចរណ៍ សមិទ្ធផលធំៗ រួមមានការធ្វើពិពិធកម្មទេសចរណ៍វប្បធម៌និងធម្មជាតិ ការបង្កើតផលិតផលថ្មី ការធានានូវសុវត្ថិភាពសម្រាប់ទេសចរ ការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាព ការធ្វើពិពិធកម្មតំបន់ទេសចរណ៍និងផលិតផលទេសចរណ៍របស់កម្ពុជាបានកាន់តែសម្បូរបែប។ ក្នុងវិស័យរ៉ែនិងថាមពល ការអភិវឌ្ឍវិស័យប្រេងកាតមានវឌ្ឍនភាព ក្នុងការស្វែងរុករកអភិវឌ្ឍផលិតកម្ម ប្រព្រឹត្តកម្ម ការដឹកជញ្ជូន សន្និធិ និងការធ្វើពាណិជ្ជកម្មប្រេងនិងឧស្ម័ន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងនៃប្រទេសជាតិនិងប្រជាជនកម្ពុជា។ ចំពោះវិស័យពាណិជ្ជកម្ម ការធ្វើពិពិធកម្មទីផ្សារនាំចេញនិងផលិតផល ត្រូវបានពង្រឹង តាមរយៈការបង្កើតស្ថានតំណាងពាណិជ្ជកម្មថ្មីនិងដាក់ឱ្យដំណើរការយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលការណ៍នេះបានជំរុញកំណើននៃការនាំចេញរបស់កម្ពុជាគួរឱ្យកត់សម្គាល់។

ជាក់ស្តែង តម្លៃទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកើនឡើងពីប្រមាណ០,៩៧ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០២១ ដល់ប្រមាណ១,៥០ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣។ តាមការវាយតម្លៃជារួម ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបន្តមាននិន្នាការវិជ្ជមាន និងមានសក្តានុពលខ្ពស់ តាមរយៈកំណើនឥតឈប់ឈរនៃចំនួនអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតចល័ត ដែលបានកើនឡើងប្រមាណ១៩លាននាក់គិតត្រឹមឆ្នាំ២០២៣ ការរីកដុះដាលនៃថ្នាលទូទាត់ប្រាក់ឌីជីថល ដែលបានកើនឡើងដល់ប្រមាណ៤៩២ពាន់លានដុល្លារអាមេរិក ឬប្រមាណ១៦ដងនៃផលិតផលជាតិសរុបក្នុងឆ្នាំ២០២៣ ការប្រែក្លាយពីបរិបទពាណិជ្ជកម្មតាមបែបប្រពៃណីមកជាការធ្វើពាណិជ្ជកម្មបែបទំនើប ជាមួយបច្ចេកវិទ្យារបស់វិស័យឯកជននិងការកើនឡើងនៃការចាប់យកបច្ចេកវិទ្យារបស់អ្នកប្រើប្រាស់ទូទៅ។

ក្នុងវិស័យវប្បធម៌ កម្ពុជាបានកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់សោភណភាពនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោក និងទីតាំងវប្បធម៌សំខាន់ៗ ដើម្បីបង្កើនភាពទាក់ទាញសម្រាប់ទេសចរណ៍ និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ពិសេសនៅរមណីយដ្ឋានអង្គរ។ ឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិតរបស់កម្ពុជា ពិសេសនៅក្នុងផ្នែកតន្ត្រី សិល្បៈទស្សនីយភាព សិល្បៈសម្តែង ម៉ូតសម្លៀកបំពាក់ សៀវភៅ ភាពយន្ត និងវីដេអូ បាននិងកំពុងបន្តមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ទាំងបរិមាណនិងគុណភាព។ ទន្ទឹមនឹងនេះ សមត្ថភាពផលិតនិងទីផ្សារសម្រាប់ទំនិញវប្បធម៌និងច្នៃប្រឌិតរបស់កម្ពុជាក៏កាន់តែមានភាពប្រសើរឡើង តាមរយៈកំណើនតម្រូវការក្នុងស្រុក ការឈានចូលទៅក្នុងទីផ្សារបរទេស ភាពអំណោយផលនៃបច្ចេកវិទ្យាឌីជីថល រួមទាំងភាពជាដៃគូរវាងរដ្ឋ វិស័យឯកជន និង

អង្គការសង្គមស៊ីវិល។ កម្ពុជាបានចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែន ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ រួមទាំងសន្ធិសញ្ញាទីក្រុងប៉េកាំង ស្ដីពីការសម្ដែងសោតទស្សន៍ បានបន្តពង្រឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងបានសហការជាមួយដៃគូនានា ដើម្បីជំរុញការអភិវឌ្ឍសិល្បៈវប្បធម៌នៅកម្ពុជានិងនៅក្នុងតំបន់អាស៊ាន។ល។

### ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

ដើម្បីជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍(វ.ប.ន.) និងឌីជីថលូបនីយកម្មនៅតាមក្រសួង ស្ថាប័ន និងក្នុងវិស័យឯកជន រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគន្លឹះ រួមមានដាក់ចេញក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ ផែនទីបង្ហាញផ្លូវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ឆ្នាំ២០៣០ ប្រព័ន្ធអេកូឡូស៊ីវ.ប.ន.កម្ពុជា ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ប្រមូល គ្រប់គ្រង និងចែករំលែកទិន្នន័យ ការអនុវត្តយន្តការគ្រប់គ្រងមតិជំទាស់និងសំណូមពរតាមប្រព័ន្ធឌីជីថល របៀបវារៈស្រាវជ្រាវជាតិឆ្នាំ២០២៥ បច្ចេកវិទ្យាកសិកម្ម បច្ចេកវិទ្យាអប់រំ បច្ចេកវិទ្យាសុខាភិបាល បច្ចេកវិទ្យាថាមពល បច្ចេកវិទ្យាទេសចរណ៍ បច្ចេកវិទ្យាឌីជីថល ផែនទីបង្ហាញពីការស្រាវជ្រាវនិងនវានុវត្តន៍កម្ពុជា ប្រព័ន្ធអេកូឡូស៊ីការស្រាវជ្រាវកម្ពុជា ក្រមសីលធម៌ស្រាវជ្រាវ បញ្ញាសិប្បនិម្មិតក្នុងប្រទេសកម្ពុជា ការវាយតម្លៃតម្រូវការបច្ចេកវិទ្យា ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវវ.ប.ន.កម្ពុជាឆ្នាំ២០៣០ គោលការណ៍ណែនាំស្ដីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយវ.ប.ន. និងសេចក្ដីព្រាងច្បាប់ស្ដីពីការផ្ទេរបច្ចេកវិទ្យា។

ក្នុងវិស័យប្រៃសណីយ៍ កម្ពុជាបានរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ឆ្នាំ២០២២-២០៣០ និងសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីសេវាប្រៃសណីយ៍ ព្រមទាំងបានដាក់ឱ្យប្រើប្រាស់ការស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតតាមប្រព័ន្ធអនឡាញ និងជំរុញការទូតក្នុងវិស័យប្រៃសណីយ៍។ វិស័យទូរគមនាគមន៍ ដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា និងមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈសន្ទុះនៃការកើនឡើងតម្រូវការនៃការប្រើប្រាស់សេវាទូរសព្ទចល័ត សេវាអ៊ីនធឺណិតល្បឿនលឿន កម្មវិធីឌីជីថលនានានិងសន្ទុះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យនេះ ដែលបានកៀរគរចំណូលជូនរដ្ឋកើនឡើង៤ដង ធៀបនឹង៣ឆ្នាំ មុនការធ្វើការកែទម្រង់។ ជាក់ស្ដែង អ្នកប្រើប្រាស់សេវាទូរសព្ទចល័តបានកើនឡើងដល់ចំនួនប្រមាណ២១លាន សេវាអ៊ីនធឺណិតចល័ត១៩លាន និងសេវាអ៊ីនធឺណិតអចល័ត៦៣៤ ៥៤៦ នៅឆ្នាំ២០២២ ដោយគ្របដណ្ដប់ស្ទើរទូទាំងប្រទេស ហើយបណ្ដាញខ្សែកាបអុបទិកលើគោក មានប្រវែងសរុបមានចំនួន៣១ ៧៦៣គ.ម. និងបណ្ដាញខ្សែកាបអុបទិកក្រោមបាតសមុទ្រកម្ពុជា មានប្រវែងសរុប៦៤០គ.ម.។ ដើម្បីជំរុញការធ្វើបរិវត្តកម្មឌីជីថលឱ្យបានជោគជ័យខ្ពស់សម្រាប់លើកកម្ពស់រដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចនិងសង្គមឌីជីថល រាជរដ្ឋាភិបាលបានបន្តធ្វើទំនើបកម្មសេវាទូរសព្ទចល័តនិងអ៊ីនធឺណិត ព្រមទាំងអភិវឌ្ឍនិងដាក់

ចេញប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសំខាន់ៗសម្រាប់បំពេញតម្រូវការនៃការអភិវឌ្ឍរបស់កម្ពុជាជាក់ស្តែង បានដាក់ចេញប្រព័ន្ធ QR Code សម្រាប់ទប់ស្កាត់កូវីដ-១៩ និងប្រព័ន្ធបណ្ណចាក់វ៉ាក់សាំងឌីជីថល (StopCovid QR Vaccine) ព្រមទាំងថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh សម្រាប់លុបបំបាត់ការក្លែងបន្លំឯកសារ ផ្តល់ភាពងាយស្រួលនិងទំនុកចិត្ត និងបង្កើនប្រសិទ្ធផលសេដ្ឋកិច្ចក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងជំរុញការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យនេះ តាមរយៈការផ្តល់អាហារូបករណ៍ជាច្រើនកន្លែង ដើម្បីកសាងសមត្ថភាព និងពង្រឹងធនធានមនុស្សក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

ក្នុងវិស័យពាណិជ្ជកម្ម ការធ្វើឌីជីថលូបនីយកម្មសម្រេចបានវឌ្ឍនភាពល្អប្រសើរ តាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្តីពី «ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក» ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការអនុវត្តប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងតភ្ជាប់ជាមួយប្រព័ន្ធទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ការផ្តល់សេវាសាធារណៈលើការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីម៉ាក និងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ការជំរុញឱ្យអាជីវករនិងពាណិជ្ជករពង្រឹងសមត្ថភាពរបស់ខ្លួនលើគ្រប់ប្រតិបត្តិការពាក់ព័ន្ធ ជាពិសេសពង្រឹងនិងពង្រីកការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីទាញយកផលវិជ្ជមានឱ្យបានច្រើនពីការធ្វើពាណិជ្ជកម្ម ក្នុងបរិបទសេដ្ឋកិច្ចឌីជីថល ការបង្កើតថ្នាលឌីជីថលសម្រាប់បម្រើការងារគ្រប់គ្រងការដាក់ពាក្យ និងវាយតម្លៃទទួលស្គាល់ផលិតផលនិងការជួយរកទីផ្សារឱ្យផលិតផលភូមិមួយផលិតផលមួយ។ ក្នុងវិស័យព័ត៌មាន រាជរដ្ឋាភិបាល ដោយមានក្រសួងព័ត៌មានជាសេនាធិការ បានរៀបចំថ្នាលទូរទស្សន៍ឌីជីថលជាតិ កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ានត្រូវបានធ្វើឡើង ដើម្បីបង្កើតសុខដុមនីយកម្មនៃការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយឌីជីថលក្នុងតំបន់ ការធ្វើបរិវត្តកម្មទូរទស្សន៍ពីអាណាឡូកទៅឌីជីថល ដើម្បីដាក់ឱ្យដំណើរការថ្នាលទូរទស្សន៍ឌីជីថលកម្ពុជានៅចុងឆ្នាំ២០២៣ និងបិទការផ្សាយទូរទស្សន៍អាណាឡូកនៅឆ្នាំ២០២៥។ ជាក់ស្តែង អង្គភាពប្រព័ន្ធផ្សព្វផ្សាយមានគេហទំព័រ និងការផ្សព្វផ្សាយបានធ្វើឡើងតាមអនឡាញនិងបច្ចេកវិទ្យាឌីជីថល។

ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់លើអាទិភាពមួយចំនួន ដើម្បីចូលរួមអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ចឌីជីថលកម្ពុជា ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងជំរុញបរិវត្តកម្មឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ ការជំរុញការសិក្សាមុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅមធ្យមសិក្សាចំណេះទូទៅ ការសិក្សាជំនាញ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅឧត្តមសិក្សា ការលើកកម្ពស់ការសិក្សាភាសាបរទេស ជំនាញសតវត្សរ៍ទី២១ និងអក្ខរកម្មឌីជីថល ការអប់រំបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងការសិក្សាពេញមួយជីវិត ដោយសម្រេចបានសមិទ្ធផលធំៗជាច្រើន ដូចជា ការដាក់ឱ្យអនុវត្តមជ្ឈមណ្ឌលឌីជីថល ការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍ កម្មវិធីសិក្សាជំនាញថ្មីពាក់ព័ន្ធនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ បញ្ញាសិប្បនិម្មិត ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ការចូលរួមក្នុងបណ្តាញសាកលវិទ្យាល័យសាយប័រ ដើម្បីពង្រឹងសមត្ថភាពសាស្ត្រាចារ្យតាមរយៈការសិក្សាផ្ទាល់ និងអនឡាញ ការដាក់ឱ្យដំណើរ

ការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន រួមមាន EMIS HEMIS FMIS HRMIS SIS Sala Digital ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសាកលវិទ្យាល័យ (UMS) ថ្នាលអប់រំ និងការធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនេះ ការបង្កើតសាលាឌីជីថល សម្រាប់បម្រើឱ្យការបង្រៀននិងរៀន ស្របតាមបរិបទថ្មីនៃការអប់រំឌីជីថល។

## ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

វិស័យហិរញ្ញវត្ថុ ទាំងធនាគារនិងមិនមែនធនាគារ មានការរីកចម្រើនយ៉ាងខ្លាំង និងបន្តរីកចម្រើនជាបន្តបន្ទាប់ ដែលឆ្លុះបញ្ចាំងដោយការកើនឡើងនៃអ្នកចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុ ចំនួនផលិតផលក្នុងទីផ្សារ លំហូរមូលធនវិនិយោគ ការធ្វើសមាហរណកម្មយន្តការគ្រប់គ្រង និងត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ វិស័យធនាគារដែលពេលមុនប្រជាជនមិនទុកចិត្ត ពេលនេះជាប្រព័ន្ធធនាគាររឹងមាំនិងមានស្ថិរភាព ដោយមានដើមទុនរឹងមាំ សន្ទនីយភាពគ្រប់គ្រាន់និងកំណើនឥណទានសមស្រប ព្រមទាំងបានក្លាយជាដៃគូសំខាន់ ក្នុងការជំរុញវិស័យពិតនៃសកម្មភាពសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន៦៣,៦% ដល់៣៤៥,១ទ្រីលានរៀល(៨៤,៥ប៊ីលានដុល្លារអាម៉េរិក)។ ទន្ទឹមនេះ ឥណទានដល់វិស័យឯកជនបានកើនឡើង៧៩,១% ដល់២៣៦,១ទ្រីលានរៀល(៥៧,៨ប៊ីលានដុល្លារអាម៉េរិក) និងប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើង៦៥,៨% ដល់១៩៧,២ទ្រីលានរៀល(៤៨,៣ប៊ីលានដុល្លារអាម៉េរិក)។ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ(M2/GDP) បានកើនឡើងពី១០៧,៧% នៅឆ្នាំ២០១៩ ដល់១៤៧,៥% នៅឆ្នាំ២០២៣។

កម្ពុជាបានពង្រឹងតួនាទីប្រាក់រៀលជាបន្តបន្ទាប់ ដើម្បីពង្រឹងអធិបតេយ្យសេដ្ឋកិច្ចជាតិ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។ តាមរយៈការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងគំនិតផ្តួចផ្តើមផ្សេងៗទៀត ចំនួនគណនីឥណទាននិងប្រាក់បញ្ញើបានកើនឡើងជាបន្តបន្ទាប់ពី៣,១លានគណនីនិង៧,៦លានគណនីនៅឆ្នាំ២០១៩ រហូតដល់៣,៩លានគណនីនិង១៩,២ លានគណនី រៀងគ្នានៅឆ្នាំ២០២៣។ រូបិយវត្ថុចរាចរណ៍ក្នុងទីផ្សារនិងប្រាក់បញ្ញើជារៀល បានកើនឡើងគួរឱ្យកត់សម្គាល់។ ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក បានកើនឡើងយ៉ាងឆាប់រហ័ស ដោយចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនពី៥,២លានគណនីនៅឆ្នាំ២០១៩ ដល់១៩,៧លានគណនី ដែលទំហំទឹកប្រាក់នៃការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកសរុបបានកើនឡើងដល់៧ដង នៃផ.ស.ស.សរុប នៅឆ្នាំ២០២៣។ បន្ថែមលើនេះ វិស័យធានារ៉ាប់រងនិងទីផ្សារមូលបត្រ កំពុងដំណើរការនិងបន្តរីកចម្រើនជាបន្តបន្ទាប់។

បន្ថែមលើនេះ កម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ថ្មីៗជាបន្តបន្ទាប់ ដូចជាប្រព័ន្ធបាគងនៅឆ្នាំ២០២០ ស្តង់ដាខេអេចយូអរ(KHQR) នៅឆ្នាំ២០២២ និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) នៅឆ្នាំ២០២៣ ដែលប្រព័ន្ធទាំងនេះបាននិងកំពុងរួមចំណែកយ៉ាងសកម្មដល់ការជំរុញការដោះដូរនិងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់និងក្រុមហ៊ុនUnionPay និងកំពុងពង្រីកការទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុន

Alipay ប្រទេសដៃគូ និងស្ថាប័នផ្សេងៗទៀត។ ជាមួយគ្នានេះ បទប្បញ្ញត្តិថ្មីៗត្រូវបានដាក់ចេញ រួមមាន សេចក្តីប្រកាសព័ត៌មានស្តីពីការឆបោកប្រាក់តាមបណ្តាញសង្គមនិងប្រព័ន្ធទូរសព្ទ សេចក្តីប្រកាសព័ត៌មានស្តីពីការផ្សព្វផ្សាយ និងផ្តល់ឥណទានដោយខុសច្បាប់ សេចក្តីប្រកាសព័ត៌មានស្តីពីគ្រោះថ្នាក់នៃកម្ចីក្រៅផ្លូវការ និងសេចក្តីថ្លែងការណ៍រួមរវាងធនាគារជាតិនៃកម្ពុជានិងអគ្គស្នងការដ្ឋាននគរបាលជាតិ។

### ១.១.៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

#### ការអភិវឌ្ឍទីផ្សារការងារ

ទីផ្សារការងារត្រូវបានអភិវឌ្ឍនិងកែលម្អជាបន្តបន្ទាប់ ដើម្បីផ្តល់កាលានុវត្តភាពការងារកាន់តែល្អប្រសើរ ជាពិសេសដល់យុវជនដែលទើបឈានដល់វ័យធ្វើការ តាមរយៈការរក្សាបាននូវអត្រាអ្នកចូលរួមកម្លាំងពលកម្មខ្ពស់និងថេរ ក្នុងរង្វង់៧៥% ដែលអត្រានេះមានកម្រិតខ្ពស់ជាងអត្រាជាមធ្យមរបស់អាស៊ានដែលមានអត្រាប្រមាណ៦៦,២%។ ជាមួយនឹងអត្រាមានការងារខ្ពស់ ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប បានកើនឡើងជាបន្តបន្ទាប់ប្រកបដោយសុខដុម ពី១៧០ ដុល្លារអាម៉េរិកក្នុង១ខែ នៅឆ្នាំ២០១៨ ដល់២០០ដុល្លារអាម៉េរិកក្នុង១ខែ នៅឆ្នាំ២០២៣ ហើយឱកាសការងារនៅក្រៅប្រទេសដែលមានលក្ខខណ្ឌការងារល្អនិងប្រាក់ចំណូលខ្ពស់ក៏ត្រូវបានពង្រីកបន្ថែម។ ប្រសិទ្ធភាពនៃការផ្តល់សេវាការងារនិងព័ត៌មានទីផ្សារ ត្រូវបានបន្តពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់ តាមរយៈការបង្កើនមជ្ឈមណ្ឌលការងារចំនួន១៤ និងមជ្ឈមណ្ឌលការងារចល័តជាច្រើនកន្លែង ការដាក់ឱ្យអនុវត្តថ្នាលឌីជីថលសេវាការងារ ដើម្បីផ្តល់សេវាជួយស្វែងរកការងារធ្វើនិងប្រឹក្សាការងារដល់ប្រជាជន ការរៀបចំវេទិកាការងារ ដោយបានផ្តល់សេវាជួយស្វែងរកការងារនិងប្រឹក្សាការងារដល់ប្រជាជនសរុបចំនួន៩០ម៉ឺននាក់។

ការពង្រឹងលក្ខខណ្ឌការងារនិងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិពាក់ព័ន្ធការងារ ការពង្រឹងប្រព័ន្ធអធិការកិច្ចការងារនៅតាមសហគ្រាសគ្រឹះស្ថាន ដោយផ្ទាល់និងតាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងការរៀបចំក្រុមអធិការកិច្ចអន្តរក្រសួង ការពិនិត្យលើលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ ការលើកកម្ពស់ការយល់ដឹងស្តីពីការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ការលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ និងការពង្រឹងយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ការពង្រឹងភាពជាដៃគូនៃកិច្ចសន្ទនាសង្គមតាមយន្តការត្រីភាគីនិងការគាំទ្រនិរន្តរភាពនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

#### ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យមនិងសហគ្រិនភាព

ការអភិវឌ្ឍនិងលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តគោលនយោបាយសំខាន់ៗនានា ការធ្វើប្រតិភូកម្មអំណាចនៃការបង្កើតនិងអនុញ្ញាតឱ្យដំណើរការសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដល់រដ្ឋបាលរាជធានី ខេត្ត កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍និងផ្នែកឯកជន ដើម្បីធ្វើការពង្រឹងសមត្ថភាពរបស់មន្ត្រីជំនាញ រួមទាំងម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម តាមរយៈការផ្តល់ប្រឹក្សាយោបល់ ការបណ្តុះបណ្តាលនិងសិក្ខាសាលា

ការជំរុញតួនាទីស្ត្រីក្នុងសហគ្រិនភាព ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់សហគ្រាសធុនតូច និងមធ្យម ការអភិវឌ្ឍបៃតងក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម ការផ្តល់អត្ថប្រយោជន៍នៃការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ការចុះបញ្ជីអាជីវកម្មតាមOnline និងការប្រើប្រាស់សេវាក្រោមដំបូលតែមួយ ការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព ការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូចនិងមធ្យម ការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសនិងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ នៅឆ្នាំ២០១៩-២០២៣ មូលដ្ឋានសហគ្រាសធុនតូចនិងមធ្យម បង្កើតថ្មីមានចំនួន៥ ៣២៨ និងផ្តល់ការងារចំនួន៧១ ៤៤១នាក់ ដែលធ្វើឱ្យមូលដ្ឋានសហគ្រាសធុនតូចនិងមធ្យម សរុបនៅឆ្នាំ២០២៣ មានចំនួន៤៤ ៦២៨ និងផ្តល់កាលានុវត្តភាពការងាររហូតដល់៤៦៣ ៩៦៦។

## ការរៀបចំនិងការអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

រាជរដ្ឋាភិបាលបានរៀបចំនិងអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដោយបានបង្កើតនិងដាក់ឱ្យអនុវត្តនូវយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ស្របតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ប្រកបដោយភាពប្រទាក់ក្រឡា សក្តិសិទ្ធិភាព ចីរភាព តម្លាភាព និងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីលើកកម្ពស់ការរៀបចំនិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈ។ ក្នុងនោះ រាជរដ្ឋាភិបាលបានបន្តខិតខំជំរុញឱ្យមានការចូលរួមពីវិស័យឯកជន ក្នុងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែម ចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំនិងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលរួមមានគោលនយោបាយនិងនីតិវិធី នីតិវិធីគ្រប់គ្រងលទ្ធកម្មគម្រោង និងគោលការណ៍ណែនាំផ្សេងទៀតពាក់ព័ន្ធនឹងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ជាក់ស្តែង តាមរយៈក្របខ័ណ្ឌគតិយុត្តដ៏រឹងមាំ ជាមួយនឹងកិច្ចគាំទ្រជាក់លាក់ ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជនទទួលបាននូវភាពជោគជ័យគួរជាទីមោទនៈ ដូចជាការរៀបចំអភិវឌ្ឍគម្រោងកំពង់ផែទេសចរណ៍អន្តរជាតិខេត្តកំពត តាមរយៈការដេញថ្លៃដោយប្រកួតប្រជែង និងការរៀបចំសិក្សាគម្រោងផ្សេងៗ តាមរយៈការរៀបចំការដេញថ្លៃចំពោះការជ្រើសរើសទីប្រឹក្សាប្រតិបត្តិការសម្រាប់គាំទ្រការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ដែលបានអនុវត្តចំពោះគម្រោងចំណតឆ្លាតវៃក្នុងខេត្តព្រះសីហនុ ជាដើម។

## ការពង្រឹងការប្រកួតប្រជែង

ការប្រកួតប្រជែងត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ការប្រកួតប្រជែងស្មើភាព សំដៅសម្រេចបាននូវសុភបរមភាវូបនីយកម្មសេដ្ឋកិច្ច តាមរយៈការរៀបចំច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់និងគោលនយោបាយប្រកួតប្រជែងអាស៊ាន ការតាមដានត្រួតពិនិត្យនិងការសម្រប

សម្រួលជាប្រចាំលើ បញ្ហាពាក់ព័ន្ធនឹងការប្រកួតប្រជែងដោយមិនស្មោះត្រង់ ការបង្កើតគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដើម្បីសម្រេចលើគោលនយោបាយនិងការអនុវត្តនីតិវិធីសំខាន់ៗពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែង ការបង្កើតគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដើម្បីជំរុញការណែនាំនិងផ្តល់ជាគោលនយោបាយលើខ្លឹមសារគន្លឹះ ក្នុងការកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ សំដៅពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងការពង្រឹងយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម ជាដើម។

### ១.១.៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ

រាជរដ្ឋាភិបាលបានបន្តជំរុញនិងលើកស្ទួយវិស័យកសិកម្ម ដែលជាសសរស្តម្ភមួយដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រនិងវិសមភាពសេដ្ឋកិច្ច។ ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលជំរុញលើកកម្ពស់ការវិភាគព័ត៌មានទីផ្សារនិងការផ្សព្វផ្សាយស្តីពីភាពទាក់ទាញការវិនិយោគកសិចំណីអាហារនៅកម្ពុជា ការពង្រឹងនិងការពង្រីកសន្តិសុខស្បៀងតាមរយៈការអនុវត្តគោលនយោបាយស្រូវ អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ ការបោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះពីផ្ទៃដីសម្រាប់វិស័យកសិកម្ម ការជួសជុល ការថែទាំ ការស្តារឡើងវិញ និងការសាងសង់ប្រព័ន្ធធារាសាស្ត្រសម្រាប់វិស័យកសិកម្ម ការគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត ការលើកទឹកចិត្តបង្កើនសហគមន៍កសិកម្ម ការបង្កើតសហភាពសហគមន៍កសិកម្ម ផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ។

ជាក់ស្តែង វិស័យនេះបានចូលរួមចំណែកប្រមាណ១៧,១% នៃផ.ស.ស. ថ្លៃបច្ចុប្បន្ន ក្នុងឆ្នាំ២០២៣ ដោយតម្លៃបន្ថែមសរុបបានកើនឡើងជារៀងរាល់ឆ្នាំពី១៩ ៧៥១ពាន់លានរៀល នៅឆ្នាំ២០១៤ ដល់២៣ ០០១ពាន់លានរៀល នៅឆ្នាំ២០១៩ និងឈានដល់២៩ ៧២១ពាន់លានរៀល នៅឆ្នាំ២០២៣។ ក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្ត**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** កន្លងទៅវិស័យនេះសម្រេចបានសមិទ្ធផលសំខាន់ៗ ដូចជា ការកើនឡើងនៃផ្ទៃដីដាំដុះដំណាំស្រូវពីប្រមាណ៣,៣៣លានហិកតា នៅឆ្នាំ២០១៩ ដល់៣,៥៥លានហិកតា នៅឆ្នាំ២០២៣ ដោយមានកំណើនជាមធ្យមប្រមាណ១,៦២% និងបរិមាណផលកើនពី១០,៨៩លានតោន នៅឆ្នាំ២០១៩ ដល់១២,៤៧លានតោន នៅឆ្នាំ២០២៣ ដោយមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៣,៥០% ការកើនឡើងនៃផ្ទៃដីដាំដុះដំណាំសាកវប្បកម្មសំខាន់ៗពី០,២៦លានហិកតា នៅឆ្នាំ២០១៩ ដល់០,៣២លានហិកតា នៅឆ្នាំ២០២៣ ដោយមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៤,៣៣% និងបរិមាណផលកើនពី៣,២៩លានតោន នៅឆ្នាំ២០១៩ ដល់៤,៩៦លានតោន នៅឆ្នាំ២០២៣ ដោយមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ១០,៨៣% និងការកើនឡើងនៃផ្ទៃដីដាំដុះដំណាំឧស្សាហកម្មពី១,២៧លានហិកតា នៅឆ្នាំ២០១៩ ដល់១,៦៣លានហិកតា នៅឆ្នាំ២០២៣ ដោយមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៦,៤២% និង

បរិមាណផលកើនពី១៦,០២លានតោន នៅឆ្នាំ២០១៩ ដល់១៨,៩៦លានតោន នៅឆ្នាំ២០២៣ ជាមួយនឹងកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៤,៣១%។

ចំពោះដំណាំកៅស៊ូ ផ្ទៃដីដាំដុះបានកើនឡើងតិចតួច ប៉ុន្តែទិន្នផលបានកើនឡើងគួរឱ្យកត់សម្គាល់។ ផលិតផលកៅស៊ូសរុបបានកើនឡើងពី២៨៧,៦ពាន់តោន នៅឆ្នាំ២០១៩ ដល់៣៩១,៨ពាន់ហិកតា នៅឆ្នាំ២០២៣(ស្មើ៣៦,២%)។ អនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ បានរួមចំណែកយ៉ាងច្រើនក្នុងការលើកកម្ពស់វិស័យកសិកម្ម។ នៅឆ្នាំ២០១៩ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបមានចំនួនជាង៣២លានក្បាលនិងបានកើនឡើងដល់ជាង៣៩លានក្បាល នៅឆ្នាំ២០២៣ ក្នុងនោះមានគោចំនួនជាង៣លានក្បាល ក្របីចំនួន៤៣១ពាន់ក្បាល ជ្រូកចំនួន១,២៤លានក្បាល និងបក្សីចំនួន៣៤,៣៩លានក្បាល។ ដោយឡែក ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានការកើនឡើងពី១៣,៨១លានក្បាល នៅឆ្នាំ២០១៩ ដល់២៧,៤៤ លានក្បាល នៅឆ្នាំ២០២៣ ក្នុងនោះ គោក្របី៣៤,៨៤ពាន់ក្បាល ជ្រូក២,៣៤លានក្បាល និងបក្សី២៤,៩៦លានក្បាល។ ពាក់ព័ន្ធនឹងការផ្គត់ផ្គង់និងតម្រូវការក្នុងស្រុក ផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពផ្គត់ផ្គង់បានក្នុងរង្វង់៨២%(ប្រមាណ២៣៩ពាន់តោន)នៅឆ្នាំ២០១៩ និងកើនដល់៩៨%(៣២០ពាន់តោន) នៅឆ្នាំ២០២៣។

អនុវិស័យជលផលក៏បានរួមចំណែកជាច្រើនក្នុងការលើកកម្ពស់វិស័យកសិកម្ម។ ការនេសាទទឹកសាប សម្រេចបានចំនួន៤៧៨,៩ពាន់តោនក្នុងឆ្នាំ២០១៩ និង៤២៦,៨ពាន់តោន នៅឆ្នាំ២០២៣ ហើយការនេសាទសមុទ្រសម្រេចបាន១២២,៣ពាន់តោន ក្នុងឆ្នាំ២០១៩ និង១២៥,៥ពាន់តោនក្នុងឆ្នាំ២០២៣។ នៅឆ្នាំ២០១៩ ផលវារីវប្បកម្មសម្រេចបានចំនួន៣០៧,៤ពាន់តោន ក្រពើ៤១២,៨ពាន់ក្បាលនិងការភ្ញាស់កូនត្រី២២២លានកូន ហើយនៅឆ្នាំ២០២៣ ផលវារីវប្បកម្មបានកើនដល់៣១៤ពាន់តោន ក្រពើ៣៣២,៧ពាន់ក្បាលនិងការភ្ញាស់កូនត្រី២៦៩លានក្បាល។ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ មានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់(ស្ត្រី ៣៥%) ក្នុងនោះសហគមន៍នេសាទបានចុះបញ្ជី មានចំនួន៤៤៧។ គិតត្រឹមឆ្នាំ២០២៣ កន្លែងអភិរក្សជលផលមានចំនួនសរុប៦៤៥កន្លែង ក្នុងនោះ៥៧៨កន្លែងនៅក្នុងដែនសហគមន៍នេសាទនិងបានបោះបង្គោលស៊ីម៉ងត៍កំណត់ព្រំប្រទល់កន្លែងអភិរក្សចំនួន៥៤៣បង្គោល សង់កន្លែងស្នាក់អភិរក្សបានចំនួន៥៤ខ្នង បានដាំព្រៃលិចទឹកនិងព្រៃកោងកាងចំនួន២ ៦៥៨ហិកតា កែលម្អទីជម្រកផ្កាថ្មនិងស្មៅសមុទ្របានចំនួន៨ ៥០០ហិកតា និងការពារអភិរក្សសត្វផ្សោតទន្លេមេគង្គបានចំនួន៩០ក្បាល រួមទាំងបានរកឃើញសំបុកអណ្តើកសមុទ្រ៩ទីតាំងនៅឆ្នេរនៃកោះព្រីង និងត្រីទឹកសាបធំបំផុត នៅលើពិភពលោកបានទទួលស្គាល់ដោយ Guinness World Record គឺបបែលញីទឹកសាបទម្ងន់ រហូតដល់៣០០គីឡូក្រាម។

ក្នុងការគ្រប់គ្រងទឹកនិងអាងទន្លេឆ្លងដែន រាជរដ្ឋាភិបាលបានបន្តសហការពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់និងប្រសិទ្ធភាពនៃការអនុវត្តផែនការអាងទន្លេនិងតាមវិស័យ ក្រោមយន្តការគណៈកម្មការទន្លេមេគង្គ ដើម្បីការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយចីរភាពនូវធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ដោយធានាបាននូវនិរន្តរភាពបរិស្ថាន និងវិបុលភាពរួម ក្នុងតំបន់មេគង្គ។

ការនាំចេញផលិតផលកសិកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ពី៤,៨៧លានតោន នៅឆ្នាំ២០១៩ ដល់៨,៤៤លានតោន នៅឆ្នាំ២០២៣ ក្នុងនោះ ការនាំចេញកសិផលច្រើនជាងគេតាមលំដាប់រួមមានស្រូវ ចំនួន២,៧៣លានតោន ចំណិតដំឡូងមីក្រៀមចំនួន១,២៨លានតោន ដំឡូងមីស្រស់ចំនួន១,៩៦លានតោន អង្ករចំនួនជាង៦៥៦ពាន់តោន គ្រាប់ស្វាយចន្ទីឆៅចំនួន៤២៦ពាន់តោន ផ្លែចេកស្រស់ចំនួន២៨៨ពាន់តោន គ្រាប់ពោតចំនួន៧១ពាន់តោន និងផ្លែស្វាយស្រស់ចំនួន១៦២ពាន់តោន។ ការនាំចេញផលិតផលកៅស៊ូមានការកើនឡើងពី២៨២,១ពាន់តោន នៅឆ្នាំ២០១៩ ដល់៣៦៨ពាន់តោន នៅឆ្នាំ២០២៣ ដែលមានកំណើនស្មើនឹង៣០,៤៥% ដោយទទួលបានចំណូលកើនឡើង៣០,១៤% ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣។ ក្នុងឆ្នាំ២០១៩-២០២៣ កម្ពុជាបាននាំចេញគោក្របីចំនួន១១៥,៣៨ពាន់ក្បាល ជ្រូកសាច់១៥,២៥ពាន់ក្បាល ជ្រូកពូជចំនួន១,៧៧ពាន់ក្បាល ស្វាក្តាម១០២,៥៩ពាន់ក្បាល ទឹកដោះគោចំនួន៦,៨៤ពាន់តោន ចំណីឆ្កែចំនួន២៦,៧៨ពាន់តោន រោមសត្វចំនួន១៤៦,៨តោន និងស្បែកគោ ក្របី ជ្រូកចំនួន២៧,១៨ពាន់តោន។ ការនាំចេញផលផលិតផលជលផលបាន៣ ៥៩០តោន ឆ្នាំ២០១៩ និង៣ ៦១០តោន ឆ្នាំ២០២៣។

ក្នុងវិស័យអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលបានរួមចំណែកយ៉ាងច្រើនក្នុងការអនុវត្តគោលនយោបាយនានាពាក់ព័ន្ធនឹងការលើកស្ទួយការអភិវឌ្ឍជនបទ ដោយបង្កើនអនាម័យនៅតំបន់ជនបទ សាងសង់អណ្តូងបានចំនួន៣ ៧៨១ ស្រះសហគមន៍ចំនួន១៨៨ អាងត្រងទឹកភ្លៀងចំនួន២១៥ ប្រព័ន្ធចែកចាយទឹកតាមបំពង់តូចសហគមន៍ចំនួន៥៥ ស្ថានីយផលិតទឹកសហគមន៍ចំនួន៨៥ និងប្រព័ន្ធស្រោចស្រពខ្នាតតូច២ខ្សែ ព្រមទាំងផលិតនិងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស តាមរយៈការអនុវត្តនូវសកម្មភាពនានា និងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ស្តារនិងសាងសង់ផ្លូវជនបទបានប្រវែង៤៥ ២០០គ.ម. នៅទូទាំងប្រទេស។ លទ្ធផលនៃការអនុវត្តគម្រោងស្តារនិងសាងសង់នេះ សម្រេចបានប្រមាណជាង៩៦% នៅឆ្នាំ២០១៩ និងសម្រេចបាន១០០% ឆ្នាំ២០២១ ទោះបីកម្ពុជារងកម្មវិបាក ដោយការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ។ ការកែលម្អផ្លូវជនបទទៅជាកៅស៊ូពីរជាន់ឬបេតុង ត្រូវបានអនុវត្តជាបន្តបន្ទាប់ដោយសម្រេចបានលទ្ធផលល្អ ប្រកបដោយភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ ប្រកបដោយចីរភាព

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដើម្បីធ្វើស្មុគបរមការូបនីយកម្មនៃធនធានដ៏សំខាន់សម្រាប់ជាឧត្តមប្រយោជន៍ជាតិ រក្សាបានតុល្យភាពការអភិវឌ្ឍនិងការអភិរក្ស ដោយបានជំរុញការអភិវឌ្ឍលើវិស័យរ៉ែ ក្នុងនោះ ទុនវិនិយោគសរុបលើវិស័យមានសរុបប្រមាណចំនួន៧,២ប៊ីលានដុល្លារអាម៉េរិក លើកកម្ពស់អភិបាលកិច្ចនិងគ្រប់គ្រងធនធាន ដោយបានលុបបំបាត់សកម្មភាពរ៉ែអនាធិបតេយ្យស្ទើរទាំងស្រុងទូទាំងប្រទេស ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលថវិកាជាតិ ក្នុងនោះចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែសម្រេចបានប្រមាណចំនួន១៧៧,២លានដុល្លារអាម៉េរិក អនុវត្តគម្រោងមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋានសរុបចំនួន៥៨នៅក្នុងខេត្តចំនួន១៣ គ្រប់គ្រងប្រតិបត្តិការរ៉ែ ដើម្បីធានានិរន្តរភាពនៃ

ការផ្គត់ផ្គង់ផលិតផលរ៉ែដោយចីរភាព តាមរយៈការរៀបចំនិងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំនានា។

ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រាជរដ្ឋាភិបាលបានជំរុញបង្កើតសហគមន៍ព្រៃឈើ ការអភិរក្សព្រៃឈើ និងការជំរុញការស្តារព្រៃឈើ តាមរយៈការដាំដើមឈើ ជាដើម។ ក្នុងរយៈពេលពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ សហគមន៍ព្រៃឈើថ្មីចំនួន១៥សហគមន៍ ត្រូវបានបង្កើតឡើង ដោយបានគ្របដណ្តប់លើផ្ទៃដីប្រមាណ១១ ៨៤១ហិកតា ដែលធ្វើឱ្យសហគមន៍ព្រៃឈើនាពេលបច្ចុប្បន្នមានចំនួនសរុប ៦៥១ និងគ្របដណ្តប់លើផ្ទៃដីប្រមាណ៥២៨ ៦៥៨ហិកតា ក្នុងនោះ សហគមន៍ចំនួន៥៤២ លើផ្ទៃដី ៤៥៥ ៥៤៩ហិកតា ត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការ។ ជាមួយគ្នានេះ កិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៦៨កន្លែងលើផ្ទៃដី៣៨៥ ៩៣៨ហិកតាត្រូវបានធ្វើឡើងនិងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១១៥ ដែលគ្របដណ្តប់លើផ្ទៃដី៧៩ ២៥០ហិកតា ត្រូវបានអនុម័ត។ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តឱ្យថែទាំចម្ការឈើចាស់ៗ ដោយរក្សាបានទំហំ៤ ០៧៨ហិកតា ចម្ការពូជឈើទំហំ៥២ហិកតា និងឡូត៍បង្ហាញកសិរុក្ខកម្មទំហំ៨៦ហិកតា ព្រមទាំងដាំឈើជាចម្ការថ្មីទំហំ១៧ ៣៩៥ពាន់ហិកតា ការពារចម្ការឈើនិងតំបន់ប្រភពគ្រាប់ពូជឈើប្រណិត បង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ដោយសម្រេចបានចំនួន៩១ទីតាំង លើផ្ទៃដីសរុបចំនួន៥០៦ ៨២២ហិកតា ក្នុងនោះ១៦ទីតាំងមានបណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ១០៦ ៩០៧ហិកតា ដើម្បីត្រៀមរៀបចំនិងជំរុញការចូលរួមវិនិយោគរបស់វិស័យឯកជននិងដៃគូពាក់ព័ន្ធនានា លើការងារដាំដុះព្រៃឈើ ដាំដើមឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារ លើផ្ទៃដីសរុបទំហំ៨១ ៨០២ហិកតានិងអនុវត្តគម្រោងដាំឈើក្នុងដីសម្បទានសេដ្ឋកិច្ចលើផ្ទៃដីចុះកិច្ចសន្យាទំហំ២៨០ ៨៧០ហិកតា សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការតាមដានត្រួតពិនិត្យនិងការពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រសិប្បកម្មកែច្នៃនិងអាជីវកម្មឈើ ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ វិធានការម៉ឺងម៉ាត់ត្រូវបានយកចិត្តទុកដាក់អនុវត្តដើម្បីទប់ស្កាត់និងលុបបំបាត់ ការកាប់បំផ្លាញព្រៃឈើ និងការទន្ទ្រានយកដីព្រៃដីធ្វើជាកម្មសិទ្ធិ។

ក្នុងវិស័យបរិស្ថាន រាជរដ្ឋាភិបាលបានអនុវត្តសកម្មភាពជាច្រើន ដូចជាការរៀបចំនិងការបង្កើនចំនួនតំបន់ការពារធម្មជាតិពី២៣តំបន់ ដែលមានផ្ទៃដីទំហំ៣,២លានហិកតា ស្មើនឹង១៨% នៃផ្ទៃប្រទេស ដល់៧៣តំបន់ ក្នុងផ្ទៃដីទំហំសរុប៧ ០៤៦ ៨៦៣,៤៦ហិកតា ស្មើនឹង៤០% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា ការដាក់ឱ្យដំណើរការកិច្ចការពារនិងអភិរក្សព្រៃឈើសម្រាប់គាំទ្រដល់ការលក់ឥណទានកាបូនលើផ្ទៃដីទំហំ១,២៧លានហិកតា ស្មើនឹង១៧,៦% នៃផ្ទៃដីតំបន់ការពារធម្មជាតិទាំងអស់ និងសិក្សាដើម្បីរៀបចំគម្រោងរេដបូកបន្ថែមទៀតលើផ្ទៃដីទំហំ១,១៩លានហិកតា ដែលធ្វើឱ្យផ្ទៃដីគម្រោងរេដបូកមានការកើនឡើងដល់ទំហំ២,៤៦លានហិកតា ស្មើនឹង៣៤,១% នៃផ្ទៃដីតំបន់ការពារធម្មជាតិទាំងអស់។ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ ការបោះបង្គោលព្រំចំនួន៣ ៥០០បង្គោល និងការចុះបញ្ជីដីរដ្ឋតាមតំបន់ការពារធម្មជាតិមានទំហំផ្ទៃដីសរុប២៧៣ ៤០០,៣៧ហិកតា ត្រូវបានធ្វើឡើងដោយជោគជ័យ។ រាជរដ្ឋាភិបាលក៏បានរៀបចំអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍ ដែលមានផ្ទៃដីសរុប

ប្រមាណ៩០០ ០០០ហិកតា អនុក្រឹត្យពាក់ព័ន្ធសម្រាប់ជំរុញការអភិវឌ្ឍនិងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងតំបន់ការពារធម្មជាតិ ប្រកាសសេចក្តីសម្រេចនិងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ សម្រាប់គាំទ្រដល់ការអនុវត្តក្នុងកិច្ចការពារ ថែរក្សា និងអភិរក្សធនធានធម្មជាតិនៅតាមតំបន់ការពារធម្មជាតិ និងបានកសាង ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធតាមតំបន់ការពារធម្មជាតិផងដែរ។

រាជរដ្ឋាភិបាលបានអនុវត្តសកម្មភាពនានាជាច្រើនទៀត និងសម្រេចបាននូវសមិទ្ធផលគួរជាទីពេញចិត្ត ដោយបានរៀបចំអនុក្រឹត្យបង្កើតតំបន់បេតិកភណ្ឌធម្មជាតិចំនួន១២ អនុក្រឹត្យស្តីពីការកំណត់ទីតាំងបេតិកភណ្ឌវប្បធម៌ដែលមានក្នុងតំបន់ការពារធម្មជាតិ ប្រកាសស្តីពីការបង្កើតនិងដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ ប្រកាសស្តីពីគោលការណ៍ណែនាំក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចស្ថិតក្នុងតំបន់ការពារធម្មជាតិ និងគោលការណ៍ណែនាំស្តីពីការប្រមូល ការដកហូតនិងការកែច្នៃអនុផលព្រៃឈើក្នុងតំបន់ការពារធម្មជាតិ និងប្រកាសស្តីពីការបង្កើតនិងដាក់ឱ្យប្រើប្រាស់នូវឯកសណ្ឋានសហគមន៍មូលដ្ឋាន។ វេទិកានានាពាក់ព័ន្ធនឹងវិស័យបរិស្ថានត្រូវបានរៀបចំ ដូចជាវេទិកាថ្នាក់តំបន់ស្តីពី«ការការពារ និង អភិរក្សធនធានធម្មជាតិ» កិច្ចប្រជុំស្តីពី «បណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិ» ដើម្បីពិនិត្យវឌ្ឍនភាព ពិភាក្សាបញ្ហាប្រឈមនិងដំណោះស្រាយលើកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ។

ក្នុងតំបន់ កម្ពុជាបានចូលរួមរៀបចំនិងទទួលបានការអនុម័តលើឯកសារសំខាន់ៗចំនួន៣ ក្នុងកំឡុងពេលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី១៨ ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន រួមមាន ១) ផែនការយុទ្ធសាស្ត្រអាស៊ានស្តីពីការគ្រប់គ្រងតំបន់ដីមមោក ២) ក្របខ័ណ្ឌវិនិយោគអាស៊ានសម្រាប់ការគ្រប់គ្រងដីដោយគ្មានផ្សែងអ័ព្ទនិងប្រកបដោយនិរន្តរភាព និង ៣) ផែនទីបង្ហាញផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានស្តីពីការគ្រប់គ្រងការបំពុលផ្សែងអ័ព្ទឆ្លងដែន ព្រមទាំងបានចូលរួមជាមួយប្រទេសចិននិងប្រទេសម៉ាដាហ្គាស្កា ផ្តួចផ្តើមនិងរៀបចំបង្កើតមជ្ឈមណ្ឌលព្រៃកោងកាងអន្តរជាតិ ក្នុងក្របខ័ណ្ឌអនុសញ្ញារ៉ាមសារ និងទទួលបានការអនុម័តនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី៦២ នៅប្រទេសស្វ៊ីស។

រាជរដ្ឋាភិបាល ដោយមានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) ជាសេនាធិការ បានអនុវត្តសកម្មភាពនានាដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈបទដ្ឋានគតិយុត្តមួយចំនួនដូចជា សារាចរស្តីពីការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួង ស្ថាប័ន សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសម្របសម្រួលការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមអន្តរាគមន៍ប្រតិបត្តិការរុករកសង្គ្រោះគ្រោះមហន្តរាយជាដើម។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញសារាចរណែនាំចំនួន៤ ពាក់ព័ន្ធនឹងការថែរក្សាទឹកទុក ដើម្បីត្រៀមលក្ខណៈឆ្លើយតបនិងកាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ការត្រៀមវិធានការទប់ទល់គ្រោះទឹកជំនន់ក្នុងពេលដែលទឹកទន្លេមេគង្គកំពុងមានចលនាជន់ឡើង ការបន្តវិធានការត្រៀមទប់ទល់នឹងគ្រោះទឹកជំនន់ ការចាត់វិធានការថែរក្សាទឹកទុកដើម្បីសង្គ្រោះការខូចខាតដំណាំកសិកម្ម និងសម្រាប់ប្រើប្រាស់ ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតប

គ្រោះអាសន្នជាតិ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន គ្រោះមហន្តរាយនៅតាមរាជធានីខេត្តទាំង២៥ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិនិងក្រោមជាតិ និងលើកកម្ពស់សមត្ថភាពស្ត្រីក្នុងកម្មវិធីការកាត់បន្ថយហានិភ័យគ្រោះ មហន្តរាយនៅមូលដ្ឋានសហគមន៍ និងបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ ព្រមទាំងប្រកាសសេចក្តីសម្រេចនិងសេចក្តីណែនាំមួយចំនួនទៀត។

ក្នុងវិស័យវប្បធម៌ កម្ពុជាបានអភិរក្សសំណង់បេតិកភណ្ឌប្រមាណ៩០៦ទីតាំង/ផ្នែក/ចំណុច។ ប្រាសាទកណ្តាលស្រះស្រង់ កំពង់ទឹកបារាយណ៍មេបុណ្យនៃប្រាសាទបន្ទាយឆ្មារ និងទម្រង់កាយវិការបដិមាព្រះបាទជ័យវរ្ម័នទី៧ ត្រូវបានស្តារឱ្យមានរូបរាងដើមឡើងវិញ។ ស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្តត្រូវបានបញ្ចប់ការជួសជុល។ វត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធសាស្ត្រប្រមាណ២៦ ៣១៨មុខត្រូវបានអភិរក្ស រីឯ៧១ ៦៨៥មុខផ្សេងទៀតត្រូវបានរកឃើញនិងទទួលបានពីគ្រប់ប្រភព។ បុរាណដ្ឋានប្រមាណ១ ១៩៩ ត្រូវបានធ្វើបណ្ណកម្មសិទ្ធិ រីឯ២០៥ ផ្សេងទៀត ត្រូវបានបោះបង្គោលការពារ។ កម្ពុជាបានចុះរមណីយដ្ឋានប្រាសាទកោះកេរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ល្ខោនខោលវត្តស្វាយអណ្តែត និងក្បាច់គុនល្បុក្កតោទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនិងទីក្រុងបាត់ដំបងទៅក្នុងបណ្តាញទីក្រុងមានភាពច្នៃប្រឌិតរបស់អង្គការយូណេស្កូ។ កម្ពុជាបានអភិរក្សនិងលើកស្ទួយសិល្បៈវប្បធម៌ជាតិ តាមរយៈការតែងតាំងមរតកមនុស្សរស់ ការជួសជុលសាស្ត្រាស្លឹករឹត រួមទាំងការសម្តែងសិល្បៈនៅក្នុងនិងក្រៅប្រទេសចំនួន៤ ៥៩៥លើក ពិសេសក្នុងព្រឹត្តិការណ៍ស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេម។ សារាចរស្តីពីការទប់ស្កាត់ការវាយកម្ទេចនិងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ ប្រកាសស្តីពីការរៀបចំនិងគ្រប់គ្រងក្រុមរបាំព្រះរាជទ្រព្យតំណាងជាតិ និងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមប្រឹក្សាពិន័យ និងលើកសរសើរ ត្រូវបានដាក់ឱ្យអនុវត្ត។ ការអប់រំបណ្តុះបណ្តាលនិងសិក្សាស្រាវជ្រាវផ្នែកសិល្បៈវប្បធម៌ត្រូវបានពង្រឹង រួមទាំងការសម្ពោធសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈថ្មី។ កម្ពុជាបានសហការជាមួយដៃគូនានា ដើម្បីជំរុញការអភិរក្សវប្បធម៌នៅកម្ពុជានិងក្នុងតំបន់អាស៊ាន ពិសេសការទប់ស្កាត់ការជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់។ល។

## ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍទីក្រុងប្រកបដោយបរិស្ថានល្អនិងមានសោភ័ណភាព សម្រាប់ការរស់នៅនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងប្រសិទ្ធភាពសង្គមសេដ្ឋកិច្ច។ ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្តនូវសកម្មភាពអាទិភាពចំនួន៦ ដោយសម្រេចបានគួរជាទីពេញចិត្ត ដែលសកម្មភាពអាទិភាពទាំងនោះ រួមមានការងាររដ្ឋបាលដីធ្លីការងាររៀបចំដែនដីនិងនគរូបនីយកម្ម នគរូបនីយការងាររដ្ឋបាលដីធ្លី ការងារគ្រប់គ្រងនិង អភិវឌ្ឍវិស័យសំណង់ ការងារលំនៅឋាននិងសម្បទានដីសង្គមកិច្ច ការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងការងាររៀបចំគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

ក្នុងផ្នែកការងាររដ្ឋបាលដីធ្លី ត្រឹមចុងឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានចុះបញ្ជីចេញបណ្ណកម្មសិទ្ធិដីធ្លីចំនួន៧ ២៣៣ ៨៩៨បណ្ណ ដោយបានបញ្ចប់ការចេញបណ្ណជំហានទី១ ប្រមាណ៧លានក្បាលដី និងបានអនុវត្តការចេញបណ្ណជំហានទី២ បានចំនួន២៣៣ ៨៩៨បណ្ណ ស្មើនឹង៤,៦៨% នៃចំនួនក្បាលដីប៉ាន់ស្មានជំហានទី២ សរុប៥លានក្បាលដី។ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន៦ ៦០២ ៩៥៦បណ្ណ ទន្ទឹមនឹងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ សម្រេចបាន៦៣០ ៩៤២បណ្ណ ក្នុងនោះដីរដ្ឋមាន២១៨ទីតាំង បានចំនួន២ ៣៧៣បណ្ណ ទំហំ១១៥៦ ២២២ហិកតា ដែលមានដីគោលដៅសម្បទានសេដ្ឋកិច្ច១៨៨ទីតាំង ចំនួន២ ១០៣បណ្ណ ទំហំផ្ទៃដីសរុបប្រមាណ៧៣៤ ០៥៣ហិកតា និងតំបន់ការពារព្រៃស្តារឡើងវិញ២៦ទីតាំង ចំនួន១៤៥បណ្ណ ទំហំ២២ ៩២០ហិកតា និងដីឯកជនចំនួន៦២៧ ៤៦៤បណ្ណ។ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច បានចំនួន៤២សហគមន៍ ស្មើនឹង១ ១០៥បណ្ណ ទំហំផ្ទៃដីសរុប៤១ ៥៣៨,៨២ហិកតា សម្រាប់៤ ១៥៩គ្រួសារ។ ក្នុងឆ្នាំ២០១៩-២០២៣ ពាក្យបណ្តឹងតវ៉ាដីធ្លីមានចំនួនសរុប៣ ៦៤៨ករណី ត្រូវបានទទួលក្នុងនោះវិវាទចំនួន៣ ០៩៥ករណី ត្រូវបានដោះស្រាយបញ្ចប់។

ជាមួយគ្នានេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដាំនិងវាស់វែងបង្គោលប្រឹថពីវិភាគលំដាប់សូន្យចំនួន៧បង្គោល លំដាប់ទី១ ចំនួន១៥៥បង្គោល លំដាប់ទី២ ចំនួន៥៧១បង្គោល លំដាប់ទី៣ ចំនួន១៧០បង្គោល និងលំដាប់ទី៤ ចំនួន១៧២បង្គោល ព្រមទាំងបានដាំនិងវាស់វែងបង្គោលរយៈកម្ពស់ចំនួន៩៧២បង្គោល និងបង្គោលទំនាញផែនដីចំនួន២៣៧បង្គោល បានសាងសង់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ចំនួន៦០ស្ថានីយ និងស្ថានីយវាស់វែងអចិន្ត្រៃយ៍ដោយផ្កាយរណប គាំទ្រដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ជប៉ុនចំនួន៥ស្ថានីយ និងបានរៀបចំលេខកូដនាមភូមិសាស្ត្រថ្មីចំនួន៣៦៦លេខកូដ។ ក្នុងផ្នែកការងារគ្រប់គ្រងនិងអភិវឌ្ឍវិស័យសំណង់ ជាមួយនឹងការរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិនិងថ្នាក់តំបន់ចំនួន២ គឺតំបន់ឆ្នេរសមុទ្រកម្ពុជា និងតំបន់ជុំវិញបឹងទន្លេសាប រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់ ១) ប្លង់គោលប្រើប្រាស់ដី និងផែនការរៀបចំដែនដីរាជធានី ខេត្ត ២) ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងនិងតំបន់ទីប្រជុំជនចំនួន១៩ ៣) ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ចំនួន៩ និង៤) ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន ២០១។

ក្នុងឆ្នាំ២០១៩-២០២៣ លិខិតអនុញ្ញាតត្រូវបានផ្តល់ដើម្បីសាងសង់ចំនួន២១ ៥១៥ គម្រោង មានផ្ទៃក្រឡាសំណង់សរុបចំនួន៨៦ ១០២ ៨១៤ម៉ែត្រការ៉េ ដោយមានទុនវិនិយោគសរុបប្រមាណ ៣២ ៩៧៧ ៧៩៩ ៥២៤ដុល្លារអាម៉េរិក។ ជាមួយគ្នានេះ វិញ្ញាបនបត្រត្រូវបានផ្តល់ដល់ក្រុមហ៊ុនប្រកបអាជីវកម្មសាងសង់បានចំនួន១ ៩៣៩ក្រុមហ៊ុន ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់បាន១២០ក្រុមហ៊ុន រូបវន្តបុគ្គល សិក្សា គម្រោងប្លង់ចំនួន៦៣៦រូប និងអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវបានផ្តល់ឱ្យក្រុមហ៊ុនចំនួន៨។ ក្នុងសកម្មភាពពាក់ព័ន្ធនឹងលំនៅឋាន រាជរដ្ឋាភិបាលបានរៀបចំផែនទីបឋមនៃទីតាំងសំណង់បណ្តោះអាសន្ន និងសហគមន៍ប្រជាពលរដ្ឋក្រីក្រចំនួន៣៩៧ទីតាំង មានចំនួន ១៣ ៥៧៨ខ្នងផ្ទះ ស្មើនឹង១៦ ៧៨៤គ្រួសារ ព្រមទាំងតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់និងដីធ្លី

ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ក្នុងនោះប្រជាពលរដ្ឋបានស្ម័គ្រចិត្តចាកចេញពីរមណីយដ្ឋានអង្គរសរុបចំនួន៩ ៩០៤គ្រួសារ ទៅរស់នៅតំបន់អភិវឌ្ឍន៍រុនតាឯកចំនួន៥ ៨៦៥គ្រួសារ និងទៅតំបន់អភិវឌ្ឍន៍ពាក់ស្នែង៤ ០៣៩គ្រួសារ ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋនៅតំបន់អភិវឌ្ឍន៍រុនតាឯកចំនួន៥ ១២១បណ្ណ និងរៀបចំអភិវឌ្ឍគម្រោងលំនៅឋានតម្លៃសមរម្យចំនួន៤គម្រោង។

ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ រាជរដ្ឋាភិបាលបានដំណើរការសាងសង់និងដាក់ឱ្យដំណើរការស្ថានីយបូមទឹកកខ្វក់ចំនួន៤ទីតាំង ស្ថិតនៅឆ្នេរឯករាជ្យ អូរសុខា អូរសម្អាត និងឆ្នេរអូរឈើទាល ព្រមទាំងបានសាងសង់ និងដាក់ឱ្យដំណើរការនូវស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន៣ ដែលស្ថានីយទី១ អាចចម្រោះទឹកកខ្វក់ចំនួន៥ ២០០ម៉ែត្រគូបក្នុង១ថ្ងៃ ស្ថានីយទី២ អាចចម្រោះទឹកកខ្វក់ចំនួន៧ ២០០ម៉ែត្រគូប ក្នុង១ថ្ងៃ និងស្ថានីយទី៣ អាចចម្រោះទឹកកខ្វក់ចំនួន២០ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃ។ រាជរដ្ឋាភិបាលបានរៀបចំកែលម្អឆ្នេរសមុទ្រប្រវែង១៨ ៨៧៤ម៉ែត្រឱ្យមានសោភណ្ឌភាពឡើងវិញ ដោយបានបើកការតភ្ជាប់ឆ្នេរសមុទ្រចំនួន៣ទីតាំង មានប្រវែងសរុប៣ ១៣៤ម៉ែត្រ។

## ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា បានផ្តោតអាទិភាពលើការបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣ ផែនការយុទ្ធសាស្ត្រ REDD+ ជាតិ និងការប្រើប្រាស់មូលនិធិបរិស្ថានសង្គមឱ្យមានប្រសិទ្ធភាព ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ច ការបំភាយកាបូនទាប និងធន់នឹងការប្រែប្រួលអាកាសធាតុ។ ដើម្បីសម្រេចបានតាមគោលបំណងនេះ គម្រោងសកម្មភាពសំខាន់ៗមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចជាការចុះសិក្សាស្រាវជ្រាវ និងការចងក្រងទិន្នន័យពីការប្រើប្រាស់បច្ចេកវិទ្យាបៃតងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យនានានៅតាមបណ្តាខេត្តគោលដៅ ការវិភាគនិងការវាយតម្លៃពីបច្ចេកវិទ្យាបៃតងនិងការសហការស្រាវជ្រាវជាមួយគ្រឹះស្ថាននានាដោយផ្តោតសំខាន់លើ ១) មធ្យោបាយដឹកជញ្ជូនបៃតង ២) ការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ថាមពលកកើតឡើងវិញ និងថាមពលស្អាត ៣) ការអនុវត្តបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន សម្រាប់តំបន់សេដ្ឋកិច្ចពិសេស ៤) ការពន្លឿននវានុវត្តន៍ និងសហគ្រិនភាព បច្ចេកវិទ្យាស្អាតក្នុងធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យម នៅកម្ពុជា ៥) ការវាយតម្លៃសក្តានុពល នៃដំណោះស្រាយដោយផ្អែកលើធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់បង្កើនសន្តិសុខទឹក និងបង្កើនភាពធន់ សម្រាប់គ្រោះទឹកជំនន់ និងរាំងស្ងួតនៅតំបន់ទីជម្រាល។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំង៧ (ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម ស្ទួង និងក្រុងបាវិត) និងផែនទីបង្ហាញផ្លូវស្តីពីការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាពនៅកម្ពុជា ឆ្នាំ២០២២-២០៣៥ ព្រមទាំងផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវស្តីពីការវិភាគស្ថានភាពអគារបៃតងនៅ

កម្ពុជា និងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសេដ្ឋកិច្ចវិលជុំឆ្នាំ២០២១-២០៣០ បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំឯកសារគោលគំនិតគោលនយោបាយ ផែនការយុទ្ធសាស្ត្រ របាយការណ៍ស្រាវជ្រាវ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយ កិច្ចព្រមព្រៀង អនុសញ្ញា ក្របខ័ណ្ឌសហប្រជាជាតិ ផែនទីបង្ហាញផ្លូវ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ អព្យាក្រឹតកាបូននៅកម្ពុជា និងផែនការអនុវត្ត និងប្រព័ន្ធតាមដានការអនុវត្តសកម្មភាព Updated NDC និង LTS4CN (NDC Tracking System)។

ក្នុងនីតិកាលទី៦ នៃរដ្ឋសភា វិស័យបរិស្ថានកម្ពុជាសម្រេចបានសមិទ្ធផលធំៗជាច្រើនជាបន្តបន្ទាប់ ដែលធ្វើឱ្យសហគមន៍អន្តរជាតិទទួលស្គាល់កម្ពុជាថាជាជើងឯកមួយនៅក្នុងវិស័យបរិស្ថាន តាមរយៈការអនុម័តអនុសញ្ញាសហប្រជាជាតិសំខាន់ៗពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ និងការប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ការអនុវត្តបានល្អប្រសើរនូវបេសកកម្មដឹកនាំកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែលជាមូលធនធម្មជាតិសម្រាប់ធានាសន្តិសុខស្បៀង សន្តិសុខទឹក សន្តិសុខថាមពល ការទ្រទ្រង់ជីវភាព ប្រជាជនសម្រាប់រយៈពេលវែងនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព ការគ្រប់គ្រងសំណល់រឹងរាវនៅទីប្រជុំជន យុទ្ធនាការលុបបំបាត់សំណល់ប្លាស្ទិក និងកែច្នៃសំណល់ទីប្រជុំជន កសិដ្ឋាន រោងចក្រ សហគ្រាស និងអង្គភាពធុរកិច្ចផ្សេងៗទៀត ស្របតាមគោលការណ៍ ៤R និងសេដ្ឋកិច្ចវិលជុំ គំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងបៃតងរបស់កម្ពុជា ដើម្បីតម្រង់ទិសអាស៊ានឱ្យស្ថិតនៅលើមាគ៌ាអភិវឌ្ឍន៍បៃតងនិងចីរភាព ការអនុវត្តគោលនយោបាយការទូតបៃតង ឥណទានកាបូននិងការលើកកម្ពស់ហិរញ្ញប្បទានបៃតង ជាដើម។

## ១.២- សមិទ្ធផលចម្បងៗក្នុងឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

រាជរដ្ឋាភិបាលជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ កម្មវិធីគោលនយោបាយអាទិភាពទាំង៦ និងវិធានការគន្លឹះទាំង៥ ដោយសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់និងសមិទ្ធផលចម្បងៗជាច្រើន នៅឆ្នាំ២០២៤។ ចំពោះវិស័យការបរទេស រាជរដ្ឋាភិបាលបានបន្តពង្រឹងនិងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជាមិត្តទាំងអស់ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ចូលរួមចំណែកយ៉ាងសកម្មនៅក្នុងយន្តការតំបន់និងសកលលោក ជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការរៀបចំនៃគណៈកម្មការកសាងសន្តិភាព (OC-PBC) អាណត្តិ២០២៥-២០២៦ និងធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗចំនួន៤ដោយរលូននិងជោគជ័យ។

ក្នុងវិស័យសន្តិសុខ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តាមរយៈការធ្វើតេស្តមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធសរុបជាង១០ម៉ឺននាក់ បង្ក្រាបបទល្មើសគ្រឿងញៀន ចំនួនជាង១ម៉ឺនករណី បង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ បង្ក្រាបសកម្មភាពក្មេងទំនើង ចំនួន១ ៦១១ករណី បង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសបច្ចេកវិទ្យា និងបទល្មើសសម្អាតប្រាក់ អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងអ្នកដំណើរTMS និងប្រព័ន្ធគ្រប់គ្រងជនបរទេសFMS ដាក់ឱ្យដំណើរការនូវការស្នើសុំលិខិតឆ្លងដែនតាមអនឡាញនិងបាន

បង្កើតក្រុមការងារចុះផ្ដល់សេវាលិខិតឆ្លងដែន ជូនប្រជាពលរដ្ឋដែលមានជំងឺ ចាស់ជរា ឬមានពិការភាពដល់លំនៅឋាន ពង្រឹងយន្តការសម្រាប់ការងារខណ្ឌសីមាជាមួយប្រទេសជិតខាង បានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនៅក្នុងនិងក្រៅតំបន់ លើកិច្ចការប្រយុទ្ធប្រឆាំងភេរវកម្មឆ្លងដែន សន្តិសុខលម្ហសមុទ្រនិងកិច្ចសហប្រតិបត្តិការរក្សាសន្តិភាព ព្រមទាំងបានបោសសម្អាតមីនលើផ្ទៃដីទំហំ៣៦៨គីឡូម៉ែត្រក្រឡា។

ចំពោះវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលបានពង្រឹងនិងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ តាមរយៈការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(អ.ជ.ក.) ការដាក់ចេញយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការនិងយុទ្ធនាការត្រួតពិនិត្យ និងបានចាត់ការសំណុំរឿងសរុបចំនួនជិត១៩ម៉ឺន ដែលស្មើនឹង៨២,៤% នៃសំណុំរឿងទូទាំងប្រទេស។ ក្នុងវិស័យមុខងារសាធារណៈ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់ គុណភាពការងារប្រកបដោយវិន័យ សីលធម៌វិជ្ជាជីវៈ និងសក្តិសិទ្ធិភាព និងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយសង្គតិភាព សមធម៌ និងចីរភាព។

ក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុសាធារណៈ។ ក្នុងនោះ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៤ ត្រូវបានប៉ាន់ស្មានថាបន្តរក្សាបាននូវចលនការនៃកំណើនក្នុងរង្វង់៦% ដែលគាំទ្រដោយវិស័យសំខាន់ ដូចជាកាត់ដេរ កម្មន្តសាលមិនមែនកាត់ដេរ កសិកម្ម ទេសចរណ៍ជាដើម។ ទំហំពាណិជ្ជកម្មអន្តរជាតិបានឡើងដល់ប្រមាណ៥៥ប៊ីលានដុល្លារអាមេរិក កើនឡើងជិត១៦% ធៀបនឹងឆ្នាំ២០២៣ ក្នុងនោះ ការនាំចេញបានកើនឡើងជិត១៤% និងការនាំចូលកើនឡើង១៧,៦%។ ទំនិញនាំចេញសំខាន់ៗរបស់កម្ពុជា រួមមានផលិតផលកាត់ដេរ គ្រឿងអេឡិចត្រូនិកនិងភាគបង្គុំ សំបកកង់រថយន្ត ទោចក្រយាននិងផលិតផលកសិកម្មសំខាន់មួយចំនួន។ ទន្ទឹមនេះ អត្រាអតិផរណា(មធ្យមប្រចាំឆ្នាំ) មានកំណើនថមថយមកត្រឹម០,៨% តែប៉ុណ្ណោះក្នុងឆ្នាំ២០២៤ ខណៈអត្រាប្ដូរប្រាក់ផ្លូវការស្ថិតក្នុងរង្វង់៤ ០៧០រៀលក្នុងមួយដុល្លារអាមេរិក ហើយទុនបម្រុងអន្តរជាតិបន្តស្ថិតក្នុងកម្រិតខ្ពស់ ប្រមាណជាង២២ប៊ីលានដុល្លារអាមេរិក ឬ៧,៩ខែ នៃការនាំចូលទំនិញ និងសេវា។ ស្របនឹងកំណើនសេដ្ឋកិច្ច និងការគ្រប់គ្រងស្ថានភាពថ្លៃនេះ អត្រាភាពក្រីក្រក៏បានធ្លាក់ចុះពី ២០,៦៨% ក្នុងឆ្នាំ ២០២៣ មកក្នុងរង្វង់ ១៧,៩៨% ក្នុងឆ្នាំ ២០២៤។ ចំពោះផ្នែកហិរញ្ញវត្ថុសាធារណៈវិញ ការប្រមូលចំណូលថវិកាជាតិក្នុងឆ្នាំ២០២៤ សម្រេចបានកំណើន២,៤% ធៀបនឹងការអនុវត្តឆ្នាំ២០២៣។ បន្ទាប់ពីវិធានការធ្វើវិចារណកម្មចំណាយ ការអនុវត្តចំណាយសរុបថវិកាជាតិបានថយចុះប្រមាណ -៧,៦% ធៀបនឹងឆ្នាំ២០២៣ ដោយអាចទ្រទ្រង់ប្រតិបត្តិការចាំបាច់គ្រប់ផ្នែករបស់រាជរដ្ឋាភិបាល។ បំណុលសាធារណៈរបស់កម្ពុជាត្រូវបានគ្រប់គ្រង យ៉ាងម៉ត់ចត់ស្របតាម «**យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨**» របស់រាជរដ្ឋាភិបាល ហើយពុំមានការកើនឡើងគួរឱ្យកត់សម្គាល់នោះទេ ពោលគឺសន្និធិបំណុលសាធារណៈជាតម្លៃបច្ចុប្បន្នធៀបនឹងផ.ស.ស. ត្រូវរក្សាបានក្នុងអត្រា១៩,៣% ក្នុងឆ្នាំ២០២៤។

ក្នុងវិស័យសង្គមកិច្ច រាជរដ្ឋាភិបាលបានបន្តកែលម្អកម្មវិធីសិក្សា អភិវឌ្ឍសៀវភៅសិក្សា ពង្រឹងសមត្ថភាពនិងឥរិយាបថរបស់គ្រូបង្រៀន លើកកម្ពស់ការគ្រប់គ្រងសាលារៀន ជំរុញការចូលរួមពីសហគមន៍ ការលើកកម្ពស់ការអប់រំឌីជីថល ជំរុញការចាប់យកមុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (STEAM) និងជំរុញចលនាយុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត ដែលការណ៍នេះបានរួមចំណែកដល់ការសម្រេចបានអត្រាប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យកើន ពី៧២,៩% ក្នុងឆ្នាំ ២០២២-២០២៣ ដល់៧៩% ក្នុងឆ្នាំ២០២៣-២០២៤។ ពាក់ព័ន្ធវិស័យដីធ្លី និងសំណង់ នៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានចេញបណ្ណកម្មសិទ្ធិដីធ្លីសរុបចំនួនជាង៨លាន២សែនបណ្ណ បានបញ្ចប់ការបោះបង្គោលព្រំបែងចែកតំបន់ក្នុងតំបន់បឹងទន្លេសាប បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន៦៨ ៣១៧គម្រោង បានខិតខំប្រឹងប្រែងដោះស្រាយបណ្តឹងចំនួនជិត១ម៉ឺន៥ពាន់(១៤ ៩១៩)ករណី និងបានដាក់ចេញវិធានការសំខាន់មួយចំនួន រួមមានការលើកលែងការយកពន្ធលើដីធ្លីមិនប្រើប្រាស់សម្រាប់ដីក្រោម ៥ហិកតា ក្នុងមួយកន្លែង ការពន្យារពេលនៃការអនុវត្តពន្ធលើចំណេញមូលធនចំពោះអចលនទ្រព្យ ការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យសម្រាប់ការទិញលំនៅឋានទី១ ដែលមានតម្លៃក្រោមឬស្មើ២១ម៉ឺនដុល្លារអាម៉េរិក។

ក្នុងវិស័យអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលបានស្ថាបនាលើកកម្រិតវិសាលភាពផ្លូវជនបទបានចំនួន២២៩ខ្សែ ប្រវែងសរុប១ ៣៦៧,៨៣គ.ម. ផ្លូវកៅស៊ូ២ជាន់ ចំនួន១១២ខ្សែ ប្រវែង៩៨៣,៤១គ.ម. ផ្លូវល្បាយក្រួសចំនួន៨៩ខ្សែ ប្រវែង២៧៧,៩៤គ.ម. ស្ពានចំនួន២១កន្លែង និងកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ និងជំរុញការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ។

ក្នុងវិស័យសុខាភិបាល សន្ទស្សន៍នៃការគ្របដណ្តប់សេវាសុខាភិបាលជាសារវន្តបានកើនឡើងដល់៦០,១% នៅឆ្នាំ២០២៤។ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវវិធានការលើកកម្ពស់គុណភាពសេវាសុខាភិបាល ដោយបានបង្កើនបរិមាណ គុណភាពថ្នាំនិងបរិក្ខារពេទ្យ ជំរុញការផ្តល់សេវា២៤ម៉ោង ពង្រឹងក្រមសីលធម៌ និងការទទួលខុសត្រូវវិជ្ជាជីវៈនិងពង្រីកសមត្ថភាពក្នុងការផ្តល់សេវានៅតាមមូលដ្ឋាន។ ទន្ទឹមនេះ ក្នុងឆ្នាំ២០២៤ បន្ថែមលើកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនិងបានធ្វើសមាហរណកម្ម និងបង្កើតថ្មីនូវកម្មវិធីជាតិជំនួយសង្គមមួយចំនួន ដោយបានចំណាយថវិការដ្ឋសរុបក្នុងឆ្នាំ២០២៤ ចំនួនប្រមាណ១ ១៤០ប៊ីលានរៀល(សមមូលប្រមាណ២៨៥លានដុល្លារអាម៉េរិក)។ កម្មវិធីជាតិជំនួយសង្គមដែលត្រូវបានធ្វើសមាហរណកម្មនិងបង្កើតថ្មី រួមមាន ១) កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្តចាប់ពីខែមេសា ឆ្នាំ២០២៤ ដែលក្រសោបកម្មវិធីចំនួន៤ គឺកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា រួមទាំងការឧបត្ថម្ភគោលសម្រាប់គ្រួសារក្រីក្រទាំងអស់និង ការឧបត្ថម្ភសមាជិកដែលរស់នៅជាមួយមេរោគ/ជំងឺអេដស៍ ២) កម្មវិធីជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈជូនយុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ ៣) ពង្រីកវិសាលភាពគ្រប់ដណ្តប់មូលនិធិសមធម៌

សុខាភិបាលដល់គ្រួសារងាយរងហានិភ័យ និង៤) កម្មវិធីស្តារជីវភាពឡើងវិញសម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែននិងឃុំពាក់ស្នែង នៃស្រុកអង្គរធំ ខេត្តសៀមរាប។ បន្ថែមលើនេះ ការពង្រីករបបថែទាំសុខភាពបានកើនឡើងសមាជិកថ្មីចំនួនប្រមាណជាង៨៨ម៉ឺននាក់ក្នុងឆ្នាំ២០២៤ ដែលធ្វើឱ្យចំនួនសមាជិកសរុបផ្នែកថែទាំសុខភាពគិតត្រឹមឆ្នាំ២០២៤ បានកើនឡើងដល់ប្រមាណជាង២,៧លាននាក់ ក្នុងនោះ សមាជិកតាមរបបភាគទានជាកាតព្វកិច្ចមានចំនួនជាង២លាន ៧ម៉ឺននាក់ និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួនប្រមាណជាង៦៣ម៉ឺននាក់។

ចំពោះការបណ្តុះបណ្តាលជំនាញ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាពទី២ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេសចំនួន១លាន៥សែននាក់។ បើគិតត្រឹមខែធ្នូ ឆ្នាំ២០២៤ យុវជនចំនួនជិត៨ម៉ឺន៦ពាន់នាក់ បានចុះឈ្មោះចូលរៀន(មកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យចំនួនជាង៣ម៉ឺន១ពាន់នាក់) នៅក្នុងកម្មវិធីសិក្សាចំនួន៨៦៦ថ្នាក់ លើមុខជំនាញចំនួន៣២។ ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជរដ្ឋាភិបាលបានប្រែក្លាយមន្ទីរពិសោធន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យដំណើរការជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ជំរុញការផ្តល់វិញ្ញាបនបត្រផ្សេងៗពាក់ព័ន្ធគុណភាព សុវត្ថិភាព និងអនាម័យ ជំរុញការអភិវឌ្ឍស្តង់ដាក្នុងស្រុកសម្រាប់ផលិតផលអាទិភាព ទទួលយកស្តង់ដាអន្តរជាតិ ឬអាស៊ាន មកធ្វើជាស្តង់ដាជាតិ ដើម្បីលើកកម្ពស់ផលិតផលក្នុងស្រុកឆ្ពោះទៅការនាំចេញនិងសុវត្ថិភាពប្រើប្រាស់សម្រាប់ផលិតផលនាំចូល ដាក់ចេញយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ក្នុងគោលដៅលើកទឹកចិត្តអ្នកប្រកបមុខរបរនិងធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ «**ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ**» ដើម្បីជាមធ្យោបាយសម្រាប់កំណត់អត្តសញ្ញាណ ប្រភេទមុខរបរ និងការងាររបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប្រជាជនប្រមាណ ៨០,៤% នៃគ្រួសារសរុបទូទាំងប្រទេសបានទទួលសេវាទឹកស្អាត។

ក្នុងវិស័យរ៉ែនិងថាមពល ក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែចំនួន៣៥៩,២ប៊ីលានរៀល(ប្រមាណ៨៩,៨លានដុល្លារអាម៉េរិក) ស្មើនឹង១៦៦% ធៀបនឹងឆ្នាំ២០២៣ វិភាគទានចូលថវិកាជាតិពីវិស័យថាមពលក្នុងចំណូលសារពើពន្ធគ្រប់ប្រភេទចំនួន ៣២០,៤ប៊ីលានរៀល(៨០,១លានដុល្លារអាម៉េរិក) ក្នុងរយៈពេល៧ខែ នៃឆ្នាំ២០២៤ ចំណូលពីវិស័យប្រេងកាតចំនួន១០,២លានដុល្លារអាម៉េរិក និងចំណូលពីកាតព្វកិច្ចនៃកិច្ចព្រមព្រៀងផ្សេងៗចំនួន២,២លានដុល្លារអាម៉េរិក។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានលុបបំបាត់ស្ទើរតែទាំងស្រុងនូវសកម្មភាពរ៉ែអណាធិបតេយ្យ បានអនុវត្តគម្រោងមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋានចំនួន៤២គម្រោង ជំរុញការអភិវឌ្ឍប្រភពអគ្គិសនីថ្មីចំនួន៣៦គម្រោង បានពង្រីកការផ្គត់ផ្គង់អគ្គិសនីចេញពីបណ្តាញជាតិបានដល់៩៩,១៥% នៃចំនួនភូមិទូទាំងប្រទេសនិងបានភ្ជាប់ចរន្តឱ្យលំនៅឋានប្រជាពលរដ្ឋរហូតដល់ ៩៥,២៤% នៃលំនៅឋានទូទាំងប្រទេស។

ក្នុងវិស័យសាធារណៈការនិងដឹកជញ្ជូន នៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានធ្វើការគ្រប់គ្រងស្ថាបនា ថែទាំផ្លូវជាតិនិងផ្លូវខេត្តប្រវែងសរុប២០ ៣០៧គ.ម.ដោយបានក្រាលកៅស៊ូនិងបេតុងសរុបប្រវែង ១១ ៦៤៩គ.ម. សាងសង់ផ្លូវល្បឿនចំនួន២ខ្សែ បានប្រវែងសរុប៣២២,១៥គ.ម. ស្ពានតូចធំគ្រប់ប្រភេទ ចំនួន២ ៥៤១ស្ពាន ប្រវែងសរុប៨៦,៤៥គ.ម. បណ្តាញលូគ្រប់ប្រភេទប្រវែងសរុប៩៧៣គ.ម. សាងសង់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន១២កន្លែង និងទីលានទុកដាក់សំរាមចំនួន១៤កន្លែងនិងកំពុងដំណើរការ អនុវត្តគម្រោងសាងសង់ព្រែកជីកហ្វូណនតេជោ។

ចំពោះវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផល សំខាន់ៗ ដូចជាពង្រីកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់បណ្តាញខ្សែកាបអុបទិកឆ្អឹងខ្នងប្រវែង៣៩ ៣០៩ គ.ម. បណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រកំពុងដំណើរការមានចំនួន២ខ្សែ និងកំពុងសាងសង់ ១ខ្សែ ការអភិវឌ្ឍនិងការដាក់ឱ្យប្រើប្រាស់ថ្នាល និងកម្មវិធីរដ្ឋាភិបាលឌីជីថលនិង/ឬប្រព័ន្ធបច្ចេកវិទ្យា ឌីជីថល ការបង្កើនធនធានមនុស្សជំនាញឌីជីថលនៅគ្រប់កម្រិត ព្រមទាំងការចូលរួមគាំទ្រដល់ការធ្វើ បរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័ននិងគ្រឹះស្ថានអប់រំ។

ក្នុងវិស័យកសិកម្ម រាជរដ្ឋាភិបាលបានលើកស្ទួយផលិតកម្ម រកទីផ្សារនិងរក្សាលំនឹងថ្លៃកសិផល ជារួមនៅក្នុងឆ្នាំ២០២៤ មានភាពល្អប្រសើរ ដាក់ចេញយន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារនិងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ដាក់ពង្រាយមន្ត្រីបច្ចេកទេស កសិកម្មឃុំចំនួន២៥០នាក់ នៅតាមគោលដៅចំនួន២៥០ឃុំ(ក្នុង៨៩ស្រុកនិង១៧ខេត្ត) រៀបចំនិង ដាក់ឱ្យដំណើរការនូវសហគមន៍កសិកម្មទំនើបចំនួន៩ និងបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការជំរុញកសាង ប្រព័ន្ធធារាសាស្ត្រនិងធនធានទឹក នៅទូទាំងប្រទេស ដែលមកដល់ពេលនេះ អាចស្រោចស្រពសរុបដល់ ជាង៦០ម៉ឺនហិកតា។ ពាក់ព័ន្ធនឹងការងារបរិស្ថាន គិតត្រឹមឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានបង្កើតសហគមន៍ តំបន់ការពារធម្មជាតិចំនួន១៩៣សហគមន៍ គ្របដណ្តប់លើផ្ទៃដីជាង៣៣ម៉ឺនហិកតា បានបង្កើតតំបន់ បេតិកភណ្ឌធម្មជាតិ ចំនួន១៤ ចុះបញ្ជីដីរដ្ឋតំបន់បេតិកភណ្ឌធម្មជាតិចំនួន៤ រៀបចំកំណត់ការគ្រប់គ្រង តំបន់ការពារធម្មជាតិ ចំនួន៤ និងគាំទ្រការអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិចំនួន៥៣សហគមន៍។

ក្នុងវិស័យវប្បធម៌ រាជរដ្ឋាភិបាលសម្រេចសមិទ្ធផលជាច្រើនលើវិស័យនេះ ដូចជាកិច្ចការថែរក្សា ជួសជុលប្រាង្គប្រាសាទនិងបុរាណដ្ឋាន ការចុះបញ្ជីជាបេតិកភណ្ឌពិភពលោក ទាំងរូបីនិងអរូបី ជាពិសេស ការចុះបញ្ជីក្រមាទៅក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃមនុស្សជាតិនិងកិច្ចការពារ និងស្តារឡើងវិញនូវប្រពៃណី ទំនៀមទម្លាប់ ទម្រង់សិល្បៈនានាដែលប្រឈមហានិភ័យបាត់បង់និងការពង្រឹងធនធានយុវជនបន្តវេន។ ចំពោះវិស័យធម្មការនិងសាសនា សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២៤ រួមមានការលើកកម្ពស់ សាសនារបស់រដ្ឋ ការលើកកម្ពស់សីលធម៌សង្គមនិងការរក្សាសុខដុមនីយកម្មសាសនា តាមរយៈការ បណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ចនិងក្រមសីលធម៌អាចារ្យខ្មែរ ការរៀបចំធ្វើកម្មវិធីទស្សនាទានព្រះពុទ្ធ សាសនា និងការរៀបចំកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គមរចនាប័ទ្មសំណង់សាសនានិងព្រះពុទ្ធ បដិមា។ ក្នុងវិស័យទេសចរណ៍ ក្នុងឆ្នាំ២០២៤ កម្ពុជាទទួលបានទេសចរអន្តរជាតិចំនួនប្រមាណ៦,៧

លាននាក់ ដែលមានកំណើនប្រមាណ២៣% ធៀបនឹងឆ្នាំ២០២៣ និងទេសចរជាតិមានចំនួន២២លាន ៥សែននាក់ ដែលមានកំណើនប្រមាណ២០% ធៀបនឹងឆ្នាំ២០២៣។

កម្ពុជាមានការទទួលស្គាល់កម្រិតអន្តរជាតិលើការងារយេនឌ័រ ដោយទទួលបានពានរង្វាន់ជាច្រើន រួមមាន ពានរង្វាន់លើគោលនយោបាយសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព(Care Policy Ecosystem) និងពានរង្វាន់សកលថ្នាក់ក្រសួង ក្នុងកិច្ចប្រជុំកំពូលស្ត្រីពិភពលោកឆ្នាំ២០២៤ នៅទីក្រុងម៉ាទ្រីដ។ រាជរដ្ឋាភិបាលបានផ្តល់សេវាផ្លូវច្បាប់ជួយស្ត្រីរងគ្រោះដោយអំពើហិង្សា បន្តអន្តរាគមន៍ទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងជំរុញបញ្ជ្រាបការងារយេនឌ័រនៅតាមក្រសួង ស្ថាប័ន។ ចំពោះការងារព័ត៌មាននិងការផ្សព្វផ្សាយ រាជរដ្ឋាភិបាលបានពង្រឹងការចុះបញ្ជីនិងការអនុលោមច្បាប់របស់អង្គភាព ទាំងក្នុងស្រុកនិងបរទេស ក៏ដូចជាលើកកម្ពស់គុណភាពព័ត៌មាន តាមរយៈការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងការកាត់បន្ថយនិងបង្ក្រាបនូវដំណឹងក្លែងក្លាយ ព័ត៌មានបំភ្លៃនិងបំពុល។

## ១.៣- បញ្ហាប្រឈមក្នុងការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣

ក្នុងកំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ រចនាសម្ព័ន្ធ និងនិម្មាបនកម្មសេដ្ឋកិច្ច សង្គម និងនយោបាយ បានប្រែប្រួលយ៉ាងខ្លាំង និងបង្កផលវិបាកលើសកលលោកទាំងមូល ដោយបង្កើតនូវបញ្ហាប្រឈមជាច្រើន ដូចជាការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ សង្គ្រាមរុស្ស៊ី អ៊ុយក្រែន សង្គ្រាមនៅមជ្ឈិមបូព៌ា សង្គ្រាមពាណិជ្ជកម្ម ការគាំពារនិងជាតិនិយម ការប្រែប្រួលអាកាសធាតុនិងការប្រែប្រួលប្រជាសាស្ត្រ ដែលធ្វើឱ្យមានការកើនឡើងនៃប្រជាជនវ័យចំណាស់។ ការណ៍នេះមានកម្មវិបាកមកលើកម្ពុជា ជាពិសេសការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ កន្លងទៅ។ ជាមួយនឹងជោគជ័យនៃការអនុវត្តផ.យ.អ.ជ. ក្នុងនីតិកាលទី៦ នៃរដ្ឋសភា កម្ពុជាបានជួបនូវបញ្ហាប្រឈមធំៗមួយចំនួន និងកិច្ចការខ្លះនៅសល់មិនទាន់អនុវត្តបានចប់ជាស្ថាពរ ដែលចាំបាច់ត្រូវបន្តដោះស្រាយក្នុងនីតិកាលទី៧ នេះ។ បញ្ហាប្រឈមចម្បងៗទាំងនោះ មានដូចខាងក្រោម៖

**ទី១-** កំណើនសេដ្ឋកិច្ចបច្ចុប្បន្ននៅពឹងផ្អែកយ៉ាងខ្លាំងលើឧស្សាហកម្មអតិពលកម្ម ដែលអាចធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាជាប់ក្នុងអន្ទាក់ជាប្រទេសចំណូលមធ្យម។ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលបាននិងកំពុងបន្តកើតឡើង ដោយសារមានការប្រែប្រួលនៃនិម្មាបនកម្មសង្គមសេដ្ឋកិច្ច ការកើនឡើងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ច សង្គ្រាមពាណិជ្ជកម្ម សង្គ្រាមរុស្ស៊ី អ៊ុយក្រែន ការរីកចម្រើនយ៉ាងរហ័សនៃបច្ចេកវិទ្យាថ្មីៗ និងបញ្ហាសង្គមសេដ្ឋកិច្ចនិងនយោបាយមួយចំនួនទៀត។ កត្តាទាំងនេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ដែលជាប្រទេសតូច បើកចំហនិងពឹងអាស្រ័យយ៉ាងខ្លាំង ទៅលើសុខភាពល្អនៃសេដ្ឋកិច្ចសកលនិងពាណិជ្ជកម្មអន្តរជាតិ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

**ទី២-** មូលធនមនុស្សនិងគុណភាពធនធានមនុស្សតាមវិស័យជាច្រើននៅមានកម្រិតនៅឡើយ ក្នុងការអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាការកសាងកំណើនសេដ្ឋកិច្ចផ្អែកលើជំនាញ បច្ចេកវិទ្យា និងនវានុវត្តន៍។ ធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញបច្ចេកទេសវិជ្ជាជីវៈនិងមូលធនមនុស្ស

ខ្ពស់ គឺជាកត្តាគន្លឹះសម្រាប់ភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ ចីរភាពនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ភាពប្រកួតប្រជែងនិងការអភិវឌ្ឍជាតិទាំងមូល ជាពិសេសនៅក្នុងបរិការណ៍នៃការកើនឡើងនៃការប្រកួតប្រជែងជាសកល ឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាឌីជីថល ដែលជំរុញដោយបដិវត្តន៍ឧស្សាហកម្មទី៤ ដែលក្នុងនោះ ការចាប់យកបច្ចេកវិទ្យា ការបន្សាំបច្ចេកវិទ្យា និងការធ្វើនវានុវត្តន៍ គឺមានសារៈសំខាន់មិនអាចខ្វះបានក្នុងការជំរុញល្បឿននៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ សំដៅបង្កើនផលិតភាព តម្លៃបន្ថែម និងឧត្តមភាព ប្រកួតប្រជែងខ្ពស់។ ជាមួយនឹងបរិមាណនៃការអភិវឌ្ឍធនធានមនុស្សក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅ កម្ពុជានៅមានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងជំនាញ សមត្ថភាព គុណភាពនៃការសិក្សា និងការសិក្សាស្រាវជ្រាវ ក្នុងវិស័យអាទិភាព ដែលចាំបាច់ត្រូវបន្តពង្រឹងបន្ថែម ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមា ពីការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗនិងនវានុវត្តន៍ ព្រមទាំងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលឱ្យបានពេញលេញ។

**ទី៣**- ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ គុណភាពធនធានមនុស្សនិងគុណភាពនៃការបណ្តុះបណ្តាលតាមវិស័យមួយចំនួនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួង ស្ថាប័ន ដែលធ្វើឱ្យការប្រើធនធានមនុស្សនិងការអនុវត្តក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ កម្មវិធីនិងលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តការងារជាក់ស្តែងដោយក្រសួង ស្ថាប័នអង្គភាពសាធារណៈ និងវិស័យឯកជន ជួបនូវបញ្ហាប្រឈមជាបន្តបន្ទាប់ និងបង្កើតឱ្យមានបញ្ហា «**លើសតែខ្វះ**» ដែលការណ៍នេះមានកម្មវិបាកជាអវិជ្ជមានលើគ្រប់វិស័យនិងធ្វើឱ្យការសម្រេចបានសមិទ្ធផលស្ថិតក្នុងកម្រិតខុសៗគ្នា និងមិនទាន់ឈានដល់សក្តានុពលខ្ពស់។

**ទី៤**- ស្ថាប័នសាធារណៈនិងអភិបាលកិច្ច ដែលជាហេដ្ឋារចនាសម្ព័ន្ធទន់ មានការកែលម្អ ប៉ុន្តែនៅមិនទាន់មានប្រសិទ្ធផលខ្ពស់នៅឡើយ ក្នុងការសម្របសម្រួលនិងការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពជាអតិបរមា ស្របតាមអភិក្រម «**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**» ដោយត្រូវបំពេញមុខងារនិងភារកិច្ច នៅក្នុងកិច្ចសហការនិងការសម្របសម្រួលល្អ ប្រកបដោយភាពរស់រវើក សហថាមពលនិងបំពេញឱ្យគ្នាទៅវិញទៅមក។ គុណភាពស្ថាប័នរឹងមាំបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធាននៃច្បាប់ការគោរពច្បាប់ ប្រព័ន្ធយុត្តិធម៌ ភាពស្អាតស្អំ ការអនុវត្តការងារដោយស្មារតីសហការ និងតម្កល់ផលប្រយោជន៍ជាតិជាធំ និងការផ្តល់សេវាសាធារណៈមានគុណភាពខ្ពស់ ឆាប់រហ័ស និងឆ្លើយតបទាន់ពេលសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយជោគជ័យ បរិយាបន្ន ភាពធន់ និងចីរភាព។ ជាក់ស្តែង ការលើកកម្ពស់អភិបាលកិច្ចល្អនិងគុណភាពស្ថាប័នសាធារណៈខ្ពស់ ការកែលម្អបរិយាកាសវិនិយោគ និងការលើកកម្ពស់គុណភាព ស្ថាប័នទីផ្សារការងារ ជាដើម រួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយថ្លៃដើមនិងពេល ព្រមទាំងបង្កើនផលិតភាពនិងប្រសិទ្ធផលសេដ្ឋកិច្ច។ ទោះបីគុណភាពស្ថាប័ននិងអភិបាលកិច្ចត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ ការអនុវត្តជាក់ស្តែងនៅមានបញ្ហាប្រឈម ដែលចាំបាច់ត្រូវបន្តពង្រឹងបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនិងភាពស្អាតស្អំ ពង្រឹងយុត្តិធម៌សេដ្ឋកិច្ចសង្គម និងលើកកម្ពស់ការអភិវឌ្ឍជាតិជារួម។

**ទី៥-** ផ្អែកលើកបទពិសោធនៃការអនុវត្តផ.យ.អ.ជ. កន្លងទៅ ភាពមានកម្រិតបានលេចឡើងជាច្រើនលើការងារកែទម្រង់មួយចំនួន ដូចជាការកែទម្រង់ច្បាប់នៅកម្ពុជា ចាប់ពីដំណាក់កាលរៀបចំសេចក្តីព្រាងការអនុម័ត ការអនុវត្ត និងការតាមដាននិងត្រួតពិនិត្យការអនុវត្ត ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការនៅមានកម្រិត ដែលធ្វើឱ្យមជ្ឈការបន្តស្ថិតនៅកម្រិតខ្ពស់ រដ្ឋបាលសាធារណៈ ជាពិសេសការផ្សារភ្ជាប់គ្នាបានល្អពីស្ថាប័នមួយទៅស្ថាប័នមួយ និងរបៀបរបបបំពេញការងារដោយផ្តោតជាសំខាន់លើសមិទ្ធកម្ម ការបែងចែកមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវ ការយល់ច្បាស់ពីទស្សនៈនៃការកែទម្រង់ដោយសារការបារម្ភធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នានា ការរៀបចំផែនការឱ្យបានច្បាស់លាស់ និងយន្តការនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្ស សមត្ថភាពធនធានមនុស្សនិងថវិកាគាំទ្រសម្រាប់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ដោយសារភាពស្រកស្រុតនៃលម្ហថវិកា ការថមថយនៃទំហំហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ កំណត់វិស័យអាទិភាពសម្រាប់គម្រោងPPP ព្រមទាំងពិនិត្យនិងវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនចាស់ៗមួយចំនួន សមត្ថភាពក្នុងការទាញយកផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០ ដើម្បីលើកកម្ពស់គុណភាពនៃប្រតិបត្តិការសេវាសាធារណៈ និងសេដ្ឋកិច្ចឌីជីថល ការយល់ដឹងអំពីការចុះបញ្ជីតាមប្រព័ន្ធអនឡាញ CamDX និងថ្នាលបច្ចេកវិទ្យា របស់មន្ត្រីជំនាញទទួលបន្ទុកនិងម្ចាស់រោងចក្រសហគ្រាសនិងសិប្បកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងបច្ចេកវិទ្យាសម្រាប់គាំទ្រដល់ការបង្កើតផលិតផលនិងសេវាវប្បធម៌ថ្មីៗដែលមានលក្ខណៈច្នៃប្រឌិត ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការអភិវឌ្ឍវិស័យប្រៃសណីយ៍ ប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលក្នុងការឆ្លើយតបទៅនឹងប្រព័ន្ធបច្ចេកវិទ្យានិងឌីជីថលដែលធ្វើឱ្យការលួចចម្លងស្នាដៃរបស់អ្នកដទៃកាន់តែមានភាពងាយស្រួលនិងពិបាកទប់ស្កាត់ឱ្យបានទាន់ពេល រចនាសម្ព័ន្ធគ្រប់គ្រង សមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រសិទ្ធភាពគ្រប់គ្រងសកម្មភាពផលិត ការធ្វើចរាចរ ការជួញដូរគ្រឿងញៀនខុសច្បាប់ក្នុងតំបន់និងពិភពលោក ការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀននិងការគ្រប់គ្រងក្នុងវិស័យសាសនា ជាដើម។

**ទី៦-** ហេដ្ឋារចនាសម្ព័ន្ធរឹងនៅមិនទាន់គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការនៃការអភិវឌ្ឍជាក់ស្តែង។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដូចជាហេដ្ឋារចនាសម្ព័ន្ធទីក្រុង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រព័ន្ធឡូជីស្ទីក ប្រព័ន្ធថាមពល ប្រព័ន្ធធារាសាស្ត្រ ជាដើម នៅបន្តជួបបញ្ហាប្រឈម ដែលត្រូវដោះស្រាយក្នុងល្បឿនលឿននិងទំហំថ្មីមួយ ដើម្បីទ្រទ្រង់ដល់នគរូបនីយកម្ម ដំណើរការផលិតកម្ម និងខ្សែច្រវាក់តម្លៃនៃវិស័យឧស្សាហកម្ម កសិឧស្សាហកម្ម និងឧស្សាហកម្មគាំទ្រ សំដៅជំរុញពិពិធកម្ម និងបង្កើនប្រសិទ្ធផលប្រសិទ្ធភាព ផលិតភាព និងឧត្តមភាពប្រកួតប្រជែងខ្ពស់ ព្រមទាំងទាក់ទាញវិនិយោគ និងពង្រីកការតភ្ជាប់នៃហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីសម្រួលពាណិជ្ជកម្មផ្ទៃក្នុង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

**ទី៧-** ថ្លៃដើមផលិតកម្មខ្ពស់ក្នុងវិស័យកសិកម្មនិងថ្លៃដើមនៃការធ្វើធុរកិច្ចនៅកម្ពុជា រាប់បញ្ចូលទាំងថ្លៃដឹកជញ្ជូននិងឡូជីស្ទិក នៅមានកម្រិតខ្ពស់ជាងបណ្តាប្រទេសជិតខាង ខណៈដែលផលិតភាព

ការងារនៅមានកំណើនទាប កម្លាំងពលកម្មជំនាញនៅខ្វះខាត ការផ្គត់ផ្គង់ធាតុចូលផលិតកម្មពីសហគ្រាសក្នុងស្រុកនៅមានកម្រិតតិចតួចនៅឡើយ ដែលការណ៍នេះបន្តជាឧបសគ្គ និងមានកម្មវិបាកអវិជ្ជមានដល់សមត្ថភាពរបស់កម្ពុជាក្នុងការទាក់ទាញការវិនិយោគ នីតិវិធីនៃការផ្តល់ការសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគ នៅពុំទាន់បានធ្វើស្វ័យប្រវត្តិកម្ម និងសាមញ្ញកម្មបានពេញលេញនៅឡើយ។

**ទី៨**- ការចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាពនៅមានកម្រិតខ្ពស់និងគុណភាពសេវាសុខាភិបាលនៅមានកម្រិត ទោះបីត្រូវបានកែលម្អមួយកម្រិតធំ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងប្រសិទ្ធភាពនៃការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ប្រព័ន្ធសុខាភិបាលដែលជាវិស័យអាទិភាពខ្ពស់នៅមានបញ្ហាប្រឈម ដែលចាំបាច់ត្រូវបន្តដោះស្រាយក្នុងស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម ដើម្បីបង្កើនគុណភាពនៃសេវាសុខាភិបាលឱ្យកាន់តែខ្ពស់ សំដៅលើកកម្ពស់ សុខភាពប្រជាពលរដ្ឋនិងបង្កើនផលិតភាពការងារផង។ ជាមួយគ្នានេះ នៅថ្ងៃអនាគត ដូចបានរំលេចនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ កម្ពុជានឹងប្រឈមនឹងការកើនឡើងនៃតម្រូវការសេវាសុខាភិបាល ដោយសារការកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់ តាមរយៈការប្រែប្រួលនៃប្រជាសាស្ត្រ និងការផ្លាស់ប្តូរបន្ទុកជំងឺ ដូចជាជំងឺមិនឆ្លងនិងការលេចឡើងសាជាថ្មីនៃជំងឺឆ្លងនានានិងគ្រោះអាសន្នសុខភាពសាធារណៈដទៃទៀត។ ការណ៍នេះទាមទារឱ្យគោលនយោបាយសុខាភិបាលកម្ពុជា គិតគូរលើគ្រប់ទិដ្ឋភាព រួមមានរចនាសម្ព័ន្ធស្ថាប័ននិងអភិបាលកិច្ចរឹងមាំ ធនធានមនុស្ស ដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ ប្រកបដោយក្រមសីលធម៌ខ្ពស់ ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលសម្រាប់ការពង្រឹងគុណភាព និងការលើកកម្ពស់ការផ្តល់សេវាសុខាភិបាល ដូចជាការបង្កើតមន្ទីរពេទ្យជាតិថ្នាក់តំបន់ ការបង្កើនការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គមជាដើម។

**ទី៩**- ការសន្សំនៅក្នុងស្រុកនៅមានកម្រិតទាប សម្រាប់គាំទ្រដល់ការវិនិយោគក្នុងស្រុកសម្រាប់រយៈពេលវែង និងពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលវិស័យនេះដើរតួនាទីសំខាន់ក្នុងវិស័យពិតនៃសេដ្ឋកិច្ចនិងជាប្រភពហិរញ្ញវត្ថុសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ទោះបីវិស័យនេះមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក៏ដោយ វិស័យហិរញ្ញវត្ថុកម្ពុជានៅបន្តមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អវិស័យនេះឱ្យកាន់តែមានការអភិវឌ្ឍមួយកម្រិតថ្មីថែមទៀត។ បញ្ហាប្រឈមក្នុងវិស័យនេះ មានដូចជាការផ្គត់ផ្គង់និងតម្រូវការហិរញ្ញប្បទាននៅមានកម្រិតទាប ដុល្លារូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ ដែលធ្វើកម្ពុជាបាត់បង់នូវប្រសិទ្ធភាពនៃការប្រើប្រាស់គោលនយោបាយរូបិយវត្ថុសម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច និងការនាំចេញរបស់កម្ពុជា អត្រាការប្រាក់មានកម្រិតខ្ពស់ ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថលនៅមានកម្រិតទាប ផលិតផលហិរញ្ញវត្ថុមានលក្ខណៈប្រមូលផ្តុំ ការជឿទុកចិត្តរបស់ប្រជាជនលើវិស័យធនាគារនៅមានកម្រិត ដែលធ្វើឱ្យការសន្សំក្នុងស្រុកបន្តមានកម្រិតទាប បំណុលគេហជននៅមានកម្រិតខ្ពស់ជាដើម។

**ទី១០**- ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញគោលនយោបាយជាតិ ដែលចង្អុលបង្ហាញដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ

២០១៩-២០២៣ សម្រាប់គ្រប់គ្រងនិងធ្វើការកែទម្រង់ក្នុងវិស័យនេះ។ យ៉ាងណាក៏ដោយ បញ្ហាប្រឈមក្នុងវិស័យនេះមានច្រើន និងបន្តកើតមានជាបន្តបន្ទាប់ ដោយសារតម្រូវការនៃការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបង្កើតនូវលក្ខខណ្ឌតម្រូវថ្មីៗលើផលិតផលកម្ពុជា ដែលទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមនិងគំនិតផ្តួចផ្តើមប្រកបដោយបរិវត្តកម្មនិងនវានុវត្តន៍ ដើម្បីធានាតុល្យភាពនៃការអភិវឌ្ឍ និងចីរភាពនៃធនធានធម្មជាតិនិងបរិស្ថាន ព្រមទាំងរក្សាបាននូវទីផ្សារសម្រាប់ទំនិញនាំចេញរបស់កម្ពុជាតាមរយៈការបំពេញលក្ខខណ្ឌពាក់ព័ន្ធនានាដោយប្រទេសនាំចូល ជាពិសេសសហគមន៍អឺរ៉ុប។ ក្នុងន័យនេះ គ្រប់គោលនយោបាយអភិវឌ្ឍន៍ជាតិតម្រូវឱ្យមានការគិតគូរអំពីចីរភាព ហើយការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាបៃតង មានសក្តានុពលខ្ពស់ ក្នុងការបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ធនធានធម្មជាតិ ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់ដល់បរិស្ថាន ក៏ដូចជាបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា។

**ទី១១-** តួនាទីស្ត្រីនិងចំនួនស្ត្រីជាថ្នាក់ដឹកនាំនៅមានកម្រិតនៅឡើយ ជាពិសេសនៅតាមវិស័យជាក់លាក់ ដូចជាការគ្រប់គ្រងគ្រោះមហន្តរាយ វិស័យបរិស្ថាន ការប្រែប្រួលអាកាសធាតុ ដែលមិនទាន់ឆ្លើយតបនឹងការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ស្ត្រីនៅតាមមូលដ្ឋានត្រូវទទួលបន្ទុកការងារផ្ទះ ការងារកសិកម្ម និងពឹងផ្អែកខ្លាំងលើធនធានធម្មជាតិសម្រាប់ទ្រទ្រង់គ្រួសារ ប៉ុន្តែស្ត្រីជាច្រើនពុំទាន់ទទួលបានឱកាសក្នុងការធ្វើសេចក្តីសម្រេចនិងទទួលបានព័ត៌មានមិនពេញលេញក្នុងការថែទាំបរិស្ថាន ការជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង។

# ជំពូកទី២
# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ប្រកបដោយប្រសិទ្ធភាពនិងភាពជោគជ័យ ទាមទារឱ្យមានការវិភាគពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងការកំណត់នូវគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និងហិរញ្ញវត្ថុ ដោយចាប់ផ្តើមពីការវិភាគនិងការពិនិត្យឡើងវិញនូវការអនុវត្តផែនការដែលបានដាក់ចេញកាលពី៥ឆ្នាំកន្លងទៅ ជាពិសេសការសម្រេចបាននូវសមិទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមនានាដែលបានជួបប្រទះនៅក្នុងកំឡុងពេលនៃការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក៏ដូចជាកាលានុវត្តភាពដែលលេចឡើងថ្មី។ ជាមួយគ្នានេះ ការរៀបចំក៏ត្រូវមានការគិតគូរពីទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនាអនាគត គោលដៅកំណើន និងការប៉ាន់ស្មានតម្រូវការវិនិយោគ ព្រមទាំងការកំណត់ទិសដៅ ដូចបានចង្អុលបង្ហាញដោយ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានាពាក់ព័ន្ធនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច រួមទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។

## ២.១- សមិទ្ធផលឆ្នាំ២០១៩-២០២៣

### ២.១.១- ស្ថានភាពនៃកំណើនសេដ្ឋកិច្ច

ក្នុងឆ្នាំ២០១៩(មុនវិបត្តិនៃជំងឺកូវីដ-១៩) សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ ក្នុងអត្រា ៧,៩% ដែលគាំទ្រដោយការរីកធំធាត់នៃវិស័យឧស្សាហកម្ម ជាពិសេស វិស័យបម្រើការនាំចេញ តួយ៉ាងដូចជាវិស័យកាត់ដេរនិងកម្មន្តសាលមិនមែនកាត់ដេរ គួបផ្សំនឹងការបន្តកើនឡើងនៃវិស័យសេវាកម្ម ដែលជំរុញដោយវិស័យទេសចរណ៍ សេវាកម្មគាំទ្រ និងវិស័យអចលនទ្រព្យ។ ការណ៍នេះ បានធ្វើឱ្យសូចនាករសង្គម សេដ្ឋកិច្ចមានការវិវត្តក្នុងនិន្នាការវិជ្ជមានគួរឱ្យកត់សម្គាល់។

មកដល់ក្នុងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចកម្ពុជាបានទទួលរងនូវកម្មវិបាកពេញទំហឹង ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះ ជាលើកដំបូង ក្នុងរយៈពេលជាង២ទសវត្សចុងក្រោយ ក្នុងអត្រា-៣,៦% ដោយសារការធ្លាក់ចុះនៃការធ្វើដំណើរនិងលំហូរវិនិយោគសកល គួបផ្សំនឹងវិធានការគោលនយោបាយទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ (ដូចជាការបិទខ្ទប់ប្រទេស ជាដើម) មកលើវិស័យចន្ទល់កំណើន ដូចជាវិស័យកាត់ដេរ សំណង់អចលនទ្រព្យ ទេសចរណ៍ និងសេវាកម្មគាំទ្រផ្សេងទៀត។

យ៉ាងណាមិញ ការសម្រេចបាននូវភាពស៊ាំសហគមន៍ក្នុងក្របខ័ណ្ឌទូទាំងប្រទេស គួបផ្សំនឹងការខិតខំប្រឹងប្រែងអនុវត្តវិធានការអន្តរាគមន៍ផ្នែកសង្គម សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យកម្ពុជាបើកប្រទេសឡើងវិញលើគ្រប់វិស័យនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ប្រកបដោយសុវត្ថិភាពនិងភាពរឹងមាំ។

ជាលទ្ធផល ក្នុងឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញក្នុងអត្រាប្រមាណ៣,១% ដោយសារការងើបឡើងវិញនៃវិស័យបម្រើការនាំចេញ ជាពិសេស វិស័យកាត់ដេរនិងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។

**រូបភាពទី២.១ : កំណើន ផ.ស.ស. ថ្លៃថេរ ឆ្នាំ២០១៩-២០២៣**




*ប្រភព : ក្រសួងផែនការ (ស៊េរីទិន្នន័យគណនេយ្យជាតិឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

ក្នុងកំឡុងឆ្នាំ២០២២-២០២៣ ក្រោយការចាកចេញពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ កម្ពុជា ក៏ដូចជាបណ្ដាប្រទេសនានាក្នុងសកលលោក បានប្រឈមនឹងវិបត្តិផ្ទួនៗ ដែលកើតឡើងជាបន្តបន្ទាប់ ដូចជាសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន និងចរន្តគាំពារនិយម ដែលបានបន្ទចបង្អាក់ខ្សែច្រវាក់ផ្គត់ផ្គង់សកល។ ទោះជាយ៉ាងនេះក្ដី ជាមួយនឹងស្មារតីបុរេសកម្មនិងចក្ខុវិស័យវែងឆ្ងាយ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍ទាន់ពេលនិងចំទិសដៅជាពិសេស «**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ២០២១-២០២៣**» ដែលបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា បន្តរក្សាបាននូវនិន្នាការល្អប្រសើរ ជាមួយនឹងអត្រាកំណើនប្រមាណ៥,១% ក្នុងឆ្នាំ២០២២។ កំណើននេះគាំទ្រដោយការបន្តងើបឡើងនៃវិស័យបម្រើការនាំចេញ ជាពិសេស វិស័យកាត់ដេរ ស្របពេលដែលវិស័យកម្មន្តសាលមិនមែនកាត់ដេរក៏ចាប់ផ្ដើមមានសន្ទុះកំណើនខ្ពស់ ដែលជាលទ្ធផលនៃការបង្វែរច្រវាក់ផលិតកម្ម (Production Relocation) គួបផ្សំនឹងការត្រឡប់ទៅរកប្រក្រតីភាពវិញនៃវិស័យទេសចរណ៍និងសេវាកម្មគាំទ្រ ដូចជាវិស័យលក់ដុំ រាយ និងដឹកជញ្ជូន ជាដើម ដែលជាលទ្ធផលនៃការងើបឡើងវិញនៃទំនុកចិត្តធ្វើដំណើរសកល។

សម្រាប់ឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជាក៏នៅបន្តរក្សាបានស្ថិរភាពនៃកំណើនក្នុងរង្វង់៥,០% ថមថយបន្តិចបើធៀបនឹងឆ្នាំ២០២២ ដោយសារផលជះជាអវិជ្ជមាននៃការអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុសកល ឆ្លើយតបទៅនឹងការកើនឡើងនៃសម្ពាធអតិផរណាសកល ដែលបង្កឡើងដោយសង្គ្រាម និងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ។ ការណ៍នេះ បានធ្វើឱ្យវិស័យកាត់ដេរធ្លាក់ចុះដោយសារការថមថយនៃតម្រូវការសេកល ស្របពេលដែលវិស័យហិរញ្ញវត្ថុ ក៏ទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ។ យ៉ាងណាមិញ កំណើនក្នុងឆ្នាំ២០២៣ ជារួមនៅបន្តទ្រទ្រង់ដោយកំណើនរឹងមាំនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលជាផ្លែផ្កានៃការផ្លាស់ប្ដូរខ្សែច្រវាក់ផលិតកម្ម ស្របពេលដែលឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក ក៏ចាប់ផ្ដើមមានសក្ដានុពល តួយ៉ាងដូចជា

ឧស្សាហកម្មដំឡើងរថយន្ត ជាដើម។ ជាមួយគ្នានេះ វិស័យទេសចរណ៍និងសេវាកម្មគាំទ្រផ្សេងទៀត ក៏នៅបន្តនិន្នាការកើនឡើង ស្របពេលដែលការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល នៅតែចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាលំនឹងជីវភាពប្រជាជន និងបន្តគាំពារ និងជំរុញវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩ ឱ្យត្រឡប់ទៅរកមាគ៌ានៃកំណើនសក្តានុពលវិញបន្តិចម្តងៗ។

**តារាងទី២.១ : សូចនាករម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣[1]**

| សូចនាករម៉ាក្រូសេដ្ឋកិច្ច | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន(ប៊ីលានរៀល) | ១៤៨ ៩៨៥ | ១៤២ ៥០៣ | ១៥០ ៧៩៣ | ១៦៤ ០៥៩ | ១៧៧ ៣៥១ |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់(ដុល្លារអាម៉េរិក) | ២ ២៨៦ | ២ ១៣៩ | ២ ២៣៤ | ២ ៣៨៣ | ២ ៥២៥ |
| កំណើន ផ.ស.ស. ពិត(ជា %) | ៧,៩% | -៣,៦% | ៣,១% | ៥,១% | ៥,០% |
| អត្រាបរិត្តិផរណា ផ.ស.ស.(កំណើនប្រចាំឆ្នាំ) | ២,៨% | -០,៨% | ២,៦% | ៣,៥% | ៣,០% |
| អត្រាអតិផរណា(កំណើនជាមធ្យមប្រចាំឆ្នាំ) | ១,៩% | ២,៩% | ២,៩% | ៥,៤% | ២,១% |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាម៉េរិក) | ៤ ០៥២ | ៤ ០៧៧ | ៤ ០៦៨ | ៤ ០៨៧ | ៤ ១១០ |
| ការនាំចេញ(% នៃ ផ.ស.ស.) | ៤០,៩% | ៥៤,៥% | ៥៣% | ៥៨,១% | ៥៥,២% |
| ការនាំចូល(% នៃ ផ.ស.ស.) | -៦០,៨% | -៦០,៣% | -៨៣,៤% | -៨០,៣% | -៦២,២% |
| សមតុល្យពាណិជ្ជកម្ម(% នៃ ផ.ស.ស.) | -១៩,៨% | -៥,៨% | -៣០,៤% | -២២,១% | -៧% |
| សមតុល្យគណនីចរន្ត(%នៃ ផ.ស.ស.រួមបញ្ចូលបង្វែរ) | -៨% | -១% | -២៩,៦% | -១៩% | ១,៣% |
| ទុនបម្រុងអន្តរជាតិ(លានដុល្លារអាម៉េរិក) | ១៨ ៧៦៣ | ២១ ៣៣៤ | ២០ ២៦៥ | ១៧ ៨០៥ | ១៩ ៩៩៨ |
| ចំនួនខែនៃការនាំចូល | ៨,៨ | ១១,១ | ៧,៤ | ៦,១ | ៨,២ |

*ប្រភព : ក្រសួងផែនការនិងធនាគារជាតិនៃកម្ពុជា(ស៊េរីទិន្នន័យគណនេយ្យជាតិឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

## ២.១.២- ស្ថានភាពនៃការវិនិយោគ

ការវិនិយោគសរុបនៅកម្ពុជា មានការកើនឡើងពីអត្រា៣០,១%នៃផ.ស.ស.ក្នុងឆ្នាំ២០១៩ ទៅ៣២,១%ក្នុងឆ្នាំ២០២០ និងបន្តកើនឡើងទៅដល់៣៧,៧%ក្នុងឆ្នាំ២០២១ និង៣៨,៤%ក្នុងឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះមកអត្រា២៧,៥%វិញក្នុងឆ្នាំ២០២៣ ដោយសារការលេចចេញឡើងជាបន្តបន្ទាប់នូវបញ្ហាប្រឈមជាសកល។

ដូចមានបង្ហាញក្នុងរូបភាពទី២.២ ខាងក្រោម ទាំងការវិនិយោគសាធារណៈ ទាំងការវិនិយោគឯកជន បានដើរតួនាទីយ៉ាងសំខាន់ដល់ដំណើរការអភិវឌ្ឍនៅកម្ពុជា។ ជាក់ស្តែង ការវិនិយោគសាធារណៈសរុប មានការកើនឡើងពីអត្រា៥,៨%នៃផ.ស.ស.ក្នុងឆ្នាំ២០១៩ ទៅដល់៨,៩%ក្នុងឆ្នាំ២០២៣ ដោយផ្តោតជាចម្បងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ វិស័យសុខាភិបាល និងវិស័យអប់រំ។

ដោយឡែក ការវិនិយោគឯកជន ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេស ដោយសារការកើនឡើងខ្ពស់នៃការវិនិយោគឯកជនដោយការផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក ខណៈការវិនិយោគឯកជនដោយការផ្តល់ហិរញ្ញប្បទានពីបរទេស បន្តរក្សាទំហំសមល្មមមួយក្នុងរង្វង់១០%នៃផ.ស.ស.។

[1] រាជរដ្ឋាភិបាលផ្លាស់ប្តូរឆ្នាំគោលនៃស៊េរីទិន្នន័យគណនេយ្យជាតិ ពីឆ្នាំ២០០០ មកឆ្នាំ២០១៤ ដែលជាលទ្ធផល ទំហំសេដ្ឋកិច្ច(ផ.ស.ស. ថ្លៃបច្ចុប្បន្ន) ក្នុងឆ្នាំ២០១៤ បានកើនឡើងប្រមាណ៣២% ធៀបនឹងឆ្នាំគោលចាស់។

ជាការកត់សម្គាល់ ការវិនិយោគឯកជនសរុប ប្រមូលផ្តុំនៅក្នុងវិស័យកម្មន្តសាល សំណង់ អចលនទ្រព្យ និងការកម្សាន្ត ហើយការវិនិយោគផ្ទាល់ពីបរទេសភាគច្រើន គឺមកពីប្រទេសចិន កូរ៉េខាងត្បូង និងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ាន និងមានសកម្មភាពមមាញឹក ក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើឱ្យការនាំចេញទៅកាន់ដៃគូពាណិជ្ជកម្មចម្បងៗរបស់កម្ពុជា ដូចជាអាស៊ាន ចិន សហរដ្ឋអាម៉េរិក សហភាពអឺរ៉ុបជាដើម។

**រូបភាពទី២.២ : ការវិនិយោគធៀបនឹង ផ.ស.ស. តាមប្រភេទនៃការវិនិយោគ**




*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

## ២.១.៣- ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលប្រមាណ២០ឆ្នាំកន្លងទៅនេះ បានបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើននៅកម្ពុជា ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម សេដ្ឋកិច្ចរបស់កម្ពុជា ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងខ្លាំង ក្នុងការពង្រឹងការគ្រប់គ្រងរដ្ឋបាលនិងគោលនយោបាយចំណូល រួមមាន ១) ទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ២) ការធ្វើឱ្យប្រសើរឡើងនូវសេវាបង់ពន្ធ ៣) ការបង្កើនការយល់ដឹងអំពីវប្បធម៌បង់ពន្ធនិង អនុលោមភាព ៤) កិច្ចខិតខំប្រឹងប្រែងធ្វើសវនកម្ម ៥) ការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធនិងការគេចវេះពន្ធ ៦) ការកែសម្រួលតម្លៃគិតពន្ធគយនិងអត្រាអាករពិសេសនៃទំនិញមួយចំនួន និង ៧) ការពង្រឹងរដ្ឋបាលនិងគោលនយោបាយចំណូលមិនមែនសារពើពន្ធ។ ជាលទ្ធផលជាក់ស្តែង ក្នុងឆ្នាំ២០១៩ ចំណូលក្នុងស្រុកសម្រេចបាន ១៨,៦៥% នៃ ផ.ស.ស. ដែលជាកម្រិតមួយខ្ពស់គួរឱ្យកត់សម្គាល់។

មិនខុសពីបណ្តាប្រទេសនានាក្នុងសកលលោក ការប្រមូលចំណូលក្នុងស្រុក ធ្លាក់ចុះមកត្រឹម ១៦,៦៩%នៃផ.ស.ស.ក្នុងឆ្នាំ២០២០ និងបន្តធ្លាក់ចុះទៅ១៥,១៤%នៃផ.ស.ស.ក្នុងឆ្នាំ២០២១ ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ បូករួមទាំងការដាក់ចេញនូវវិធានការលើកទឹកចិត្ត និងការអនុគ្រោះនានា

ដើម្បីសម្រាលបន្ទុក និងរក្សាលំនឹងសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យសំខាន់ៗ។ ការប្រមូលចំណូលក្នុងស្រុកបានងើបវិញ ក្នុងអត្រា១៦,៨%នៃផ.ស.ស.ក្នុងឆ្នាំ២០២២ បន្ទាប់ពីការចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ គួបផ្សំនឹងការបន្តអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៣** ប្រកបដោយភាពប្រុងប្រយ័ត្ន ប៉ុន្តែបានធ្លាក់ទៅអត្រា១៥,៥%នៃផ.ស.ស.វិញក្នុងឆ្នាំ២០២៣ ដោយសារការបន្តដាក់ចេញនូវវិធានការលើកទឹកចិត្តនិងការអនុគ្រោះនានា ដើម្បីបន្តស្តារនិងជំរុញកំណើនសេដ្ឋកិច្ច ស្របពេលដែលមានការលេចឡើងនូវបញ្ហាប្រឈមជាសកល ជាពិសេស ចរន្តគាំពារនិយម ដែលបានធ្វើឱ្យពាណិជ្ជកម្មក្នុងប្រទេស ក៏ដូចជាក្នុងតំបន់និងលើសកលលោកទាំងមូល មានការថមថយ។

ក្នុងទិដ្ឋភាពចំណាយ ចំណាយសាធារណៈបានកើនឡើងពី១៩,២%នៃផ.ស.ស.ក្នុងឆ្នាំ២០១៩ ទៅដល់២២%នៃផ.ស.ស.ក្នុងឆ្នាំ២០២០ និង២២,៧%នៃផ.ស.ស.ក្នុងឆ្នាំ២០២១ ដោយសារការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ជាពិសេស ការបើកយុទ្ធនាការចាក់វ៉ាក់សាំង ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងការដាក់ចេញនូវវិធានការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច សង្គម ដើម្បីជួយរក្សាលំនឹងធុរកិច្ចនិង ជីវភាពរស់នៅរបស់ប្រជាជន។ ក្នុងកំឡុងឆ្នាំ២០២២-២០២៣ ចំណាយសាធារណៈមានការថមថយបន្តិច ប៉ុន្តែនៅបន្តខ្ពស់ជាងអត្រាមុនវិបត្តិនៃជំងឺកូវីដ-១៩ ដោយសារការបន្តវិធានការរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេស កម្មករនិយោជិត និងគ្រួសារក្រីក្រនិងជនងាយរងគ្រោះ។

**រូបភាពទី២.៣ : តុល្យភាពថវិកាឆ្នាំ២០១៩-២០២៣ ធៀបនឹងផ.ស.ស.**




*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

ការថមថយនៃចំណូលនិងការកើនឡើងនៃចំណាយសាធារណៈ បានធ្វើឱ្យឱនភាពថវិកាសរុបកើនឡើងពីអត្រា-០,៦%នៃផ.ស.ស. មុនវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០១៩ ទៅក្នុងអត្រាប្រចាំឆ្នាំជាមធ្យម-៥,៣៥%នៃផ.ស.ស.ក្នុងអំឡុងឆ្នាំ២០២០-២០២៣។ ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំរបស់រាជរដ្ឋាភិបាល ក្នុងការព្យាយាមកៀរគរធនធានឱ្យអស់សក្តានុពល ទាំងចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ ព្រមទាំងការពង្រឹងប្រសិទ្ធភាពចំណាយ បានជួយបន្ធូរនូវសម្ពាធ និងរក្សាស្ថានភាពហិរញ្ញវត្ថុសាធារណៈឱ្យបន្តមានចីរភាព និង អាចឆ្លើយតបបានទៅនឹងតម្រូវការអភិវឌ្ឍប្រទេស ដើម្បីគាំទ្រដល់ការងើបវិញនៃសេដ្ឋកិច្ច និងជំរុញកំណើនឱ្យដល់សក្តានុពល ព្រមទាំងធានាបាននូវប្រក្រតីភាពនៃកិច្ចដំណើរការរបស់ក្រសួង ស្ថាប័ន និងបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់បានយ៉ាងទៀងទាត់និងទាន់ពេល។

## ២.១.៤- ស្ថានភាពបំណុលសាធារណៈ

ដូចបានគូសបញ្ជាក់ខាងលើ បើទោះបីជាត្រូវប្រឈមនឹងវិបត្តិនៃជំងឺកូវីដ-១៩ និង ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលក៏ដោយ ក៏កម្ពុជានៅតែអាចគ្រប់គ្រងស្ថានការណ៍បានដោយជោគជ័យ និងអាចរក្សាអត្រាកំណើនសេដ្ឋកិច្ចនិងវិនិយោគ ក្នុងកម្រិតខ្ពស់ ដោយមិនប៉ះពាល់ដល់ចីរភាពនៃហិរញ្ញវត្ថុសាធារណៈ។ ជាលទ្ធផល ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា បន្តមាន«ចីរភាព» និង «ហានិភ័យកម្រិតទាប» ដោយរាល់សូចនាករបំណុលគន្លឹះៗទាំងអស់សុទ្ធតែស្ថិតក្រោមពិតានកំណត់។ ជាក់ស្តែង សូចនាករតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុបធៀបនឹងផ.ស.ស. ស្ថិតក្នុងរង្វង់១៨% ក្នុងកំឡុងឆ្នាំ២០២០-២០២៣ ប៉ុណ្ណោះ បើធៀបនឹងអនុបាតគោលក្នុងអត្រា៥៥%។

លទ្ធផលនេះ ឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងបំណុលសាធារណៈយ៉ាងប្រុងប្រយ័ត្ននិងត្រឹមត្រូវតាមរយៈការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះចំនួន៥ ក្នុងការគ្រប់គ្រងបំណុលសាធារណៈរួមមាន ១) ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកានិងសេដ្ឋកិច្ច អាចទ្រាំទ្របាន ២) ខ្ចីតែឥណទាន ដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣) ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម ៤) ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពខ្ពស់បំផុត និង ៥) ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដានិងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ជាពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ចសង្គម បរិស្ថាន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះ រាជរដ្ឋាភិបាល ក៏បានខិតខំធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន ឱ្យបានទូលំទូលាយជាងមុន តាមរយៈការបោះផ្សាយមូលបត្ររដ្ឋក្នុងទីផ្សារសំដៅចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសបង្កើននូវទ្រនាប់ថវិកាស្របតាមរបត់ថ្មីនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ក្នុងការត្រៀមខ្លួនចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច ដែលអាចជាក់កំហិតដល់លទ្ធភាពក្នុងការទទួលបានឥណទានកម្រិតសម្បទានខ្ពស់។

**តារាងទី២.២ : អនុបាតកម្រិតស្ថិរភាពបំណុល**

| សូចនាករ | ពិតាន | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| **តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប** | | | | | | |
| ធៀបនឹងផ.ស.ស. | ៥៥% | ១៥,០% | ១៨,២% | ១៨,៦% | ១៨,១% | ១៨,៨% |
| **តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស** | | | | | | |
| ធៀបនឹងផ.ស.ស. | ៤០% | ១៥,០% | ១៨,២% | ១៨,៦% | ១៨,០% | ១៨,៧% |
| ធៀបនឹងការនាំចេញ | ១៨០% | ២៦,៧% | ៣២,៨% | ៣៤,២% | ២៨,៤% | ២៩,០% |
| **សេវាបំណុលសាធារណៈក្រៅប្រទេស** | | | | | | |
| ធៀបនឹងការនាំចេញ | ១៥% | ១,៥% | ១,៨% | ១,៩% | ១,៨% | ១,៨% |
| ធៀបនឹងចំណូលថវិកាជាតិ | ១៨% | ៤,៥% | ៦,២% | ៦,៩% | ៦,៩% | ៧,៥% |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

### ២.១.៥- អតិផរណានិងអត្រាប្តូរប្រាក់

ក្នុងកំឡុងឆ្នាំ២០១៩-២០២១ ទោះបីជាមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ អតិផរណានៅកម្ពុជា បន្តស្ថិតក្នុងអត្រាទាប និងមានស្ថិរភាព ក្នុងរង្វង់ជាមធ្យម២,៥% ដោយសារការបន្តរក្សាបាននូវស្ថិរភាពនៃថ្លៃទំនិញក្នុងស្រុក ជាពិសេសថ្លៃម្ហូបអាហារ ស្របពេលដែលថ្លៃទំនិញអន្តរជាតិ ជាពិសេសថ្លៃប្រេងឥន្ធនៈមានស្ថិរភាព។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់ផ្លូវការ ក៏រក្សាបាននូវស្ថិរភាពផងដែរ ក្នុងរង្វង់ ៤ ០៦៦រៀលក្នុង១ដុល្លារអាមេរិក ដោយសារគោលនយោបាយអន្តរាគមន៍អត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងធានាបាននូវស្ថិរភាពថ្លៃនិងអំណាចទិញរបស់ប្រជាជន។ ក្នុងឆ្នាំ២០២២ អតិផរណា បានកើនឡើងខ្ពស់ទៅដល់អត្រា៥,៣% ដោយសារការកើនឡើងនៃថ្លៃទំនិញអន្តរជាតិ ជាពិសេសថ្លៃប្រេងឥន្ធនៈ និងថ្លៃម្ហូបអាហារ ដែលបង្កឡើងដោយសារសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន ស្របពេលដែលអត្រាប្តូរប្រាក់ផ្លូវការបានកើនឡើងទៅប្រមាណ៤ ០៨៧រៀលក្នុង១ដុល្លារអាមេរិក ដោយសារការចាប់ផ្តើមអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ សម្រាប់ឆ្នាំ២០២៣ អតិផរណាចាប់ផ្តើមថមថយមកវិញ ក្នុងរង្វង់២,១% ដោយសារការត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេងឥន្ធនៈ ប៉ុន្តែអត្រាប្តូរប្រាក់នៅបន្តកើនឡើងដល់ប្រមាណ៤ ១១០រៀលក្នុង១ដុល្លារអាមេរិក ដោយសារការបន្តអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ។ យ៉ាងណាមិញ ធនាគារជាតិនៃកម្ពុជា ក៏បានខិតខំធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ដើម្បីធានាស្ថិរភាពថ្លៃនិងបង្ការការបន្តកើនឡើងថ្លៃនៃរូបិយបណ្ណដុល្លារធៀបនឹងប្រាក់រៀល។

### ២.១.៦- ស្ថានភាពរូបិយវត្ថុ

កំណើនរូបិយវត្ថុទូទៅបានថមថយល្បឿនពី១៨,២% ក្នុងឆ្នាំ២០១៩ មកត្រឹម៨,២% ក្នុងឆ្នាំ២០២២ មុននឹងកើនឡើងវិញដល់១២,៥% ក្នុងឆ្នាំ២០២៣ ដោយមានកម្រិតជាមធ្យម១៤,១% ក្នុងកំឡុងឆ្នាំ២០១៩-២០២៣។ ក្នុងនោះ កំណើនM2 ត្រូវបានគាំទ្រដោយកំណើនប្រាក់បញ្ញើជារូបិយបណ្ណ និងប្រាក់បញ្ញើជារៀល។ ក្នុងកំឡុងឆ្នាំ២០១៩-២០២៣ ប្រាក់បញ្ញើជារូបិយបណ្ណមានកំណើនជាមធ្យម១៣,៥% ហើយប្រាក់បញ្ញើជារៀលមានកំណើនជាមធ្យម២៦,៨%។ រូបិយវត្ថុក្នុងចរាចរណ៍ កើនជាមធ្យម១២,២% ពី១៣ទ្រីលានរៀល ក្នុងឆ្នាំ២០១៩ ដល់១៧,៣ទ្រីលានរៀល ក្នុងឆ្នាំ២០២៣។ រូបិយវត្ថុទូទៅធៀបនឹងផ.ស.ស. បានកើនឡើងពី៧៩%នៃផ.ស.ស. ឬ១១៨,៤ទ្រីលានរៀល ក្នុងឆ្នាំ២០១៩ ដល់ ១១១%នៃផ.ស.ស. ឬ១៩៣,៥ទ្រីលានរៀល ក្នុងឆ្នាំ២០២៣។ ការប្រើប្រាស់ប្រាក់រៀល បន្តកើនឡើងជាលំដាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ការទូទាត់តាមរយៈប្រព័ន្ធអេឡិចត្រូនិកដែលត្រូវបានអភិវឌ្ឍ និងជំរុញដោយធនាគារជាតិនៃកម្ពុជា ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក។

ជារួម ការអនុវត្តនយោបាយរូបិយវត្ថុនៅមានបញ្ហាប្រឈម ដោយសារកម្រិតខ្ពស់នៃដុល្លាររូបនីយកម្ម។ ជាក់ស្តែង អនុបាតប្រាក់បញ្ញើជារូបិយបណ្ណធៀបនឹងរូបិយវត្ថុទូទៅ និងប្រាក់បញ្ញើជារូបិយបណ្ណ ធៀបនឹងប្រាក់បញ្ញើសរុបមានកម្រិតជាមធ្យម៨៣,៧% និង៩២,៣% រៀងគ្នា ក្នុងកំឡុងឆ្នាំ២០១៩-២០២៣។ ក្នុងស្ថានភាពនេះ ឧបករណ៍នយោបាយរូបិយវត្ថុ ត្រូវបានអភិវឌ្ឍដើម្បីរួមចំណែកបង្កើនប្រសិទ្ធភាពនៃនយោបាយរូបិយវត្ថុ។

### រូបភាពទី២.៤ : សមាសធាតុនៃរូបិយវត្ថុទូទៅនិងកំណើន ឆ្នាំ២០១៩-២០២៣




*ប្រភព : ធនាគារជាតិនៃកម្ពុជា(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

## ២.១.៧- ស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ដោយសង្កេតឃើញពីការវិវត្តយ៉ាងឆាប់និងការបន្តរីកធំធាត់នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារទាំង៦(វិស័យធានារ៉ាប់រងនិងសោធននិវត្តន៍ឯកជន មូលបត្រ សន្តិសុខសង្គម បរធនបាលកិច្ច គណនេយ្យ និងសវនកម្ម និងអចលនវត្ថុ បញ្ចាំនិងប្រាតិភោគដោយអនុប្បទាន) ជាមួយនឹងគោលដៅធានាបាននូវការគ្រប់គ្រងការអភិវឌ្ឍប្រកបដោយសុខុមាលភាព និងចីរភាព រាជរដ្ឋាភិបាលបានបង្កើត **«អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)»** ក្នុងឆ្នាំ២០២១ ដែលមាននិយ័តករទាំង៦ ស្ថិតក្រោមឱវាទ ហើយអ.ស.ហ. គឺជាយន្តការស្ថាប័ន ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងតាមដានការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ជារួម។

សមិទ្ធផលគន្លឹះៗក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ អាចត្រូវបានឆ្លុះបញ្ចាំង តាមរយៈការបន្តរីកធំធាត់នៃវិស័យនីមួយៗ ដូចខាងក្រោម៖

- **វិស័យធានារ៉ាប់រង:** ចំនួនក្រុមហ៊ុនធានារ៉ាប់រង(ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច) មានចំនួនប្រមាណ៤០ក្រុមហ៊ុន ស្របពេលដែលទំហំបុព្វលាភធានារ៉ាប់រងដុល ក៏បានបន្តកើនឡើងជាលំដាប់ប្រមាណ៣៨៤លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៣ ពីប្រមាណ២៥៣លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩។ ជាមួយគ្នានេះ អត្រាភាគទានធានារ៉ាប់រង ក៏បានបន្តកើនឡើងជាលំដាប់មកដល់ប្រមាណ១,១៦% ក្នុងឆ្នាំ២០២៣ ពីប្រមាណ០,៩៣% ក្នុងឆ្នាំ២០១៩
- **វិស័យមូលបត្រ:** ចំពោះការចុះបញ្ជីមូលបត្រកម្មសិទ្ធិ គិតត្រឹមឆ្នាំ២០២៣ មានក្រុមហ៊ុនសរុបចំនួន១១ បានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) ដែល

ក្នុងនោះក្រុមហ៊ុនចំនួន៩ បានចុះបញ្ជីនៅទីផ្សារគោល និងក្រុមហ៊ុនចំនួន២ បានចុះបញ្ជីនៅទីផ្សារកំណើន ដោយបានកៀរគរមូលធនសរុបចំនួន៥១៦,៧ប៊ីលានរៀល(ប្រហែល ១២៩លានដុល្លារអាម៉េរិក)។ ជាមួយគ្នានេះ ចំពោះការបោះផ្សាយលក់មូលបត្រ បំណុលវិញ គិតត្រឹមឆ្នាំ២០២៣ ក្រុមហ៊ុនចំនួន១១ បានចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មនៅផ.ម.ក. ហើយសាច់ប្រាក់ដែលប្រមូលបានតាមរយៈការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មសរុបមានចំនួន១ ០០៣ប៊ីលានរៀល(ប្រមាណ២៤៨,៣លានដុល្លារអាម៉េរិក)

- **វិស័យសោធននៃប្រព័ន្ធសន្តិសុខសង្គម:** របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជនត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០២២ ខណៈដែលភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចត្រូវបានចាប់ផ្តើមប្រមូលចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។ គិតត្រឹមចុងឆ្នាំ២០២៣ របបសន្តិសុខសង្គម(ប.ស.ស.) បានប្រមូលភាគទានពីរបបនេះបានចំនួនសរុបប្រមាណ៣២ ៣៧៨ប៊ីលានរៀល ឬប្រមាណ៨៣ពាន់លានដុល្លារអាម៉េរិក ពីសមាជិកសរុបចំនួនប្រមាណ១,៤លាននាក់
- **វិស័យបរធនបាលកិច្ច:** ក្នុងឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ចបានផ្តល់ការអនុញ្ញាតចុះបញ្ជីបរធនបាលកិច្ចចំនួន៧៨៨ករណី ជាមួយនឹងទំហំបរធនសរុបចំនួន១ ២៧១លានដុល្លារអាម៉េរិក។ ក្នុងនោះ បរធនបាលកិច្ចសាធារណៈមានទំហំប្រមាណ៦៤លានដុល្លារអាម៉េរិក បរធនបាលកិច្ចហិរញ្ញវត្ថុ(៣៦៩លានដុល្លារអាម៉េរិក) បរធនបាលពាណិជ្ជកម្ម(៨៣៤លានដុល្លារអាម៉េរិក) បរធនបាលកិច្ចសង្គម(១លានដុល្លារអាម៉េរិក) និងបរធនបាលបុគ្គល(២លានដុល្លារអាម៉េរិក)
- **វិស័យគណនេយ្យនិងសវនកម្ម:** ក្នុងឆ្នាំ២០២៣ និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.) បានផ្តល់អាជ្ញាបណ្ណផ្តល់សេវាគណនេយ្យនិងសវនកម្មចំនួន៧០ក្រុមហ៊ុន ដែលក្នុងនោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ មាន៨ក្រុមហ៊ុន និងកម្រិត២ មាន៩ក្រុមហ៊ុន និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្មមាន៥៣ក្រុមហ៊ុន។ ជាមួយគ្នានេះ ក្រុមហ៊ុនដែលបានបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រព័ន្ធ(E-filling) ក៏មានការកើនឡើងដល់ប្រមាណ១៥ ៤៤៦ក្រុមហ៊ុន ដែលក្នុងនោះ១៤ ៧៥៦ គឺជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងប្រមាណ៦៩០ គឺជាសហគ្រាស និង
- **វិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន:** ក្នុងកំឡុងឆ្នាំ២០១៩-២០២៣ និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ(ន.អ.ប.) បានផ្តល់អាជ្ញាបណ្ណដល់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ សរុបប្រមាណ២៥២គម្រោង ដែលមានទុនវិនិយោគសរុបប្រមាណ៥,៦ពាន់លានដុល្លារអាម៉េរិក។ ក្នុងនោះទុនវិនិយោគក្នុងស្រុកមានប្រមាណជាង ៨០% ខណៈដែល២០%ផ្សេងទៀត គឺជាទុនវិនិយោគក្រៅស្រុក។ ចំពោះវិស័យបញ្ចាំវិញ ក្នុងឆ្នាំ២០១៩-២០២៣ ន.អ.ប.បានផ្តល់អាជ្ញាបណ្ណថ្មីដល់ក្រុមហ៊ុន/សហគ្រាសអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន សរុបប្រមាណ២៧៨ក្រុមហ៊ុន ដែលស្មើនឹងទឹក

ប្រាក់ប្រមាណ២៤លានដុល្លារអាមេរិក។ ជាមួយគ្នានេះ ទំហំកម្ចីសរុបក្នុងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទានមានទំហំសរុបប្រមាណ៨៤៤លានដុល្លារអាមេរិក ដែលក្នុងនោះ១២៥លានដុល្លារអាមេរិកជាកម្ចីអចលនវត្ថុ និងប្រមាណ៧១៩លានដុល្លារគឺជាកម្ចីចលនវត្ថុ។

### ២.១.៨- ជញ្ជីងទូទាត់កម្ពុជា

ក្នុងកំឡុងឆ្នាំ២០១៩-២០២៣ ស្ថានភាពជញ្ជីងទូទាត់កម្ពុជាមានអតិរេកជាមធ្យមប្រចាំឆ្នាំប្រមាណ ២% នៃផ.ស.ស. ប៉ុន្តែទំហំនៃអតិរេកមានការថមថយពីប្រមាណ២ ៦៦៨លានដុល្លារអាមេរិក(៧,៣%នៃផ.ស.ស.)ក្នុងឆ្នាំ២០១៩ មកត្រឹមប្រមាណ៧៣លានដុល្លារអាមេរិក(០,២%នៃផ.ស.ស.)ក្នុងឆ្នាំ២០២៣។ ការថមថយទំហំនៃអតិរេកជញ្ជីងទូទាត់នេះបណ្តាលមកពីកត្តាចម្បងៗចំនួន២ ដូចខាងក្រោម៖

**១)- ការរីកធំនៃឱនភាពគណនីទំនិញ ដោយសារការថមថយនៃសកម្មភាពនាំចេញ នាំចូល ក្នុងវិបត្តិនៃជំងឺកូវីដ-១៩** : ក្នុងកំឡុងឆ្នាំ២០១៩-២០២៣ សមតុល្យពាណិជ្ជកម្មទំនិញមានឱនភាពជាមធ្យម ៦,៥ប៊ីលានដុល្លារអាមេរិក(១៧%នៃផ.ស.ស.) ដោយបានកើនឡើងពីទំហំ៧,៣ប៊ីលានដុល្លារអាមេរិក (១៩,៨%នៃផ.ស.ស.)ក្នុងឆ្នាំ២០១៩ ទៅក្នុងរង្វង់ជាមធ្យមប្រមាណ១០ប៊ីលានដុល្លារអាមេរិក(២៦%នៃផ.ស.ស.)ក្នុងកំឡុងឆ្នាំ២០២០-២០២១ ដោយសារការថមថយនៃសកម្មភាពនាំចេញ នាំចូល ប៉ុន្តែបានចាប់ផ្តើមរួមតូចមកវិញជាបណ្តើរៗក្នុងកំឡុងឆ្នាំ២០២២-២០២៣។ ជាក់ស្តែង ក្នុងឆ្នាំ២០២៣ ឱនភាពពាណិជ្ជកម្មបានរួមតូចមកត្រឹមប្រមាណ៣ប៊ីលានដុល្លារអាមេរិក(៧%នៃផ.ស.ស.) ដោយសារកំណើននៃការនាំចេញលឿនជាងការនាំចូល។ ក្នុងនោះ បើធៀបនឹងឆ្នាំ២០១៩ ការនាំចេញបានកើនឡើង៥៧,២% (ការនាំចេញគ្រឿងអេឡិចត្រូនិក កើន៧,២ដង កៅស៊ូ១,៤ដង ស្បែកជើង៧,៩% ផលិតផលវាយនភណ្ឌផ្សេងទៀត៥៨,៣% ទោចក្រយាន១៧,៤% និងអង្ករ១១,៥% ខណៈដែលការនាំចេញសម្លៀកបំពាក់ថយចុះ ៤,៤%) ស្របពេលដែលការនាំចូលបានកើនឡើងត្រឹម១៩,៤%(ការនាំចូលប្រេងឥន្ធនៈកើន៧៥,៦% ម្ហូបអាហារនិងភេសជ្ជៈកើន៣០,៥% និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរកើន១០,៦% ខណៈការនាំចូលយានយន្តថយចុះ៤៥% និងសម្ភារៈនិងបរិក្ខារសំណង់១៣,២%)។ ក្នុងឆ្នាំ២០២៣ ក្រៅពីការធ្លាក់ចុះនៃឱនភាពពាណិជ្ជកម្មទំនិញ ឱនភាពគណនីចំណូលបឋមក៏បានថយចុះ៤២% និងអតិរេកចំណូលបន្ទាប់បន្សំបានកើនឡើង០,៦% ខណៈដែលអតិរេកគណនីសេវាបានថយចុះ៥៣,១% បើធៀបនឹងឆ្នាំ២០១៩។

**២)- ការធ្លាក់ចុះនៃគណនីសេវា ដោយសារការធ្លាក់ចុះខ្លាំងនៃចំណូលពីវិស័យទេសចរណ៍** : សមតុល្យគណនីសេវាក្នុងកំឡុងឆ្នាំ២០១៩-២០២៣ មានអតិរេកជាមធ្យមត្រឹម៤០១លានដុល្លារអាមេរិក (១,០% នៃផ.ស.ស.)។ ក្នុងនោះ សមតុល្យគណនីសេវា មានអតិរេកប្រមាណ២ ៨១២លានដុល្លារអាមេរិក (៧,៦%នៃផ.ស.ស.) ក្នុងឆ្នាំ២០១៩ ប៉ុន្តែមានឱនភាពជាលើកដំបូងក្នុងទំហំជាមធ្យមប្រមាណ៧០៨លានដុល្លារអាមេរិក(២%នៃផ.ស.ស.) ក្នុងកំឡុងឆ្នាំ២០២០-២០២២ ដោយសារការធ្លាក់ចុះខ្លាំងនៃចំណូល

ពីវិស័យទេសចរណ៍ ដែលបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩។ ក្នុងឆ្នាំ២០២៣ ដោយសារការងើបឡើងវិញនៃវិស័យទេសចរណ៍ សមតុល្យគណនីសេវា ក៏បានចាប់ផ្តើមមានអតិរេកឡើងវិញ ក្នុងទំហំប្រមាណ ១ ៣១៣លានដុល្លារអាមេរិក(៣,១%នៃផ.ស.ស.) ប៉ុន្តែមិនទាន់ងើបទៅដល់កម្រិតមុនវិបត្តិនៅឡើយ។

**រូបភាពទី២.៥ : គណនីចរន្តនិងដើមទុន(% នៃផ.ស.ស.) ឆ្នាំ២០១៤-២០២៣**




*ប្រភព : ធនាគារជាតិនៃកម្ពុជា(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

ដោយឡែក សមតុល្យគណនីហិរញ្ញវត្ថុបានបង្ហាញពីការធ្លាក់ចុះនៃទ្រព្យអកម្មសុទ្ធពីអត្រាជាមធ្យម ១៩%នៃផ.ស.ស. ក្នុងកំឡុងឆ្នាំ២០១៩-២០២២ មកត្រឹម១,២%នៃផ.ស.ស. ក្នុងឆ្នាំ២០២៣(ដែលបានថយចុះ៩១,៩% បើធៀបនឹងឆ្នាំ២០១៩) ដោយសារការកើនឡើងនៃទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធនៃគណនីវិនិយោគផ្សេងទៀត ខណៈដែលលំហូរវិនិយោគផ្ទាល់បរទេសបានកើនឡើង។

ទុនបម្រុងអន្តរជាតិ[2] បានបន្តពូនគរពីប្រមាណ១៨,៨ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០១៩ ដល់២០ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០២៣។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលស្មើនឹង៧ខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍ(៣ខែ)។

[2] ទុនបម្រុងអន្តរជាតិជាទ្រព្យសកម្មបរទេសដែលគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា រួមមាន មាស SDR និងរូបិយបណ្ណបរទេស(ដែលរក្សាទុកនៅបរទេសនិងនៅធនាគារជាតិនៃកម្ពុជា)។

## រូបភាពទី២.៦ : គណនីហិរញ្ញវត្ថុ(%នៃផ.ស.ស.) ឆ្នាំ២០១៤-២០២៣




*ប្រភព : ធនាគារជាតិនៃកម្ពុជា(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

## រូបភាពទី២.៧ : ទុនបម្រុងអន្តរជាតិឆ្នាំ២០១៩-២០២៣




*ប្រភព : ធនាគារជាតិនៃកម្ពុជា(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

### ២.១.៩- ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងភាពក្រីក្រ

សរុបមក ចលនការនៃកំណើនសេដ្ឋកិច្ច បាននាំឱ្យមានការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ វិស័យកសិកម្មបានចូលរួមចំណែកក្នុងផ.ស.ស ប្រមាណ១៥,៤% វិស័យសេវាកម្ម៣៩,១% និងវិស័យឧស្សាហកម្ម៣៩,០%។ បន្ទាប់ពីឆ្លងកាត់វិបត្តិសកលជាបន្តបន្ទាប់មក ក្នុងឆ្នាំ២០២៣ វិស័យកសិកម្មបានចូលរួមចំណែកក្នុងផ.ស.ស ប្រមាណជាង១៥,៨% វិស័យសេវាកម្ម៣៧,៤% និងវិស័យឧស្សាហកម្ម៤០,៥%។ ការណ៍នេះ បានបង្ហាញពីតួនាទីនៃវិស័យចន្លល់ជាអាទិភាព ក្នុងការរក្សាកំណើនសេដ្ឋកិច្ចជាប្រចាំ តួយ៉ាងវិស័យកសិកម្ម ដែលបាននិងកំពុងទ្រទ្រង់សន្តិសុខស្បៀងយ៉ាងសំខាន់(ដំណាំស្រូវនិងកសិឧស្សាហកម្ម) និងបានចូលរួមជំរុញល្បឿនក្នុង

វិស័យនាំចេញផងដែរ។ វិស័យឧស្សាហកម្ម ទាំងវិស័យកម្មន្តសាលកាត់ដេរនិងកម្មន្តសាលមិនមែនកាត់ដេរ នៅបន្តជាចលករនៃកំណើនសេដ្ឋកិច្ច ស្របពេលដែលវិស័យសេវាកម្ម ជាពិសេសវិស័យទេសចរណ៍ បានទទួលរងផលប៉ះពាល់ខ្លាំងជាងគេ និងបាននិងកំពុងងើបឡើងវិញសន្សឹមៗ ដែលធ្វើឱ្យមានផលជះទៅលើវិស័យសេវាដទៃផ្សេងទៀត។

ជុំវិញអត្រាភាពក្រីក្រនៅកម្ពុជា វិបត្តិនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ដោយប្រជាជនភាគច្រើន បានរឹតត្បិតចំណាយនិងបង្កើនប្រាក់សន្សំរបស់ខ្លួន សម្រាប់ដោះគ្រាអាសន្ន ទន្ទឹមនឹងការកើនឡើងថ្លៃទំនិញជាទូទៅ ជាបន្តបន្ទាប់ ដែលការណ៍នេះ ធ្វើឱ្យអំណាចទិញធ្លាក់ចុះឬបរិមាណនៃការប្រើប្រាស់ធ្លាក់ចុះ។ អត្រាភាពក្រីក្រនៅកម្ពុជា ស្ថិតក្នុងអត្រា១៧,៥% ក្នុងឆ្នាំ២០១៩ ប៉ុន្តែបានឡើងទៅដល់៣២,១% ក្នុងឆ្នាំ២០២១ ដោយសារវិបត្តិនៃជំងឺកូវីដ-១៩។ ទោះជាយ៉ាងនេះក្តី ការដាក់ចេញនិងការអនុវត្តវិធានការអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ទាំងក្នុងការគ្រប់គ្រងវិបត្តិ ទាំងក្នុងការរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន បានជួយបង្កើនអំណាចទិញរបស់ប្រជាជនមកវិញ និងធ្វើឱ្យអត្រាភាពក្រីក្រធ្លាក់ចុះមកក្នុងរង្វង់២០,៦៨% ក្នុងឆ្នាំ២០២៣។

## ២.២- បញ្ហាប្រឈមនិងកាលានុវត្តភាព

### ២.២.១- បញ្ហាប្រឈម

ស្របពេលដែលសេដ្ឋកិច្ច បានងើបឡើងវិញពីវិបត្តិផ្ទួនៗ កម្ពុជានៅបន្តជួបប្រទះនឹងបញ្ហាប្រឈមជារចនាសម្ព័ន្ធចម្បងៗមួយចំនួន ដែលស្តែងឱ្យឃើញកាន់តែច្បាស់ ក្រោយពីមានការប្រែប្រួលរចនាសម្ព័ន្ធនិងនិម្មាបនកម្មសេដ្ឋកិច្ចសកល ជាពិសេសក្រោយវិបត្តិនៃជំងឺកូវីដ-១៩ និងក្នុងបរិការណ៍មិនប្រាកដប្រជាខ្ពស់នៃទស្សនវិស័យសេដ្ឋកិច្ចសកល។ បញ្ហាប្រឈមចម្បងៗទាំងនោះ រួមមាន៖

- ការបន្តពឹងផ្អែកខ្លាំងលើឧស្សាហកម្មអតិពលកម្ម ខណៈដែលល្បឿននៃពិពិធកម្មសេដ្ឋកិច្ចនៅមានកម្រិត ដែលធ្វើឱ្យមូលដ្ឋានកំណើននៅមានភាពតូចចង្អៀត និង ងាយរងផលប៉ះពាល់ពីកត្តាខាងក្រៅ
- ភាពមានកម្រិតនៃធនធានមនុស្ស ទាំងបរិមាណ ទាំងគុណភាព ដែលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ក៏ដូចជាតម្រូវការកសាងសេដ្ឋកិច្ចផ្អែកលើជំនាញ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលការណ៍នេះទាមទារឱ្យមានការបន្តជំរុញសម្ទុះនៃការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់លើការកែទម្រង់វិស័យអប់រំ ការចាប់យកបច្ចេកវិទ្យា ការបន្សាំបច្ចេកវិទ្យា និងការធ្វើនវានុវត្តន៍
- ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល
- ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាលនិងប្រព័ន្ធគាំពារសង្គម
- ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្មនិងបរិយាកាសធុរកិច្ច ដែលធ្វើឱ្យវិនិយោគិនខ្លះនៅតែស្ទាក់ស្ទើរក្នុងការសម្រេចចិត្តវិនិយោគនៅកម្ពុជា
- ភាពមានកម្រិតនៃសមត្ថភាពរបស់ស្ថាប័នសាធារណៈ ក្នុងការបង្កើនប្រសិទ្ធភាពនៃការរៀបចំ

និងការអនុវត្តគោលនយោបាយ ការផ្តល់សេវាសាធារណៈ ការកែលម្អបរិយាកាសធុរកិច្ច និង វិនិយោគ ព្រមទាំងកិច្ចសហការអន្តរស្ថាប័ន

- ភាពមានកម្រិតនៃការសន្សំក្នុងស្រុក សម្រាប់ការវិនិយោគ និងកំណើនសេដ្ឋកិច្ចរយៈពេលវែង ដែលឆ្លុះបញ្ចាំងឱ្យឃើញ តាមរយៈកត្តាមួយចំនួន រួមមានការផ្គត់ផ្គង់និងតម្រូវការហិរញ្ញប្បទាន នៅមានកម្រិតទាប ដុល្លារូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ អត្រាការប្រាក់មានកម្រិតខ្ពស់ ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថលនៅមានកម្រិតទាប ផលិតផលហិរញ្ញវត្ថុមាន លក្ខណៈប្រមូលផ្តុំនិងការជឿទុកចិត្តលើវិស័យធនាគារនៅមានកម្រិត ខណៈដែលការ អភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏ចាំបាច់បន្តពង្រឹងបន្ថែមទៀត ក្នុងទិដ្ឋភាពជាច្រើន
- ភាពមានកម្រិតនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយសារកត្តាចម្បងៗ ដូចជាកង្វះយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង ភាពមិនគ្រប់គ្រាន់នៃឯកសារគតិយុត្ត ភាពមាន កម្រិតនៃសមត្ថភាពរបស់មន្ត្រីបច្ចេកទេស កង្វះក្របខ័ណ្ឌរួមនៃកិច្ចគាំពារអតិថិជន និងភាព មិនទាន់ពេញលេញនិងគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សមិទ្ធកម្ម និង
- ភាពមានកម្រិតនៃការគិតគូរពីការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ដោយគ្រប់គោល នយោបាយអភិវឌ្ឍជាតិ ត្រូវមានការថ្លឹងថ្លែងឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេស អំពីចីរភាព និង ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## ២.២.២- កាលានុវត្តភាព

ស្របពេលដែលកម្ពុជាត្រូវបន្តជួបប្រទះនឹងបញ្ហាប្រឈម ដូចបានរៀបរាប់ខាងលើ បរិការណ៍សកល និងក្នុងប្រទេស នាពេលបច្ចុប្បន្ន ក៏បាននាំមកនូវកាលានុវត្តភាពសំខាន់ៗ សម្រាប់កម្ពុជា ដូចខាងក្រោម៖

- ការបន្តពង្រឹងស្មារតីសន្តិសហវិជ្ជមាន ដោយការកសាងនិងពង្រីកទំនាក់ទំនងល្អ តាមរយៈ នយោបាយការទូត ប្រកបដោយភាពប៉ិនប្រសប់ របស់កម្ពុជាជាមួយបណ្តាដៃគូសំខាន់ៗ សម្រាប់ជាឱកាសបន្ថែម ក្នុងការជំរុញល្បឿនកំណើនពាណិជ្ជកម្ម វិនិយោគ ពិពិធកម្ម សេដ្ឋកិច្ច និងការផ្ទេរបច្ចេកវិទ្យាឱ្យកាន់តែប្រសើរ ក្នុងន័យទាញយកប្រយោជន៍ជាអតិបរមា ពីខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃសកល
- ឧត្តមភាពនៃទីតាំងភូមិសាស្ត្ររបស់កម្ពុជានឹងកាន់តែទាក់ទាញ ព្រោះចរន្តនៃការបន្តផ្លាស់ប្តូរ ទីប្រជុំទម្ងន់នៃកំណើនសេដ្ឋកិច្ចសកលមកទ្វីបអាស៊ី នឹងបង្កើតបានជាឱកាសមាស សម្រាប់ កម្ពុជា ក្នុងការអភិវឌ្ឍនិងការធ្វើឧស្សាហូបនីយកម្ម ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការកើនឡើង នៃផលិតកម្មនិងសេវាកម្ម ការបង្កើនការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងសេដ្ឋកិច្ចតំបន់និង សកល និងការធ្វើសមាហរណកម្មជាមួយនឹងសេដ្ឋកិច្ចនៃប្រទេសក្នុងតំបន់
- ភាគលាភសន្តិភាព នឹងផ្តល់នូវឧត្តមប្រយោជន៍សម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនិងសង្គម ដោយការបង្កើតបរិយាកាសអនុគ្រោះដ៏ប្រសើរ ទន្ទឹមនឹងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការលើកកម្ពស់ការវិនិយោគឯកជននិងធុរកិច្ច ដែលជាចន្ទល់នៃកំណើនសេដ្ឋកិច្ចនិងការ បង្កើតការងារ

- ការអភិវឌ្ឍជាលំដាប់នៃប្រព័ន្ធហិរញ្ញវត្ថុ(ធនាគារនិងមិនមែនធនាគារ) បាននិងកំពុងផ្តល់លទ្ធភាពទូលំទូលាយ ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងសេវាហិរញ្ញវត្ថុ ទាំងក្នុងប្រទេស និងតំបន់ ទន្ទឹមនឹងការធ្វើបរិវត្តកម្មឌីជីថលនៃសេវាហិរញ្ញវត្ថុ ដែលនឹងគាំទ្រដល់ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល ការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនិងបរិយាបន្នហិរញ្ញវត្ថុ
- ការអភិវឌ្ឍសមត្ថភាពឧស្សាហកម្មគាំទ្រក្នុងស្រុក នឹងជួយបង្កើនតម្លៃបន្ថែម និងឱកាសតាមរយៈប្រសិទ្ធភាព ផលិតភាព និងភាពប្រកួតប្រជែង ដែលសបញ្ជាក់ពីការបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់ធាតុចូល ការកាត់បន្ថយថ្លៃដើម ការចែករំលែកបច្ចេកវិទ្យា និងការផ្តល់ព័ត៌មានអំពីកត្តាផលិតកម្ម ជាដើម។ល។
- ការរីកចម្រើនផ្នែកបច្ចេកវិទ្យានិងឌីជីថលភាវូបនីយកម្ម នឹងផ្តល់នូវកាលានុវត្តភាពថ្មី សម្រាប់ជាម៉ូដែលនៃកំណើនថ្មី ដោយផ្អែកលើជំនាញ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការបង្កើតមុខរបរ និងធុរកិច្ចថ្មីៗ ដែលសំដៅជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា និង
- ស្ថានភាពប្រជាសាស្ត្ររបស់កម្ពុជានាបច្ចុប្បន្ន ផ្តល់នូវកាលានុវត្តភាព សម្រាប់ការស្រូបទាញអត្ថប្រយោជន៍ តាមរយៈភាគលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រនិងការលើកកម្ពស់សមភាពយេនឌ័រ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ការផ្ទេរបច្ចេកវិទ្យា ការលើកកម្ពស់ផលិតភាពកម្លាំងពលកម្ម និងការធ្វើឱ្យប្រសើរឡើងនូវឧត្តមភាពប្រកួតប្រជែង ដើម្បីជំរុញការអភិវឌ្ឍជាតិប្រកបដោយបរិយាបន្ន ភាពធន់ និងចីរភាព។

## ២.៣- ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនិងគោលដៅកំណើនសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា

### ២.៣.១- គោលដៅនៃកំណើនសេដ្ឋកិច្ចតាមវិស័យ

ការសម្រេចបាននូវចក្ខុវិស័យរយៈពេលមធ្យមនិងវែង ទាមទារឱ្យមានការវាយតម្លៃល្អិតល្អន់លើទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងការកំណត់គោលដៅកំណើន ប្រកបដោយភាពជាក់ស្តែងនិយម ដើម្បីអាចដាក់ចេញនូវទិសដៅគោលនយោបាយ ដោយមានការគិតគូរគ្រប់ជ្រុងជ្រោយពីឧត្តមភាពដែលពោរពេញដោយសក្តានុពលកម្រិតខ្ពស់ លក្ខខណ្ឌអំណោយផលក្នុងបរិស្ថានសេដ្ឋកិច្ច ក៏ដូចជាបញ្ហាប្រឈមកំពុងជួបប្រទះ និងកាលានុវត្តភាពចម្បងៗ។ **សម្រាប់រយៈពេលមធ្យមខាងមុខ(ឆ្នាំ២០២៤-២០២៨) សេដ្ឋកិច្ចកម្ពុជាត្រូវបានកំណត់គោលដៅសម្រេចបាននូវអត្រាកំណើនជាមធ្យម៦,៣% ក្នុងមួយឆ្នាំ**។ ការសម្រេចបានអត្រាកំណើននេះ ទាមទារឱ្យមានការបន្តជំរុញការអភិវឌ្ឍវិស័យចន្លល់គន្លឹះៗដូចខាងក្រោម៖

**វិស័យឧស្សាហកម្ម ត្រូវសម្រេចឱ្យបានកំណើនជាមធ្យមក្នុងរង្វង់៩,១%**។ ក្នុងនោះ អនុវិស័យកាត់ដេរ ត្រូវបន្តរក្សាបានកំណើន ប្រហាក់ប្រហែលមុនវិបត្តិនៃជំងឺកូវីដ-១៩ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ត្រូវរក្សាឱ្យបានកំណើនរឹងមាំ ស្របតាមកំណើននៃតម្រូវការខាងក្រៅនិងទីផ្សារ

ក្នុងស្រុក និងការជំរុញសហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព។ អនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ នៅតែជាមូលដ្ឋានកំណើនល្អ ដែលត្រូវបន្តរុញច្រានទៅមុខបន្ថែម។ ដោយឡែក សម្រាប់អនុវិស័យសំណង់ កម្ពុជាត្រូវខិតខំជំរុញអនុវិស័យនេះឱ្យចេញពីកំណើនទាបឆ្ពោះទៅរកនិន្នាការធម្មតា ជាពិសេសសំណង់លំនៅឋាន និងសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម។ អនុវិស័យនេះ ត្រូវជំរុញដោយសកម្មភាពសំណង់ដែលចេញពីតម្រូវការពិត ជាពិសេស ផ្នែកលំនៅឋាន ដែលគាំទ្រដោយភាពប្រសើរនៃកត្តាភាគលាភប្រជាសាស្ត្រកម្ពុជា ខណៈសំណង់បម្រើឱ្យឧស្សាហកម្ម រោងចក្រ និងសកម្មភាពពាណិជ្ជកម្មផ្សេងទៀត ក៏នឹងក្លាយជានិន្នាការថ្មីមួយ ក្នុងការជួយទ្រទ្រង់វិស័យនេះក្នុងរយៈពេលខ្លីនិងមធ្យមខាងមុខ។

**វិស័យសេវាកម្ម ត្រូវសម្រេចឱ្យបានកំណើនក្នុងរង្វង់៥,០%** ដែលត្រូវគាំទ្រដោយកំណើននៃអនុវិស័យបដិសណ្ឋារកិច្ចនិងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត។ ក្នុងនោះ អនុវិស័យបដិសណ្ឋារកិច្ចនិងសេវាកម្មម្ហូបអាហារ ត្រូវបន្តសម្រេចបានកំណើនជាបន្តបន្ទាប់អាស្រ័យនឹងការមកដល់នៃកំណើនភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ អនុវិស័យលក់ដុំ រាយ ត្រូវសម្រេចបានកំណើនប្រហាក់ប្រហែលទៅនឹងនិន្នាការធម្មតា ដោយសារសម្ពាធពីវិបត្តិនៅតែធ្វើឱ្យសកម្មភាពចាយវាយ និងតម្រូវការក្នុងស្រុក ហាក់នៅពុំទាន់ផុសផុលដូចគ្រាមុនវិបត្តិ។ អនុវិស័យអចលនទ្រព្យនឹងត្រូវងើបឡើងក្នុងអត្រាទាប ប៉ុន្តែសកម្មភាពទិញ លក់ ជាពិសេស ផ្នែកលំនៅឋានថ្លៃទាបនិងមធ្យម នឹងបន្តគាំទ្រដល់កំណើនជារួមក្នុងអនុវិស័យនេះ។ អនុវិស័យដឹកជញ្ជូននិងស្តុក ត្រូវបន្តរក្សាបានកំណើនរឹងមាំដោយសកម្មភាពដឹកជញ្ជូនកាន់តែមមាញឹក ជាពិសេស ការដឹកជញ្ជូនទំនិញក្នុងស្រុកនិងការដឹកជញ្ជូនទំនិញគោលដៅចុងក្រោយដល់អ្នកប្រើប្រាស់។ អនុវិស័យហិរញ្ញវត្ថុនិងធានារ៉ាប់រង ត្រូវរក្សាបានចលនការដែលគាំទ្រដោយការបន្តធ្វើទំនើបកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ សំដៅបម្រើដល់តម្រូវការប្រជាជននិងអាជីវកម្ម។ ជាងនេះទៅទៀត អនុវិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ត្រូវបានមើលឃើញថានឹងបន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការធម្មតា ដោយសារការបន្តកើននៃសកម្មភាពប្រើប្រាស់អ៊ីនធឺណិត និងការផ្តល់សេវានូវដំណោះស្រាយបច្ចេកវិទ្យាថ្មី។

**វិស័យកសិកម្ម ត្រូវសម្រេចឱ្យបានកំណើនក្នុងរង្វង់១,០%** ដែលជានិន្នាការប្រហាក់ប្រហែលទៅនឹងឆ្នាំកន្លងទៅ ដោយផ្អែកលើប្រក្រតីភាពនៃកំណើនល្អក្នុងអនុវិស័យដំណាំនិងចិញ្ចឹមសត្វ និងការងើបសន្សឹមៗនៃអនុវិស័យនេសាទ ក្នុងនោះ អនុវិស័យដំណាំត្រូវសម្រេចបានកំណើនល្អ ដោយផ្អែកលើការបន្តកើនឡើងនៃការវិនិយោគទាំងក្នុងស្រុកនិងពីបរទេស លើការកែច្នៃផលិតផលកសិកម្ម ការបង្កើនវិនិយោគសាធារណៈ និងកិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល។ ទន្ទឹមគ្នានេះ អនុវិស័យចិញ្ចឹមសត្វ បាននិងកំពុងងើបជាសន្សឹមៗ តាមរយៈយន្តការលើកទឹកចិត្តនិងជំរុញផលិតភាពចិញ្ចឹមក្នុងស្រុក។ ដោយឡែក អនុវិស័យនេសាទត្រូវបានបន្តជំរុញផ្អែកលើសុទិដ្ឋិនិយមនៃកំណើនផលចាប់ទឹកសាប ដែលបន្តស្តារឡើងវិញ ក្រោយការដាក់ចេញនូវគោលនយោបាយបង្ក្រាបបទល្មើសនេសាទនិងការវិនិយោគក្នុងវារីវប្បកម្ម។

## តារាងទី២.៤ : គោលដៅនៃអត្រាកំណើនតាមវិស័យឆ្នាំ២០២៤-២០២៨

| កំណើន (%) | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| **ផ.ស.ស.** | **៥,០** | **៦,០** | **៦,៣** | **៦,៣** | **៦,៥** | **៦,៥** |
| **វិស័យកសិកម្ម** | **០,៩** | **០,៩** | **០,៩** | **១,០** | **១,២** | **១,២** |
| ដំណាំ | ១,៣ | ១,៦ | ១,៤ | ១,៥ | ១,៦ | ១,៧ |
| នេសាទ | ០,១ | ០,៩ | ០,២ | ០,៣ | ០,៤ | ០,៥ |
| ចិញ្ចឹមសត្វ | ០,៩ | - ១,៩ | ០,២ | ០,៤ | ០,៦ | ០,៧ |
| **វិស័យឧស្សាហកម្ម** | **៤,៣** | **៩,២** | **៩,៣** | **៨,៩** | **៩,០** | **៨,៩** |
| កាត់ដេរ | - ៣,៥ | ១៦,៩ | ១២,០ | ៩,១ | ៨,៣ | ៧,៧ |
| សំណង់ | ០,៧ | ១,១ | ២,៥ | ៤,០ | ៥,៨ | ៦,០ |
| ផលិតកម្មម្ហូបអាហារ | ៧,៣ | ៦,១ | ៦,៦ | ៧,២ | ៧,៤ | ៧,៤ |
| ផលិតកម្មភេសជ្ជៈ និងថ្នាំជក់ | ៦,៨ | ៣,៣ | ៥,៥ | ៦,៣ | ៦,២ | ៦,១ |
| កម្មន្តសាលមិនមែនកាត់ដេរ | ១៧,០ | ៧,១ | ១១,០ | ១១,៩ | ១២,០ | ១២,១ |
| **សេវាកម្ម** | **៧,២** | **៤,៥** | **៤,៨** | **៥,០** | **៥,៣** | **៥,២** |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | ៤៧,៥ | ១២,៩ | ៨,៧ | ៦,២ | ៥,៧ | ៤,១ |
| លក់ដុំ-រាយ | ៤,០ | ៣,៩ | ៤,៥ | ៥,០ | ៥,៦ | ៥,៧ |
| ដឹកជញ្ជូន និងស្តុក | ៤,៧ | ៧,២ | ៦,៧ | ៦,៥ | ៦,៥ | ៦,៥ |
| បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | ៩,០ | ៧,០ | ៧,១ | ៧,៣ | ៧,៥ | ៧,៦ |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | - ៤,០ | - ០,៦ | ១,០ | ២,៤ | ៣,០ | ៣,៤ |
| អចលនទ្រព្យ | ០,០ | ១,២ | ២,៨ | ៣,៧ | ៤,៩ | ៥,១ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

### ២.៣.២- ចំហាក (សេណារីយ៉ូ) ម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅមុខ

ជាមួយនឹងការសម្រេចបាននូវគោលដៅកំណើនសេដ្ឋកិច្ចតាមវិស័យ ដូចបានកំណត់ខាងលើ ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ នឹងកើនឡើងពី២ ៧១៩ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ ទៅ៣ ៦៣៦ ដុល្លារអាមេរិក ត្រឹមដំណាច់ឆ្នាំ២០២៨ ក្នុងនោះ អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,២% ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ។ អត្រាប្តូរប្រាក់ផ្លូវការ (រៀលក្នុង១ដុល្លារអាមេរិក) រំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម៤ ០៥៥ រៀលក្នុង១ដុល្លារអាមេរិក ក្នុងអំឡុងឆ្នាំ២០២៤-២០២៨។

វិហូរការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងរង្វង់ជាមធ្យមប្រមាណ ៨,២%នៃផ.ស.ស. ដោយសារការបន្តកើនឡើងនៃទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែ

អំណោយផលសម្រាប់ការវិនិយោគនៅកម្ពុជា តាមរយៈការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយគាំទ្រមួយចំនួនទៀត។ គួរបញ្ជាក់ថា ក្នុងរយៈពេលមធ្យមខាងមុខ កម្ពុជារំពឹងថានឹងអាចទាក់ទាញការវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់ ជាពិសេស ក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ រួមមានបង្គុំអេឡិចត្រូនិក ដំឡើងយានយន្ត ផលិតកម្មសំបកកង់យានយន្ត និងផលិតផលកែច្នៃផ្សេងទៀត។

ឱនភាពគណនីចរន្ត(រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ -២,៧% ដោយសារការរំពឹងទុកនៃការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍នៅបន្តមាននិន្នាការល្អ។ ជាមួយគ្នានេះ ឱនភាពថវិកាទូទៅ ត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមរួមតូចនិងជាសន្សឹមៗ ពីអត្រា-៣,០% នៃផ.ស.ស. ក្នុងឆ្នាំ២០២៤ មកត្រឹម-២,២% នៃផ.ស.ស. ក្នុងឆ្នាំ២០២៨ ដែលការណ៍នេះឆ្លុះបញ្ចាំងពីអំពីការដាក់ចេញនូវគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន ក្នុងរយៈពេលមធ្យម។ ក្នុងនោះ ចំណូលថវិកាសរុបត្រូវបានរំពឹងទុកថានឹងមានកំណើនសមគួរ ពោលគឺកើនឡើងពី១៥,០% នៃផ.ស.ស. ក្នុងឆ្នាំ២០២៤ ទៅ១៥,៤% នៃផ.ស.ស. ក្នុងឆ្នាំ២០២៨ ខណៈចំណាយថវិកាសរុប នឹងស្ថិតក្នុងរង្វង់ជាមធ្យម១៧,៦% នៃផ.ស.ស. សម្រាប់ឆ្នាំ២០២៤-២០២៨។

ការនាំចេញរំពឹងថានឹងបន្តកើនឡើង ដែលបន្តជំរុញដោយការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ(គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារិម និងសំបកកង់រថយន្ត) និងផលិតផលកសិកម្ម។ ជាមួយគ្នានេះ ការនាំចូល ក៏រំពឹងថានឹងបន្តនិន្នាការល្អ ដោយការកើនឡើងនៃការនាំចូលវត្ថុធាតុដើមផលិតបម្រើឱ្យវិស័យកម្មន្តសាល និងផលិតកម្មផ្សេងៗក្នុងស្រុក និងការនាំចូលទំនិញប្រើប្រាស់ផ្សេងៗ ដោយសារការបន្តកើនឡើងនៃសកម្មភាពចាយវាយ និងការប្រើប្រាស់ក្នុងស្រុក។ ដោយឡែក ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តកើនដល់ប្រមាណ៣០ ៨៧១លានដុល្លារអាម៉េរិក ឬស្មើប្រមាណ ៦,២ខែនៃការនាំចូល នៅឆ្នាំ២០២៨។

### តារាងទី២.៥ : សង្ខេបចំហាកម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅឆ្នាំ២០២៨

| សូចនាករ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| **ជាតុចេញ** | | | | | | |
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ១៧៧ ៣៥១ | ១៩១ ៨៦២ | ២០៨ ៤០០ | ២២៦ ६១៨ | ២៤៧ ០០៨ | ២៦៩ ២០១ |
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (លានដុល្លារអាម៉េរិក) | ៤៣ ១៥១ | ៤៧ ១៣៧ | ៥១ ៤០៦ | ៥៥ ៩៣០ | ៦០ ៩៥៥ | ៦៦ ៤៤៧ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាម៉េរិក) | ២ ៥២៥ | ២ ៧១៩ | ២ ៩២៤ | ៣ ១៣៩ | ៣ ៣៧៩ | ៣ ៦៣៦ |
| អត្រាកំណើនពិតនៃផ.ស.ស. (%) | ៥,០% | ៦,០% | ៦,៣% | ៦,៣% | ៦,៥% | ៦,៥% |
| ចំនួនប្រជាជន (លាននាក់) | ១៧,១ | ១៧,៣ | ១៧,៦ | ១៧,៨ | ១៨,១ | ១៨,៣ |
| **ការវិនិយោគ និងការសន្សំ** | | | | | | |
| **ការវិនិយោគសរុប (% ផ.ស.ស.)** | ២៧,៥% | ២៥,៩% | ២៧,៦% | ២៦,៦% | ២៥,៤% | ២៦,៩% |
| ការវិនិយោគសាធារណៈ (% ផ.ស.ស.) | ៨,៩% | ៥,៨% | ៥,៤% | ៥,៣% | ៥,៧% | ៤,៤% |
| ការវិនិយោគឯកជន (% ផ.ស.ស.) | ១៨,៦% | ២០,០% | ២២,២% | ២១,៣% | ១៩,៨% | ២២,៤% |

| | | | | | | |
|---|---|---|---|---|---|---|
| សញ្ច័យជាតិ(សន្សំ) (% ផ.ស.ស.) | ៩,៩% | ២៧,០% | ២៦,២% | ២៤,២% | ២១,៩% | ២២,៥% |
| សញ្ច័យក្រៅប្រទេស(សន្សំ) (% ផ.ស.ស.) | ១៧,៦% | -១,២% | ១,៤% | ២,៤% | ៣,៥% | ៤,៤% |
| **អតិផរណា និង រូបិយវត្ថុ** | | | | | | |
| *អតិផរណា (ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ - %)* | ២,១% | ០,៨% | ៣,០% | ២,១% | ២,៥% | ២,៥% |
| អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ(មធ្យមប្រចាំឆ្នាំ) | ៤ ១១០ | ៤ ០៧០ | ៤ ០៥៤ | ៤ ០៥២ | ៤ ០៥០ | ៤ ០៥០ |
| **ស្ថានភាពសារពើពន្ធ** | | | | | | |
| ចំណូលថវិកាសរុប( ផ.ស.ស.) | ១៩,៨% | ១៥,០% | ១៥,២% | ១៥,០% | ១៥,២% | ១៥,៤% |
| ចំណាយថវិកាសរុប( ផ.ស.ស.) | ២១,១% | ១៨,០% | ១៨,២% | ១៧,២% | ១៧,២% | ១៧,៦% |
| ឱនភាព/អតិរេកថវិកាចរន្ត( ផ.ស.ស.) | ២,២% | ២,០% | ២,១% | ២,៤% | ២,៩% | ៣,៣% |
| ឱនភាព/អតិរេកថវិកាទូទៅ( ផ.ស.ស.) | - ៥,៦% | - ៣,០% | - ៣,០% | - ២,១% | - ២,០% | - ២,២% |
| **ជញ្ជីងទូទាត់** | | | | | | |
| ការនាំចេញទំនិញ ( ផ.ស.ស.) | ៥៥,២% | ៥៦,៨% | ៥៩,៤% | ៦២,៨% | ៦៦,៤% | ៧០,៤% |
| ការនាំចូលទំនិញ ( ផ.ស.ស.) | ៦២,២% | ៦៦,៣% | ៧១,២% | ៧៥,៦% | ៧៩,៧% | ៨៤,២% |
| តុល្យភាពពាណិជ្ជកម្ម ( ផ.ស.ស.) | -៦,៩% | -៩,៥% | -១១,៨% | -១២,៨% | -១៣,៣% | -១៣,៨% |
| តុល្យភាពគណនីចរន្ត( ផ.ស.ស.) | ១,៣% | -០,១% | -២,៦% | -៣,៨% | -៣,៧% | -៣,៧% |
| **ទុនបម្រុង** | | | | | | |
| ទុនបម្រុងបរទេសដុល (លានដុល្លារអាម៉េរិក) | ១៩ ៩៩៨ | ២២ ៥១១ | ២៤ ៤៣២ | ២៦ ៤២១ | ២៨ ៥៧៧ | ៣០ ៨៧១ |
| ទុនបម្រុងបរទេសដុល (ចំនួនខែនាំចូលទំនិញនិងសេវា) | ៨,២ | ៧,៩ | ៧,៣ | ៦,៩ | ៦,៥ | ៦,២ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ(ស៊េរីទិន្នន័យគណនេយ្យជាតិ ឆ្នាំគោលថ្មី ឆ្នាំ២០១៤)*

## ២.៤- គោលដៅយុទ្ធសាស្ត្រនិងគោលនយោបាយអាទិភាពសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា

ការសម្រេចបាននូវគោលដៅកំណើនសេដ្ឋកិច្ច ទាមទារឱ្យមានការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាពជាក់ស្តែងនិងចំៗ ដោយត្រូវមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពថ្មីៗឱ្យអស់លទ្ធភាព ដោយមិនប៉ះពាល់ដល់ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច។

### ២.៤.១- គោលដៅយុទ្ធសាស្ត្រ

គោលដៅជាយុទ្ធសាស្ត្រទាំង៥ ដូចមានចែងក្នុង**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា រួមមាន៖

**ទី១-** ធានាឱ្យបានកំណើនសេដ្ឋកិច្ចរយៈពេលវែង ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយភាពធន់ តាមរយៈការជំរុញសម្ទុះនៃការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួត

ប្រជែង និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ធានាស្ថិរភាពអត្រាប្តូរប្រាក់ ខិតខំបង្កើនទុនបម្រុង និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងបំណុលសាធារណៈ។

**ទី២-** បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណនិងគុណភាព ជូនដល់ប្រជាជនកម្ពុជា ជាពិសេសយុវជន តាមរយៈការពង្រឹងគុណភាពអប់រំនិងការបណ្តុះបណ្តាលជំនាញ ទាំងជំនាញរឹងនិងជំនាញទន់ ក៏ដូចជាការពង្រឹងបរិយាកាសការងារឱ្យកាន់តែល្អប្រសើរទៅដល់និយោជិក និងបរិយាកាសវិនិយោគឱ្យកាន់តែទាក់ទាញបន្ថែមទៅដល់និយោជិត។

**ទី៣-** កាត់បន្ថយភាពក្រីក្រឱ្យនៅក្នុងអត្រាទាបជាង១០% និងបន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រឱ្យបានជាអប្បបរមា តាមរយៈវិធានការបង្រួមវិសមភាពសេដ្ឋកិច្ច ការអភិវឌ្ឍ និងការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំនិងសង្គតិភាព ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងបរិយាបន្ន។

**ទី៤-** បន្តពង្រឹងសមត្ថភាពអភិបាលកិច្ចនិងលើកកម្ពស់គុណភាពស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន និងបន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផលដល់ធុរកិច្ច ការវិនិយោគ និងពាណិជ្ជកម្ម។

**ទី៥-** ធានាចីរភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដោយកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើសុកបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ពង្រឹងភាពធន់នៃប្រជាសាស្ត្រ លើកកម្ពស់សមភាពយេនឌ័រ គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព បង្កើនហិរញ្ញប្បទានចីរភាព និង បង្កើនកម្ចីបៃតងសម្រាប់ការវិនិយោគបៃតង និងសេដ្ឋកិច្ចបៃតង។

## ២.៤.២- គោលនយោបាយអាទិភាព

កិច្ចការអាទិភាពចំនួន៥ នៃ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** បានបន្តកំណត់យកមនុស្សជាអាទិភាពគន្លឹះទី១ ហើយផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ ដែលមានលក្ខណៈប្រទាក់ក្រឡា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងទិសដៅនៃការអភិវឌ្ឍកម្ពុជា ក្នុងដំណាក់កាលថ្មីខាងមុខ។ កិច្ចការអាទិភាពទាំង៥នោះ រួមមាន៖

**ទី១- ការអភិវឌ្ឍមូលធនមនុស្ស** ដោយផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង និងការពង្រឹងភាពជាពលរដ្ឋ ដែលមានអារ្យធម៌ខ្ពស់ សីលធម៌ សមធម៌ និងបរិយាបន្ន។

**ទី២- ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង** ដោយផ្តោតលើការអភិវឌ្ឍវិស័យគន្លឹះ ប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច ការលើកកម្ពស់ការតភ្ជាប់ និងបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូនឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស ដែលមានសួនឧស្សាហកម្ម សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក និងការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាននិងផលិតផល

ហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ។

**ទី៣- ការអភិវឌ្ឍវិស័យឯកជននិងការងារ** ដោយផ្តោតលើការអភិវឌ្ឍទីផ្សារការងារ ការលើកស្ទួយសហគ្រាសមីក្រូធុនតូចនិងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាពថ្មីនិងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងឯកជន ការពង្រឹងការប្រកួតប្រជែង ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

**ទី៤- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** ដោយផ្តោតលើការធ្វើសុគបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌និងទេសចរណ៍ប្រកបដោយចីរភាព ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម និងការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។

**ទី៥- ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល** ដោយផ្តោតលើការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។

## ២.៤.៣- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្នុងបរិការណ៍សកលដែលហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាកាន់តែខ្ពស់ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានក្លាយជាឧបករណ៍គោលនយោបាយដ៏សំខាន់របស់រាជរដ្ឋាភិបាលក្នុងការទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងការគ្រប់គ្រងសភាពការណ៍នៃបញ្ហាប្រឈមនានា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានគិតគូរដោយស្មារតីបុរេសកម្ម ក្នុងការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែល***ម្ខាង*** ផ្តោតសំខាន់លើការធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ និងភាពជាម្ចាស់របស់កម្ពុជាលើការគ្រប់គ្រងដោគវាសនារបស់ខ្លួន ដោយមិនអនុញ្ញាតឱ្យប្រទេសជាតិធ្លាក់ចូលក្នុងស្ថានភាពបំណុលវ័ណ្ឌក ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ និង***ម្ខាងទៀត*** ផ្តោតលើការគាំទ្រដល់ការសម្រេចបាននូវរបៀបវារៈគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ សម្រាប់រយៈពេលមធ្យមខាងមុខ រាជរដ្ឋាភិបាលនឹងប្រកាន់ខ្ជាប់ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលមានចរិតជា**គោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** (Gradual Fiscal Consolidation Stance)។ ក្នុងស្មារតីនេះ ជាទិសដៅទៅមុខ រាជរដ្ឋាភិបាលនឹងផ្តោតចម្បងលើការអនុវត្តវិធានការគោលនយោបាយសំខាន់ៗ ដូចខាងក្រោម៖

- បន្តផ្តល់គុណតម្លៃនៃការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា និងប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយថវិកាជាតិ ដោយធ្វើអាទិភាពូបនីយកម្មមុខសញ្ញាចំណាយ ពោលគឺត្រូវតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវនិងចំទិសដៅ ស្របតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ហើយត្រូវមានភាពឆ្លាតវៃក្នុងការចាយវាយ ដោយផ្តោតលើតម្លៃនៃលុយ ព្រមទាំងគិតគូរបន្ថែមអំពីយន្តការប្រភពហិរញ្ញប្បទានផ្សេងៗ ដើម្បីបំពេញឱ្យបានរាល់តម្រូវការ

អាទិភាពចំណាយ ដូចជា កិច្ចការកែទម្រង់គន្លឹះៗរបស់រាជរដ្ឋាភិបាល ការបន្តគាំទ្រប្រព័ន្ធគាំពារសង្គម ការបង្កើនផលិតភាព ការលើកស្ទួយភាពប្រកួតប្រជែង និងការទាក់ទាញការវិនិយោគ ជាដើម ស្របតាមលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ

- ពង្រឹងការតាមដាន និងវាយតម្លៃលើការអនុវត្តថវិកា ឱ្យកាន់តែហ្មត់ចត់ លើភាពសមស្របនៃថ្លៃ បរិមាណ និងគុណភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកា និងបង្កើនគុណភាពនៃការកំណត់សូចនាករគន្លឹះឱ្យបានសមស្រប ក្នុងក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធថវិកាពត៌មានសមិទ្ធកម្ម
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨ សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ជាពិសេស វិស័យបង្កើនផលិតភាព និងតម្លៃបន្ថែមខ្ពស់ ជំរុញការតភ្ជាប់ និងពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច
- ពង្រឹងជាប្រព័ន្ធនូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកាជាតិ តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ និងបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ
- បន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា តាមរយៈការពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ និងអស់សក្តានុពល ប៉ុន្តែត្រូវមានការថ្លឹងថ្លែងនឹងការបន្តរក្សាបាននូវចលនការ និងសម្ទុះសេដ្ឋកិច្ច ដោយខិតខំចៀសវាងឱ្យបានជាអតិបរមានូវវិការភាពសេដ្ឋកិច្ច
- បន្តលើកស្ទួយវិស័យឯកជន ដោយគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមានការបង្កើតបរិយាកាសល្អប្រសើរ តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការដាក់ចេញវិធានការលើកទឹកចិត្តដាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ចជាមួយនឹងភាពប្រកួតប្រជែងនិងសមភាព
- បន្តពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តការលើកទឹកចិត្តផ្នែកពន្ធនានា និងប្រកាន់យកអភិក្រមពុំបង្កើតបន្ទុកពន្ធថ្មីដល់ប្រជាជន និងវិស័យឯកជន
- រៀបចំវិធានការ សំដៅពង្រឹងប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ដើម្បីត្រៀមទប់ទល់នឹងវិបត្តិនាអនាគត
- បន្តពង្រឹងនិងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ និងសមិទ្ធកម្មការងារ និងបង្កើនផលិតភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង
- បន្តអនុវត្តកិច្ចការកែទម្រង់ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលជាឃ្នាស់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាព និងសក្តិសិទ្ធិភាពគោលនយោបាយ ជាពិសេស ក្នុងការបង្កើនប្រសិទ្ធភាពចំណាយ ការកែទម្រង់រដ្ឋបាលប្រមូលចំណូល និងការរៀបចំប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា សំដៅរក្សា និងធានាចីរភាពហិរញ្ញវត្ថុសាធារណៈ។

## ២.៤.៤- ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ

ជារួម ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ គោលនយោបាយរូបិយវត្ថុបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច បើទោះបីជាសេដ្ឋកិច្ចកម្ពុជានៅបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់ក៏ដោយ។ ការអនុវត្តគោលនយោបាយរូបិយវត្ថុ មានភាពបត់បែនខ្ពស់ ទៅតាមនិន្នាការសេដ្ឋកិច្ច ដោយផ្តោតលើ ១) ការបន្តគ្រប់គ្រងស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់លើទីផ្សារ ២) ការគ្រប់គ្រងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងអភិវឌ្ឍវិស័យធនាគារ ឆ្លើយតបទៅនឹងតម្រូវការសង្គម សេដ្ឋកិច្ច និង៣) ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់។ គោលនយោបាយរូបិយវត្ថុទាំងបីនេះ នៅតែជាគោលនយោបាយត្រឹមត្រូវ សម្រាប់ការចូលរួមជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖

- រក្សាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាម៉េរិកឱ្យមានស្ថិរភាព ដើម្បីរក្សានិងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ក៏ដូចជាអំណាចទិញរបស់ប្រាក់រៀល
- បន្តតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានឥណទានជាប្រាក់រៀលយ៉ាងតិច១០% នៃសម្ពាធឥណទានសរុប
- បន្តពង្រឹងឧបករណ៍រូបិយវត្ថុ ដើម្បីគាំទ្រការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ។ ជាមួយគ្នានេះ សញ្ញាបណ្ណសាជីវកម្មនិងសញ្ញាបណ្ណរដ្ឋាភិបាល ត្រូវបានបោះផ្សាយជារៀល ដើម្បីបង្ហាញពីការអភិវឌ្ឍទីផ្សារទុនជារៀល
- បន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ជាពិសេសប្រព័ន្ធបាគង ដើម្បីសម្រួលដល់ការទូទាត់ជាប្រាក់រៀលឱ្យមានភាពងាយស្រួល សុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងពង្រីកវិសាលភាពនៃការទូទាត់ឆ្លងប្រទេស តាមរយៈការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់និងក្រុមហ៊ុនទូទាត់អន្តរជាតិនានា
- លើកកម្ពស់ចំណេះដឹងសាធារណជនអំពីសារៈសំខាន់នៃប្រាក់រៀលនិងការប្រើប្រាស់ប្រាក់រៀល តាមរយៈកម្មវិធីផ្សព្វផ្សាយពីប្រាក់រៀល សិក្ខាសាលា ឬវេទិកាសាធារណៈនានានៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា
- អភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ដើម្បីគាំទ្រអន្តរការីកម្មហិរញ្ញវត្ថុ ការប្រើប្រាស់ប្រាក់រៀល និងឥទ្ធិពលរបស់នយោបាយរូបិយវត្ថុ ជាពិសេសតាមរយៈអត្រាការប្រាក់
- ពង្រឹងភាពធន់និងការរីកចម្រើនរបស់ប្រព័ន្ធធនាគារ ដើម្បីគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចនិងទំនុកចិត្តវិនិយោគ និង
- លើកទឹកចិត្តការបើកគណនីធនាគារជាប្រាក់រៀល កិច្ចសហការជាមួយស្ថាប័នសាធារណៈ និងវិស័យឯកជនពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានការបើកប្រាក់បៀវត្ស ដាក់តាំងស្លាកតម្លៃ និងទូទាត់ជាប្រាក់រៀល លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅតាមទីជនបទ ជាពិសេសការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។

## ២.៤.៥- ក្របខ័ណ្ឌគោលនយោបាយទាក់ទាញវិនិយោគ

ដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ២០៥០ ក្នុងការក្លាយជាប្រទេសចំណូលខ្ពស់ ស្របតាម**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល ការកំណត់គោលនយោបាយទាក់ទាញវិនិយោគឱ្យចំគោលដៅនិងមានប្រសិទ្ធភាព គឺជាកត្តារួមផ្សំដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ក្នុងនោះ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់នេះ ដែលត្រូវបានរៀបចំឡើងដោយរួមបញ្ចូលនូវការគិតគូរឆ្លើយតបនិងចាប់យកកាលានុវត្តភាពដែលកើតចេញពីនិន្នាការតំបន់និងសកល បានផ្តល់នូវមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការបង្កើតបរិយាកាសវិនិយោគដ៏ទាក់ទាញ សម្រាប់វិនិយោគិន ទាំងក្នុងស្រុកនិងបរទេស។ ជាក់ស្តែង យោងតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា វិនិយោគិនដែលបានស្នើសុំជាគម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ (គ.ល.គ.) នឹងទទួលបានការសម្របសម្រួលនិងអត្ថប្រយោជន៍ជាច្រើន តាមរយៈការលើកទឹកចិត្តពន្ធដារ (ការលើកលែងពន្ធលើប្រាក់ចំណូលរហូតដល់៩ឆ្នាំ ការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើន៦ឆ្នាំ ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ការលើកលែងពន្ធអប្បបរមា ការលើកលែងអាករនាំចេញ ជាដើម) និងការលើកទឹកចិត្តមិនមែនពន្ធ រួមមាន ការសិក្សាវាយតម្លៃស្ថានភាព និងស្វែងយល់ពីវឌ្ឍនភាព តម្រូវការជាក់ស្តែង និងបញ្ហាប្រឈមរបស់គម្រោងវិនិយោគ ការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដើម្បីសម្រួលដល់ការទទួលបានអាជ្ញាបណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា និងទិដ្ឋាការចេញចូលនិងស្នាក់នៅរបស់វិនិយោគិន ការពិគ្រោះយោបល់លើការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងនវានុវត្តន៍ ការសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធលើការគាំទ្រហិរញ្ញវត្ថុដល់វិនិយោគិន ការពិគ្រោះយោបល់ជាមួយវិនិយោគិន លើបញ្ហាប្រឈមនានា និងស្វែងរកលទ្ធភាពផ្តល់ជាដំណោះស្រាយ ដើម្បីទប់ស្កាត់វិវាទវិនិយោគ។

គោលនយោបាយទាក់ទាញវិនិយោគត្រូវផ្តោតលើការទាក់ទាញវិនិយោគដែលមានគុណភាព មានតម្លៃបន្ថែមខ្ពស់ និងអនុញ្ញាតឱ្យកម្ពុជាអាចផ្លក់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់និងសកល សំដៅបង្កើតការងារដែលមានប្រាក់ឈ្នួលសមរម្យ ប្រកបដោយគុណភាព ជូនប្រជាជនកម្ពុជា។ ក្នុងការងារនេះ តំបន់សេដ្ឋកិច្ចពិសេសនឹងបន្តដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញពិពិធកម្មឧស្សាហកម្មនិងសេដ្ឋកិច្ច ដែលមកទល់បច្ចុប្បន្ន តំបន់សេដ្ឋកិច្ចពិសេសដែលកំពុងដំណើរការមានចំនួន៣២ ហើយតំបន់ទាំងនេះបានផ្តល់នូវបរិយាកាសវិនិយោគដ៏ទាក់ទាញ ដោយមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល លើការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងនីតិវិធីរដ្ឋបាលនានា។ ទន្ទឹមគ្នានេះ ជាផ្នែកមួយនៃការថែទាំវិនិយោគ រាជរដ្ឋាភិបាល បាននិងកំពុងបន្តអនុវត្តយន្តការកិច្ចសន្ទនារវាងរដ្ឋនិងឯកជន ដើម្បីតម្រង់ទិសការអភិវឌ្ឍរបស់វិស័យឯកជន និងដោះស្រាយនូវរាល់បញ្ហាប្រឈមរបស់វិនិយោគិននិងធុរជន សំដៅធានាបាននូវភាពជោគជ័យ និងរីកចម្រើននៃប្រតិបត្តិការអាជីវកម្មរបស់វិស័យឯកជននៅកម្ពុជា។

ឈរលើមូលដ្ឋានដ៏រឹងមាំនេះ សម្រាប់ទិសដៅទៅមុខ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការជាអាទិភាព រួមមាន៖

- បន្តរៀបចំដាក់ចេញនិងខិតខំជំរុញអនុវត្តឱ្យបាននូវការកែទម្រង់ជារចនាសម្ព័ន្ធផ្ទៃក្នុងផង និងការពង្រីកទីផ្សារខាងក្រៅផង

- ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការកាត់បន្ថយនូវតម្រូវការឯកសារ និងការត្រួតពិនិត្យសាំញ៉ាំ ក៏ដូចជាការជំរុញនូវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុងសម្រាប់ប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ
- កាត់បន្ថយថ្លៃអនុលោមភាព (Compliance cost) ក្នុងការវិនិយោគ និងការធ្វើធុរកិច្ច ដោយត្រូវធានាឱ្យបាននូវ ***ម្ខាង*** ភាពយុត្តិធម៌ ភាពងាយស្រួល និងការចៀសវាងការរំខានសម្រាប់វិនិយោគិន និង ***ម្ខាងទៀត*** អនុលោមភាពនៅក្នុងការបំពេញកាតព្វកិច្ចនានា ស្របតាមគោលនយោបាយនិងបទប្បញ្ញត្តិច្បាប់ជាធរមាន
- ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសក្នុងវិស័យបច្ចេកវិទ្យាខ្ពស់
- ទាញយកឱ្យបានជាអតិបរមានូវផលប្រយោជន៍ពីទីផ្សារដែលមានស្រាប់ និងការជំរុញបើកទីផ្សារថ្មីៗបន្ថែមទៀត តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាទ្វេភាគី ឬពហុភាគី និង
- ជំរុញការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រដែលមានស្រាប់ ជាអាទិ៍គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ផែនការមេអភិវឌ្ឍខេត្តព្រះសីហនុជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងអភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡា កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥-២០២៨ និងផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ឆ្នាំ២០២៣-២០៣៣។

# ជំពូកទី៣
# គោលនយោបាយនិងសកម្មភាពអាទិភាព សម្រាប់ នីតិកាលទី៧ នៃរដ្ឋសភា

រាជរដ្ឋាភិបាលបានដាក់ចេញ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ និងថែរក្សាសមិទ្ធផលជាតិ ព្រមទាំងបង្កើតសមិទ្ធផលថ្មីៗបន្ថែមទៀតសម្រាប់លើកកម្ពស់កិត្យានុភាពជាតិ ជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដើម្បីឈានដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ យុទ្ធសាស្ត្រនេះនឹងត្រូវអនុវត្តជា៥ដំណាក់កាលសម្រាប់រយៈពេល២៥ឆ្នាំទៅមុខ ដោយមានគោលដៅយុទ្ធសាស្ត្រចំនួន៥ គឺ ១) ធានាឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ ដើម្បីឈានដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ២) បង្កើតការងារឱ្យបានកាន់តែច្រើនទាំងបរិមាណនិងគុណភាព ៣) សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រក្នុងអត្រាទាបជាង១០% និងបន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា ៤) បន្តពង្រឹងសមត្ថភាពធនធានមនុស្ស អភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃរដ្ឋបាលនិងសេវាសាធារណៈ និង៥) ធានាចីរភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គឺជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដែលត្រូវបានរៀបចំឡើង តាមការចង្អុលបង្ហាញរបស់ **យុទ្ធសាស្ត្របញ្ចកោណ** ដើម្បីបន្សីគ្នារវាងកម្មវិធីនយោបាយ និងគោលនយោបាយអាទិភាពសំខាន់ៗរបស់យុទ្ធសាស្ត្រនេះ ជាមួយនឹងផែនការសកម្មភាព កម្មវិធី និងគម្រោងអាទិភាពរបស់ក្រសួង ស្ថាប័ន ដែលត្រូវទទួលបន្ទុកអនុវត្ត សំដៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍជាតិ ដែលបានរំលេចនៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

## ៣.១- ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ

### ៣.១.១- ការពង្រឹងនិងការកែទម្រង់ស្ថាប័ន

គោលដៅជាយុទ្ធសាស្ត្រនៃការពង្រឹងនិងការកែទម្រង់ស្ថាប័ន គឺការកសាងរដ្ឋបាលសាធារណៈឱ្យមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា។ ក្រសួង ស្ថាប័នត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗ របស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

ទី១- ការធ្វើវិចារណកម្ម មុខងារ និងរចនាសម្ព័ន្ធស្ថាប័ន និងការកំណត់បែបបទនៃការផ្តល់សេវារបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ការកំណត់ច្បាស់លាស់នូវមុខងារ

និងភារកិច្ច ការធ្វើប្រតិភូកម្មអំណាចសមស្រប ការកំណត់កម្រិតសិទ្ធិអំណាច ការទទួលខុសត្រូវនិងគណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការដឹកនាំ ការគ្រប់គ្រងនិងប្រតិបត្តិការ ការពង្រឹងយន្តការសម្របសម្រួលផ្នែកស្ថាប័ន និងសមាហរណកម្មសេវា និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈ។

ទី២- ការពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំ តាមរយៈការរៀបចំនិងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌសមត្ថភាពនៃភាពជាអ្នកដឹកនាំ ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការវាយតម្លៃ និងការទទួលស្គាល់អ្នកដឹកនាំគំរូនិងការរៀបចំបណ្តាញអ្នកដឹកនាំ ក្នុងរដ្ឋបាលសាធារណៈ។

ទី៣- ការពង្រឹងប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈនិងសមត្ថភាពគ្រប់គ្រងរដ្ឋបាលសាធារណៈ តាមរយៈការកែលម្អក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងមុខងារសាធារណៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនៃការលើកកម្ពស់ផលិតភាពការងារ ការគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម និងការជំរុញចលនាប្រឡងប្រណាំងនិងការធ្វើនវានុវត្តន៍។

ទី៤- ការបន្តជំរុញលើកកម្ពស់សមត្ថភាពកងកម្លាំងប្រដាប់អាវុធ តាមរយៈការអភិវឌ្ឍស្ថាប័ននិងការកសាងមូលធនមនុស្ស ការយកចិត្តទុកដាក់ខ្ពស់លើជីវភាពនិងសុខុមាលភាពនៃកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការជំរុញការអនុវត្តគោលនយោបាយសមស្របចំពោះកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ បាត់បង់សមត្ថភាព ពលីពិការ ដោយសារបុព្វហេតុថែរក្សាការពារសន្តិសុខជាតិ។

## សកម្មភាពនិងកម្មវិធីអាទិភាព សម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងមុខងារសាធារណៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធ្វើវិចារណកម្មមុខងារ ពង្រឹងប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈនិងសមត្ថភាពគ្រប់គ្រងរដ្ឋបាលសាធារណៈ ដោយកំណត់ច្បាស់លាស់នូវមុខងារនិងភារកិច្ច កំណត់កម្រិតសិទ្ធិអំណាចនិងធ្វើប្រតិភូកម្មអំណាចសមស្រប និងធានាគណនេយ្យភាពក្នុងក្របខ័ណ្ឌនៃការដឹកនាំ
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់ប្រសិទ្ធភាពនៃដំណើរការយន្តការស្ថាប័ន កំណត់បែបបទនៃការផ្តល់សេវារបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំង ពង្រឹងយន្តការសម្របសម្រួលផ្នែកស្ថាប័ននិងសមាហរណកម្មសេវាសាធារណៈ
- លើកកម្ពស់ការផ្តល់សេវាសាធារណៈ តាមរយៈការពង្រឹងនិងការកែលម្អយន្តការ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព គុណភាព តម្លាភាព ឆាប់រហ័ស ងាយស្រួល បរិយាបន្ន និងសមធម៌សង្គម ព្រមទាំងពង្រឹងយន្តការផ្តល់ព័ត៌មានត្រឡប់។

**ទី២- ក្រសួងមហាផ្ទៃ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងការគ្រប់គ្រងធនធានមនុស្សស្របតាមច្បាប់លក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីរាជការស៊ីវិល នគរបាលជាតិនិងមន្ត្រីពន្ធនាគារ និងស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងមន្ត្រីរាជការ
- លើកកម្ពស់ការសិក្សាស្រាវជ្រាវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ពន្ធនាគារ និងការងារពាក់ព័ន្ធផ្សេងទៀត ការអភិវឌ្ឍមូលដ្ឋាននិងអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ព្រមទាំងការជំរុញនវានុវត្តន៍ តាមរយៈ១) ការបង្កើនសកម្មភាពស្រាវជ្រាវនិងការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ២) ការរៀបចំមណ្ឌលចំណេះដឹងអំពីការអភិវឌ្ឍមូលដ្ឋាន និង ៣) ការលើកកម្ពស់សមត្ថភាពនវានុវត្តន៍
- ពង្រឹងការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ តាមរយៈ១) ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សានីតិកម្មនិងអង្គភាពរៀបចំគោលនយោបាយ ២) ការផ្តល់គោលការណ៍ណែនាំតម្រង់ទិសដល់ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាបាននូវការរៀបចំតាក់តែងច្បាប់និងលិខិតបទដ្ឋានទាំងនោះស្របតាមទម្រង់ នីតិវិធីដែលមានកំណត់ និងមានសង្គតិភាព និង៣) ការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងក្របខ័ណ្ឌគតិយុត្តចាំបាច់នានាដែលបម្រើឱ្យតម្រូវការនៃការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ព្រមទាំងត្រួតពិនិត្យនិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- ពង្រឹងការអនុវត្តការងារសវនកម្មផ្ទៃក្នុងការធ្វើអធិការកិច្ច និងដោះស្រាយបណ្តឹងក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃឱ្យបានត្រឹមត្រូវ តម្លាភាព និងប្រសិទ្ធភាព តាមរយៈ ១) ការរៀបចំនិងការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឱ្យបានទៀងទាត់និងតាមភាពចាំបាច់និងលើកកម្ពស់គុណភាពសវនកម្មផ្ទៃក្នុងនៅតាមបណ្តាអង្គភាពនានា ក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ លើកអនុសាសន៍និងតាមដានការអនុវត្តតាមអនុសាសន៍របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ២) ការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកជំនាញសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ និង៣) ការលើកកម្ពស់សុចរិតភាព ការធ្វើអធិការកិច្ច និងការដោះស្រាយបណ្តឹងនៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

**ទី៣- ក្រសួងការពារជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់កងយោធពលខេមរភូមិន្ទ តាមរយៈការអនុវត្តយុទ្ធសាស្ត្រ៣ សកម្មភាពប្រតិបត្តិការ និងការអភិវឌ្ឍ១០ ព្រមទាំងធ្វើបច្ចុប្បន្នកម្មនិងជំរុញអនុវត្តផែនការយុទ្ធសាស្ត្រជាតិក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធភាពលើការបំពេញតួនាទីរបស់កងកម្លាំងប្រដាប់អាវុធ

- អភិវឌ្ឍធនធានមនុស្សនិងបង្កើនសមត្ថភាពកម្លាំងប្រដាប់អាវុធ តាមរយៈការធ្វើទំនើបកម្ម ការបំពាក់បច្ចេកវិទ្យាសមស្រប និងបង្កើនគុណភាពហ្វឹកហ្វឺន ជាពិសេសការបណ្តុះបណ្តាលយោធិនអាជីព និងការកសាងជួរកងកម្លាំងប្រដាប់អាវុធវ័យក្មេង ដើម្បីបន្តវេន និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត
- បន្តផ្តល់ការយកចិត្តទុកដាក់អតីតយុទ្ធជន យោធិនពិការ គ្រួសារយោធិនពលីមរណៈ និងគ្រួសារកងទ័ពនៃកងកម្លាំងប្រដាប់អាវុធ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសតាមរយៈការបន្តផ្តល់និងការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសម្បទានដីសង្គមកិច្ច និងគម្រោងអភិវឌ្ឍន៍សម្រាប់សហគមន៍ គ្រួសារកងទ័ព និងកម្លាំងប្រដាប់អាវុធនៅតាមបន្ទាត់ព្រំដែន
- លើកកម្ពស់កិច្ចសហប្រតិបត្តិការកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រវាងកងកម្លាំងប្រដាប់អាវុធជាមួយក្រសួង ស្ថាប័ន ព្រមទាំងបន្តពង្រឹងប្រពៃណីនៃទំនាក់ទំនងរវាងកងកម្លាំងប្រដាប់អាវុធនិងប្រជាជន ជាពិសេសតាមរយៈការធ្វើអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ការបំពេញប្រតិបត្តិការមនុស្សធម៌ ការជួយបង្កបង្កើនផល និងការរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ
- អភិវឌ្ឍធនធានមនុស្សក្នុងកងយោធពលខេមរភូមិន្ទលើជំនាញអាជីពវិស័យកសិកម្ម(ដាំដុះ ចិញ្ចឹមសត្វ និងជំនាញដែលអាចបង្កើតរបរផ្ទាល់ខ្លួន) សិប្បកម្ម ឧស្សាហកម្មធុនមីក្រូ តូច និងមធ្យម រ៉ែ ព័ត៌មានវិទ្យា ដើម្បីឱ្យអង្គភាពទ័ពនិងសហគមន៍កងទ័ព សំដៅបង្កើនចំណូល និងលើកកម្ពស់សុខុមាលភាពសហគមន៍កងទ័ព
- បង្កើតកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ស្ថាប័នរដ្ឋ និងឯកជននានា ដើម្បីអភិវឌ្ឍផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍ ចែករំលែកព័ត៌មាននិងបទពិសោធឱ្យបានទាន់ពេល។

**ទី៤- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្ត ឱ្យស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ ដើម្បីធ្វើឱ្យរដ្ឋបាលខេត្តក្លាយជារដ្ឋបាលមានភាពរឹងមាំ វៃឆ្លាត ខ្លាំង និងស្អាតស្អំ
- ពង្រឹងនិងពិនិត្យវាយតម្លៃលើការរៀបចំរចនាសម្ព័ន្ធនិងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ឱ្យស្របតាមចរិតលក្ខណៈជារដ្ឋបាលទីប្រជុំជននិងតំបន់ជនបទ និងស្របតាមស្ថានភាពភូមិសាស្ត្រប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ច
- រៀបចំបង្កើតនិងដាក់ឱ្យអនុវត្តនូវអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពបរិវត្តកម្មឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងកិច្ចសហការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីកៀរគរធនធានគាំទ្រ និងការចូលរួមដល់ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- បន្តសហការនិងសម្របសម្រួលជាមួយការកែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល ដើម្បីធានាដល់ការគាំទ្រគ្នាទៅវិញទៅមក ធ្វើឱ្យមានសង្គតិភាព និងសុខដុមនីយកម្ម តាមអភិក្រម «**ជវភាពក្នុងប្រព័ន្ធតួអង្គតែមួយ**»
- បន្តពង្រឹងនិងពង្រីកការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។

### ៣.១.២- ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

គោលដៅជាយុទ្ធសាស្ត្រនៃការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ គឺការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញ ឆន្ទៈ ម្ចាស់ការ និងក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតួនាទីនិងការទទួលខុសត្រូវ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ក្នុងមុខងារសាធារណៈ ផ្អែកលើគុណាធិបតេយ្យ ក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់និងឋានន្តរសក្តិ និងការផ្តល់ការលើកទឹកចិត្តសមស្រប ព្រមទាំងការរៀបចំប្រព័ន្ធអភិវឌ្ឍសមត្ថភាពគ្រប់ជ្រុងជ្រោយ។

ទី២- ការរៀបចំ ប្រព័ន្ធបៀវត្ស និងប្រព័ន្ធលើកទឹកចិត្ត ក្នុងវិស័យសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើគុណាធិបតេយ្យ សំដៅលើកកម្ពស់ផលិតភាពការងារ សមិទ្ធកម្ម និងជីវភាពមន្ត្រីសាធារណៈ ឱ្យមានសង្គតិភាព ជាមួយកំណើនសេដ្ឋកិច្ចនិងលទ្ធភាពនៃថវិកាជាតិ។

ទី៣- ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវ ក្នុងការជ្រើសរើស ការគ្រប់គ្រងការចាត់ចែង និងការប្រើប្រាស់បុគ្គលិក។

ទី៤- ការបន្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើននូវភាពជឿទុកចិត្តនៃថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម សំដៅកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ។

ទី៥- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុនិងការរៀបចំផែនការ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាធនធានថវិកាសមស្រប សម្រាប់បំពេញមុខងារនិងអាទិភាពគោលនយោបាយ ដូចមានកំណត់ក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិកា។

ទី៦- ការបន្តជំរុញការធ្វើទំនើបកម្មនិងការប្រើប្រាស់មូលដ្ឋានទិន្នន័យ និងការចែករំលែកនិងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងមុខងារសាធារណៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងប្រព័ន្ធគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្ស ទាំងជំនាញរឹងនិងទន់ក្នុងវិស័យមុខងារសាធារណៈឱ្យមានសមត្ថភាពខ្ពស់ និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់លើកកម្ពស់ផលិតភាពនិងប្រសិទ្ធភាពការងារ
- រៀបចំប្រព័ន្ធបៀវត្សនិងប្រព័ន្ធលើកទឹកចិត្តក្នុងវិស័យសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពមន្ត្រី និងការលើកកម្ពស់សមិទ្ធកម្ម និងរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងរដ្ឋបាលសាធារណៈ ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ ជាពិសេសក្នុងវិស័យអប់រំនិងសុខាភិបាល
- ពង្រឹងនិងពង្រីកភាពជាដៃគូក្នុងក្របខ័ណ្ឌលើកកម្ពស់សមត្ថភាពធនធានមនុស្ស ជាមួយក្រសួងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- កែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ផ្អែកលើគុណាធិតេយ្យ ព្រមទាំងពិនិត្យឡើងវិញនិងវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន
- រៀបចំនិងដាក់ឱ្យអនុវត្តយន្តការពង្រាយមន្ត្រីរាជការ បន្ថែមលើការប្រើប្រាស់ធនធានមនុស្សដែលមានស្រាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- អភិវឌ្ឍកម្មវិធីសិក្សា ជំរុញការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារ តាមរយៈការបង្កើនការរៀបចំវគ្គបណ្តុះបណ្តាល ការបង្កើនកម្មវិធីទស្សនកិច្ចសិក្សា និងសកម្មភាពសង្គមផ្សេងៗ។

**ទី២- ក្រសួងមហាផ្ទៃ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញកិច្ចសហប្រតិបត្តិការ និងពង្រឹងពង្រីកភាពជាដៃគូរជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សាជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- ពង្រឹងការគ្រប់គ្រងធនធានមនុស្សស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា។

**ទី៣- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងនិងលើកកម្ពស់ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំបុគ្គលិកឱ្យបានសមស្របតាមតម្រូវការជាក់ស្តែង មានសមត្ថភាព ជំនាញវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខខណ្ឌការងារច្បាស់លាស់សម្រាប់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សានិងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងនិងការបណ្តុះបណ្តាលបុគ្គលិកតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដឹកនាំនិងសម្របសម្រួលក្នុងការសិក្សានិងការកំណត់អំពីគោលនយោបាយសម្រាប់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទាក់ទាញនិងធានាឱ្យមានបុគ្គលិកមានសមត្ថភាព បទពិសោធ និងជំនាញវិជ្ជាជីវៈ សម្រាប់បំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល
- ពង្រឹងនិងធ្វើទំនើបកម្មការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យការផ្តល់សេវាមានភាពសាមញ្ញ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ គណនេយ្យភាព តម្លាភាព និងភាពជឿទុកចិត្ត
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការគាំទ្រ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ លើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.១.៣- ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

គោលដៅជាយុទ្ធសាស្ត្រ គឺការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំ ភាពសុចរិត និងជំនឿទុកចិត្តចំពោះរដ្ឋបាលសាធារណៈ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការរៀបចំនិងការដាក់ឱ្យអនុវត្ត ក្រមសីលធម៌វិជ្ជាជីវៈនិងក្រមប្រតិបត្តិ ក្នុងមុខងារសាធារណៈ ព្រមទាំងការជំរុញការគោរពខ្ជាប់ខ្ជួននូវគោលការណ៍វិសមិតភាពមុខងារនិងទំនាស់ផលប្រយោជន៍ នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ។

ទី២- ការពង្រឹងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចនិងសវនកម្ម ព្រមទាំងការរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធអធិការកិច្ចនិងសវនកម្ម ដើម្បីធានាសុខដុមនីយកម្មនៃមុខងារអធិការកិច្ចនិងសវនកម្មក្នុងរដ្ឋបាលសាធារណៈ។

ទី៣- ការពង្រឹងយន្តការគ្រប់គ្រងនិងផ្តល់សេវាសាធារណៈ ការផ្តល់ការលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់ ក្នុងការអនុវត្តតួនាទីនិងភារកិច្ច ដើម្បីបង្កើនជំនឿទុកចិត្តនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ទី៤- ការបន្តពង្រឹងនិងពង្រីកការងារអប់រំ និងបង្ការទប់ស្កាត់ជាចម្បង ព្រមទាំងការពង្រឹងការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ ដើម្បីបង្ក្រាបបទល្មើសអំពើពុករលួយ។

ទី៥- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងអំពើពុករលួយនិងស្ថាប័នសាធារណៈ ជាពិសេសតាមរយៈយន្តការជនបង្គោល ទាំងការងារអប់រំនិងការងារបង្ការទប់ស្កាត់ ដើម្បីរៀបចំដាក់ឱ្យអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការលើកកម្ពស់ភាពស្អាតស្អំនៅតាមស្ថាប័នសាធារណៈ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពដូចតទៅ៖

**ទី១- ក្រសួងមុខងារសាធារណៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈនិងក្រមប្រតិបត្តិ ក្នុងមុខងារសាធារណៈ ព្រមទាំងពង្រឹងយន្តការគ្រប់គ្រងនិងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ
- បញ្ជ្រាបនិងពង្រឹងភាពស្អាតស្អំ ជំរុញការគោរពខ្ជាប់ខ្ជួនគោលការណ៍វិសមិតភាពមុខងារនិងទំនាស់ផលប្រយោជន៍ក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ និងចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់ក្នុងការអនុវត្តតួនាទីនិងភារកិច្ច ដើម្បីបង្កើនជំនឿទុកចិត្តនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ
- រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា ដោយផ្អែកលើគុណាធិបតេយ្យ និងប្រកបដោយតម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព
- រៀបចំនិយាមនីតិវិធីប្រតិបត្តិសម្រាប់គ្រប់គ្រងសេវាសាធារណៈ ដែលកំណត់អំពីរបៀបរបបការងារ ពេលវេលាឆ្លើយតប ឯកសារតម្រូវ ដើម្បីជានាភាពរលូន ទាន់ពេល និងស្អាតស្អំជូនដល់មន្ត្រីរាជការថ្នាក់ជាតិនិងក្រោមជាតិ
- ពង្រឹងកិច្ចការអធិការកិច្ចមុខងារសាធារណៈ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងដោះស្រាយបញ្ហាប្រឈមនានាឱ្យមានប្រសិទ្ធភាព។

**ទី២- ក្រសួងអធិការកិច្ច** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធ្វើអធិការកិច្ចលើគ្រប់វិស័យនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងអភិបាលកិច្ចនិងលើកកម្ពស់ភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ
- តាមដាននិងជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីសម្រេចផ្សេងៗរបស់ប្រមុខរាជរដ្ឋាភិបាល នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាស

សាធារណៈ គ្រឹះស្ថានសាធារណរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញប្រសិទ្ធភាពការងារ

- ពង្រឹងយន្តការពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ានិងបណ្តឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន និងយន្តការនៃការទទួលបណ្តឹងអនឡាញ ក្នុងដែនសមត្ថកិច្ចរាជរដ្ឋាភិបាលដោយឈរលើយុទ្ធសាស្ត្រឈ្នះ ឈ្នះ សំដៅថែរក្សាបរិយាកាសសុខដុមនីយកម្មក្នុងសង្គមជាតិ ពង្រឹងយន្តការវេទិកាសាធារណៈ កម្មវិធីអប់រំ ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជូនប្រជាពលរដ្ឋ
- អភិវឌ្ឍលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច មានជាអាទិ៍ សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច សេចក្តីព្រាងច្បាប់ស្តីពីបណ្តឹងតវ៉ានិងបណ្តឹងបរិហារ សេចក្តីព្រាងគោលនយោបាយជាតិអធិការកិច្ច សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច សេចក្តីព្រាងស្តង់ដាប្រតិបត្តិអធិការកិច្ច សេចក្តីព្រាងគោលការណ៍ណែនាំនៃការចុះអង្កេតស្រាវជ្រាវ និងដោះស្រាយបណ្តឹង សេចក្តីព្រាងក្រមសីលធម៌មន្ត្រីអធិការកិច្ច សេចក្តីព្រាងក្រមសីលធម៌មន្ត្រីទទួល និងដោះស្រាយបណ្តឹង និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

**ទី៣- ក្រសួងមហាផ្ទៃ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពពាក់ព័ន្ធនឹងការពង្រឹងនិងការកែលម្អយន្តការនិងនីតិវិធីទទួលដោះស្រាយបណ្តឹង និងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការចូលរួមនិងការជឿទុកចិត្តមកលើការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវា តាមរយៈយន្តការគណនេយ្យភាពសង្គម យន្តការផ្តល់ព័ត៌មាន និងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ។

**ទី៤- អង្គភាពប្រឆាំងអំពើពុករលួយ** បន្តអនុវត្តសកម្មភាពអាទិភាព៖

- បង្កើនចំណេះដឹង សមត្ថភាពដល់ក្រុមជនបង្គោលនិងការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត លើការងារអប់រំ បង្ការ ទប់ស្កាត់អំពើពុករលួយ
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការសកម្មភាពស្អាតស្អំ ព្រមទាំងដាក់ចេញផែនការសកម្មភាពស្អាតស្អំតាមស្ថាប័នសាធារណៈ(ឬ ផែនការសកម្មភាពរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ស្ថាប័នសាធារណៈ និងការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត)
- បន្តអនុវត្តយន្តការត្រួតពិនិត្យអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយនៅកម្ពុជា និងការអនុវត្តគោលនយោបាយប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

### ៣.១.៤- ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌

គោលដៅជាយុទ្ធសាស្ត្រនៃការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌ គឺការពង្រឹងគោលការណ៍នីតិរដ្ឋ ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម និងការពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យយុត្តិធម៌ ដែលជាកត្តារួមចំណែកដ៏សំខាន់ ក្នុងការធានាបាននូវការថែរក្សាស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ និងភាពសុខដុមរមនា ក្នុងសង្គមជាតិ។ ក្រសួង ស្ថាប័ន ត្រូវ

រៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស ក្នុងវិស័យយុត្តិធម៌ ទាំងបរិមាណនិងគុណភាព ដើម្បីបង្កើនប្រសិទ្ធភាពការងារ ក្នុងវិស័យយុត្តិធម៌ និងប្រសិទ្ធភាពនិងភាពរហ័ស នៃការដោះស្រាយវិវាទ ទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ។

ទី២- ការលើកកម្ពស់ប្រសិទ្ធភាព សង្គតិភាព និងអនុលោមភាពគតិយុត្តនៃការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សំដៅជានាឆ្លើយតបទៅនឹងចក្ខុវិស័យនិងសេចក្តីត្រូវការនានារបស់សង្គមជាតិ។

ទី៣- ការលើកកម្ពស់ការគោរពច្បាប់និងការផ្តល់សេវាជំនួយផ្នែកច្បាប់ តាមរយៈការបន្តជំរុញការអប់រំនិងការផ្សព្វផ្សាយច្បាប់ ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្តល់ការការពារក្តី នៅចំពោះមុខតុលាការ សំដៅជានាសិទ្ធិទទួលបានយុត្តិធម៌ ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ។

ទី៤- ការលើកកម្ពស់ភាពត្រឹមត្រូវនិងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេសការពង្រឹងប្រសិទ្ធភាពនៃចំណាត់ការលើសំណុំរឿង ការពង្រឹងភាពសុចរិតភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈ របស់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ ព្រមទាំងការពង្រឹង យន្តការអធិការកិច្ច និងការដាក់វិន័យ សំដៅបង្កើនជំនឿទុកចិត្តលើការអនុវត្តច្បាប់។

ទី៥- ការលើកកម្ពស់ គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែល្អប្រសើរ និងការពង្រឹងគុណភាពនៃយុត្តិធម៌។

ទី៦- ការជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រុះសម្រួលនិងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ ប្រសិទ្ធភាព និងភាពរហ័ស នៃការដោះស្រាយវិវាទ និងបង្ខិតសេវានៃការដោះស្រាយវិវាទ ឱ្យកៀកនឹងប្រជាពលរដ្ឋ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន២ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងយុត្តិធម៌** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- កសាងនិងធ្វើទំនើបកម្មច្បាប់ក្នុងវិស័យយុត្តិធម៌ ដោយបន្តរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗ ដែលជាសេចក្តីត្រូវការចាំបាច់ក្នុងវិស័យយុត្តិធម៌ ពិនិត្យឡើងវិញដើម្បីធ្វើទំនើបកម្មនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យយុត្តិធម៌ និងបន្តរៀបចំក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ដំណើរការតុលាការជំនាញផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងបរិបទនៃឌីជីថលូបនីយកម្ម ព្រមទាំងបន្តធ្វើការពិនិត្យនិងសិក្សារៀបចំសេចក្តីព្រាងសន្ធិសញ្ញា និង

កិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនទៀតក្នុងវិស័យព្រហ្មទណ្ឌនិងវិស័យរដ្ឋប្បវេណី ក៏ដូចជារៀបចំសេចក្តីព្រាងច្បាប់និងព្រាងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀតតាមការចាំបាច់

- លើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការរៀបចំក្របខ័ណ្ឌច្បាប់ និងយន្តការសម្រុះសម្រួលនិងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាពនិងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ ការជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ការបង្កិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួលនិងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋ និងការធានាបាននូវបរិយាកាសសន្តិភាពនិយមនិងភាពសុខដុមរមនាក្នុងសង្គមជាតិ
- ត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ តាមរយៈការពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធតុលាការ ដែលជាគោលដៅចម្បងមួយនៃការកែទម្រង់វិស័យយុត្តិធម៌និងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ និងការលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ
- ជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ តាមរយៈការដោះស្រាយរឿងក្តីដោយតុលាការឱ្យបានឆាប់រហ័សនិងដោយយុត្តិធម៌ ដែលជាអាទិភាពដ៏សំខាន់ក្នុងការងារការកែទម្រង់ប្រព័ន្ធតុលាការ សំដៅលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័ស ងាយស្រួល និងត្រឹមត្រូវតាមនីតិវិធីច្បាប់
- លើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ដោយកសាងនិងពង្រឹងធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ទាំងលើបរិមាណនិងគុណភាព ជាមូលដ្ឋានគ្រឹះសម្រាប់ឆ្លើយតបនឹងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងគុណភាពការងារនៅក្នុងប្រព័ន្ធយុត្តិធម៌ តាមរយៈការពង្រឹងគុណភាពនិងប្រសិទ្ធភាពបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ការពង្រឹងវិន័យ និងក្រមសីលធម៌សម្រាប់មន្ត្រីយុត្តិធម៌ ពង្រឹងយន្តការនិងការលើកទឹកចិត្តដល់មន្ត្រីដែលមានស្នាដៃក្នុងការអនុវត្តការងារប្រកបដោយតម្លាភាព ការបន្តរៀបចំបណ្តុះបណ្តាលនូវលិខិតបទដ្ឋានថ្មីៗដល់មន្ត្រីយុត្តិធម៌ និងការបន្តកិច្ចសហការជាមួយដៃគូសហប្រតិបត្តិការអន្តរជាតិលើគម្រោងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យច្បាប់និងយុត្តិធម៌
- លើកកម្ពស់ការយល់ដឹងអំពីច្បាប់នៅក្នុងសង្គម តាមរយៈការលើកកម្ពស់ «វប្បធម៌នៃការគោរពច្បាប់» ដែលជាគ្រឹះនៃ«សង្គមនីតិរដ្ឋ» ស្របតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ
- លើកកម្ពស់ការផ្តល់ជំនួយផ្នែកច្បាប់ តាមរយៈការធានាសិទ្ធិទទួលបានយុត្តិធម៌ដល់ប្រជាពលរដ្ឋគ្រប់រូបដោយស្មើភាពគ្នាចំពោះមុខច្បាប់ ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះនៅក្នុងសង្គម ដោយរៀបចំយន្តការផ្តល់ការពិគ្រោះប្រឹក្សាយោបល់និងអប់រំផ្សព្វផ្សាយច្បាប់តាមប្រព័ន្ធឌីជីថល រៀបចំយន្តការពិគ្រោះយោបល់ផ្នែកច្បាប់នៅតាមសាលាជម្រះក្តី បន្ត

រៀបចំយន្តការមេធាវីស្ម័គ្រចិត្តការពារក្តីសម្រាប់ជនក្រីក្រឱ្យបានទាន់ពេលវេលាឆាប់រហ័ស ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ សិក្សានិងវាយតម្លៃការផ្តល់សេវាជំនួយផ្នែកច្បាប់ និងការផ្តល់សេវាការពារក្តីនៅចំពោះមុខតុលាការ ព្រមទាំងបង្កើតយន្តការតាមដាន វាយតម្លៃ និងពង្រឹងក្រមសីលធម៌និងក្រមប្រតិបត្តិដល់អ្នកផ្តល់សេវាពិគ្រោះយោបល់និងអ្នកផ្តល់សេវាការពារក្តីសម្រាប់ជនក្រីក្រ

- ដាក់ដំណើរការតុលាការជំនាញ តាមរយៈការដាក់ឱ្យដំណើរការនូវតុលាការជំនាញពិសេស តុលាការពាណិជ្ជកម្មនិងតុលាការការងារ ដែលជាសេចក្តីត្រូវការចាំបាច់ក្នុងការងារកែទម្រង់ប្រព័ន្ធតុលាការ សំដៅលើកកម្ពស់គុណភាពនៃការដោះស្រាយរឿងក្តីប្រកបដោយប្រសិទ្ធភាព ជំនឿទុកចិត្ត និងភាពឆាប់រហ័ស ក៏ដូចជាអាចឆ្លើយតបបានទៅនឹងសំណូមពរនៃការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនិងធុរកិច្ចនៅកម្ពុជា។

**ទី២- ទីស្តីការគណៈរដ្ឋមន្ត្រី** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពៈ

- ដឹកនាំនិងអនុវត្តការដ្ឋានការកែទម្រង់ច្បាប់ ដើម្បីបង្កើតភាពរឹងមាំ ច្បាស់លាស់ និងការជឿទុកចិត្តពីប្រជាពលរដ្ឋសម្រាប់រយៈពេលវែង សំដៅធានាការពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋនិងការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** ឱ្យមានប្រសិទ្ធភាពនិងជោគជ័យ
- បង្កើតយន្តការតាមដាននិងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់ក្រសួង ស្ថាប័ន ដើម្បីធានាគណនេយ្យភាពនិងប្រសិទ្ធភាពខ្ពស់
- បង្កើតប្រព័ន្ធត្រួតពិនិត្យសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ រួមទាំងប្រព័ន្ធឃ្លាំងទិន្នន័យ និងប្រព័ន្ធផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលមានលក្ខណៈទំនើប និងឌីជីថល សំដៅពង្រឹងប្រសិទ្ធភាពនៃការតាក់តែងនិងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា
- ពង្រឹងយន្តការនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដោយ ***ម្ខាង*** ផ្តោតលើការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដល់ក្រុមការងារការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័ន និង ***ម្ខាងទៀត*** តម្រូវឱ្យក្រសួង ស្ថាប័នភ្ជាប់មកជាមួយនូវរបាយការណ៍ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅពេលលើកការស្នើពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ក្របខ័ណ្ឌគោលនយោបាយ/យុទ្ធសាស្ត្រ និងឯកសារពាក់ព័ន្ធ
- រៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** ព្រមទាំងអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ របស់ក្រសួង ស្ថាប័ន គណៈកម្មាធិការ ក្រុមប្រឹក្សា និងអាជ្ញាធរ ដែលជាអង្គភាពអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** និងរៀបចំរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល

- ស្រាវជ្រាវ តាមដាន វិភាគ និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាប្រចាំ ដើម្បីផ្តល់បច្ច័យគោលនយោបាយជាក់លាក់ តាមរយៈការវិភាគស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយ តាមបែបវិទ្យាសាស្ត្រ (Evidence-based Policy Implications) និងរៀបចំរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល
- បង្កើតនិងពង្រឹងប្រព័ន្ធគ្រប់គ្រងបណ្ណសារសាធារណៈឱ្យសមស្របតាមលក្ខណៈបច្ចេកទេសសមរម្យ និងលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីសាធារណៈ អំពីសារៈសំខាន់នៃការគ្រប់គ្រងបណ្ណសារសាធារណៈ ព្រមទាំងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងបណ្ណសារសាធារណៈនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.១.៥- ការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច

គោលដៅជាយុទ្ធសាស្ត្រនៃការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច គឺការពង្រឹងជំនឿទុកចិត្តរបស់តួអង្គពាក់ព័ន្ធមកលើវិស័យឯកជននិងធុរកិច្ច តាមរយៈការជំរុញឱ្យមានអភិបាលកិច្ចល្អក្នុងវិស័យឯកជន និងធុរកិច្ច។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងនិងការលើកកម្ពស់ អភិបាលកិច្ចល្អក្នុងវិស័យឯកជននិងធុរកិច្ច តាមរយៈការរៀបចំនិងការដាក់ចេញក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ លិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំពាក់ព័ន្ធចាំបាច់នានា ក្នុងវិស័យឯកជននិងធុរកិច្ច។

ទី២- ការជំរុញការរៀបចំនិងការដាក់ឱ្យអនុវត្ត ក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គមនិងបរិស្ថានរបស់វិស័យឯកជននិងធុរកិច្ច ដើម្បីបង្កើនការចូលរួមដោះស្រាយបញ្ហាសង្គម និងលើកកម្ពស់តម្លៃសីលធម៌សង្គមនិងវប្បធម៌ជាតិ និងការថែរក្សាបរិស្ថាន ដោយផ្តល់នូវយន្តការគាំទ្រនិងលើកទឹកចិត្តសមស្រប ដល់ធុរកិច្ចទាំងឡាយណា ដែលអនុវត្តបាននូវអភិបាលកិច្ចល្អនិងមានការទទួលខុសត្រូវខ្ពស់ផ្នែកសង្គមនិងបរិស្ថាន។

ទី៣- ការពិនិត្យឡើងវិញ ការធ្វើបច្ចុប្បន្នកម្ម ការកែលម្អ និងការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងការពិនិត្យនិងការដាក់ចេញនូវយន្តការពង្រឹងការអនុវត្តច្បាប់

ទី៤- ការជំរុញការរៀបចំនិងការផ្តល់ការគាំទ្រ ដល់វិស័យឯកជននិងអង្គការសង្គមស៊ីវិល ក្នុងការរៀបចំក្រមសីលធម៌និងវិជ្ជាជីវៈនិងលើកទឹកចិត្តឱ្យមានការរៀបចំស្តង់ដាគុណវុឌ្ឍិសម្រាប់គណៈគ្រប់គ្រងនៃវិស័យឯកជននិងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនការទទួលខុសត្រូវផ្ទាល់ខ្លួននិងកាត់បន្ថយទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួននិងផលប្រយោជន៍សាធារណៈ។

ទី៥- ការបង្កើនប្រសិទ្ធភាពយន្តការសន្ទនានិងភាពជាដៃគូ រវាងរដ្ឋនិងឯកជន ក្នុងកម្រិតគោលនយោបាយនិងបច្ចេកទេស ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការពិភាក្សាផ្នែកគោល

នយោបាយ និងការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្ម ទាំងក្នុងនិងក្រៅស្រុក និងតួអង្គពាក់ព័ន្ធ។

ទី៦- ការបង្កើនប្រសិទ្ធភាពនិងតម្លាភាព នៃអធិការកិច្ចវិស័យឯកជននិងធុរកិច្ច តាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការធ្វើអធិការកិច្ច ការពង្រឹងសមត្ថភាព និងភាពសុចរិតរបស់អ្នកធ្វើអធិការកិច្ចនិងការជំរុញការអនុវត្តវិធានការអធិការកិច្ច។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៥ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

- បន្តពង្រឹងនិងពង្រីកថ្នាលនៃយន្តការសន្ទនានៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន និងបន្តសម្របសម្រួលរៀបចំវេទិកានេះឱ្យបានយ៉ាងហោចណាស់២លើក ក្នុងមួយអាណត្តិ ព្រមទាំងតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការដែលអង្គវេទិកាបានដាក់ចេញនិងរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាលរៀងរាល់៦ខែម្តង
- បន្តរៀបចំកិច្ចប្រជុំនិងកិច្ចសន្ទនារវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ដូចជាកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា ជប៉ុន ក្រោមកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងជប៉ុនស្តីពីសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ និងក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិក ជាដើម
- ជំរុញចលនការនៃយន្តការសេវាថៃទាំវិនិយោគឱ្យកាន់តែមានភាពសកម្ម មុតស្រួច និងចំគោលដៅព្រមទាំងធានាបាននូវភាពសុខដុមរបស់វិស័យឯកជននៅកម្ពុជា។

**ទី២- ក្រសួងពាណិជ្ជកម្ម** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច និងបង្កើនជំនឿចិត្តរបស់ភាគីពាក់ព័ន្ធ តាមរយៈការអភិវឌ្ឍនិងការធ្វើវិសោធនកម្មច្បាប់ ព្រមទាំងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម
- បន្តសម្របសម្រួលនិងផ្តល់ការគាំទ្រដល់វិស័យឯកជន ដើម្បីបង្កើនប្រសិទ្ធភាពរបស់វិស័យនេះ ដោយជំរុញការលើកកម្ពស់សមត្ថភាពជំនាញ និងការទទួលខុសត្រូវរបស់សភាពាណិជ្ជកម្ម សម្ព័ន្ធអាជីវកម្ម សមាគមធុរកិច្ច ព្រមទាំងពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធជាមួយវិស័យឯកជន
- បន្តអនុវត្តភាពជាដៃគូរវាងរដ្ឋនិងឯកជនក្នុងកម្រិតនយោបាយនិងបច្ចេកទេស ដើម្បីអភិវឌ្ឍវិស័យឯកជន តាមរយៈការបង្កើនប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហានិងការបង្កើតគំនិតផ្តួចផ្តើម

ថ្មីៗនៅក្នុងយន្តការកិច្ចសន្ទនានិងភាពជាដៃគូរវាងរដ្ឋនិងឯកជន នៅថ្នាក់ជាតិនិងក្រោមជាតិ សំដៅសម្រួលពាណិជ្ជកម្ម ក៏ដូចជាធ្វើពិពិធកម្មទំនិញនិងទីផ្សារ។

**ទី៣- ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

- បន្តអនុវត្តនិងពង្រឹងការគ្រប់គ្រងវិស័យឧស្សាហកម្ម កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម បច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម និងផលិតភាព ស្របតាមច្បាប់លិខិតបទដ្ឋានគតិយុត្ត តម្រូវការ និងការឆ្លើយតបនឹងការរីកចម្រើននៃវិស័យឧស្សាហកម្ម សំដៅជំរុញការជឿទុកចិត្តពីវិស័យឯកជននិងធុរកិច្ច
- ពង្រឹងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ពិសេសការចុះបញ្ជី ការគ្រប់គ្រង ការសម្របសម្រួលចាំបាច់នានា និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដើម្បីទាក់ទាញសហគ្រាស និងសិប្បកម្មឱ្យចុះបញ្ជី និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាល ក្នុងការរៀបចំគោលនយោបាយគាំទ្រនានាដល់សហគ្រាសទាំងនោះ ក៏ដូចជាអនុញ្ញាតឱ្យសហគ្រាសដែលបានចុះបញ្ជីអាចទទួលបានព័ត៌មានអំពីផលប្រយោជន៍ផ្សេងៗ និងការពិគ្រោះយោបល់ផ្នែកធុរកិច្ចសម្រាប់ពង្រីកសកម្មភាពនិងការវិនិយោគរបស់ខ្លួន
- ជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួម ដោយថ្នក់ភ្ជាប់ជាមួយនឹងថ្នាលCamDX សម្រាប់ការស្នើសុំបើកអាជីវកម្មផ្សេងៗនៅថ្នាក់ក្រោមជាតិ ការចុះបញ្ជីពន្ធដារនិងការចុះបញ្ជិកា នៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងប.ស.ស. ព្រមទាំងរៀបចំទម្រង់បែបបទនិងនីតិវិធីបច្ចេកទេសនៃការផ្តល់សេវាជាកញ្ចប់ឱ្យមានស្តង់ដា ដោយមានការសម្រួលនីតិវិធីនិងកាត់បន្ថយបន្ទុកចំណាយទាំងពេលនិងថវិកា
- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំផែនការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម
- ពង្រឹងការអនុវត្តប្រតិភូកម្មអំណាចលើការចុះបញ្ជីឬបង្កើត និងវិញ្ញាបនបត្រអនុញ្ញាត ដំណើរការសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មរបស់មន្ទីររាជធានី ខេត្ត។

**ទី៤- អង្គភាពប្រឆាំងអំពើពុករលួយ** បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជនបន្ថែម តាមរយៈការបន្តចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រុមហ៊ុនថ្មីៗទៀត ដើម្បីបញ្ជ្រាបការប្រឆាំងអំពើពុករលួយទៅក្នុងវិស័យឯកជន ក៏ដូចជាដើម្បីពង្រឹងតម្លាភាពនិងសុចរិតភាពក្នុងការអនុវត្តធុរកិច្ចនៅកម្ពុជា ដោយពង្រឹងការផ្តល់សេវាសាធារណៈរបស់ស្ថាប័នរដ្ឋនិងអាជ្ញាធរ ជូនក្រុមហ៊ុន។

**ទី៥- គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** សម្របសម្រួលនិងពិនិត្យលទ្ធភាពផ្គួបបញ្ចូលគ្នានូវលិខិតអនុញ្ញាត អាជ្ញាបណ្ណ និងវិញ្ញាបនបត្រ ដែលមានតម្លៃប្រហាក់ប្រហែលគ្នា ឬមិនមានតម្លៃ

បន្ថែមខ្ពស់ ព្រមទាំងរៀបចំដាក់បញ្ចូលសេវាទាំងនេះទៅក្នុងយន្តការចុះបញ្ជីអាជីវកម្មតាមថ្នាលCamDX សំដៅបង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចក្នុងការចូលរួមកែលម្អបរិយាកាសធុរកិច្ចក្នុងប្រទេស។

## ៣.២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

### ៣.២.១- ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលកត្តាទាំងនេះជាបុរេលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការការពារ ឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី មិនឱ្យមានការលូកដៃជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ព្រមទាំងការទប់ស្កាត់និងការប្រឆាំងដាច់ខាត រាល់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ឬការញុះញង់ណាមួយ ដើម្បីបង្កអស្ថិរភាពនយោបាយឬចលាចលក្នុងសង្គម។

ទី២- ការបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស វប្បធម៌សន្តិភាព សីលធម៌សង្គម ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបន្តពង្រឹងបរិយាកាសល្អនិងប្រក្រតីភាពរឹងមាំ ក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ។

ទី៣- ការបន្តដោះស្រាយបញ្ហាព្រំដែនគោកនិងសមុទ្រ ជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ ក៏ដូចជាការបន្តរៀបចំនិងការជំរុញ អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់គោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង។

ទី៤- ការទប់ស្កាត់និងការបង្រ្កាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អំពើជួញដូរមនុស្ស ការជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ បទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ការប្រយុទ្ធប្រឆាំងសកម្មភាពពាក់ព័ន្ធនឹងការជួញដូរនិងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ល្បែងស៊ីសងខុសច្បាប់ ព្រមទាំងការបន្តពង្រឹង ការអនុវត្ត«**គោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព**»។

ទី៥- ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍និងសណ្តាប់ធ្នាប់តាមដងផ្លូវ តាមទីក្រុង និងទីប្រជុំជន ដើម្បីដោះស្រាយការកកស្ទះចរាចរណ៍ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ សំដៅកាត់បន្ថយថ្លៃនានា និងបង្កើនការធ្វើសុភបរមូបនីយកម្មផលសេដ្ឋកិច្ច។

ទី៦- ការបន្តជំរុញកិច្ចប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវ«**កម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥** និងកាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា»។

ទី៧- ការបង្ការនិងការដោះស្រាយបញ្ហាអគ្គិភ័យនិងគ្រោះថ្នាក់នានាក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាពជូនប្រជាជន ខណៈមានការកើនឡើងនៃនគរូបនីយកម្ម ប្រជាជននៅទីប្រជុំជន និងការអភិវឌ្ឍសំណង់អគារខ្ពស់ៗ។

ទី៨- ការបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសញ្ជាតិ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ការបន្តជំរុញរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការនានា ដើម្បីធានាថា«**មនុស្សម្នាក់មានអត្តសញ្ញាណតែមួយ**» និង»**មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ**» ការគ្រប់គ្រងការចេញ ចូលកម្ពុជា ការគ្រប់គ្រងការស្នាក់នៅនិងការប្រកបមុខរបររបស់ជនបរទេស និងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍ សំដៅបង្ការនិងទប់ស្កាត់ការលបលួចជ្រៀតចូល ការស្នាក់នៅ និងការប្រកបមុខរបរដោយខុសច្បាប់។

ទី៩- ការពង្រឹងការអនុវត្តច្បាប់និងការកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទី១០- ការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦ ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យប្រជាជន រៀបចំឱ្យប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណបុគ្គល និងជំរុញការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន១១ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តការពារប្តូរផ្តាច់នូវសន្តិភាព អធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី និងប្រឆាំងនឹងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងពីគ្រប់រូបភាព
- បន្តចូលរួមសហការដោះស្រាយបញ្ហាព្រំដែនគោកនិងសមុទ្រ ជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ ក៏ដូចជាបន្តរៀបចំនិងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។

**ទី២- ក្រសួងការពារជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងខ្សែរយៈចាត់តាំងក្នុងកងកម្លាំងប្រដាប់អាវុធ ជាពិសេសក្នុងជួរកងទ័ពនៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង
- ផ្តល់សម្ភារៈបច្ចេកទេសចាំបាច់និងលើកកម្ពស់សុខុមាលភាពរបស់កងទ័ព ជាពិសេស បង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់និងការគ្រប់គ្រងភស្តុភារហិរញ្ញវត្ថុ សម្រាប់បណ្តាកងឯកភាពដែលឈរជើងនៅតាមខ្សែត្រៀមជួរមុខ និងការពារដែនកោះ
- ពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធលើគ្រប់ផ្នែក ព្រមទាំងបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

- បន្តការអភិវឌ្ឍលើវិស័យឧស្សាហកម្មយោធា ដែលជាកត្តាចាំបាច់ក្នុងការធ្វើទំនើបកម្មយោធា សំដៅធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព ឯករាជ្យភាព វឌ្ឍនភាព និងការកាត់បន្ថយការចំណាយលើការទិញពីបរទេស។

**ទី៣- ក្រសួងមហាផ្ទៃ** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តការពារសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី និងខឿនសន្តិសុខជាតិ តាមរយៈវិធានការចាំបាច់នានា ព្រមទាំងបន្តរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេសការពង្រឹងការអនុវត្តគោលនយោបាយ **ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព**
- ពង្រឹងនិងអភិវឌ្ឍនគរបាល តាមរយៈការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងលើកកម្ពស់សមត្ថភាពមន្ត្រីនគរបាល ការពង្រឹង និងការលើកកម្ពស់យន្តការគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យការងារនគរបាល ការសិក្សាស្រាវជ្រាវ ការពង្រឹង និងការពង្រីកកម្លាំងបង្អែកនៅមូលដ្ឋាន និងការជំរុញការកសាងប្រព័ន្ធទទួលនិងផ្ដល់ព័ត៌មាន(E-Police) សម្រាប់បង្កើនទំនាក់ទំនងរវាងមន្ត្រីនគរបាលនិងប្រជាជន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមប៉ុស្តិ៍នគរបាល ប៉ុស្តិ៍ការពារច្រកព្រំដែន អធិការដ្ឋាននគរបាល និងមន្ទីរពេទ្យ១៦ ឧសភា ដើម្បីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ
- ពង្រឹងការគ្រប់គ្រងច្រកទ្វារព្រំដែន ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ ការលើកកម្ពស់ការផ្ដល់សេវាអន្តោប្រវេសន៍ និងការពង្រឹងពង្រីកចំណងមិត្តភាព សហប្រតិបត្តិការជាតិ អន្តរជាតិ
- ពង្រឹងការគ្រប់គ្រងពន្ធនាគារតាមស្តង់ដាច្បាស់លាស់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសុខភាពជនជាប់ឃុំ ព្រមទាំងអភិវឌ្ឍជំនាញវិជ្ជាជីវៈ ផ្ដល់សេវាអប់រំកែប្រែ ស្តារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ជនជាប់ឃុំនិងធ្វើសមាហរណកម្មជនដែលត្រូវបានដោះលែងឱ្យបានល្អសមរម្យទៅក្នុងសហគមន៍វិញ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ និងការបំពាក់នូវឧបករណ៍សម្ភារៈឱ្យស្របតាមស្តង់ដាពន្ធនាគារ ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព និងសុខភាព ស្របតាមគោលការណ៍មនុស្សធម៌។

**ទី៤- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តដោះស្រាយបញ្ហាព្រំដែនគោកនិងសមុទ្រ ជាមួយប្រទេសជិតខាងដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ ក៏ដូចជាបន្តរៀបចំនិងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ
- បន្តចរចា វាស់វែងខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក កំណត់ព្រំដែនសមុទ្រ និងការផលិតផែនទីព្រំដែន អភិរក្ស និងថែរក្សាបង្គោលព្រំដែន និងបរិវេណបង្គោលព្រំដែន ព្រមទាំងបន្តការងារសាងសង់ផ្លូវក្រវាត់ព្រំដែន។

**ទី៥- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បន្តអនុវត្តយុទ្ធសាស្ត្រចំនួន៦ ឱ្យបានជោគជ័យ រួមមាន ១) កាត់បន្ថយតម្រូវការគ្រឿងញៀន ២) កាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ៣) ពង្រឹងប្រសិទ្ធភាព

ព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម ៤) ពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ៥) ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និង៦) ពង្រឹងយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**ទី៦- លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពចម្បងៗមួយចំនួន រួមមានការងារប្រឆាំងភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ការងារយុទ្ធសាស្ត្រជាតិក្នុងការប្រឆាំងភេរវកម្ម ការងារសមយុទ្ធ ការងារប្រមូលព័ត៌មានសម្ងាត់ និងចំហ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រទេសនិងក្រៅប្រទេស ពាក់ព័ន្ធនឹងអំពើភេរវកម្ម និងការរួមចំណែកក្នុងការរក្សានិងការពារសន្តិសុខសុវត្ថិភាពជូនជាតិនិងប្រជាពលរដ្ឋ។

**ទី៧- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពៈ

- រៀបចំផែនការបោសសម្អាតមីន និងអនុវត្តយន្តការភូមិអស់មីនឱ្យមានប្រសិទ្ធភាពនិងជោគជ័យ ព្រមទាំងរៀបចំការស្នើសុំពន្យារពេលបញ្ចប់ការបោសសម្អាតមីនប្រឆាំងមនុស្សទៅគណៈកម្មការពាក់ព័ន្ធនៃអនុសញ្ញាអូតាវ៉ា
- រៀបចំគោលនយោបាយជាតិនិងយុទ្ធសាស្ត្រនានា សម្រាប់គ្រប់គ្រងសំណល់ជាតិផ្ទុះពីសង្គ្រាមហានិភ័យ និងក្រោយអស់ការគម្រាមដោយសារមីន ព្រមទាំងបន្តចូលរួមចែករំលែកបទពិសោធលើវិស័យសកម្មភាពមីន
- បន្តចលនាកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ ប្រទេសជាមិត្ត អ្នកវិនិយោគិន និងសប្បុរសជននានាដើម្បីរួមចំណែកដល់ការងារសកម្មភាពមីន និងការបោសសម្អាតមីន
- បន្តចូលរួមអនុវត្តអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់ ការលុបបំបាត់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ដោយត្រូវចូលរួមក្នុងកិច្ចប្រជុំនានា និងរៀបចំរបាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាល
- បន្តសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការអប់រំផ្សព្វផ្សាយកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនិងរៀបចំឯកសារគតិយុត្ត និងគោលនយោបាយ ដើម្បីជួយលើកកម្ពស់សិទ្ធិនិងជីវភាពរបស់ជនមានពិការភាពដោយសារមីន។

**ទី៨- មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន** ផ្តោតការអនុវត្តសកម្មភាពអាទិភាពលើការប្រយុទ្ធប្រឆាំងអំពើភេរវកម្មនិងឧក្រិដ្ឋកម្មនៅកម្ពុជាតាមប្រព័ន្ធព័ត៌មានវិទ្យានិងឌីជីថល ការបង្ការនិងការទប់ស្កាត់ចលនាវិទ្ធង្សនា ចលនាជ្រុលនិយម ការផ្សព្វផ្សាយព័ត៌មានមិនពិត និងការបំផុសញុះញង់បង្កចលាចលសង្គមប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ គ្រប់គ្រង និងការពារសន្តិសុខបច្ចេកវិទ្យា ការកសាងនិងការពង្រឹងសមត្ថភាពធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធកម្លាំងសន្តិសុខក្នុងវិស័យបច្ចេកវិទ្យាទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការការងារសន្តិសុខក្នុងវិស័យបច្ចេកវិទ្យាជាមួយបណ្តាដៃគូ ទាំងក្នុងនិងក្រៅប្រទេស។

**ទី៩- ក្រសួងព័ត៌មាន** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំសណ្តាប់ធ្នាប់អ្នកសារព័ត៌មានដោយអនុវត្តពេញលេញនូវធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានក្នុងការបំពេញភារកិច្ចជាអ្នកសារព័ត៌មានអាជីពប្រកបដោយភាពបុរេសកម្ម អន្តរសកម្ម និងប្រសិទ្ធភាព
- ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តដែលមានធរមាន ដើម្បីជំរុញប្រសិទ្ធភាពការផ្សព្វផ្សាយប្រកបដោយបរិយាបន្ន
- រៀបចំយុទ្ធនាការរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ដោយកំណត់នូវយន្តការជាក់លាក់ក្នុងការដោះស្រាយ
- បណ្តុះបណ្តាលជំនាញដល់មន្ត្រីរាជការនិងអ្នកសារព័ត៌មានលើបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនគុណភាព និងសក្តិសិទ្ធភាពក្នុងការងារព័ត៌មាន និងសាធារណមតិឱ្យស្របតាមបរិបទសង្គម និងនិម្មាបនកម្មសកល
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រងព័ត៌មាន និងសាធារណមតិ ដោយធ្វើការផ្សព្វផ្សាយគ្រប់ទម្រង់ ជាពិសេសតាមប្រព័ន្ធទូរទស្សន៍ឌីជីថល និងវិទ្យុឌីជីថល និងពង្រីកវិសាលភាពការផ្សាយ និងឆ្លើយតបឱ្យទាន់ពេលទៅនឹងរាល់ព័ត៌មានអវិជ្ជមាន ប្រកបដោយស្មារតីបុរេសកម្ម និងសហថាមពល សំដៅការពារសមិទ្ធផល ស្នាដៃ និងកេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាល
- ជំរុញសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាព ផ្លាស់ប្តូរបទពិសោធ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យព័ត៌មាន។
- និពន្ធអត្ថបទ រៀបចំកិច្ចសម្ភាសន៍ និងផលិតវីដេអូ សារសំឡេង រូបភាព ព្រឹត្តិបត្រព័ត៌មានស្តីពីគោលនយោបាយ យុទ្ធសាស្ត្រ សកម្មភាព និងសមិទ្ធផលរបស់រាជរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយឱ្យបានលឿនរហ័សនិងមានប្រសិទ្ធភាព។

**ទី១០- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** ផ្តោតលើការជំរុញការអនុម័តច្បាប់ស្តីពីសន្តិសុខសាយប័រ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការរៀបចំប្រព័ន្ធគ្រប់គ្រងសន្តិសុខសាយប័រ និងការជំរុញការបណ្តុះបណ្តាល និងការបញ្ជ្រាបការយល់ដឹងអំពីសន្តិសុខសាយប័រជាដើម។

**ទី១១- គណៈកម្មការសន្តិសុខឌីជីថល** ដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គសង្គមទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព ឆ្លើយតបទាំងផ្នែកបច្ចេកទេស និងកម្លាំងពាក់ព័ន្ធនឹងការធានានិងការពារសន្តិសុខឌីជីថល។

### ៣.២.២- ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងឈ្លាសវៃ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់ ក្នុងកិច្ចការពារ និងក្នុងការជំរុញបង្កើនផលប្រយោជន៍ស្នូលរបស់ជាតិ និងការកសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយប្រទេសទាំងអស់នៅលើសកលលោក និងអង្គការអន្តរជាតិនានា ព្រមទាំងការចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាព ក្នុងតំបន់ និងសកលលោក ស្របតាមអភិក្រម«**រក្សាចាស់ បង្កើតថ្មី**»។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

- ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ និងគោរពដាច់ខាតនូវអធិបតេយ្យ បូរណភាពទឹកដី និងឯករាជ្យរបស់រដ្ឋសមាជិក អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងគោលការណ៍ដែលទទួលស្គាល់ជាសកល
- ការបន្តប្រកាន់គោលការណ៍មិនគាំទ្រការប្រើប្រាស់ឬការគំរាមប្រើប្រាស់កម្លាំង ក្នុងទំនាក់ទំនងអន្តរជាតិ ការឈ្លានពានប្រឆាំងរដ្ឋឯករាជ្យ ការបំបែករដ្ឋ ការកាត់យកទឹកដីពីរដ្ឋអធិបតេយ្យ និងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃ ព្រមទាំងការបន្តប្រកាន់ជំហរម៉ឺងម៉ាត់ ក្នុងការមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសក្នុងទឹកដីកម្ពុជា
- ការបន្តប្រកាន់គោលការណ៍អព្យាក្រឹតអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ និងការអនុវត្តការទូតទន់ភ្លន់ ប៉ុន្តែម៉ឺងម៉ាត់ បត់បែន និងថ្លឹងថ្លែង ស្របតាមការផ្លាស់ប្តូរផ្នែកយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយ ក្នុងតំបន់ និងសកលលោក
- ការបន្តតម្កល់ផលប្រយោជន៍ស្នូលរបស់ជាតិជាចម្បង ក្នុងការអនុវត្តគោលនយោបាយការបរទេសដែលចូលរួមចំណែកដល់ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចសម្រាប់លើកកម្ពស់ជីវភាពប្រជាជន និងការលើកតម្កើងកិត្យានុភាពនិងឧត្តមភាពជាតិ ទាំងក្នុងក្របខ័ណ្ឌតំបន់និងសកលលោក
- ការលើកកម្ពស់ទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ដើម្បីសម្រេចចក្ខុវិស័យប្រែក្លាយព្រំដែនទៅជាតំបន់សន្តិភាព ស្ថិរភាព និងការរីកចម្រើន ទន្ទឹមនឹងការបន្តពង្រឹងនិងពង្រីកទំនាក់ទំនងជាមួយដៃគូយុទ្ធសាស្ត្រនានា ទាំងក្នុងនិងក្រៅតំបន់
- ការបន្តពង្រឹងតួនាទីរបស់កម្ពុជានៅក្នុងអាស៊ាន តាមរយៈការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីស្ថាបនានៅក្នុងការងាររក្សាសាមគ្គីភាពផ្ទៃក្នុងអាស៊ាន និងការធ្វើសមាហរណកម្មតំបន់ស្របតាមធម្មនុញ្ញអាស៊ាន ជាពិសេសការធ្វើការសម្រេចចិត្តនានាដោយផ្អែកលើការពិភាក្សា និងយន្តការកុងសង់ស៊ីស និងដោយមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសសមាជិក

- ការបន្តពង្រឹងពហុភាគីនិយម តាមរយៈការចូលរួមសកម្មក្នុងវេទិកាតំបន់និងអន្តរជាតិ ការរួមចំណែកក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ការចូលរួមរក្សាស្ថិរភាព និងសន្តិភាព ដោយលើកតម្កើងកិច្ចសន្ទនា និងការដោះស្រាយបញ្ហាដោយសន្តិវិធី និងការលើកស្ទួយពាណិជ្ជកម្មពហុភាគីដែលសេរី បើកចំហ និងផ្អែកលើវិធាននៃច្បាប់
- ការបន្តអនុវត្តគោលនយោបាយការបរទេសពហុវិមាត្រ និងពហុសណ្ឋាន សំដៅបង្កើនប្រសិទ្ធភាពក្នុងកិច្ចការពារ និងការជំរុញផលប្រយោជន៍ជាតិ ដោយចូលរួមយ៉ាងសកម្មក្នុងវិស័យពាក់ព័ន្ធដែលបង្កើតឱ្យមានសហថាមពលក្នុងការបង្កើនអំណាចចរចានិងសំដៅឆ្លើយតបទាន់ពេល ដើម្បីពង្រីកលំហបត់បែនយុទ្ធសាស្ត្រ នៅក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិ
- ការបន្តពង្រឹង ជំនឿពីអន្តរជាតិ និងការយល់ឃើញត្រឹមត្រូវមកលើកម្ពុជា ជាពិសេសអំពីស្ថានភាពពិតនិងជាក់ស្តែងរបស់កម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយដៃគូ កិត្យានុភាព និងការផ្សព្វផ្សាយកម្ពុជាជាសកល សំដៅបង្កើនភាពទាក់ទាញនិងលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចការវិនិយោគ និងទេសចរណ៍
- ការបន្តធ្វើការកែទម្រង់ស្ថាប័ននិងបណ្តុះបណ្តាលធនធានមនុស្ស ក្នុងកិច្ចការការបរទេសឱ្យមានសមត្ថភាពខ្ពស់ ជំនាញគ្រប់គ្រាន់ និងភាពប៉ិនប្រសប់ សម្រាប់ការពារប្រយោជន៍ស្នូលរបស់ជាតិ។

### ៣.២.៣- ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយ បរិយាបន្ន ភាពធន់ និងចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីធានាបានចីរភាពនៃកំណើនប្រកបដោយបរិយាបន្ន តាមរយៈការគ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតសមស្រប ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ការបង្កីនទុនបម្រុងរបស់ជាតិ និងការរក្សាលំនឹងជីវភាពប្រជាជន។

ទី២- ការកែទម្រង់កាន់តែស៊ីជម្រៅនិងមុតស្រួច ពិសេសចំពោះបញ្ហាប្រឈមដែលមានចរិតជារចនាសម្ព័ន្ធនិងអន្តរស្ថាប័ន សំដៅលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច បង្កីនផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា។

ទី៣- ការរក្សាចីរភាពហិរញ្ញវត្ថុសាធាណៈ តាមរយៈការបន្តជំរុញអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើការពង្រឹងការប្រមូលចំណូលនិងការបង្កើនប្រសិទ្ធភាពចំណាយ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព ការជំរុញអភិវឌ្ឍយន្តការកៀរគរហិរញ្ញប្បទាន ពីប្រភពធនធានក្នុងស្រុកនិងការពង្រីកលំហថវិកាជាតិជាលំដាប់។

ទី៤- ការពង្រឹង ស្ថិរភាព និងភាពធន់ហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ពិសេសតាមរយៈការអភិវឌ្ឍបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុ( Financial Safety Net) និងការជំរុញភាពស៊ីជម្រៅហិរញ្ញវត្ថុ( Financial Deepening)។

ទី៥- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងតំបន់និងសកលលោក សំដៅរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ កៀរគរធនធាន និងអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ។

ទី៦- ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្ន ដើម្បីពង្រឹងភាពធន់នៃសង្គម សេដ្ឋកិច្ច។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ពិសេសកំណត់នូវគោលជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយស្មារតីប្រយ័ត្នប្រយែង ដោយធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងចីរភាពហិរញ្ញវត្ថុសាធារណៈ
- ជំរុញការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ ដោយត្រូវមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការ និងសន្ទុះនៃសកម្មភាពសេដ្ឋកិច្ច ក៏ដូចជាការផ្តល់នូវភាពត្រឹមត្រូវ តម្លាភាព និងភាពយុត្តិធម៌ ក្នុងការវាយតម្លៃពន្ធ ដល់អ្នកបង់ពន្ធ និងដោយត្រូវផ្តោតលើប្រភពចំណូលដែលជាសក្តានុពល និងដែលមិនបង្កផលប៉ះពាល់ធំដុំដល់សេដ្ឋកិច្ច
- បន្តនូវភាពប្រយ័ត្នប្រយែង និងបុរេសកម្មខ្ពស់ ក្នុងការអនុវត្តចំណាយថវិកា ដោយឈរលើគោលការណ៍វិន័យ និងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ ពោលគឺចាយឱ្យចំទិសដៅ និងផ្តោតលើតម្លៃនៃថវិកា
- រៀបចំវិធានការសំដៅពង្រឹងប្រាក់សន្សំរបស់រាជរដ្ឋាភិបាលឡើងវិញ ដើម្បីត្រៀមទប់ទល់នឹងវិបត្តិនាពេលអនាគត តាមរយៈការចាប់ផ្តើមដាក់ឱ្យអនុវត្តនូវមូលនិធិបម្រុងហិរញ្ញវត្ថុ ដែលជាមូលនិធិប្រាក់សន្សំរបស់រដ្ឋ
- បន្តគ្រប់គ្រងស្ថានភាពបំណុលសាធារណៈប្រកបដោយវិន័យនិងប្រសិទ្ធភាពខ្ពស់ តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍វិន័យគន្លឹះ ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០២៤-២០២៨

- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈការអនុវត្តវិធានការ និងផែនការសកម្មភាពដែលមានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥
- បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ដោយផ្តោតលើគណនេយ្យភាពសមិទ្ធកម្ម ក្នុងស្មារតីពង្រឹងប្រសិទ្ធភាព គុណភាព និងការទទួលខុសត្រូវលើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ
- ជំរុញការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ និងមានវិសាលភាពគ្របដណ្តប់ទាំងវិស័យសាធារណៈនិងឯកជន ដោយផ្តោតលើការកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធគាំពារសង្គម ការបង្កើនប្រសិទ្ធភាពចំណាយថវិការដ្ឋ ការពង្រីកវិសាលភាពគ្របដណ្តប់ជាអតិបរមា និងការពិនិត្យបញ្ហាឆ្លងវិស័យ
- ជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០។

**ទី២- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** បន្តលើកកម្ពស់ប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូប្រកបដោយបរិយាបន្នជាមួយតួអង្គអភិវឌ្ឍទាំងអស់ ដោយឈរលើគោលការណ៍ស្មើភាព និងការគោរពគ្នាទៅវិញទៅមក ទន្ទឹមនឹងការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍជាតិ និងបន្តលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ទាំងនេះ។

**ទី៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងអនុវត្តកម្មវិធីជាតិជំនួយសង្គមជាកញ្ចប់គ្រួសារប្រកបដោយសុតបរមា ព្រមទាំងបន្តរៀបចំនិងពង្រឹងកម្លាំងសេវាសង្គមក្នុងក្របខ័ណ្ឌជំនួយសង្គមឱ្យបានទូលំទូលាយ និងប្រកបដោយសមត្ថភាព ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់ជំនួយសង្គម
- ពង្រឹងប្រព័ន្ធអភិបាលកិច្ចរបស់មូលនិធិជាតិជំនួយសង្គមឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព ដោយធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ពង្រឹងប្រសិទ្ធភាពនៃសេវារដ្ឋបាល និងអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្ស ពង្រឹងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន ធនាគារ និងអង្គការដៃគូ និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ គណនេយ្យ ការធ្វើសវនកម្ម និងអធិការកិច្ចការអនុវត្តកម្មវិធីគាំពារសង្គម។

**ទី៤- អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បន្តអភិវឌ្ឍសេវាហិរញ្ញវត្ថុមិនមែនធនាគារឱ្យកាន់តែប្រសើរ ព្រមទាំងសិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍ស្តីពីស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារជាប្រចាំ ដែលជាធាតុចូលមួយសម្រាប់ការបន្តរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដំណាក់កាលទី១ ដែលនឹងរំលេចអំពីប្រភេទហានិភ័យចម្បងៗ នៃអនុវិស័យហិរញ្ញវត្ថុ មិនមែនធនាគារ រួមទាំងភាពប្រទាក់ក្រឡានៃហានិភ័យជាប្រព័ន្ធ។

### ៣.២.៤- ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ននិងស័ក្តិសិទ្ធិភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ននិងស័ក្តិសិទ្ធិភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជាភាពចាំបាច់សម្រាប់បង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយ បរិយាបន្ន ភាពធន់ និងចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការរៀបចំនិងការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨**» ដើម្បីពង្រឹងភាពជាដៃគូ ប្រកបដោយបរិយាបន្ន។

ទី២- ការកៀរគរ ការសម្របសម្រួល និងការគ្រប់គ្រង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ពីគ្រប់ប្រភពនិងការតម្រឹមធនធាន ជាមួយអាទិភាពជាតិ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន។

ទី៣- ការបង្កើនប្រសិទ្ធភាពនៃការអនុវត្ត យន្តការ និងឧបករណ៍នានានៃភាពជាដៃគូដែលមានស្រាប់ និងអាចបង្កើតថ្មីបន្ថែមទៀត ក្នុងករណីចាំបាច់ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិសនិងបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន។

ទី៤- ការបន្តដំណើរការសមាហរណកម្មនិងទំនាក់ទំនង នៅក្នុងតំបន់និងសកលលោក តាមរយៈយន្តការ វិធានការ កម្មវិធី និងគំនិតផ្តួចផ្តើមនានា ដើម្បីលើកកម្ពស់កិត្យានុភាពនិងផលប្រយោជន៍កម្ពុជា ក៏ដូចជាដើម្បីបង្កើនកាលានុវត្តភាព សម្រាប់ការអភិវឌ្ឍនិងទំនុកចិត្តលើបរិយាកាសវិនិយោគ ធុរកិច្ច និងពាណិជ្ជកម្មនៅកម្ពុជា ដោយឈរលើគោលការណ៍«**ស្មើសិទ្ធិនិងស្មើភាព**»។

ទី៥- ការបន្តអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ទី៦- ការបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើនកិច្ចសហការក្នុងភាពជាដៃគូ ប្រកបដោយសុខដុមនីយកម្ម ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

#### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ដើម្បីបន្តពង្រឹងភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍជាតិ ក៏ដូចជាបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្នជាមួយតួអង្គអភិវឌ្ឍទាំងអស់
- បន្តកៀរគរ សម្របសម្រួល និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ពីគ្រប់ប្រភពនិងតម្រឹមធនធានទាំងនោះប្រកបដោយសុភបរមា ជាមួយអាទិភាពអភិវឌ្ឍន៍ជាតិ
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តយន្តការនិងឧបករណ៍សម្របសម្រួលភាពជាដៃគូដែលមានស្រាប់ ឬអាចបង្កើតថ្មីបន្ថែមទៀត ក្នុងករណីចាំបាច់ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិស និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន
- បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការអនុវត្តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីបង្កើនកិច្ចសហការក្នុងភាពជាដៃគូ ប្រកបដោយសុខដុមនីយកម្ម ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពិនិត្យឡើងវិញនូវតួនាទីរបស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឆ្លើយតបនឹងការប្រែប្រួលឆាប់រហ័សនៃបរិការណ៍ និងនិម្នាបនកម្មអភិវឌ្ឍន៍សកលនិងក្នុងប្រទេស ក៏ដូចជារចនាសម្ព័ន្ធនៃលំហូរហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍកម្ពុជា
- បន្តចូលរួមក្នុងវេទិកាអន្តរជាតិស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍ និងបន្តអនុវត្តរួមគ្នាជាមួយបណ្តាតួអង្គអភិវឌ្ឍនូវការប្តេជ្ញានានា ស្របតាមបរិការណ៍កម្ពុជា និងយន្តការពិគ្រោះយោបល់ដែលមានស្រាប់របស់រាជរដ្ឋាភិបាល។

**ទី២- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអនុវត្តកិច្ចសហប្រតិបត្តិការល្អ ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ដើម្បីផលប្រយោជន៍ជាតិ តាមរយៈការបង្កបរិយាកាសអំណោយផលសម្រាប់ការចុះបញ្ជីថ្មី ក៏ដូចជាការបន្តសុពលភាពអង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅជានាដល់ការបំពេញបេសកកម្មប្រកបដោយតម្លាភាព និងជួយរួមចំណែកដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា
- បន្តប្រើប្រាស់មធ្យោបាយការទូត ដើម្បីរឹតបន្តឹង និងពង្រីកចំណងសេដ្ឋកិច្ចជាមួយដៃគូបរទេស ក៏ដូចជាទាញយកកាលានុវត្តភាពចេញពីកិច្ចសហប្រតិបត្តិការពហុភាគី តាមរយៈការកៀរគរទុនវិនិយោគបរទេស ភ្ញៀវទេសចរអន្តរជាតិ និងការផ្សព្វផ្សាយពង្រីកទីផ្សារថ្មី ដើម្បីបង្កើនការនាំចេញរបស់កម្ពុជា ព្រមទាំងបន្តអនុវត្តការទូតវប្បធម៌ រួមមានការផ្សព្វផ្សាយអំពីវប្បធម៌ អរិយធម៌ សិល្បៈ និងម្ហូបអាហារក្នុងស្មារតីបង្កើតនិងបង្កើនអំណាចទន់ និងការស្គាល់កម្ពុជាលើឆាកអន្តរជាតិ។

**ទី៣- វេទិកាសម្ព័ន្ធសង្គមស៊ីវិល**(វ.ស.ស.) ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាញអង្គការសង្គមស៊ីវិលតាមរាជធានី ខេត្ត តាមវិស័យ និងសមាជិកដៃគូ និងអង្គការសង្គមស៊ីវិលទូទៅ ព្រមទាំងបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលនៃបណ្តាប្រទេសជាមិត្ត ដើម្បីកៀរគរជំនួយនិងធនធានហិរញ្ញវត្ថុសម្រាប់ជួយដល់អង្គការសង្គមស៊ីវិលដៃគូក្នុងស្រុក ក៏ដូចជាការរឹតចំណងសាមគ្គីភាពរវាងប្រជាជន និងប្រជាជននៃបណ្តាប្រទេសជាមិត្ត
- ធ្វើការស្រាវជ្រាវនិងធ្វើចំណាត់ថ្នាក់ និងប្រភេទអង្គការសង្គមស៊ីវិលក្នុងស្រុក ព្រមទាំងបន្តពង្រឹងសមត្ថភាពស្ថាប័ន វ.ស.ស. តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពមន្ត្រី ការបញ្ជូនមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលនានា ទាំងក្នុងនិងក្រៅប្រទេស និងការលើកទឹកចិត្តមន្ត្រីផ្អែកលើគុណាធិបតេយ្យ
- បន្តអនុវត្តគម្រោងដែលមានស្រាប់ និងស្វែងរកដៃគូអភិវឌ្ឍ ដើម្បីអនុវត្តគម្រោងថ្មីបន្ថែម
- ស្វែងរកប្រភពមូលនិធិ ដើម្បីជួយអង្គការសង្គមស៊ីវិលដៃគូសហការនានា ដើម្បីជួយដល់ការអនុវត្តគម្រោងតូចៗឱ្យមានលទ្ធភាពបន្តសកម្មភាព។

### ៣.២.៥- ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងសកលលោក

ការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងសកលលោក បង្កើតនូវកាលានុវត្តភាព ក្នុងការជំរុញនិងការគាំទ្រពាណិជ្ជកម្មអន្តរជាតិ និងការទាក់ទាញការវិនិយោគ ក៏ដូចជាការចូលរួមកាន់តែជ្រៅទៅក្នុងខ្សែប្រវាក់តម្លៃនិងការផ្គត់ផ្គង់ ក្នុងតំបន់និងជាសកល សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជានិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ប្រកបដោយចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តចរចាបើកទីផ្សារសក្តានុពលថ្មី ទាំងទ្វេភាគីនិងពហុភាគី ឱ្យមានលក្ខណៈកាន់តែទូលំទូលាយនិងឈានដល់កម្រិតខ្ពស់ថ្មីមួយបន្ថែមទៀត និងការចរចាកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្តោតជាពិសេសលើកិច្ចព្រមព្រៀងទ្វេភាគីដែលត្រូវបានទទួលស្គាល់ថាជាយន្តការមានប្រសិទ្ធភាពនិងសក្តានុពលខ្ពស់ សំដៅបង្កើនពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ។

ទី២- ការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាព ដើម្បីជំរុញសមាហរណកម្មកម្ពុជាឱ្យកាន់តែស៊ីជម្រៅ តាមរយៈយន្តការពហុភាគីនិងទ្វេភាគី ដែលមានស្រាប់ សំដៅពង្រីកការតភ្ជាប់កម្ពុជាប្រកបដោយប្រពលភាពជាមួយខ្សែប្រវាក់តម្លៃនិងផ្គត់ផ្គង់ក្នុងតំបន់និងសកលលោក។

ទី៣- ការរៀបចំវិធានការគោលនយោបាយ សម្រាប់កាត់បន្ថយថ្លៃពាណិជ្ជកម្មនិងថ្លៃពាក់ព័ន្ធនានា និង លុបបំបាត់របាំងពាណិជ្ជកម្មដែលមិនចាំបាច់ ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ព្រមទាំងការអភិវឌ្ឍ និងការលើកកម្ពស់អនុលោមភាពស្តង់ដា និងបទប្បញ្ញត្តិរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ពិសេស ឧស្សាហកម្មវ័យក្មេងនិងថ្មីៗ ដែលមានសក្តានុពលនាំចេញ និងភាពប្រកួតប្រជែងខ្ពស់។

ទី៤- ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើមអន្តរជាតិសំខាន់ៗ និងការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលមានលក្ខណៈសកល ឈរលើគោលការណ៍បើកចំហ តម្លាភាព បរិយាបន្ន និងការប្រកួតប្រជែងស្មើភាព។

ទី៥- ការពង្រឹងនិងការពង្រីក កិច្ចសហការនិងការសម្របសម្រួលរវាងក្រសួង ស្ថាប័នសាធារណៈ និងគ្រប់តួអង្គអភិវឌ្ឍផ្សេងទៀត ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងពង្រីកសមត្ថភាពឧស្សាហកម្ម និងពាណិជ្ជកម្ម ស្របតាមនិន្នាការតំបន់និងសកល ពិសេសការតភ្ជាប់ផលិតកម្មក្នុងស្រុកទៅនឹងទីផ្សារ ផលិតផលអន្តរជាតិ។

ទី៦- ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការត្រៀមខ្លួន ក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍ តិចតួច ដោយរលូននិងរឹងមាំ និងក្របខ័ណ្ឌគោលនយោបាយតម្រង់ទិសសមាហរណកម្មសេដ្ឋកិច្ច ប្រកបដោយយុទ្ធសាស្ត្រ សម្រាប់រយៈពេលវែង ដោយត្រូវបន្តចរចាក្នុងរយៈពេលអន្តរកាល ដើម្បីទទួលបាន ភាពអនុគ្រោះថ្មីៗ សំដៅរក្សាលំនឹងទីផ្សារនាំចេញនិងទីផ្សារថ្មីៗ សម្រាប់ផលិតផលកម្ពុជា។

### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័ន ទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងពាណិជ្ជកម្ម** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងអនុតំបន់ តំបន់ និងពិភពលោក ដោយប្រឹងប្រែង ពង្រឹងទីផ្សារចាស់និងពង្រីកទីផ្សារថ្មីៗ តាមរយៈការចាប់ដៃគូពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអាស៊ាន អាស៊ានជាមួយដៃគូនិងអាសិប ព្រមទាំងបន្តសម្របសម្រួលសហការធ្វើពាណិជ្ជកម្មតាមព្រំដែន ជាមួយប្រទេសជិតខាងនិងដៃគូពាណិជ្ជកម្មអន្តរជាតិផ្សេងទៀត សំដៅធានាបាននូវភាពប្រសើរ ឡើងនៃតុល្យភាពជញ្ជីងពាណិជ្ជកម្ម ក៏ដូចជាអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀង ពាណិជ្ជកម្មទ្វេភាគី ពហុភាគី ដែលមានស្រាប់ ព្រមទាំងរៀបចំការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្ម ថ្មីៗទៀត
- បន្តអនុវត្តកាតព្វកិច្ចស្របតាមកិច្ចសន្យារបស់រាជរដ្ឋាភិបាល ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្ម ពិភពលោក តាមរយៈការខិតខំប្រឹងប្រែងរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត កែទម្រង់ គោលនយោបាយពាណិជ្ជកម្ម និងយន្តការអនុវត្តនីតិវិធីទាក់ទងនឹងវិស័យពាណិជ្ជកម្ម ស្របតាម កិច្ចព្រមព្រៀងនិងលិខិតុបករណ៍អន្តរជាតិនានា សំដៅគាំទ្រការរីកចម្រើននៃប្រព័ន្ធពាណិជ្ជកម្ម

ពហុភាគីនិយម ដើម្បីធានារំហូរពាណិជ្ជកម្មដោយសេរី ជំរុញការរីកចម្រើនសេដ្ឋកិច្ចសកល ចូលរួមបង្កើនការងារ និងកាត់បន្ថយភាពក្រីក្រ

- ចូលរួមការអនុវត្តយុទ្ធសាស្ត្រសម្រាប់ត្រៀមខ្លួនជាស្រេចក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច តាមរយៈការបង្កើនភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម ការធ្វើពិពិធកម្មទីផ្សារ ការធ្វើពិពិធកម្មទំនិញ ការបង្កើនគុណភាពផលិតផល និងការជំរុញបង្កើតមុខទំនិញថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនិងលក្ខខណ្ឌតម្រូវនៃទីផ្សារ និងបន្តជំរុញអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ ដើម្បីជំនួសប្រព័ន្ធអនុគ្រោះនានា ដែលអាចនឹងត្រូវបាត់បង់នៅក្រោយពេលចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួចនិងជំរុញបង្កើតក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មកម្ពុជា។

**ទី២- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពិនិត្យលទ្ធភាពក្នុងការចុះអនុស្សរណៈយោគយល់គ្នាស្តីពីការផ្សព្វផ្សាយនិងការជំរុញវិនិយោគទៅវិញទៅមក ឬកិច្ចព្រមព្រៀងស្តីពីការជំរុញនិងការការពារវិនិយោគរវាងកម្ពុជានិងប្រទេសជាដៃគូថ្មីផ្សេងទៀត ដើម្បីបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការវិនិយោគក្នុងក្របខ័ណ្ឌទ្វេភាគី
- បន្តចូលរួមចំណែកក្នុងការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ ក្រោមក្របខ័ណ្ឌអាស៊ាន ដើម្បីជំឡើងកម្រិតនៃការប្តេជ្ញាបើកចំហទីផ្សាររបស់អាស៊ាននិងរបស់ដៃគូពាណិជ្ជកម្មអាស៊ាន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់រវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន ព្រមទាំងបន្តការចរចាបើកចំហទីផ្សារថ្មីក្រោមក្របខ័ណ្ឌអាស៊ាន
- បន្តចូលរួមក្នុងសកម្មភាពនានារបស់អាស៊ានពាក់ព័ន្ធនឹងការវិនិយោគ ដូចជាការចូលរួមពិនិត្យនិងធ្វើរបាយការណ៍វិនិយោគអាស៊ានប្រចាំឆ្នាំ និងការរៀបចំវេទិកាវិនិយោគអាស៊ានជាដើម តាមរយៈកិច្ចសហការជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធ
- ចូលរួមបង្កើតយុទ្ធសាស្ត្រប្រទេសបូក ទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខដូចមានចែងជាវិធានការក្នុងផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកកម្ពុជា
- ពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការការពារវិនិយោគនិងចូលរួមអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី ព្រមទាំងអនុស្សរណៈយោគយល់គ្នាពាក់ព័ន្ធនឹងការវិនិយោគប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព
- ជំរុញការប្រើប្រាស់ប្រព័ន្ធទិន្នន័យសន្ទានកម្មខ្សែចង្វាក់ផ្គត់ផ្គង់អភិវឌ្ឍន៍ដោយចីរភាព(SD2) ដែលជាប្រព័ន្ធទិន្នន័យព័ត៌មានអំពីសហគ្រាសផ្គត់ផ្គង់ក្នុងស្រុក ដែលមានលក្ខណៈសម្បត្តិប្រកបដោយចីរភាព សម្រាប់ឱ្យក្រុមហ៊ុនបរទេសអាចស្វែងរកនិងចាប់ដៃគូក្នុងការផ្គត់ផ្គង់ផលិតផលនិងសេវាកម្ម

- ជំរុញការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនិងទាក់ទាញការវិនិយោគចូលក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងនេះ។

**ទី៣- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ចូលរួមការធ្វើពិពិធកម្មវិស័យឧស្សាហកម្ម តាមរយៈការទាក់ទាញការវិនិយោគកម្មន្តសាលកែច្នៃកសិឧស្សាហកម្មសម្រាប់កសិផលមានសក្តានុពលក្នុងការនាំចេញ និងរៀបចំផែនការយុទ្ធសាស្ត្រក្នុងការជំរុញនិងទាក់ទាញការវិនិយោគលើកម្មន្តសាលផ្គុំនិងដំឡើងរថយន្ត និងអេឡិចត្រូនិកផ្អែកលើផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកកម្ពុជា
- ជំរុញការចូលរួមរបស់សមាគម អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ ជាពិសេសវិស័យឯកជនក្នុងការជំរុញអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ
- គាំទ្រនិងជំរុញការផ្ទេរបច្ចេកវិទ្យា តាមរយៈការកសាងក្របខណ្ឌគតិយុត្តនិងប្រព័ន្ធអេកូឡូស៊ីអំណោយផល
- ជំរុញផលិតកម្មនិងធ្វើពិពិធកម្មផលិតកម្មវិស័យឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យមកម្ពុជា
- ចូលជាសមាជិកពេញសិទ្ធិនៃស្ថាប័ន APAC IHAF ILAC និងIAF លើវិសាលភាពផ្សេងទៀតក្រៅពីមន្ទីរពិសោធន៍ធ្វើតេស្ត ISO/IEC ១៧០២៥ ដើម្បីទទួលបានការទទួលស្គាល់ជាអន្តរជាតិលើគ្រប់វិសាលភាព សំដៅជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម កាត់បន្ថយចំណាយធុរកិច្ច កាត់បន្ថយនូវរបាំងបច្ចេកទេសនៃការធ្វើពាណិជ្ជកម្ម របាំងអនាម័យនិងភូតគាមអនាម័យ
- បន្តរៀបចំដំណើរការផ្តល់ការចុះបញ្ជីបញ្ជាក់ការទទួលស្គាល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពដែលភ្ជាប់ជាមួយទំនិញនាំចេញ នាំចូល សំដៅកាត់បន្ថយនូវទំនិញគ្មានគុណភាព ដើម្បីជួយគាំទ្រនិងការពារផលប្រយោជន៍អតិថិជន លើកកម្ពស់សុខភាពសាធារណៈ ព្រមទាំងជួយគាំទ្រដល់ការធ្វើពាណិជ្ជកម្មរបស់កម្ពុជា។

**ទី៤- ក្រសួងផែនការ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងអនុវត្តយុទ្ធសាស្ត្រអន្តរកាលដោយរលូនសម្រាប់ការចាកចេញរបស់កម្ពុជាពីក្រុមប្រទេសអភិវឌ្ឍតិចតួច ប្រកបដោយចលនការ
- ជំរុញការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ សំដៅបញ្ជាក់ពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមចំណែកជាមួយនឹងពិភពលោកដល់ការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ ទីក្រុងណៃរ៉ូប៊ី ក៏ដូចជាអនុសញ្ញានានារបស់អង្គការសហប្រជាជាតិ

- បន្តចូលរួមជាមួយនឹងប្រព័ន្ធសហប្រជាជាតិ ក្នុងការជំរុញអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) ដោយបន្តពង្រឹងប្រព័ន្ធស្ថិតិជាតិ ក្នុងការផលិតព័ត៌មានស្ថិតិសម្រាប់តាមដានត្រួតពិនិត្យការអនុវត្តគ.អ.ច.ក. សំដៅផ្តល់ការរួមចំណែករបស់កម្ពុជាដល់ការសម្រេចបានរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ៣.៣- ការអភិវឌ្ឍមូលធនមនុស្ស

### ៣.៣.១- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

គោលដៅជាយុទ្ធសាស្ត្រនៃការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គឺការបង្កើតបរិយាកាសល្អសម្រាប់ការអប់រំនិងការបណ្តុះបណ្តាល ប្រកបដោយគុណភាពនិងជំនាញខ្ពស់ដោយផ្តោតលើការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រប់កម្រិត ការបង្កើនគុណភាព និងការចូលរៀនមុខវិជ្ជា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(STEAM) និងការពង្រឹងការអប់រំកាយ និងកីឡា។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តពង្រឹងគុណភាពអប់រំនិងការបណ្តុះបណ្តាលគ្រប់កម្រិត ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សានៅគ្រប់កម្រិត និងការបង្កើតបរិយាកាសល្អ សម្រាប់ការសិក្សាពេញមួយជីវិត។

ទី២- ការបន្តកែទម្រង់សាលារៀន ដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់ ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ ការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និងកីឡា ព្រមទាំងការជំរុញការចូលរួម និងភាពជាម្ចាស់របស់មាតាបិតា សហគមន៍ និងវិស័យឯកជន។

ទី៣- ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀននិងវិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ ជីវភាព និងគុណតម្លៃបុគ្គលិកគ្រប់កម្រិត។

ទី៤- ការបន្តលើកកម្ពស់ការអប់រំឌីជីថល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀននិងការជំរុញនូវការចាប់យកមុខវិជ្ជា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(STEAM)។

ទី៥- ការលើកកម្ពស់សុខភាពសិក្សានិងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និស្សិត ក្រីក្រ និងងាយរងគ្រោះ។

ទី៦- ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងការធ្វើនវានុវត្តន៍ និងការជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ទី៧- ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំនិងការបន្តជំរុញចលនា«**យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត**»។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងអប់រំ យុវជន និងកីឡា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តលើកកម្ពស់គុណភាពអប់រំនៅគ្រប់កម្រិតសិក្សា ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាគ្រប់កម្រិតឱ្យស្របតាមតម្រូវការទីផ្សារការងារជាក់ស្តែង ជំរុញការបង្កើនសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ និងបង្កើតបរិយាកាសអំណោយផលដល់ការសិក្សាពេញមួយជីវិត
- បន្តជំរុញអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅនិងការពង្រឹងអភិបាលកិច្ចឱ្យកាន់តែប្រសើរក្នុងវិស័យអប់រំ យុវជន និងកីឡា នៅគ្រប់កម្រិតសិក្សា លើកកម្ពស់ការសិក្សាស្រាវជ្រាវ និងការបោះពុម្ពលទ្ធផលនៅក្នុងទិនានុប្បវត្តិវិទ្យាសាស្ត្រ នវានុវត្តន៍ និងការច្នៃប្រឌិត តាមរយៈយន្តការលើកទឹកចិត្តចាំបាច់នានា ការបន្តបង្កើនការរៀបចំពិព័រណ៍តាំងបង្ហាញសមិទ្ធផលគម្រោងស្រាវជ្រាវ ការរៀបចំការប្រកួតប្រជែង និងការចូលរួមក្នុងសន្និសីទនៅក្នុងប្រទេសនិងអន្តរជាតិ
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀន ក៏ដូចជាការបន្តលើកកម្ពស់ជីវភាពនិងការលើកកម្ពស់តម្លៃសង្គមរបស់បុគ្គលិកបង្រៀននៅគ្រប់កម្រិតសិក្សា ព្រមទាំងលើកកម្ពស់សុខភាពសិក្សានិងបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស និស្សិតក្រីក្រ និងពូកែ
- បន្តលើកកម្ពស់ការអប់រំឌីជីថល អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងសាលារៀន និងលើកកម្ពស់និងកែលម្អវិធីសាស្ត្របង្រៀននិងការសិក្សាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្តល់ការគាំទ្រចាំបាច់នានានិងជំរុញគម្រោងស្រាវជ្រាវពាក់ព័ន្ធនឹងមុខវិជ្ជាស្ទែម
- វិនិយោគបន្ថែមលើការបំពាក់សម្ភារៈឧបទេសនិងជំរុញការធ្វើពិសោធន៍នៅតាមសាលារៀនជំនាន់ថ្មី សាលារៀនគំរូ និងវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស ដើម្បីបង្កើនគុណភាពនៃការអប់រំទូទៅក៏ដូចជាមុខវិជ្ជាស្ទែមនៅកម្ពុជា
- ជំរុញការបង្កើតក្លឹបសិក្សា រួមទាំងក្លឹបសិក្សាពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល ពង្រឹងក្រុមប្រឹក្សាយុវជន និងបង្កើតប្រព័ន្ធអេកូឡូស៊ី ដូចជាការតាំងពិព័រណ៍វិទ្យាសាស្ត្រ ពិព័រណ៍ស្នាដៃសិស្ស និស្សិត ការប្រកួតប្រជែងស្នាដៃ និងការបង្កើតភាពជាដៃគូរវាងគ្រឹះស្ថានមធ្យមសិក្សាជាមួយគ្រឹះស្ថានឧត្តមសិក្សានិងវិស័យឯកជន ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងសតវត្សទី២១ និងទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យា
- អភិវឌ្ឍយុវជន ទាំងបំណិនរឹងនិងបំណិនទន់ ដោយផ្តោតលើបំណិនសតវត្សទី២១ និងការលើកកម្ពស់ភាពជាអ្នកដឹកនាំ ព្រមទាំងផ្តល់ឱកាសឱ្យយុវជនបញ្ចេញគំនិតយោបល់ បង្ហាញទេពកោសល្យ បង្កើតទំនាក់ទំនងល្អរវាងយុវជននិងយុវជន និងលើកកម្ពស់តម្លៃមិត្តភាព បង្កើត

ជាថ្នាលសម្រាប់យុវជនហាត់ការ ដើម្បីបង្កើនឱ្យមានភាពរឹងមាំ ភាពចាស់ទុំគំនិត និងការចេះគិតស៊ីជម្រៅហ្មត់ចត់

- ជំរុញការកែទម្រង់ស៊ីជម្រៅនិងលើកកម្ពស់វិស័យអប់រំកាយនិងកីឡា និងបណ្តុះវប្បធម៌អប់រំកាយនិងកីឡា ដើម្បីលើកកម្ពស់សុខភាពល្អ សុខុមាលភាព កាយសម្បទាមាំមួន ឆន្ទៈមោះមុត អំណត់ព្យាយាម និងគំនិតច្នៃប្រឌិត សំដៅបង្កើនផលិតភាពការងារ ក៏ដូចជាការដណ្តើមបានលទ្ធផលល្អប្រសើរ ក្នុងការប្រកួតកីឡាលើឆាកអន្តរជាតិ ព្រមទាំងបន្តជំរុញចលនា«**យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត**»
- ផ្សារភ្ជាប់មធ្យមសិក្សាទៅនឹងឧត្តមសិក្សានិងបង្កើនការចូលរៀនជំនាញអប់រំបច្ចេកទេស តាមរយៈមុខវិជ្ជាទាក់ទាញ និងការផ្តល់អាហារូបករណ៍ ការផ្តល់ប្រឹក្សាអាជីព និងការលើកកម្ពស់ការបណ្តុះបណ្តាលបំណិនជីវិត ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាឬគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនានា។

**ទី២- ក្រសួងធម្មការនិងសាសនា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពពាក់ព័ន្ធនឹងការពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាទាំងកម្រិតពុទ្ធិកបឋមសិក្សារហូត ដល់ពុទ្ធិកក្រោយឧត្តមសិក្សាឱ្យស្របតាមស្តង់ដាអប់រំជាតិនិងអន្តរជាតិ ដោយបើកវគ្គបណ្តុះបណ្តាលនិងរិក្រឹតការគ្រូពុទ្ធិកសិក្សាគ្រប់កម្រិតអភិវឌ្ឍ សិក្សាស្រាវជ្រាវ ចងក្រងឯកសារពាក់ព័ន្ធពុទ្ធិកសិក្សាគ្រប់កម្រិត ពង្រឹងនិងពង្រីកបណ្ណាល័យនៅតាមបណ្តាវត្ត និងសាលាពុទ្ធិកសិក្សា សហប្រតិបត្តិការជាមួយស្ថាប័នដៃគូជាតិនិងអន្តរជាតិ លើវិស័យពុទ្ធិកសិក្សា និងបន្តពង្រឹងនិងពង្រីកសាលាពុទ្ធិកសិក្សានៅតាមមូលដ្ឋាន។

**ទី៣- រាជបណ្ឌិត្យសភាកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញបង្កើនសមត្ថភាពស្រាវជ្រាវ តាមរយៈការបង្កើនសម្ទុះនៃការអភិវឌ្ឍវិធីសាស្ត្រស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា កិច្ចសហការស្រាវជ្រាវជាមួយគ្រឹះស្ថានឧត្តមសិក្សាជាតិនិងអន្តរជាតិ ការរៀបចំសិក្ខាសាលាអំពីវិធីសាស្ត្រស្រាវជ្រាវនិងការសរសេរអត្ថបទស្រាវជ្រាវ ការធ្វើទស្សនកិច្ចសិក្សាពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវជាមួយគ្រឹះស្ថានស្រាវជ្រាវអន្តរជាតិជាដើម
- បង្កើនការស្រាវជ្រាវវិទ្យាសាស្ត្រលើវិស័យដែលជាឯកទេសរបស់រាជបណ្ឌិត្យសភាកម្ពុជា លើកកម្ពស់កិច្ចសហប្រតិបត្តិការលើផ្នែកស្រាវជ្រាវជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងប្រមូល ចងក្រង បោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិវិទ្យាសាស្ត្រ និងតម្កល់ឯកសារ ស្នាដៃ និងរបកគំហើញនានានៃការសិក្សាស្រាវជ្រាវ សម្រាប់បម្រើឱ្យការអនុវត្តជាក់ស្តែង ក៏ដូចជាសម្រាប់ជាធាតុចូលដល់គោលនយោបាយនិងយុទ្ធសាស្ត្រជាតិ
- កៀរគរបញ្ញាជនដែលមានបទពិសោធស្រាវជ្រាវនិងបោះពុម្ពជាអន្តរជាតិ ទាំងក្នុងប្រទេសនិងក្រៅប្រទេស ឱ្យចូលរួមកាន់តែទូលំទូលាយដល់ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងការស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា

- អភិរក្ស អភិវឌ្ឍ និងលើកកម្ពស់ការប្រើប្រាស់ភាសានិងអក្សរសាស្ត្រខ្មែរ ប្រកបដោយនិរន្តរភាព ព្រមទាំងស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ និងវប្បធម៌នៅកម្ពុជា ក៏ដូចជានៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប។

### ៣.៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

គោលដៅជាយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស គឺការធ្វើបរិវត្តកម្មការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ការបង្កើនការចុះឈ្មោះចូលរៀន ការរៀបចំជំនាញឡើងវិញ និងការបង្កើនជំនាញ ( Reskilling and Upskilling ) ការពង្រឹងប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍជំនាញ ការដោះស្រាយបញ្ហានៃភាពមិនស៊ីចង្វាក់គ្នារវាងការបណ្តុះបណ្តាល និងតម្រូវការទាំងប្រភេទនិងគុណភាពជំនាញ និងការពង្រឹង ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងអភិបាលកិច្ចប្រព័ន្ធនិងគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ទាំងរដ្ឋនិងឯកជន តាមរយៈការធ្វើបច្ចុប្បន្នកម្មគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការធ្វើឌីជីថលូបនីយកម្ម និងការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ទី២- ការបន្តលើកកម្ពស់សមត្ថភាពនិងគុណវុឌ្ឍិ តាមរយៈការជំរុញលើកទឹកចិត្តគ្រូបង្រៀនឱ្យបន្តសិក្សាបន្ថែម និងសិក្សាស្រាវជ្រាវជាប្រចាំ ព្រមទាំងការទាក់ទាញគ្រូបង្រៀន ដែលមានគុណវុឌ្ឍិខ្ពស់និងឧត្តមានុវត្តន៍ជាក់ស្តែង មកបង្រៀននៅតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅទូទាំងប្រទេស។

ទី៣- ការពង្រឹងគុណភាពជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងជំនាញទន់និងរឹង តាមរយៈការដាក់ឱ្យដំណើរការពេញលេញនូវកម្មវិធីបណ្តុះបណ្តាល ផ្អែកលើសមត្ថភាពនិងតម្រូវការឧស្សាហកម្ម។

ទី៤- ការជំរុញនិងការពង្រឹង កម្មវិធីបង្កើនជំនាញ ការពង្រីកការបណ្តុះបណ្តាលជំនាញ កម្មវិធីរៀបចំជំនាញឡើងវិញ និងកម្មវិធីធ្វើតេស្តទទួលស្គាល់ជំនាញ និងការជំរុញការសិក្សាស្រាវជ្រាវ ការធ្វើនវានុវត្តន៍ និងបច្ចេកទេសអនុវត្ត ស្របតាមតម្រូវការជាក់ស្តែង ព្រមទាំងការផ្សព្វផ្សាយគ្រប់ទម្រង់។

ទី៥- ការរៀបចំយន្តការផ្តល់ឥណទានដល់សិស្ស និស្សិត ដើម្បីលើកទឹកចិត្តដល់ការចាប់យកជំនាញបច្ចេកទេសវិជ្ជាជីវៈ ជាពិសេសជំនាញអាទិភាព។

ទី៦- ការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន ការជំរុញកិច្ចសន្ទនាជាប្រចាំរវាងរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍ និងការកៀរគរមូលនិធិគាំទ្រដល់ការស្រាវជ្រាវនិងការអភិវឌ្ឍ។

### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមាន**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចខាងក្រោម៖

- លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចនិងពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការធ្វើបច្ចុប្បន្នភាពគោលនយោបាយ ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ព្រមទាំងពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ទាំងបរិមាណ និងគុណភាព ដើម្បីបង្កើនសមត្ថភាព និងផលិតភាពកម្លាំងពលកម្មឱ្យកាន់តែឆ្លើយតបនឹងតម្រូវការទីផ្សារពលកម្ម
- ជំរុញភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍ ដើម្បីលើកកម្ពស់តួនាទីដ៏សំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅក្នុងដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងដើម្បីលើកកម្ពស់កិច្ចសន្ទនាទៀងទាត់រវាងវិស័យសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍ និងកៀរគរមូលនិធិសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ
- ជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ តាមរយៈការបង្កើនចំនួនមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងឧស្សាហកម្មស្វ័យប្រវត្តកម្មឬរ៉ូបូត
- បន្តលើកកម្ពស់សមត្ថភាពនិងគុណវុឌ្ឍិរបស់គ្រូបង្រៀន អភិវឌ្ឍកម្មវិធីសិក្សា ការហាត់ការ និងធ្វើការស្រាវជ្រាវជាប្រចាំ ព្រមទាំងទាក់ទាញគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងបទពិសោធអនុវត្តជាក់ស្តែង
- លើកកម្ពស់ការអប់រំបច្ចេកទេសស្របតាមស្តង់ដា ដោយជំរុញឱ្យមានការប្រឡងប្រណាំងការបណ្តុះបណ្តាលឌីជីថលូបនីយកម្ម និងពង្រឹងយន្តការត្រួតពិនិត្យ និងវាយតម្លៃលើការបណ្តុះបណ្តាល។

## ៣.៣.៣- ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន

គោលដៅជាយុទ្ធសាស្ត្រនៃការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន គឺការបន្តកាត់បន្ថយអត្រាឈឺនិងស្លាប់បណ្តាលមកពីជំងឺមិនឆ្លងចម្បងៗ ការបន្តលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងវ័យជំទង់ ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំបរិវត្តកម្ម និងអភិបាលកិច្ចក្នុងវិស័យសុខាភិបាល ការបន្តបង្កើនគុណភាព និងសមត្ថភាពរោគវិនិច្ឆ័យ ក្នុងការព្យាបាល និងការថែទាំ ការបន្តពង្រឹងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល ការលើកកម្ពស់សមត្ថភាពជំនាញ ការលើកកម្ពស់កិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងការចូលរួមរបស់ប្រជាជនតាមសហគមន៍។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំអភិបាលកិច្ច និងបរិវត្តកម្មឌីជីថល ក្នុងវិស័យសុខាភិបាល ការរៀបចំច្បាប់និងនីតិក្រមសុខាភិបាល ការជំរុញការអនុវត្តយន្តការនិយ័តកម្មសេវាសុខាភិបាលសាធារណៈនិងឯកជន ការលើកកម្ពស់ការសិក្សាស្រាវជ្រាវសុខាភិបាល និងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ។

ទី២- ការពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាលនិងសេវាសង្គមកិច្ច ដើម្បីឆ្លើយតបទាន់ពេល និងប្រកបដោយប្រសិទ្ធភាពទៅនឹងការលើកកម្ពស់ សុខភាព និងសុខុមាលភាពសាធារណៈ រួមទាំងការផ្ទុះឡើងនៃជំងឺកាចសាហាវនានា។

ទី៣- ការពង្រឹងប្រព័ន្ធផ្តល់សេវាថែទាំសុខភាពប្រកបដោយនវានុវត្តន៍ ដោយផ្តោតជាចម្បងលើការថែទាំសុខភាពបឋម ការលើកកម្ពស់របបអាហារសុខភាពសម្រាប់ទាំងអស់គ្នា ការបង្កើនគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាព ការចែកចាយ និងការប្រើប្រាស់ឱសថ និងការជំរុញការអនុវត្តយន្តការ តាមដាន វាយតម្លៃ និងអភិបាលកិច្ចគុណភាព។

ទី៤- ការបង្កើនការអប់រំសុខភាពនិងការផ្សព្វផ្សាយ សំដៅលើកកម្ពស់ការយល់ដឹងនិងការប្រតិបត្តិត្រឹមត្រូវរបស់ប្រជាជនក្នុងការបង្ការ និងការគ្រប់គ្រងជំងឺឬបញ្ហាសុខភាពសាធារណៈ ព្រមទាំងការស្វែងរកនិងការប្រើសេវាថែទាំសុខភាពត្រឹមត្រូវ។

ទី៥- ការបង្កើនគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល និងវិជ្ជាជីវៈអមសុខាភិបាល ដោយឈរលើសមត្ថភាពជាមូលដ្ឋាន ការជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ និងការលើកកម្ពស់ការពង្រាយគ្រូពេទ្យ និងបុគ្គលិកសុខាភិបាល សមស្របតាមនិយាមបច្ចេកទេស។

ទី៦- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងការផ្គត់ផ្គង់ឱសថ បរិក្ខារ និងការបំពាក់ឧបករណ៍ពេទ្យ ដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យបង្អែកអាទិភាព នៃខេត្តគោលដៅ និងមន្ទីរពេទ្យជាតិ ឱ្យបានស្របតាមនិយាមបច្ចេកទេសទំនើប។

ទី៧- ការពង្រឹងកិច្ចសហការ ពហុវិស័យ និងអន្តរវិស័យ ការចូលរួមរបស់សហគមន៍ និងការលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្តល់សេវាថែទាំសុខភាព ដែលឆ្លើយតបនឹងតម្រូវការជាសារវន្ត ផ្នែកសុខភាព របស់ប្រជាជននៅមូលដ្ឋាន។

ទី៨- ការកសាងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល និងការបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់និងសកលលោក ក្នុងការពង្រឹងភាពធន់ ការអភិវឌ្ឍវិស័យសុខាភិបាល និងការពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងសុខាភិបាល** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធានាប្រជាជនគ្រប់រូបទទួលបានសេវាថែទាំសុខភាពគ្រប់ជ្រុងជ្រោយ ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន តាមរយៈការធ្វើនវានុវត្តន៍ប្រព័ន្ធផ្តល់សេវាសុខាភិបាល ដែលផ្តោតលើការថែទាំសុខភាពបឋមគុណភាពខ្ពស់ ការបង្កើនចំណេះដឹងផ្នែកសុខភាព និងការបង្កើនបរិស្ថានគាំទ្រដល់បុគ្គល គ្រួសារ និងសហគមន៍ ក្នុងការអនុវត្តរបៀបរស់នៅប្រកបដោយសុខភាពល្អនិងការប្រើប្រាស់សេវាថែទាំសុខភាពត្រឹមត្រូវ ការអភិវឌ្ឍ និងការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាព ការរក្សាទំនាក់ទំនងប្រកបដោយទំនុកចិត្តរវាងមូលដ្ឋានសុខាភិបាលនិងប្រជាជន ព្រមទាំងការជំរុញការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍ ការតាមដាន និងវាយតម្លៃការផ្តល់សេវា និងការពង្រឹងកិច្ចសហការពហុជំនាញ និងពហុវិស័យ រួមទាំងវិស័យឯកជន ដើម្បីកែលម្អកត្តាបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលមានកម្មវិបាកលើសុខភាព និងអន្តរាគមន៍ជាអាទិភាពនានា
- ផ្តល់សេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន ដោយអនុលោមជាមួយស្តង់ដាគុណភាពខ្ពស់ តាមរយៈការរៀបចំចាត់ចែងរំហូរអ្នកជំងឺ/អ្នកប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាល ការលើកកម្ពស់សុវត្ថិភាពអ្នកជំងឺ/អ្នកប្រើប្រាស់សេវា និងអ្នកផ្តល់សេវានៅក្នុងដំណើរការនៃការផ្តល់សេវាថែទាំសុខភាព ការពង្រឹងការថែទាំព្យាបាលតាមគន្លងគ្លីនិករួមមានចំណេះដឹងនិងជំនាញវេជ្ជសាស្ត្រ ក្នុងការធ្វើរោគវិនិច្ឆ័យនិងការថែទាំព្យាបាល ការលើកកម្ពស់គុណភាពសេវាជាប្រចាំ និងការពង្រឹងអនុលោមភាពនៃការប្រតិបត្តិគ្លីនិក ព្រមទាំងធ្វើអន្តរាគមន៍អាទិភាពនានា
- ធានាប្រជាជនគ្រប់រូបទទួលបានជាសកលនូវសេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងទាន់ពេល តាមរយៈអន្តរាគមន៍នៃប្រព័ន្ធគាំពារសុខភាពសង្គម ប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល ប្រកបដោយចីរភាព និងសមធម៌ នវានុវត្តន៍ប្រព័ន្ធទូទាត់ចំណាយលើសេវាថែទាំសុខភាព ការធ្វើសុខដុមនីយកម្មមូលនិធិ និងការពង្រឹងអភិបាលកិច្ចហិរញ្ញប្បទានសុខាភិបាល
- ពង្រឹងប្រព័ន្ធសុខាភិបាលឱ្យមានសមត្ថភាពរឹងមាំ និងឆ្លើយតបទាន់ពេលប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ចំពោះគ្រប់ទម្រង់នៃការគំរាមកំហែងសុខភាពសាធារណៈ និងគ្រោះអាសន្នសុខភាព តាមរយៈការពង្រឹងសមត្ថភាពត្រៀមឆ្លើយតបនឹងគ្រោះអាសន្នសុខភាព ការបង្ការ និងការគ្រប់គ្រងហានិភ័យសុខភាពតែមួយ ការពង្រឹងសមត្ថភាពសេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ និងសេវាផ្តល់ឈាមមានគុណភាព និងសុវត្ថិភាព ព្រមទាំងការពង្រឹងកិច្ចសហការ និងអភិបាលកិច្ចសន្តិសុខសុខភាព

- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគ្រឹះជាសារវ័ន្តនៃប្រព័ន្ធសុខាភិបាល ដើម្បីពង្រឹងសមត្ថភាពផ្តល់សេវាថែទាំសុខភាព និងធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល ដោយផ្តោតលើ (១) ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល (២) ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល (៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយសមិទ្ធកម្មខ្ពស់ (៤) ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ឱសថ សម្ភារៈ ឧបករណ៍ពេទ្យ និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ និងការពង្រីក និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង(៥) ការអភិវឌ្ឍទិន្នន័យ ការគ្រប់គ្រងព័ត៌មានសុខាភិបាល និងការធ្វើឌីជីថលូបនីយកម្មក្នុងវិស័យសុខាភិបាល។

**ទី២- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ផ្តោតការអនុវត្តសកម្មភាពអាទិភាពក្នុងការពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍និងជំងឺអេដស៍ ដើម្បីអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨ និងធានាថារាល់កម្មវិធីឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តគោលការណ៍បីមួយ គឺយុទ្ធសាស្ត្រជាតិតែមួយ យន្តការសម្របសម្រួលតែមួយ និងប្រព័ន្ធតាមដានវាយតម្លៃតែមួយ។

**ទី៣- ក្រសួងអភិវឌ្ឍន៍ជនបទ** ផ្តោតការអនុវត្តសកម្មភាពអាទិភាព ក្នុងការលើកកម្ពស់អនាម័យបរិស្ថានជនបទ តាមរយៈការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តអនាម័យជនបទ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ និងការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាអនាម័យឱ្យបានស៊ីជម្រៅ និងអាចអនុវត្តបាន ដើម្បីបន្តអភិវឌ្ឍវិស័យជនបទប្រកបដោយសមធម៌ ភាពធន់ និងចីរភាព។

### ៣.៣.៤- ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង

គោលដៅជាយុទ្ធសាស្ត្រនៃការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង គឺការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំនិងសង្គតិភាព ទាំងក្នុងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម និងការពង្រឹងប្រព័ន្ធស្បៀងដែលផ្តល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប។ ការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឈរលើស្មារតី «មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់» ហើយនឹងការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តទ្រទ្រង់ជីវភាពគ្រួសារគោលដៅ តាមកម្មវិធីជាតិជំនួយសង្គម ដោយក្នុងរយៈពេលខ្លីត្រូវផ្តោតលើកម្មវិធីជាតិជំនួយសង្គមជាកញ្ចប់គ្រួសារ កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅ រួមទាំងការលើកកម្ពស់ភាពអង់អាចរបស់ពួកគេ កម្មវិធីកិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពក្រីក្រ និងការធ្វើស្ថាបនូបនីយកម្មក្របខ័ណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយគិតបញ្ចូលផងដែរនូវការពង្រឹងប្រព័ន្ធស្បៀងឱ្យកាន់តែ រឹងមាំ វៃឆ្លាត ធន់ និងបរិយាបន្ន។

ទី២- ការបន្តអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម ការអនុវត្តរបបសន្តិសុខសង្គម និងការបន្តពង្រីកសេវាថែទាំសុខភាពសង្គម ឆ្ពោះទៅដល់ការគ្របដណ្តប់សុខភាពសកល ស្របតាមការវិវឌ្ឍនៃស្ថានភាពសង្គមសេដ្ឋកិច្ច។

ទី៣- ការបន្តពង្រឹងប្រព័ន្ធអភិបាលកិច្ចឱ្យកាន់តែ រឹងមាំ និងមានប្រសិទ្ធភាព តាមមុខងារទាំង៣ កម្រិត រួមមានកម្រិតគោលនយោបាយរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម កម្រិតនិយ័តករសន្តិសុខសង្គម និងកម្រិតប្រតិបត្តិកររបស់បេឡាជាតិសន្តិសុខសង្គម មូលនិធិជាតិជំនួយសង្គម និងប្រតិបត្តិករពាក់ព័ន្ធផ្សេងៗទៀតឱ្យមានលក្ខណៈស្តង់ដា។

ទី៤- ការដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិបញ្ញាក់ចំណាយឯករាជ្យ ដែលគ្របដណ្តប់គ្រប់របបថែទាំសុខភាពនិងរបបហានិភ័យការងារ។

ទី៥- ការលើកកម្ពស់ការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបន្តពង្រឹងនិងកែលម្អប្រព័ន្ធកំណត់ក្រុមគ្រួសារ និងក្រុមបុគ្គលគោលដៅ សម្រាប់ប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានសុក្រឹតភាព និងឈានដល់ការដាក់ឱ្យដំណើរការប្រព័ន្ធមូលដ្ឋានចុះបញ្ជីនិងទិន្នន័យសង្គមថ្នាក់ជាតិ។

ទី៦- ការជំរុញការផ្សព្វផ្សាយអំពីសារៈសំខាន់និងតួនាទី នៃប្រព័ន្ធគាំពារសង្គម និងការបង្កើតយន្តការផ្តល់មតិនិងសំណូមពរ និងយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ទី៧- ការជំរុញនិងការបង្កើន សុខុមាលភាពនៃគ្រួសារក្រីក្រ គ្រួសារយុទ្ធជនមានពិការភាព ពលីមរណៈ និងគ្រួសារអតីតយុទ្ធជន ដោយផ្តល់ការគាំពារនានា រួមទាំងការបន្តធ្វើប្រទានកម្មដីនិងការផ្តល់ដីសម្បទានសង្គមកិច្ច សម្រាប់លំនៅឋាននិងកសិកម្ម។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៦ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងសុខាភិបាល** ផ្តោតលើអាទិភាវូបនីយកម្មប្រជាជនគោលដៅ ឆ្ពោះដល់ការគាំពារសុខភាពសង្គមជាសកល ដែលសង្កត់ធ្ងន់លើការពង្រីកការគ្របដណ្តប់នៃការគាំពារសុខភាពសង្គមដល់បុគ្គលគ្រប់រូប ដោយរាប់បញ្ចូលទាំងប្រជាជនចំណាកស្រុក ការពង្រឹងការអនុវត្តយន្តការគាំពារសុខភាពសង្គម និងការចូលរួមក្នុងការធ្វើស្លាបនូបនីយកម្មវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រព័ន្ធគាំពារសង្គម និងការកសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមានចីរភាពសម្រាប់ការគ្របដណ្តប់សុខភាពជាសកល។

**ទី២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់សេវាសង្គមកិច្ច តាមរយៈការលើកកម្ពស់សេវាគាំពារមនុស្សចាស់ និងអតីតយុទ្ធជន ការលើកកម្ពស់សេវាកិច្ចការពារកុមារ ការលើកកម្ពស់ការតាមដានការអនុវត្តសិទ្ធិកុមារ ការលើកកម្ពស់កិច្ចការគ្រួសារ និងការលើកកម្ពស់សេវាគាំពារជនរងគ្រោះ
- ពង្រឹងការគ្រប់គ្រងសេវាស្តារជនរងគ្រោះ តាមរយៈការលើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ការពង្រឹងការសេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការលើកកម្ពស់សុខុមាលភាពជនមាន

ពិការភាព ការលើកកម្ពស់វិជ្ជាជីវៈសង្គមកិច្ច ការពង្រឹង និងពង្រីកការសេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព ការពង្រឹងការតាមដានការអនុវត្តសិទ្ធិជនពិការ និងការកៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច ដើម្បីទ្រទ្រង់ការងារសង្គមកិច្ចប្រកបដោយសមធម៌ បរិយាបន្ន និងចីរភាព

- ពង្រឹងការអនុវត្តកម្មវិធីគាំពារសង្គម តាមរយៈកម្មវិធីជំនួយសង្គមឆ្លើយតបនឹងគ្រោះអាសន្នសម្រាប់អន្តរាគមន៍ដល់គ្រួសាររងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយផ្សេងៗ កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនមកពីគ្រួសារក្រីក្រ និងកម្មវិធីគាំពារសង្គមដើម្បីចាកចេញពីភាពក្រីក្រ ការរៀបចំកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ ការលើកកម្ពស់ និងពង្រឹងទំនាក់ទំនងសាធារណៈ ដោយផ្សព្វផ្សាយអំពីសារៈសំខាន់និងតួនាទីនៃប្រព័ន្ធគាំពារសង្គម និងការលើកកម្ពស់សេវាបើកផ្តល់តាវកាលិក និងរបបគោលនយោបាយ
- ពង្រឹងការអភិវឌ្ឍនិងការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ តាមរយៈការកសាងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចល្អ ការអភិវឌ្ឍធនធានមនុស្សវិស័យសង្គមកិច្ច លើកកម្ពស់ការអភិវឌ្ឍគោលនយោបាយសង្គមកិច្ច ការរៀបចំនិងទទួលស្គាល់វិជ្ជាជីវៈកម្លាំងសេវាសង្គម ដើម្បីធានាដល់ប្រសិទ្ធភាពនៃការផ្តល់ជំនួយសង្គមនិងសេវាសង្គម ដោយបន្តអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១។

**ទី៣- ក្រសួងផែនការ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តពង្រឹងការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ សំដៅផ្តល់ទិន្នន័យសម្រាប់ការងារកម្មវិធីជាតិជំនួយសង្គមនិងរបបសន្តិសុខសង្គមទាន់ពេល និងប្រកបដោយគុណភាព
- ពង្រឹងតម្លាភាពនិងគណនេយ្យភាព ក្នុងការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ តាមរយៈប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង មតិត្រឡប់ និងសំណូមពរ ការរៀបចំឡើងឱ្យមានលក្ខណៈសាមញ្ញ និងងាយស្រួល ព្រមទាំងការរក្សាការសម្ងាត់ ដោយបង្កើតនូវជម្រើសច្រើន ទាំងការដាក់ពាក្យដោយផ្ទាល់នៅសាលាឃុំ សង្កាត់ ឬតាមប្រព័ន្ធកម្មវិធីទូរសព្ទដៃឆ្លាតវៃ ដើម្បីឆ្ពោះទៅការធ្វើសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង មតិត្រឡប់ និងសំណូមពរដោយប្រកាន់ភ្ជាប់នូវគោលការណ៍បរិយាបន្ន និងសមធម៌
- បន្តរៀបចំយុទ្ធសាស្ត្រជាតិលើកទី១ ស្តីពី «ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា ឆ្នាំ២០២៥-២០២៨» ដើម្បីតម្រង់ទិសសម្រាប់ការពង្រឹងនិងពង្រីកវិសាលភាពនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ កិច្ចការពារ និងគ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភមីក្រូសារជាតិនៅកម្ពុជា តាមរយៈការរៀបចំគោលការណ៍ណែនាំបច្ចេកទេសស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឱ្យបានទូលំទូលាយ ការជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង

ការពង្រឹងចំណីអាហារនៅកម្ពុជាប្រកបដោយគុណភាពនិងសុវត្ថិភាព និងការជំរុញការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយ។

**ទី៤- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងនិងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ស្របតាមការវិវឌ្ឍនៃស្ថានភាពសង្គម សេដ្ឋកិច្ច តាមរយៈការពង្រឹង និងបង្កើនការចុះបញ្ជីស្ថាប័ន សហគ្រាស គ្រឹះស្ថាន សំដៅធ្វើការពង្រីកការគ្របដណ្តប់ដល់ជនគោលដៅដទៃផ្សេងទៀត ក្នុងរបបសន្តិសុខសង្គមជារបបភាគទានកាតព្វកិច្ច ពង្រឹង និងបង្កើនការចុះបញ្ជីសមាជិកប.ស.ស. ក្នុងរបបភាគទានដោយស្ម័គ្រចិត្ត ព្រមទាំងចូលរួមក្នុងការពង្រឹងការអនុវត្តមូលនិធិសមធម៌សុខាភិបាល សហការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់ការចុះបញ្ជី និងបន្តពង្រឹងសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជីក្រោមប្រព័ន្ធរួមតែមួយ រៀបចំ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងជំរុញកិច្ចប្រជុំពិភាក្សាជាមួយបណ្តាប្រទេសនានា សំដៅអនុវត្តនូវចល័តភាពរបបសន្តិសុខសង្គម និងសិក្សាសមិទ្ធិលទ្ធភាពរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ
- ពង្រឹងនិងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម តាមរយៈការពង្រឹង និងបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលរបស់មូលដ្ឋានសុខាភិបាលជាដៃគូ ការសិក្សាវាយតម្លៃ និងពិនិត្យលទ្ធភាពនៃការកែសម្រួលលើឯកតាចំណាយនៃកញ្ចប់ព្យាបាលជំងឺឱ្យស្របតាមស្ថានភាពនៃទីផ្សារសុខភាព ការសិក្សា ការចងក្រង និងការកំណត់សេវាបង្ការសុខភាព និងប្រភេទជំងឺវិជ្ជាជីវៈ ការពង្រឹងសេវាទូទាត់ និងការបើកផ្តល់តាវកាលិករបបសន្តិសុខសង្គម ការពង្រឹងសេវាស្តារនីតិសម្បទា និងការសិក្សាលទ្ធភាពសហការជាមួយដៃគូផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងអង្គភាពផ្តល់សេវាការងារសាធារណៈ
- លើកកម្ពស់ការយល់ដឹងនិងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម តាមរយៈការពង្រឹងសេវាផ្តល់ព័ត៌មានអតិថិជន និងដោះស្រាយបណ្តឹង ការសហការបង្កើនការអប់រំ និងផ្សព្វផ្សាយអំពីរបបសន្តិសុខសង្គម ការពង្រឹងការអប់រំ និងការផ្សព្វផ្សាយលើកកម្ពស់សុខុមាលភាព ការបង្ការហានិភ័យការងារ និងការគ្រប់គ្រងហិរញ្ញវត្ថុ ការសិក្សា និងការរៀបចំមធ្យោបាយធ្វើដំណើរសមរម្យសម្រាប់កម្មករនិយោជិត និងការពង្រឹងអនុលោមភាពការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការចាត់វិធានការចាំបាច់ ដោយការធ្វើសមាហរណកម្មនៃប្រព័ន្ធអធិការកិច្ចតែមួយ និងតាមរយៈអធិការសន្តិសុខសង្គម
- ពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម ដើម្បីបង្កើនប្រយោជន៍បន្ថែមដល់សមាជិក ប.ស.ស. និងវិស័យទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងការបង់ភាគទាន ការត្រួតពិនិត្យ ការតាមដាន ការចាត់វិធានការពង្រឹងការគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុនិងគណនេយ្យ ការសិក្សា ការតាមដាន និងការវាយតម្លៃស្ថានភាពហានិភ័យហិរញ្ញវត្ថុ ដើម្បីការពារអត្ថប្រយោជន៍ជូនសមាជិកប.ស.ស. ការពង្រឹងការងារវិនិយោគមូលនិធិសន្តិសុខសង្គម ដោយរៀបចំផែនការ

វិនិយោគឱ្យស្របតាមគោលការណ៍ណែនាំ សម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម ព្រមទាំងតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងហានិភ័យនៃការវិនិយោគមូលនិធិសន្តិសុខសង្គម

- អភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម តាមរយៈការពិនិត្យ និងការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការងារគ្រប់គ្រងផ្ទៃក្នុង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការរៀបចំយន្តការ និងផែនការគ្រប់គ្រងចំណេះដឹង ការចូលរួមការរៀបចំអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីនយោបាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងអនុសញ្ញាអន្តរជាតិ ការពង្រឹងនិងការពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ សំដៅកៀរគរធនធាន និងការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីអភិវឌ្ឍសមត្ថភាពផ្តល់សេវាកម្ម និងការគ្រប់គ្រងស្ថាប័ន។

**ទី៥- ក្រសួងពាណិជ្ជកម្ម** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តចូលរួមចំណែកក្នុងការគ្រប់គ្រងនិងថែរក្សាសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងពង្រឹងការធ្វើពាណិជ្ជកម្មអង្ករ និងកសិផលសក្តានុពលផ្សេងទៀតសម្រាប់បម្រើការនាំចេញ តាមរយៈការលើកកម្ពស់ផលិតកម្មស្រូវ អង្ករ ការអភិវឌ្ឍគុណភាពខ្សែច្រវាក់តម្លៃស្រូវ អង្ករ និងការធ្វើពិពិធកម្មទីផ្សារអង្ករ និងកសិផលដទៃទៀត ដោយផ្តោតលើភាពប្រកួតប្រជែងដែលមានស្រាប់ និងតម្រូវការជាអាទិភាពនៃទីផ្សារ
- បន្តចូលរួមរក្សាស្ថិរភាពថ្លៃស្បៀងយុទ្ធសាស្ត្រលើទីផ្សារក្នុងស្រុក តាមរយៈការលក់ជូនប្រជាពលរដ្ឋក្នុងតម្លៃសមរម្យ ដោយធានាបានទាំងគុណភាពនិងបរិមាណ ដើម្បីឆ្លើយតបទៅនឹងការប្រើប្រាស់ក្នុងស្រុក ព្រមទាំងរួមចំណែកក្នុងការគ្រប់គ្រងការនាំចេញ និងនាំចូលស្បៀងនិងម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃតុល្យភាពស្បៀងនិងម្ហូបអាហារទូទាំងប្រទេស។

**ទី៦- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំផ្សព្វផ្សាយនិងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨ ព្រមទាំងបន្តអនុវត្តនិងធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០
- ពង្រឹងការអភិវឌ្ឍស្ថាប័ននិងបន្តលើកកម្ពស់សមត្ថភាពក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរាជធានី ខេត្ត ដើម្បីលើកទឹកចិត្តដល់ការអនុវត្តការកែលម្អវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ រួមទាំងការសាកល្បងបង្កើតក្រុមការងារស្នូលសម្រាប់ទឹកស្អាត និងអនាម័យដែលគិតគូរពីអាហារូបត្ថម្ភនៅថ្នាក់ក្រោមជាតិ
- ជំរុញការសិក្សាស្រាវជ្រាវ ដើម្បីប្រមូលភស្តុតាងសម្រាប់ជាធាតុចូលដល់ការអនុវត្ត ក៏ដូចជាការធ្វើបច្ចុប្បន្នកម្មគោលនយោបាយនិងយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ព្រមទាំងចែករំលែកលទ្ធផលតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការលើកកម្ពស់អន្តរកម្មរវាងវិស័យសាធារណៈ និង

ឯកជនប្រកបដោយនវានុវត្តន៍ និងការធ្វើឌីជីថលូបនីយកម្ម ដើម្បីគាំទ្រដល់ការប្រមូល ការស្តុកទុក និងការផ្សព្វផ្សាយ

- ដឹកនាំចលនាបង្កើនអាហារូបត្ថម្ភនិងដើរតួនាទីតំណាងកម្ពុជា ក្នុងនាមសមាជិកស្ថាបនិកនៃសម្ព័ន្ធជើងឯក សម្រាប់បរិវត្តកម្មប្រព័ន្ធស្បៀង ដោយជំរុញអនុវត្តសកម្មភាពនៅផ្នែកអន្តរាគមន៍សំខាន់ៗ ព្រមទាំងរៀបចំទិវាជាតិអាហារូបត្ថម្ភនិងទិវាសុវត្ថិភាពម្ហូបអាហារចាំបាច់នានា និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឱ្យបានទៀងទាត់ សំដៅបន្តលើកកម្ពស់វិស័យទាំងនេះ
- ធ្វើបច្ចុប្បន្នកម្មនិងអនុវត្តផែនការសកម្មភាពសកលសម្រាប់ការទប់ស្កាត់បញ្ហាស្គមស្គាំងរបស់កុមារ ព្រមទាំងធ្វើបច្ចុប្បន្នកម្មនិងអនុវត្តសេចក្តីសម្រេចរបស់កម្ពុជាស្តីពីអាហារូបត្ថម្ភសម្រាប់ការលូតលាស់
- រៀបចំនិងអនុវត្តសូចនាករគន្លឹះនានា តាមដាននិងវាយតម្លៃលើការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងរៀបចំរបាយការណ៍ទៀងទាត់ជូនរាជរដ្ឋាភិបាល។

### ៣.៣.៥- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយ សីលធម៌ សមធម៌ និងបរិយាបន្ន

ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន មានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការធ្វើពលភាវូបនីយកម្មពលរដ្ឋ (People Revitalization) ឱ្យមានសមត្ថភាព ផលិតភាព សីលធម៌ គុណធម៌ ចរិយាធម៌ ភាពអំណត់ សុចរិតភាព វិន័យ និងការទទួលខុសត្រូវខ្ពស់ និងការលើកកម្ពស់ ស្មារតី និងមនសិការស្នេហាជាតិ ការពារជាតិ ឯកភាពជាតិ ការចេះយកអាសាគ្នា ការចែករំលែក ការចូលរួម គុណតម្លៃសង្គម និងស្មារតី គោរពច្បាប់ ស្រឡាញ់សន្តិភាព វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ អំពើល្អ និងយុត្តិធម៌ សំដៅធានាបាននូវសិនិទ្ធភាពសង្គម (Social Cohesion) និងសុខដុមរមនាសង្គម។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងនិងការបង្កើនកិច្ចសហការក្នុងការអប់រំ អំពីសីលធម៌ គុណធម៌ និងសុជីវធម៌ ដល់សិស្ស និស្សិត និងយុវជនទាំងក្នុងនិងក្រៅប្រព័ន្ធអប់រំ។

ទី២- ការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីបណ្តុះទម្លាប់មានសីលធម៌ គុណធម៌ និងសុជីវធម៌ និងទម្លាប់គោរព ច្បាប់ និងវិន័យ និងបញ្ចូលការអប់រំអំពីព្រះពុទ្ធសាសនានិងផ្នែកសិល្បៈវប្បធម៌ខ្មែរ ទាំងរូបី និងអរូបី ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ព្រមទាំងផ្សព្វផ្សាយនិងបញ្ជ្រាបទៅគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ទី៣- ការលើកកម្ពស់ការយល់ដឹងអំពីអត្តសញ្ញាណជាតិនិងភាពជាម្ចាស់ក្នុងការអភិរក្សនិងការអភិវឌ្ឍវប្បធម៌ជាតិ ការជំរុញការច្នៃប្រឌិតផលិតផលវប្បធម៌ថ្មីៗ ដោយរក្សាក្បាច់រចនាខ្មែរ និងឈរលើមូលដ្ឋានអត្តសញ្ញាណជាតិ ការលើកកម្ពស់ការចូលរួមពីសំណាក់ព្រឹទ្ធាចារ្យសិល្បៈ ដែលជាមរតកមនុស្សរស់ និងការបណ្តុះអ្នកបន្តវេនសិល្បករបុរាណ និងការពង្រឹងការចូលរួមអនុវត្តពីសំណាក់មហាជន។

ទី៤- ការបណ្តុះទស្សនៈ មនសិការជាតិ និងឧត្តមគតិវិជ្ជមាន ក្នុងការអភិរក្ស ការអភិវឌ្ឍ និងការធ្វើនវានុវត្តន៍សិល្បៈវប្បធម៌ជាតិ។

ទី៥- ការពង្រឹងប្រសិទ្ធភាពនៃការស្រាវជ្រាវ ការចងក្រង និងការផ្សព្វផ្សាយគុណតម្លៃប្រវត្តិសាស្ត្រនៃសំណង់បេតិកភណ្ឌ វត្ថុបុរាណ ស្ថានីយបុរាណ សិលាចារឹក សាស្ត្រាស្លឹករឹត ក្បួនច្បាប់បុរាណ ប្រពៃណីទំនៀមទម្លាប់ ចរិយាធម៌ខ្មែរ និងវប្បធម៌កតញ្ញូជាតិ។

ទី៦- ការបណ្តុះទម្លាប់ ស្មារតីគោរពច្បាប់ និងវិន័យល្អដល់ពលរដ្ឋ និងការរៀបចំដាក់ចេញលក្ខណវិនិច្ឆ័យ សម្រាប់លើកទឹកចិត្តដល់ការធ្វើអំពើល្អជា ពលរដ្ឋគំរូ និងពលរដ្ឋសកល។

ទី៧- ការបន្តលើកកម្ពស់ការគោរព សីលធម៌ តម្លៃស្ត្រី សេចក្តីថ្លៃថ្នូរ ក្នុងគ្រួសារ និងសង្គមខ្មែរ។

ទី៨- ការលើកកម្ពស់ការយល់ដឹងនិងការជំរុញតួនាទីព្រះពុទ្ធសាសនា នៅក្នុងការចូលរួមអប់រំសីលធម៌ គុណធម៌ និងសុជីវធម៌ និងការបំផុសគំនិតច្នៃប្រឌិត ដើម្បីចូលរួមលើកកម្ពស់សង្គមជាតិ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងអប់រំ យុវជន និងកីឡា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បង្កើនការយកចិត្តទុកដាក់លើ«ការអភិវឌ្ឍជំនាញទន់» តាមរយៈការបញ្ជ្រាបនិងបញ្ចូលកម្មវិធីអភិវឌ្ឍយុវជននៅក្នុងសាលារៀន ដើម្បីបង្កើតទម្លាប់ល្អរបស់សិស្ស រៀបចំ «កម្មវិធីអប់រំចរិយាធម៌» ដោយផ្តោតលើការចេះគោរពចាស់ទុំតាមរយៈការសំពះ ការស្លៀកពាក់ និងអនាម័យល្អ ព្រមទាំងរៀបចំវិធានការប្រកដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការយល់ដឹងពីវប្បធម៌ និងអារ្យធម៌ខ្មែរ និងឥរិយាបថល្អ សម្រាប់កុមារនិងយុវជន
- ជំរុញសកម្មភាពរបស់ក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជននៅក្នុងការងារសង្គម ដូចជាកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីបង្រៀនសិស្សខ្សោយ ក្លឹបសិក្សា ការជួយដល់ការងារសហគមន៍ ការសម្អាតថ្នាក់រៀន បន្ទប់ទឹក សាលារៀន ការដាំដើមឈើ សួនបន្លែ ការលើកកម្ពស់បរិស្ថានសាលារៀនស្អាត ការងារស្វ័យសិក្សា ការហាត់កីឡាដើម្បីសុខភាព ការងារស្ម័គ្រចិត្ត និងការអប់រំប្រឆាំងការប្រើប្រាស់សារធាតុញៀន។

**ទី២- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់ការចូលរួមរបស់ប្រជាជនពីគ្រប់ស្រទាប់សង្គម ពិសេសយុវជន ដើម្បីលើកស្ទួយសិល្បៈ វប្បធម៌ជាតិ អត្តសញ្ញាណជាតិ កិត្យានុភាព គុណតម្លៃខ្មែរ សេចក្តីថ្លៃថ្នូរ និងសីលធម៌សង្គម តាមរយៈការបណ្តុះស្មារតីស្នេហាជាតិ ស្នេហាវប្បធម៌ និងការគាំទ្រផលិតផលជាតិ ការបង្កើនការផ្សព្វផ្សាយសិល្បៈវប្បធម៌ខ្មែរជាអន្តរជាតិនិងនៅលើបណ្តាញសង្គម ការចងក្រង និងការផ្សព្វផ្សាយក្បួនខ្នាតទំនៀមទម្លាប់ប្រពៃណីខ្មែរ និងកិច្ចប្រតិបត្តិសង្គម ការជំរុញភាពច្នៃប្រឌិតនិងការបង្កើតស្នាដៃសិល្បៈវប្បធម៌ថ្មីៗ ដែលមានគុណភាពនិងគុណតម្លៃ រួមទាំងស្នាដៃសម្រាប់ផ្សព្វផ្សាយនៅលើបណ្តាញសង្គម និងការជំរុញឱ្យមានការគោរពច្បាប់ ពិសេសពាក់ព័ន្ធនឹងកិច្ចការពារបេតិកភណ្ឌវប្បធម៌ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- លើកកម្ពស់ការស្រឡាញ់ចំពោះការសិក្សារៀនសូត្រនិងរៀនពេញមួយជីវិត ជាពិសេសក្នុងចំណោមយុវជនកម្ពុជា តាមរយៈការលើកស្ទួយវប្បធម៌នៃការអាននិងតែងនិពន្ធ ដូចជាការរៀបចំទិវាវប្បធម៌ជាតិ ពិព័រណ៍សៀវភៅកម្ពុជា ព្រឹត្តិការណ៍រាត្រីចងចាំ កម្មវិធីប្រកួតប្រជែងការតែងនិពន្ធស្នាដៃសិល្បៈវប្បធម៌ ការបន្តចលនា«វប្បធម៌ដើម្បីការអប់រំ ការអប់រំដើម្បីវប្បធម៌» កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំបកប្រែជាភាសាខ្មែរនូវបច្ចេកសព្ទបរទេសថ្មីៗនៅក្នុងវិស័យសិល្បៈ ការលើកស្ទួយចំណេះដឹងបុរាណនិងប្រពៃណីខ្មែរ និងការរៀបចំកម្មវិធីនិងព្រឹត្តិការណ៍គាំទ្រផ្សេងៗ។

**ទី៣- ក្រសួងធម្មការនិងសាសនា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់សាសនារបស់រដ្ឋ តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសាសនា ការរៀបចំក្រុមជំនុំព្រះត្រៃបិដកខ្មែរ ការរៀបចំគោលនយោបាយស្តីពីកិច្ចគាំពារពុទ្ធសាសនា ការរៀបចំនីតិវិធីរួមស្តីពីកិច្ចគាំពារសង្គមតាមវិស័យសាសនា ការរៀបចំគោលការណ៍ណែនាំស្តីពីការបំបួសកុលបុត្រក្នុងព្រះពុទ្ធសាសនា ការបន្តរៀបចំ និងផ្សព្វផ្សាយអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស ការសហការជាមួយក្រសួងពាក់ព័ន្ធនិងគណៈសង្ឃ ដើម្បីបញ្ចូលកម្មវិធីអប់រំព្រះពុទ្ធសាសនាទៅក្នុងកម្មវិធីសិក្សាជាតិ ការលើកតម្កើងតម្លៃព្រះពុទ្ធសាសនា តាមរយៈអធិការកិច្ចសង្ឃនៅតាមបណ្តារាជធានី ខេត្ត ការបោះពុម្ពប្រវត្តិនិងស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ ការពិនិត្យនិងជំរុញការបោះពុម្ពផ្សាយក្នុងវិស័យសាសនារដ្ឋ ការធ្វើអធិការកិច្ចផ្នែករដ្ឋបាលលើវិស័យសាសនា ការពង្រឹងការគ្រប់គ្រងវត្តអារាម មណ្ឌលវិបស្សនាធុរៈ និងពិធីកម្មសាសនា ការរៀបចំផែនការអភិវឌ្ឍវត្តអារាមពុទ្ធសាសនា ការរៀបចំរចនាបថសំណង់សាសនា ការរៀបចំនីតិវិធីយន្តការស្តីពីពានរង្វាន់វត្តអារាមឆ្នើមនិងការរៀបចំវត្តអារាម ទៅជារមណីយដ្ឋានទេសចរសាសនា
- លើកកម្ពស់សីលធម៌សង្គម តាមរយៈការបង្កើនការអប់រំនិងផ្សព្វផ្សាយអំពីសារប្រយោជន៍នៃសីលធម៌សង្គមនិងគុណតម្លៃសាសនា ជាពិសេសដល់ស្រទាប់យុវជន ការបង្កើតឱ្យមានលិខិតបទដ្ឋានស្តីពីការរៀបចំពិធីសាសនាឱ្យស្របទៅនឹងទំនៀមទម្លាប់ខ្មែរ ការរៀបចំសិក្ខាសាលា

ផ្សព្វផ្សាយស្តីពីការប្រើប្រាស់សង្ឃសព្វដល់អង្គភាពសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ ការផលិតវីដេអូអប់រំខ្លីៗពាក់ព័ន្ធវិស័យសាសនា ការរៀបចំផ្សព្វផ្សាយកម្មវិធីតួនាទីព្រះពុទ្ធសាសនាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការរៀបចំនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម និងវគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ និងការរៀបចំវគ្គបណ្តុះបណ្តាលតួនាទីភារកិច្ចដល់ព្រះមន្ត្រីសង្ឃ អាចារ្យ គណៈកម្មការអាចារ្យវត្ត ជាពិសេសប្រព័ន្ធសង្ឃាភិបាលនិងព្រះពុទ្ធប្បដិមា

- រក្សាសុខដុមនីយកម្មសាសនា តាមរយៈការសហការជាមួយមេដឹកនាំគ្រប់សាសនា បំពេញភារកិច្ចក្នុងវិស័យធម្មការនិងសាសនា ការចុះអនុស្សរណៈនៃការយោគយល់ ឬកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍលើវិស័យធម្មការនិងសាសនា ការលើកទឹកចិត្តឱ្យគ្រប់សាសនាទាំងអស់ចូលរួមក្នុងការងារសង្គមនិងសកម្មភាពមនុស្សធម៌ ការទប់ស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម ឬធ្វើទង្វើពុំគប្បីណាមួយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ការដោះស្រាយអធិករណ៍ក្នុងវិស័យសាសនានានា ការរៀបចំគោលនយោបាយស្តីពីកិច្ចគាំពារពហិរសាសនានិងសាលាសាសនា ការរៀបចំគោលនយោបាយជាតិស្តីពីសុខដុមនីយកម្មសាសនានៅកម្ពុជា ការរៀបចំវេទិកាកិច្ចសន្ទនាអន្តរជំនឿ និងការប្រមូលចងក្រងឯកសារស្តីពីជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ជនជាតិដើមភាគតិច។

**ទី៤- ក្រសួងកិច្ចការនារី** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពៈ

- លើកកម្ពស់ការអប់រំនិងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី ដើម្បីក្លាយជាមូលធនមនុស្សនិងតួអង្គប្រកបដោយសក្តានុពល មានសីលធម៌ ចំណេះដឹង និងជំនាញខ្ពស់ ព្រមទាំងកសាងភាពសុខដុមរមនាក្នុងគ្រួសារនិងសង្គមជាតិ តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន និងកម្មវិធីលើកកម្ពស់សេដ្ឋកិច្ចគិតគូរពីសុខុមាលភាពស្ត្រីនិងសង្គម មានជាអាទិ៍ ការបង្កើតទារកដ្ឋាននៅកន្លែងធ្វើការនិងនៅតាមសហគមន៍ ការបង្កើតកន្លែងបំបៅដោះកូនជាដើម
- លើកកម្ពស់ការគោរពច្បាប់និងកែលម្អនិយាមសង្គមអវិជ្ជមាន សំដៅរក្សាអត្តសញ្ញាណជាតិខ្មែរ និងពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលក្នុងនោះ «ស្ត្រីគឺជាស្នូល» ដោយផ្តោតលើ (១)ការផ្តល់តម្លៃលើតួនាទីស្ត្រី តម្លៃគ្រួសារ ភាពជាមាតាបិតា ភាពគំរូបុរសល្អ និងវប្បធម៌អហិង្សា (២)ការលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់និងសុខុមាលភាពក្នុងការរស់នៅ និង(៣)ការអប់រំកូនចៅអំពីសីលធម៌ គុណធម៌ និងសុជីវធម៌
- ដឹកនាំសម្របសម្រួលនិងជំរុញការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា ដើម្បីផ្តល់កិច្ចអន្តរាគមន៍និងឆ្លើយតបឱ្យបានទាន់ពេលវេលា សំដៅលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ រួមទាំងការបង្កើនការអប់រំផ្សព្វផ្សាយដល់សាធារណជនតាមគ្រប់មធ្យោបាយ ទាំងប្រព័ន្ធបែបប្រពៃណីនិងទំនើប។

## ៣.៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង

### ៣.៤.១- ការអភិវឌ្ឍវិស័យគន្លឹះនិងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច

គោលដៅជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យគន្លឹះនិងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច គឺការពង្រីក និងការធ្វើពិពិធកម្ម មូលដ្ឋានកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើន តម្លៃបន្ថែមក្នុងវិស័យគន្លឹះដែលមានស្រាប់ និងការអភិវឌ្ឍប្រភពថ្មីនៃកំណើន ដែលជាកត្តាមិនអាចខ្វះបាន ក្នុងការបង្កើនសក្តានុពលកំណើន និងការពង្រឹងភាពធន់នឹងវិបត្តិ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗ របស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម តាមរយៈការពង្រឹងឧស្សាហកម្មប្រតិគមន៍(Backward Linkages) និងការលើកកម្ពស់លទ្ធភាពទទួលបានការផ្ទេរបច្ចេកវិទ្យា ការស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការរៀបចំនិងការដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យមកម្ពុជា។

ទី២- ការបន្តជំរុញបង្កើតនិងអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទាំងទ្វេភាគី ពហុភាគី និងតំបន់ ឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការពង្រឹងការសម្របសម្រួលអន្តរស្ថាប័ន។

ទី៣- ការជំរុញនិងការលើកកម្ពស់ ការទាក់ទាញការវិនិយោគក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងឧស្សាហកម្មបៃតង តាមរយៈការអនុវត្តផែនទីចង្អុលផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងគ្រឿងបង្គុំអេឡិចត្រូនិកកម្ពុជា យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ និងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ទី៤- ការបន្តលើកកម្ពស់ និងបង្កើនតម្លៃបន្ថែមវិស័យកសិកម្ម និងកសិឧស្សាហកម្ម តាមរយៈការបន្តអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ និងការបង្កើនពាណិជ្ជូបនីយកម្ម ព្រមទាំងការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០។

ទី៥- ការបន្តលើកកម្ពស់វិស័យទេសចរណ៍ ជាពិសេសការបន្តជំរុញការអភិវឌ្ឍទេសចរណ៍វប្បធម៌ និងធម្មជាតិ ដោយបន្ថែមទេសចរណ៍បៃតង ស្អាត និងវៃឆ្លាត ការជំរុញការបង្កើតប្រភេទទេសចរណ៍ថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ និងទេសចរណ៍ធុរកិច្ច តាមរយៈការលើកកម្ពស់ការអនុវត្ត ក៏ដូចជាការរៀបចំ និងការដាក់ចេញគោលនយោបាយ និងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍នានា។

ទី៦- ការបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យសេវាកម្មផ្នែកកម្សាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចលភាពយន្ត និងឧស្សាហកម្មច្នៃប្រឌិតនានា ដែលមានសក្តានុពលខ្ពស់ ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំ និងដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដើម្បីជំរុញការអភិវឌ្ឍវិស័យទាំងនេះ។

ទី៧- ការពន្លឿនការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់សម្រាប់វិស័យទេសចរណ៍ មជ្ឈមណ្ឌលសេវាហិរញ្ញវត្ថុ តំបន់ឧស្សាហកម្មជាដើម ដោយកំណត់យន្តការអនុវត្តឱ្យបានច្បាស់លាស់គ្រប់ជ្រុងជ្រោយ និងការរៀបចំផែនការមេអភិវឌ្ឍន៍បណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡា។

ទី៨- ការបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយនេះ ឱ្យស្របទៅនឹងបរិការណ៍ថ្មីនៃការផ្លាស់ប្តូរនិម្មាបនកម្មពាណិជ្ជកម្ម និងសេដ្ឋកិច្ចតំបន់និងសកលលោក។

ទី៩- ការបន្តជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនិស្សារណកម្មនិងឧស្សាហកម្មគាំទ្រ ដោយបង្កើតនិងដាក់ឱ្យដំណើរការក្រុមហ៊ុនប្រេងកាតជាតិ ការបន្តជំរុញការអភិវឌ្ឍវិស័យប្រេងកាតនិងឧស្ម័ន ជាពិសេសការដាក់ឱ្យដំណើរការអណ្តូងប្រេងកាតឡើងវិញ និងការបន្តលើកទឹកចិត្តឱ្យមានការវិនិយោគលើឧស្សាហកម្មធនធានរ៉ែ និងការគិតគូររៀបចំគោលនយោបាយផលិតវត្ថុធាតុដែលកម្ពុជាមានទាយជ្ជទាន។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៦ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអនុវត្តវិធានការសម្របសម្រួល ជំរុញ និងតាមដានវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ព្រមទាំងចូលរួមសិក្សាកំណត់អត្តសញ្ញាណ និងជំរុញការវិនិយោគក្នុងឧស្សាហកម្មយុទ្ធសាស្ត្រដែលកំពុងលេចឡើងថ្មី
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព ព្រមទាំងបន្តរៀបចំវេទិកានិងសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងអនុក្រឹត្យនេះ វេទិកាជំរុញវិនិយោគទាំងក្នុងនិងក្រៅប្រទេស និងព្រឹត្តិការណ៍ពាក់ព័ន្ធ
- បង្កើនការសិក្សាស្រាវជ្រាវ ដើម្បីទទួលបាននូវបទពិសោធនិងឧត្តមានុវត្តន៍ជាសកលនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម កំណត់វិស័យវិនិយោគអាទិភាព និងសហការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាថ្មី
- ចូលរួមផ្តល់ធាតុចូលលើការរៀបចំផែនការមេអភិវឌ្ឍន៍ខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងការអភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡា។

**ទី២- ក្រសួងពាណិជ្ជកម្ម** បន្តចូលរួមអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច តាមរយៈការបន្តជំរុញបង្កើត និងអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគី ពហុភាគី តំបន់ និងអនុតំបន់ឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសពង្រឹងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលជាមួយអន្តរស្ថាប័នក្នុងការអនុវត្ត និងការបង្កើតកិច្ចព្រមព្រៀងទាំងនេះ ព្រមទាំងរៀបចំនិងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនានា ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរិមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់និងទ្វេភាគីទាំងឡាយ សំដៅជំរុញការនាំចេញរបស់កម្ពុជា និងចូលរួមកាន់តែខ្លាំងក្នុងខ្សែច្រវាក់តម្លៃនិងផ្គត់ផ្គង់តំបន់និងសកល។

**ទី៣- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំគោលនយោបាយជាតិស្តីពីវិស័យប្រេងកាត យុទ្ធសាស្ត្រជំរុញការអភិវឌ្ឍធនធានរ៉ែប្រកបដោយចីរភាព ផែនការមេស្តីពីខ្សែច្រវាក់នៃការផ្គត់ផ្គង់ឧស្ម័ន **អិល ភី ជី** ផែនការមេស្តីពីសន្និធិប្រេងបម្រុងយុទ្ធសាស្ត្រ ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធប្រព័ន្ធផ្គត់ផ្គង់និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ
- សិក្សានិងរៀបចំគោលនយោបាយលើកទឹកចិត្ត ដើម្បីទាក់ទាញវិនិយោគក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម និងវិស័យប្រេងកាត ទាំងផ្នែកអាប់ស្ទ្រីម និងផ្នែកដោនស្ទ្រីម
- ជំរុញដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្ត្រជាតិ ការរៀបចំឃ្លាំងតម្កល់សំណាកគំរូរ៉ែ ការរៀបចំសារមន្ទីរភូគព្ភសាស្ត្រជាតិ និងបណ្ណសារដ្ឋានភូគព្ភសាស្ត្រ និងការបង្កើតតំបន់ឧទ្យានភូគព្ភសាស្ត្រជាតិ។
- សិក្សានិងវាយតម្លៃអំពីតម្រូវការ និងការផ្គត់ផ្គង់ផលិតផលរ៉ែសំណង់ សិក្សាអំពីសន្ទស្សន៍ថ្លៃរ៉ែសំណង់ ព្រមទាំងត្រួតពិនិត្យនិងពង្រឹងអនុលោមភាពនៃស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈឱ្យបាន ៩០%
- ខិតខំស្វែងរកលទ្ធភាពដាក់ឱ្យដំណើរការផលិតកម្មប្រេងកាតនៅប្លុកA ឡើងវិញ និងបន្តជំរុញការចរចាស្វែងរកការឯកភាពគ្នាក្នុងការអភិវឌ្ឍរួមគ្នាក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា។

**ទី៤- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ចូលរួមជំរុញនិងគាំទ្រផែនការបង្កើតតំបន់សេដ្ឋកិច្ចដែលវិនិយោគដោយរដ្ឋនៅទីតាំងយុទ្ធសាស្ត្រមួយចំនួន សំដៅគាំទ្រដល់ការប្រមូលផ្តុំរោងចក្រសហគ្រាសក្នុងស្រុកនិងបរទេស ដើម្បីផលិតនិងកែច្នៃផលិតផល ក៏ដូចជាសំដៅគាំទ្រវិស័យដែលមានសក្តានុពល ដែលវិស័យឯកជនពុំមានលទ្ធភាពវិនិយោគ ដើម្បីបង្កើតឱកាសការងារនិងជំរុញពិពិធកម្មសេដ្ឋកិច្ច
- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ផ្នែកឯកជន និងរៀបចំលិខិតបទដ្ឋានគតិយុត្តឧស្សាហកម្មសម្រាប់បង្កើតមូលដ្ឋានឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងអនុវត្តឧស្សាហកម្មបៃតង

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិនានា ព្រមទាំងកែលម្អអភិបាលកិច្ច ដើម្បីបង្កើតបរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី និងលើកកម្ពស់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពដល់គ្រប់តួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព
- ជំរុញការវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាពនិងសមត្ថកិច្ច ដល់អង្គភាពវាយតម្លៃអនុលោមភាពដែលផ្តល់សេវាកម្មបញ្ជាក់អនុលោមភាពតាមស្តង់ដាជាតិនិងអន្តរជាតិ និងការចុះបញ្ជីផ្សេងៗ និងបន្តសហការជាមួយអង្គភាពវាយតម្លៃទទួលស្គាល់នៃប្រទេសដៃគូ ដើម្បីសហការវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃអនុលោមភាពនៅកម្ពុជា
- បង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈការអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការ ការផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសដៃគូនានា និងការសម្រួលការចុះបញ្ជីភ្នាក់ងារ ដែលប្រកបអាជីវកម្មជាតំណាងរបស់អ្នកដាក់ពាក្យសុំចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម
- ជំរុញការអភិវឌ្ឍស្តង់ដាជាតិសម្រាប់ផលិតផលថ្មីៗក្នុងស្រុក ដែលជាប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច និងស្តង់ដាជាតិលើគ្រប់វិស័យ សម្រាប់ពង្រីកពិពិធកម្មពាណិជ្ជកម្មឱ្យស្របនឹងវិស័យឧស្សាហកម្ម ៤.០
- លើកកម្ពស់និងពង្រីកសេវាកម្មហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ដែលជួយគាំទ្រដល់ឧស្សាហកម្មពាណិជ្ជកម្មនិងសេវាកម្ម
- ពង្រឹងនិងពង្រីកវិសាលភាពនៃការធ្វើតេស្តវិភាគនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវវិធីសាស្ត្រតេស្តវិភាគ ដើម្បីឱ្យស្របតាមការវិវឌ្ឍនៃបទប្បញ្ញត្តិអន្តរជាតិសម្រាប់ជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនិងទីផ្សារ
- ជំរុញឧត្តមភាពបច្ចេកទេសនិងប្រសិទ្ធភាពប្រតិបត្តិការ ដោយពង្រីកវិសាលភាពនៃការធ្វើតេស្តវិភាគផ្នែកមេកានិក អគ្គិសនី និងអេឡិចត្រូនិក ការវាយតម្លៃទទួលស្គាល់អនុលោមស្តង់ដាពីស្ថាប័នអន្តរជាតិ ISO/IEC 17043 ការបំពាក់ឧបករណ៍ពិសោធន៍ទំនើបៗ និងពង្រីកសេវាកម្ម។

**ទី៥- ក្រសួងទេសចរណ៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដែលត្រូវអនុវត្តជា៣ដំណាក់កាល រួមមានការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មីនិងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ ការស្តារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ និងការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា
- ជំរុញកំណើនសេដ្ឋកិច្ចនិងការងារសមរម្យក្នុងវិស័យទេសចរណ៍ តាមរយៈការបណ្តុះបណ្តាលស្របតាមគុណវុឌ្ឍិជាតិកម្ពុជានិងស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍អាស៊ាន

- ពង្រឹងទេសចរណ៍ក្នុងស្រុកនិងពង្រីកការទាក់ទាញទេសចរមកកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិថ្មី និងជំរុញការទាក់ទាញទេសចរឡើងវិញពីប្រភពទីផ្សារចិន កូរ៉េ ជប៉ុន និងប្រភពទីផ្សារទេសចរណ៍ផ្លូវឆ្ងាយ(Long Haul)
- អនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗ រួមមាន ១) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងកិត្តិនាមកម្ពុជា ២) បង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយភាពទាក់ទាញទេសចរមកកម្ពុជាទៅកាន់ទីផ្សារសំខាន់ៗ ៣) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកិច្ចការផ្ទៃក្នុងពាក់ព័ន្ធនឹងការធ្វើដំណើររបស់ទេសចរ រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹងនិងទន់ ៤) បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍផលិតផលទេសចរណ៍ ៥) បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍធនធានក្នុងវិស័យទេសចរណ៍ និងគោលដៅទាក់ទាញទេសចរប្រកបដោយភាពប្រកួតប្រជែងខ្ពស់ ៦) អភិវឌ្ឍស្ថាប័ន ៧) អភិវឌ្ឍបរិវត្តកម្មឌីជីថល និង៨) អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ពន្លឿនការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ២០២៥-២០៣៥
- បន្តអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប កែប និងមណ្ឌលគិរី និងរៀបចំផ្លូវទស្សនា និងរបៀងទេសចរណ៍តភ្ជាប់ពីតំបន់ប៉ូលទេសចរណ៍អាទិភាព ដើម្បីបង្កើតផលិតផលទេសចរណ៍សម្បូរបែប ចម្រុះ និងមានសក្តានុពលប្រកួតប្រជែងខ្ពស់ ព្រមទាំងបន្តជំរុញការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ តាមរយៈការអភិវឌ្ឍឌីជីថលូបនីយកម្ម
- បន្តជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងក្របខ័ណ្ឌអង្គការទេសចរណ៍ពិភពលោក តំបន់ អនុតំបន់ និងទ្វេភាគី សំដៅលើកកម្ពស់កិត្តិនាមកម្ពុជាលើឆាកអន្តរជាតិ។

**ទី៦- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បង្កើនភាពច្នៃប្រឌិតនិងនវានុវត្តន៍ ក្នុងការងារអភិវឌ្ឍសិល្បៈវប្បធម៌ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យានិងគំនិតផ្តួចផ្តើមថ្មីៗ ការគាំទ្រផ្នែកបច្ចេកទេស ការលើកទឹកចិត្ត និងការសម្របសម្រួលផ្សេងៗ និងការពង្រឹងការសិក្សាស្រាវជ្រាវនិងការបង្កើតថ្មីក្នុងស្នាដៃសិល្បៈវប្បធម៌
- បង្កើនផលិតភាពនិងសហគ្រិនភាពក្នុងផ្នែកសិល្បៈវប្បធម៌ ព្រមទាំងបន្តជំរុញផលិតផល និងសេវាវប្បធម៌ថ្មីៗ ជាពិសេសសេវាពិនិត្យវត្ថុសិល្បៈនាំចេញ នាំចូល សេវាផ្នែកភាពយន្ត វីដេអូ សេវាផ្នែកសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល រួមទាំងសេវាផ្នែកសៀវភៅនិងការអាន
- បន្តពង្រឹងគុណភាពនិងបរិមាណមូលធនមនុស្សនៅក្នុងផ្នែកសិល្បៈនិងវប្បធម៌ ដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការបង្កើតមុខរបរនៅក្នុងវិស័យសិល្បៈវប្បធម៌ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការអប់រំនិងបណ្តុះបណ្តាលក្នុងនិងក្រៅប្រព័ន្ធ រួមទាំងការវិនិយោគនិងការទាញអត្ថប្រយោជន៍ពីផលលាភប្រជាសាស្ត្រកម្ពុជា ព្រមទាំងលើកកម្ពស់ការចូលរួមរបស់យុវជន ពិសេសស្ត្រីឱ្យបានកាន់តែច្រើនសម្រាប់ធ្វើជាកម្លាំងផលិត និងប្រើប្រាស់ផលិតផល និងសេវាសិល្បៈវប្បធម៌

- ជំរុញការផលិតវត្ថុសិល្បៈវប្បធម៌ ជាពិសេសស្នាដៃដែលកើតចេញពីជំនាញសិល្បៈវប្បធម៌របស់ដូនតាខ្មែរឱ្យកាន់តែមានគុណភាព និងភាពប្រណីតខ្ពស់
- បន្តពង្រឹងប្រព័ន្ធគ្រប់គ្រងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលឱ្យមានភាពឆ្លើយតបទៅនឹងប្រព័ន្ធបច្ចេកវិទ្យានិងឌីជីថល ដើម្បីទប់ស្កាត់និងបង្ក្រាបការលួចចម្លងស្នាដៃរបស់អ្នកដទៃឱ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំព្រឹត្តិការណ៍និងកម្មវិធីសិល្បៈវប្បធម៌សំខាន់ៗ ដើម្បីគាំទ្រនិងជំរុញដល់តួអង្គក្នុងវិស័យឯកជននិងអង្គការសង្គមស៊ីវិល ឱ្យដើរតួកាន់តែផុសផុល នៅក្នុងឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិត
- បន្តជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់បេតិកភណ្ឌពិភពលោកនិងទីតាំងវប្បធម៌ដែលមានសក្តានុពល ដោយផ្តោតលើការកសាងច្បាប់និងបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងការលើកកម្ពស់សោភណ្ឌភាពនិងទេសភាពវប្បធម៌
- បន្តពង្រឹងនិងពង្រីកប្រព័ន្ធនិងយន្តការការងារ ឱ្យមានភាពប្រទាក់ក្រឡាគ្នាជាយុទ្ធសាស្ត្រ រួមទាំងកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ដើម្បីកៀរគរថវិកានិងបច្ចេកទេសសម្រាប់គាំទ្រដល់ការងារអភិវឌ្ឍឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិត។

## ៣.៤.២- ការលើកកម្ពស់ការតភ្ជាប់និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូននិងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល

ការលើកកម្ពស់ការតភ្ជាប់និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូននិងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល មានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការបន្តកសាងនិងការពង្រឹងមូលដ្ឋានគ្រឹះនិងបុរេលក្ខខណ្ឌគន្លឹះៗ សម្រាប់បង្កើនផលិតភាព លើកកម្ពស់ភាពប្រកួតប្រជែងនិងជំរុញពិពិធកម្ម តាមរយៈការបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

### ក- វិស័យដឹកជញ្ជូននិងឡូជីស្ទិក

ទី១- ការបន្តជំរុញការអនុវត្តផែនការមេអន្តរកាលស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្មឆ្នាំ២០២១-២០៣០ ព្រមទាំងជំរុញការអនុម័តនិងការអនុវត្តផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយនិងឡូជីស្ទិកកម្ពុជា ឆ្នាំ២០២៣-២០៣០។

ទី២- ការជំរុញនិងការពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ឆ្នាំ២០២២-២០៣០។

ទី៣- ការបន្តបង្កើនថវិកាវិនិយោគនិងកៀរគរហិរញ្ញប្បទាន ព្រមទាំងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ ដើម្បីបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគន្លឹះៗ ទាំងផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស

ជាពិសេសគម្រោងផ្លូវនាវាចរណ៍និងប្រព័ន្ធឡូជីស្ទិក គម្រោងស្តីពីការធ្វើទំនើបកម្មប្រព័ន្ធខ្សែផ្លូវរថភ្លើង ភ្នំពេញ ក្រុងព្រះសីហនុដែលមានស្រាប់ និងខ្សែផ្លូវរថភ្លើងថ្មី ប៉ោយប៉ែត សៀមរាប ភ្នំពេញ ព្រមទាំងការគិតគូរអភិវឌ្ឍផ្លូវល្បឿនបន្ថែមទៀត ការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះ ក្នុងប្រទេសទៅនឹងប្រទេសជិតខាង។

ទី៤- ការសិក្សាពីផ្លូវថ្នល់និងការធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ដើម្បីកែសម្រួលកម្រិតទម្ងន់អតិបរមា និងការពន្លឿនការរៀបចំច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវគោក ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែ និងច្បាប់ស្តីពីផ្លូវដែក ព្រមទាំងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងការលើកកម្ពស់ការអភិវឌ្ឍជំនាញឡូជីស្ទិក។

### ខ- វិស័យថាមពល

ទី៥- ការបន្តរក្សាលំនឹងថ្លៃនិងពិនិត្យលទ្ធភាពបញ្ចុះថ្លៃអគ្គិសនី ព្រមទាំងធានាភាពគ្រប់គ្រាន់ និងស្ថិរភាព នៃការផ្គត់ផ្គង់អគ្គិសនីសម្រាប់ឧស្សាហកម្មនិងកសិកម្ម។

ទី៦- ការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនិងការអនុវត្តកម្មវិធីប្រសិទ្ធភាពថាមពល ឱ្យអស់សក្តានុពល។

ទី៧- ការបង្កើនការគ្រប់គ្រង ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការលើសសរស្តម្ភទាំងបីនៃអនុវិស័យថាមពល បរមាណូស៊ីវិល និងវិទ្យុសកម្ម ដើម្បីធានាបាននូវសន្តិសុខថាមពល។

### គ- វិស័យទឹកស្អាត

ទី៨- ការរៀបចំនិងការដាក់ចេញផែនការមេស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីសម្រេចបានគោលដៅផ្គត់ផ្គង់ទឹកស្អាត១០០% នៅឆ្នាំ២០៣០។

ទី៩- ការបន្តពិនិត្យនិងការរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងវិស័យទឹកស្អាត ជាពិសេសការសម្រួលនីតិវិធីនៃការស្នើសុំភ្ជាប់បណ្តាញ ការពង្រឹងការអនុវត្តលក្ខខណ្ឌអាជ្ញាបណ្ណ និងការរក្សាប្រភពទឹកឆៅ ព្រមទាំងការបង្កើតយន្តការស្ថាប័នសំខាន់ៗ និងការបង្កើតនិយ័តករទឹកស្អាត ដើម្បីគ្រប់គ្រងអភិវឌ្ឍ និងដោះស្រាយបញ្ហាប្រឈមនានា សំដៅធានាឱ្យបាននូវសន្តិសុខទឹក។

ទី១០- ការលើកកម្ពស់តួនាទីជាយុទ្ធសាស្ត្រនិងការចូលរួមរបស់រដ្ឋ និងការដាក់ចេញការលើកទឹកចិត្តដល់វិស័យឯកជន សម្រាប់ការវិនិយោគលើវិស័យទឹកស្អាត ក្នុងភូមិសាស្ត្រអាទិភាព ដូចជាតំបន់សេដ្ឋកិច្ចពិសេស សួនបណ្តុំសហគ្រាសធុនតូចនិងមធ្យម និងតំបន់ប៉ូលសេដ្ឋកិច្ច នៅបណ្តារាជធានី ខេត្តជាដើម។

ទី១១- ការបន្តជំរុញស្វ័យតកម្មនិងលើកទឹកចិត្តរដ្ឋាករទឹកស្អាតនៅទីប្រជុំជនខេត្ត ក្រុង។

### ឃ- វិស័យឌីជីថល

ទី១២- ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានជាអតិបរមា ជាពិសេសក្នុងសកម្មភាពធុរកិច្ចនិងសេដ្ឋកិច្ច តាមរយៈវិធានការប្រទាក់ក្រឡានិងជាប្រព័ន្ធ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថានប័នចម្បងៗចំនួន៧ សម្របសម្រួលដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រតាមវិស័យនិងសកម្មភាពអាទិភាព ដូចតទៅ៖

### ក- វិស័យដឹកជញ្ជូននិងឡូជីស្ទិក

**ទី១- ក្រសួងសាធារណការនិងដឹកជញ្ជូន** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់សេវាកម្មដឹកជញ្ជូន ការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងឌីជីថល តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងសារពើភណ្ឌផ្លូវថ្នល់និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការប្រើប្រាស់សម្ភារៈសំណង់មានគុណភាពក្នុងការសាងសង់ ជួសជុល និងថែទាំ ការលើកកម្ពស់ការគ្រប់គ្រងសេវាដឹកជញ្ជូនគ្រប់ប្រភេទឱ្យបានល្អប្រសើរ ការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានឱ្យបានទូលំទូលាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសាធារណការនិងដឹកជញ្ជូន ការប្រើប្រាស់ និងការធ្វើបច្ចុប្បន្នភាពឧបករណ៍ពិសោធន៍ទំនើបសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាល ការសិក្សា ការសាងសង់ ការជួសជុស និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការបន្តធ្វើទំនើបកម្ម និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការលើកកម្ពស់សេវាកម្ម និងការគ្រប់គ្រងការដឹកជញ្ជូន និងយានយន្ត ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការតភ្ជាប់ពហុមធ្យោបាយ និងភស្តុភារកម្ម តាមរយៈការជំរុញអនុវត្តផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ឆ្នាំ២០២៣-២០៣៣ ការរៀបចំផែនការមេដឹកជញ្ជូនផ្លូវទឹក ការធ្វើបច្ចុប្បន្នកម្មផែនការមេផ្លូវដែក ការបន្តការថែទាំ ការស្តារ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូនផ្លូវដែក ការបន្តអនុវត្តអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀងពហុភាគី ទ្វេភាគី ក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងជំរុញការអនុវត្តការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ការសម្របសម្រួលលើការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការស្នើគោលនយោបាយពាក់ព័ន្ធនឹងវិស័យយានយន្តអគ្គិសនី ការសម្របសម្រួលលើការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការសកម្មភាព និងសូចនាកររបស់ក្រសួង ស្ថាប័ន ការរៀបចំផែនការមេ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ទូទាំងប្រទេស ការជំរុញការអនុវត្តគម្រោងសាងសង់ព្រែកជីកហ្វូណនតេជោ។

**ទី២- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចដឹកជញ្ជូនតាមផ្លូវអាកាស តាមរយៈការពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តនៃការដឹកជញ្ជូន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ការបង្កើនអត្ថប្រយោជន៍ និងជម្រើសដល់អ្នកប្រើប្រាស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសឱ្យកាន់តែប្រសើរឡើង ការបង្កើត

ឱកាសអាជីវកម្មក្នុងទីផ្សារដឹកជញ្ជូនតាមផ្លូវអាកាស និងការពង្រីកការតភ្ជាប់ផ្លូវអាកាសកម្ពុជាក្នុងស្រុក តំបន់ និងសកលលោក

- ពង្រឹងសុវត្ថិភាព រក្សាបានសណ្តាប់ធ្នាប់ និងធានាសុវត្ថិភាពប្រតិបត្តិការអាកាសយាន បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រង និងផ្តល់ទំនុកចិត្តខ្ពស់លើការដឹកជញ្ជូនតាមផ្លូវអាកាស ស្របតាមបទដ្ឋានអន្តរជាតិ
- ពង្រឹងសន្តិសុខ តាមរយៈការអនុវត្តឱ្យបានយ៉ាងហ្មត់ចត់នូវសន្តិសុខអាកាសចរណ៍ស៊ីវិល ស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ សំដៅការពារ ទប់ស្កាត់ និងប្រឆាំងនូវរាល់អំពើរំលោភច្បាប់នានាដូចជាការបំផ្ទុះ អំពើភេរវកម្ម ការបំផ្លិចបំផ្លាញ ការគំរាមកំហែងជីវិតមនុស្ស និងទ្រព្យសម្បត្តិជាដើម
- ពង្រឹងប្រសិទ្ធភាពចរាចរណ៍នាំផ្លូវអាកាស ដោយពង្រឹងសេវាកម្មនាំផ្លូវអាកាស ដើម្បីធានាសុវត្ថិភាពខ្ពស់ ទំនុកចិត្តក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធនាំផ្លូវហោះហើរ ស្របតាមបទដ្ឋានអន្តរជាតិ
- គ្រប់គ្រងប្រតិបត្តិការនិងសេវាកម្មអាកាសចរណ៍ស៊ីវិល ដោយពង្រឹងសេវាកម្មគាំទ្រការដឹកជញ្ជូនតាមផ្លូវអាកាស និងត្រៀមខ្លួនសម្រាប់ការធ្វើបរិវត្តកម្មឱដីថល តាមរយៈការធ្វើស្វ័យប្រវត្តកម្ម និងឌីជីថលូបនីយកម្ម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងលើកកម្ពស់គុណភាពសេវាកម្មគាំទ្រក្នុងវិស័យអាកាសចរណ៍ស៊ីវិល
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងលើកកម្ពស់ការការពារបរិស្ថាន តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន ស្របគ្នានឹងកំណើននៃចំនួនអ្នកដំណើរនិងទំនិញតាមផ្លូវអាកាស ដែលអាចឆ្លើយតបបានយ៉ាងល្អប្រសើរទៅនឹងតម្រូវការជាក់ស្តែងនៃការធ្វើដំណើរតាមផ្លូវអាកាស ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស និងការចុះចតរបស់អាកាសយានគ្រប់ប្រភេទ ប្រកបដោយសុវត្ថិភាព និងភាពអំណោយផលផ្នែកសេដ្ឋកិច្ច និងការជួយការពារបរិស្ថាន
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈការពង្រឹងនិងការពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិក្នុងវិស័យអាកាសចរណ៍ស៊ីវិល និងការធ្វើឱ្យមានភាពសុខដុមនីយកម្ម គោលនយោបាយ និងផែនទីមគ្គុទ្ទេសក៍ក្នុងការអភិវឌ្ឍវិស័យអាកាសចរណ៍ស៊ីវិលទាំងក្នុង អនុតំបន់ តំបន់ និងសកលលោក
- អភិវឌ្ឍធនធានមនុស្សនិងពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈការបណ្តុះបណ្តាលមន្ត្រីឱ្យមានសមត្ថភាពខ្ពស់ ឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវការ និងស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។

## ខ- វិស័យថាមពល

**ទី៣- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអភិវឌ្ឍប្រភពអគ្គិសនីថ្មីៗបន្ថែម ដោយយកចិត្តទុកដាក់លើការបន្ថយថ្លៃដើមនៃល្បាយប្រភពអគ្គិសនី បន្ថយអតុល្យភាពនៃអានុភាពរវាងពេលថ្ងៃ ពេលយប់ និងរដូវប្រាំង រដូវវស្សា ព្រមទាំង

ពង្រឹងគុណភាពនិងស្ថិរភាពប្រព័ន្ធបញ្ជូន និងយកចិត្តទុកដាក់បញ្ចូលការអភិវឌ្ឍប្រភពថាមពលស្អាត និងចីរភាពឱ្យបានជាអតិបរមា ក្នុងផែនការមេ

- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពលអគ្គិសនីនៅក្នុងវិស័យឧស្សាហកម្ម វិស័យលំនៅឋាន វិស័យអគារ វិស័យសាធារណៈ និងវិស័យដឹកជញ្ជូន
- ពង្រឹងនិងពង្រីករចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសន្តិសុខ សម្រាប់ការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម
- បន្តរៀបចំក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសផ្នែកថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម
- បន្តពង្រឹងការអនុវត្តមុខងារជាបញ្ញត្តិករគ្រប់គ្រងសុវត្ថិភាព សន្តិសុខ និងការត្រួតពិនិត្យបច្ចេកទេស ដើម្បីពង្រឹងអនុលោមភាពទៅនឹងលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសជាធរមាន លើការផ្តល់សេវាទាំងឡាយណាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម
- បន្តពង្រឹងនិងពង្រីកការអភិវឌ្ឍធនធានមនុស្សឱ្យមានសមត្ថភាពនិងជំនាញគ្រប់គ្រាន់ បំពាក់ឧបករណ៍និងសម្ភារៈបច្ចេកទេស ក្នុងការអនុវត្តការងារ ស្របតាមគោលការណ៍ណែនាំ និងឧត្តមានុវត្តន៍ជាអន្តរជាតិ ព្រមទាំងលើកកម្ពស់ការងារគ្រប់គ្រងនិងជួយគាំទ្រដល់ការអនុវត្តការងារបច្ចេកទេសពាក់ព័ន្ធនឹងសសរស្តម្ភទាំងបី គឺសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាពនៃផ្នែកថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍនានា សំដៅកៀរគរជំនួយជាគម្រោងបច្ចេកទេសគាំទ្រដល់ការងាររៀបចំនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសន្តិសុខវិទ្យុសកម្ម ដើម្បីបម្រើដល់វិស័យថាមពល សុខាភិបាល កសិកម្ម ធនធានទឹក និងបរិស្ថាន ការសិក្សាស្រាវជ្រាវ ឧស្សាហកម្ម និងការអភិរក្សសម្បត្តិបេតិកភណ្ឌជាតិ
- បង្កើនការងារផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងឱ្យកាន់តែទូលំទូលាយពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអត្ថប្រយោជន៍នៃអនុវិស័យនេះ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជានាអនាគត។

**គ- វិស័យទឹកស្អាត**

**ទី៤- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិស្តីពីទឹកស្អាតនិងអនាម័យ ស្របតាមបរិបទសេដ្ឋកិច្ច និងសង្គម កសាងផែនការអភិវឌ្ឍន៍វិស័យទឹកស្អាត និងពង្រឹងតួនាទីជាយុទ្ធសាស្ត្ររបស់រដ្ឋាករទឹក
- ពង្រឹងគុណភាពសេវាកម្មផ្គត់ផ្គង់ទឹកស្អាត ឱ្យអនុវត្តស្របតាមបទដ្ឋាននិង/ឬបច្ចេកទេស និងអនុលោមតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ

- ពង្រឹងការអនុវត្តនិងផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតឱ្យបានទូលាយនិងមានប្រសិទ្ធភាព ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទឹកស្អាតនិងការចូលរួមដើម្បីសម្រេចបាន «ទឹកស្អាតសម្រាប់ទាំងអស់គ្នា»
- ពង្រឹងការងារបញ្ញត្តកម្ម ដោយធ្វើការសិក្សាបង្កើតនិយ័តករទឹកស្អាតកម្ពុជា ជាពិសេសសម្រាប់គ្រប់គ្រងប្រតិបត្តិករឯកជន
- ជំរុញការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទឹកស្អាត ពង្រីកវិសាលភាព និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងបន្តអនុវត្តគោលនយោបាយឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាត
- ផ្តល់ការឧបត្ថម្ភធនគម្រោងវិនិយោគ ដើម្បីពន្លឿនការអភិវឌ្ឍនៅតំបន់ដែលមានសក្តានុពលតិចតួច និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ជាពិសេសសម្រាប់មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត។

**ទី៥- ក្រសួងអភិវឌ្ឍន៍ជនបទ** ផ្តោតការអនុវត្តសកម្មភាពអាទិភាព រួមមានការស្តាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ និងការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាទឹកស្អាត។

**ឃ- វិស័យឌីជីថល**

**ទី៦- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

**ការងារប្រៃសណីយ៍**

- រៀបចំច្បាប់ស្តីពីប្រៃសណីយ៍និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងគុណភាពសេវា និងការប្រកួតប្រជែងនៅក្នុងវិស័យប្រៃសណីយ៍
- រៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញប្រៃសណីយ៍ ដែលមានភាពប្រទាក់ក្រឡាឱ្យដល់ឃុំសង្កាត់ និងការកសាងហេដ្ឋារចនាសម្ព័ន្ធគន្លឹះ រួមមានឃ្លាំងភស្តុភារកម្មប្រៃសណីយ៍ និងភណ្ឌាគារគយមានដែនកំណត់
- រៀបចំប្រព័ន្ធអាសយដ្ឋាននិងលេខកូដប្រៃសណីយ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការទទួល និងចែកបញ្ញើ ឱ្យបានកាន់តែឆាប់រហ័ស និងឆ្លើយតបនឹងតម្រូវការរបស់ធុរកិច្ចនិងប្រជាជន
- រៀបចំប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ឌីជីថល តាមរយៈការបង្កើតនិងប្រើប្រាស់ថ្នាលប្រៃសណីយ៍ឌីជីថល ដូចជាថ្នាល DGPost ដើម្បីគាំទ្រដល់ការផ្តល់សេវាប្រៃសណីយ៍ជូនអ្នកប្រើប្រាស់ និងការដឹកជញ្ជូនគោលដៅចុងក្រោយ
- ជំរុញការកសាងថ្នាលបច្ចេកវិទ្យាគាំទ្រដល់ពាណិជ្ជកម្មអេឡិចត្រូនិក ដើម្បីសម្រួលដល់ការធ្វើអាជីវកម្មស្របច្បាប់។

**ការងារទូរគមនាគមន៍**

- រៀបចំនិងធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីរលកវិទ្យុនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- រៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងខ្សែកាបក្រោមបាតសមុទ្រ លំហអាកាស និងផ្កាយរណប
- រៀបចំផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ និងបទប្បញ្ញត្តិពាក់ព័ន្ធការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ ដើម្បីគ្រប់គ្រងប្រេកង់វិទ្យុដែលជាធនធានកម្មសិទ្ធិរបស់ជាតិឱ្យមានប្រសិទ្ធភាពស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ
- បន្តតាមដានការអនុវត្តគម្រោងសាងសង់ស្ថានីយអង់តែនទូរសព្ទចល័ត ដើម្បីពង្រីកវិសាលភាពគ្របដណ្តប់ និងលើកកម្ពស់គុណភាពសេវាទូរគមនាគមន៍នៅទូទាំងប្រទេស ជាពិសេសនៅតាមគោលដៅទេសចរណ៍អាទិភាព និងតំបន់ទេសចរណ៍ដាច់ស្រយាល
- បង្កើនសមត្ថភាពប្រតិបត្តិការខ្សែកាបអុបទិកក្រោមបាតសមុទ្រនិងខ្សែកាបអុបទិកឆ្លងព្រំដែនគោកដែលមានស្រាប់ និងពង្រីកការសាងសង់ខ្សែកាបអុបទិកក្រោមបាតសមុទ្រថ្មីនិងខ្សែកាបអុបទិកឆ្លងព្រំដែនគោកបន្ថែម ដើម្បីបង្កើនគុណភាពសេវាអ៊ីនធឺណិតឱ្យមានល្បឿនលឿន និងឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់ប្រកបដោយស្ថិរភាពខ្ពស់
- ពង្រីកការកសាងបណ្តាញខ្សែកាបអុបទិកឆ្អឹងខ្នងនិងខ្សែកាបអុបទិកចែកចាយ សំដៅកាត់បន្ថយគម្លាតឌីជីថលរវាងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ពោលគឺបន្តជំរុញការពង្រឹងនិងពង្រីកវិសាលភាពគ្របដណ្តប់នៃការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ខ្សែកាបអុបទិកឆ្អឹងខ្នងនិងខ្សែកាបអុបទិកចែកចាយអ៊ីនធឺណិតល្បឿនលឿនទៅដល់កម្រិតរាជធានី ខេត្ត និងឃុំ សង្កាត់។

**ការងារបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**

- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដូចជាផែនទីបង្ហាញផ្លូវរដ្ឋាភិបាលឌីជីថល គោលនយោបាយ អភិបាលកិច្ចទិន្នន័យ គោលនយោបាយទិន្នន័យបើកចំហ គោលនយោបាយក្លោដអាទិភាព យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត ច្បាប់ស្តីពីសន្តិសុខសាយប័រ ច្បាប់ស្តីពីកិច្ចការការពារទិន្នន័យបុគ្គល ច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ច្បាប់ស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ច្បាប់ស្តីពីសុវត្ថិភាពអនឡាញ អនុក្រឹត្យគោលការណ៍នៃការបង្កើតអង្គភាពបរិវត្តកម្មឌីជីថល បទដ្ឋាន និងសេចក្តីណែនាំស្តីពីហត្ថលេខាឌីជីថល ស្តង់ដាមជ្ឈមណ្ឌលទិន្នន័យ ក្របខណ្ឌអន្តរប្រតិបត្តិការ និងបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងសន្តិសុខសាយប័រជាដើម
- ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្រសួង ស្ថាប័នរដ្ឋ និងឯកជន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល និងប្រព័ន្ធគ្រប់គ្រងលេខទូរសព្ទ ដើម្បីគាំទ្រដល់ការគ្រប់គ្រង ការប្រើប្រាស់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណរូបវន្តបុគ្គល និងនីតិបុគ្គលក្នុងទម្រង់ឌីជីថល សម្រាប់ធ្វើប្រតិបត្តិការលើថ្នាលឌីជីថល និងដើម្បីពង្រឹងការគ្រប់គ្រងសន្តិសុខជាតិ និងបុគ្គល

- រៀបចំថ្នាលសេវាច្រកចេញចូលតែមួយ ដើម្បីបម្រើសេវាសាធារណៈ នៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងក្រោមជាតិ
- ជំរុញការរៀបចំថ្នាលអប់រំនិងបណ្តុះបណ្តាលជាតិ ដើម្បីផ្តល់មាតិកាអប់រំសម្រាប់លើកកម្ពស់ និងកាត់បន្ថយគម្លាតឌីជីថល ជាពិសេសតាមតំបន់ជនបទដាច់ស្រយាល តាមរយៈប្រព័ន្ធអនឡាញ
- លើកកម្ពស់បរិយាបន្នឌីជីថល តាមរយៈការគាំទ្រដល់ការអភិវឌ្ឍនិងការបំពាក់ឧបករណ៍ប្រព័ន្ធ និងមាតិកាឌីជីថល សម្រាប់ជនមានពិការភាព កុមារតូច ចាស់ជរា និងអនក្ខរជនជាដើម
- ជំរុញការអភិវឌ្ឍធនធានមនុស្សជំនាញឌីជីថល ស្របតាមផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥
- លើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍន៍(R&D) និងនវានុវត្តន៍ឌីជីថល ទាំងក្នុងស្ថាប័នសាធារណៈ និងឯកជន ស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា
- រៀបចំសួនឌីជីថលនិងពង្រីកឱកាសទីផ្សារសម្រាប់ធុរកិច្ចថ្មីឌីជីថល តាមរយៈការជំរុញភាពជាដៃគូរវាងធុរកិច្ចថ្មីឌីជីថលនិងសហគ្រាសគ្រប់ទំហំនិងគ្រប់វិស័យ។

**ទី៧- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** រៀបចំប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីប្រើប្រាស់សម្រាប់ដំណើរការបញ្ជូន ទទួល និងបញ្ជាក់វិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងអ្នកទិញនិងអ្នកលក់ ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាសស្នាមនិងជួយជំរុញកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការធ្វើពាណិជ្ជកម្មឌីជីថល។

### ៣.៤.៣- ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ

ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ មានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការបន្តកែលម្អបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច ការធ្វើពាណិជ្ជកម្ម និងការវិនិយោគ តាមរយៈការសម្រួល និងការធ្វើសាមញ្ញកម្ម នីតិវិធីពាក់ព័ន្ធនានា ការធ្វើឌីជីថលភាវូបនីយកម្ម សម្រាប់ការផ្តល់សេវាសាធារណៈ និងកិច្ចការរដ្ឋបាល ការពង្រឹងសមត្ថភាពស្ថាប័ន និងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលអន្តរក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោមៈ

ទី១- ការបន្តរៀបចំនិងធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដូចជាច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីក្ស័យធននិងការបញ្ចប់ការរៀបចំច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនអាចផ្សព្វផ្សាយ ដើម្បីធានាដល់ការគ្រប់គ្រងកម្មសិទ្ធិបញ្ញានិងការពារមិនឱ្យលេចធ្លាយព័ត៌មានពាណិជ្ជកម្ម។

ទី២- ការលើកកម្ពស់គុណភាព តម្លាភាព ប្រសិទ្ធភាព និងការជឿទុកចិត្ត និងការបង្ហិតសេវាសាធារណៈ ទៅជិតអ្នកប្រើប្រាស់ តាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មនិងថ្នាលបច្ចេកវិទ្យា ក្នុងការផ្តល់សេវាសាធារណៈ ដើម្បីសម្រួលនីតិវិធី កាត់បន្ថយពេល និងចំណាយពាក់ព័ន្ធផ្សេងៗ ព្រមទាំងការធ្វើអធិការកិច្ចនិងការបំពេញអនុលោមភាពផ្សេងទៀត ដើម្បីធានាការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព។

ទី៣- ការបន្តជំរុញការកែទម្រង់ស៊ីជម្រៅនិងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដើម្បីបង្កើនប្រសិទ្ធភាពប្រមូលចំណូលនិងបង្កើតការប្រកួតប្រជែងដោយស្មើភាព ក្នុងការធ្វើធុរកិច្ចនិងការវិនិយោគ និងដើម្បីកាត់បន្ថយបន្ទុកចំណាយលើការបំពេញតាមកាតព្វកិច្ចនិងនីតិវិធីសារពើពន្ធ។

ទី៤- ការបន្តពង្រឹងអភិបាលកិច្ចនិងពង្រីកតួនាទីរបស់វិស័យឯកជនក្នុងវេទិកាធុរកិច្ច ក្រោមក្របខ័ណ្ឌអាស៊ាន អាស៊ានជាមួយដៃគូ និងអាសិប (RCEP) ដើម្បីជំរុញពាណិជ្ជកម្ម ទាក់ទាញការវិនិយោគនិងទេសចរពីបរទេស។

ទី៥- ការជំរុញការអនុម័តយល់ព្រម ដោយអង្គនីតិប្បញ្ញត្តិនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីអំពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដោយមិនប្រើក្រដាសស្នាម (Framework Agreement on Cross-Border Paperless Trade Facilitation) និងការសហការអនុវត្ត ប្រកបដោយប្រសិទ្ធភាព សំដៅជំរុញការនាំចេញនិងការនាំចូល ដោយប្រើប្រាស់ប្រព័ន្ធឌីជីថល។

ទី៦- ការលើកកម្ពស់ការដោះស្រាយវិវាទពាណិជ្ជកម្ម ទាំងក្នុងប្រព័ន្ធតុលាការនិងក្រៅប្រព័ន្ធតុលាការ ប្រកបដោយប្រសិទ្ធភាព ជំនាញ និងសមត្ថភាព តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការតុលាការពាណិជ្ជកម្ម។

ទី៧- ការរៀបចំយន្តការតាមដាននិងវាយតម្លៃ ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគដោយផ្អែកលើការវាយតម្លៃលើភាពងាយស្រួលនៃការធ្វើធុរកិច្ចនិងការវិនិយោគនៅកម្ពុជា។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន២ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តពង្រឹងយន្តការច្រកចេញ ចូលតែមួយ និងយន្តការគាំទ្រនានា ព្រមទាំងធ្វើសាមញ្ញកម្មនីតិវិធីចាំបាច់នានា ដើម្បីសម្រួលដល់វិនិយោគនិងធុរកិច្ច។
- បន្តអនុវត្តកាតព្វកិច្ចបើកច្រកទីផ្សារ ធ្វើសាមញ្ញកម្មនីតិវិធីពិនិត្យ និងការសម្រេចលើគម្រោងវិនិយោគ ការការពារវិនិយោគ និងការជូនដំណឹងអំពីវិធានការថ្មីៗរបស់រដ្ឋ ពាក់ព័ន្ធនឹងការវិនិយោគ

និងធុរកិច្ច ក៏ដូចជាបន្តតាមដាននិងវាយតម្លៃការអនុវត្តកាតព្វកិច្ចខាងលើនេះរបស់រដ្ឋ ជាសមាជិកអាសិប(RCEP)

- បង្កើនការធ្វើទំនើបកម្មនិងស្វ័យប្រវត្តកម្មថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាពិសេសប្រព័ន្ធចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ឱ្យកាន់តែប្រសើរ មានបច្ចុប្បន្នភាព និងបំពាក់សមត្ថភាពពេញលេញ ព្រមទាំងជំរុញការប្រើប្រាស់ថ្នាលបច្ចេកវិទ្យាព័ត៌មានទាំងនេះ
- បន្តពង្រឹងគុណភាពនិងភាពឆ្លើយតបនៃការផ្តល់សេវាសាធារណៈ ជូនវិនិយោគនិងធុរកិច្ចតាមទម្រង់ដោយផ្ទាល់និងអនឡាញ
- បន្តអនុវត្តយន្តការគុវិនិយោគ តាមប្រទេសនិងតាមវិស័យ ឱ្យបានទូលំទូលាយ ប្រកបដោយប្រសិទ្ធភាពខ្ពស់
- ចូលរួមអនុវត្តកិច្ចការពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មលើកទី៥ នៃកិច្ចព្រមព្រៀងវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន ដែលផ្តោតលើការបើកវិស័យបន្ថែមទៀត
- បន្តសិក្សានិងកែលម្អច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់ពាក់ព័ន្ធនឹងការវិនិយោគ
- ចូលរួមរៀបចំយន្តការតាមដាននិងវាយតម្លៃការកែលម្អបរិយាកាសវិនិយោគ ដោយផ្តោតសំខាន់លើការតាមដានវឌ្ឍនភាពវិធានការ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើកទី១៩ និងវិធានការផ្សេងទៀតដែលលើកឡើងក្នុងវេទិកា និងកិច្ចសន្ទនាពាក់ព័ន្ធ ដែលសម្របសម្រួលដោយ គ.វ.ក.។

**ទី២- ក្រសួងពាណិជ្ជកម្ម** បន្តលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ចនិងវិនិយោគតាមរយៈកិច្ចសម្រួលពាណិជ្ជកម្ម ការធ្វើឌីជីថលភាវូបនីយកម្មសម្រាប់ផ្តល់សេវាពាណិជ្ជកម្ម ឱ្យមានប្រសិទ្ធភាព ការពង្រឹងការគ្រប់គ្រងទីផ្សារ និងការការពារផលប្រយោជន៍អ្នកផលិតនិងអ្នកប្រើប្រាស់ ការជំរុញបង្កើតទីផ្សារនៅមូលដ្ឋានសម្រាប់អាជីវករ សហគ្រិន និងកសិករខ្នាតតូច និងការអភិវឌ្ឍខ្សែច្រវាក់តម្លៃនិងការផ្គត់ផ្គង់ ដើម្បីផ្សារភ្ជាប់រវាងអ្នកដាំដុះ អ្នកផលិត អ្នកកែច្នៃ អ្នកប្រមូលទិញ និងអ្នកនាំចេញ ជាពិសេសការបន្តកែលម្អនិងការតភ្ជាប់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ លិខិតអនុញ្ញាត និងអាជ្ញាបណ្ណនានា តាមប្រព័ន្ធថ្នាលឌីជីថល។

## ៣.៤.៤- ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក

គោលដៅជាយុទ្ធសាស្ត្រនៃការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក គឺការប្រមូលផ្តុំ និងការអភិវឌ្ឍបណ្តាញផលិតកម្មឱ្យដើរតួនាទីសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពនិងភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា សំដៅបង្កើនការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសនិងក្នុងស្រុក លើកកម្ពស់

ផលិតកម្មនិងការកែច្នៃសម្រាប់នាំចេញ និងជាពិសេសគាំទ្រដល់ការបង្កើតការងារនិងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការរៀបចំនិងការដាក់ឱ្យអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគ្រប់គ្រង និងលើកទឹកចិត្តដល់ការបង្កើតនិងការវិនិយោគ ក្នុងតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្មសួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក ដើម្បីជំរុញការប្រមូលផ្តុំរោងចក្រសហគ្រាសសំដៅលើកកម្ពស់ប្រសិទ្ធភាពនិងភាពងាយស្រួល សម្រាប់គាំទ្រដល់ការអភិវឌ្ឍផលិតផលសក្តានុពលជាអាទិ៍កសិកម្មនិងកសិឧស្សាហកម្ម គ្រឿងបង្គុំអេឡិចត្រូនិក រថយន្ត វាយនភណ្ឌនិង/ឬគ្រឿងសង្ហារិម។

ទី២- ការសិក្សានិងការពិនិត្យលទ្ធភាពក្នុងការអភិវឌ្ឍនិងការប្រើប្រាស់ ដីឯកជនរបស់រដ្ឋ ឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក សំដៅជានាការបង្កើតការងារនិងធ្វើពិពិធកម្មផលិតកម្ម។

ទី៣- ការបង្កើតតំបន់សេដ្ឋកិច្ចដែលវិនិយោគដោយរដ្ឋ នៅទីតាំងយុទ្ធសាស្ត្រមួយចំនួន សំដៅគាំទ្រដល់ការប្រមូលផ្តុំរោងចក្រ សហគ្រាស ក្នុងស្រុកនិងបរទេស ដើម្បីផលិតនិងកែច្នៃផលិតផលក៏ដូចជាសំដៅគាំទ្រវិស័យដែលមានសក្តានុពល ដែលវិស័យឯកជនពុំមានលទ្ធភាពវិនិយោគ។

ទី៤- ការបន្តពង្រឹងនិងពង្រីកវិនិយោគសាធារណៈ លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ដូចជាផ្លូវថ្នល់ ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក បណ្តាញអគ្គិសនី ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាដើម ទៅតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម សួនបច្ចេកវិទ្យា និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក។

ទី៥- ការជំរុញការតភ្ជាប់រវាងការវិនិយោគផ្ទាល់ពីបរទេសនិងសហគ្រាសធុនមីក្រូ តូច មធ្យម និងធំ ដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក សំដៅគាំទ្រដល់ការត្រៀមខ្លួនរបស់សហគ្រាសក្នុងស្រុក ចូលរួមក្នុងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកល។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសនិងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់នេះ ព្រមទាំងជំរុញការតភ្ជាប់ខ្សែច្រវាក់ផលិតកម្មរវាងគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស និងចូលរួមសិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដែលវិនិយោគដោយរដ្ឋ នៅទីតាំងយុទ្ធសាស្ត្រជាក់លាក់ ដើម្បីជំរុញបង្កើតចង្កោមឧស្សាហកម្មនិងឧស្សាហកម្មប្រតិគមន៍
- ចូលរួមជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីតភ្ជាប់ការដឹកជញ្ជូនទំនិញនិងឡជីស្ទិកកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការនាំទំនិញចេញ ចូលក្នុងតំបន់សេដ្ឋកិច្ចពិសេស ទៅកាន់កំពង់ផែជាតិ អន្តរជាតិ និងច្រកព្រំដែន
- ចូលរួមជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ជាពិសេសការប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាដើម ក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ចូលរួមរៀបចំឬធ្វើទស្សនកិច្ចសិក្សាក្រៅប្រទេស ដើម្បីស្វែងយល់អំពីការរៀបចំសួនឧស្សាហកម្ម សម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក។

**ទី២- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បង្កើនគុណភាពការផ្គត់ផ្គង់អគ្គិសនី ដោយបន្តជំរុញអភិវឌ្ឍបណ្តាញបញ្ជូន អនុស្ថានីយ និងប្រព័ន្ធចែកចាយអគ្គិសនីបន្ថែម ដើម្បីគ្របដណ្តប់នៅទូទាំងប្រទេស ប្រកបដោយភាពប្រទាក់បណ្តាញគ្នាជួយគ្នា ដើម្បីបំពេញតម្រូវការជាក់ស្តែង និងពង្រឹងស្ថិរភាពនៃការផ្គត់ផ្គង់
- បន្តអភិវឌ្ឍភ្ជាប់តំបន់ដែលនៅសល់ជាមួយប្រភពបណ្តាញជាតិ ដើម្បីឱ្យការផ្គត់ផ្គង់នៅទូទាំងប្រទេស ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការផ្គត់ផ្គង់របស់ប្រព័ន្ធបណ្តាញជាតិ ព្រមទាំងពិនិត្យ សិក្សា និងវិនិយោគ ដើម្បីកែលម្អបង្កើនគុណភាព សុវត្ថិភាព និងភាពអាចទុកចិត្តបាននៅក្នុងការផ្គត់ផ្គង់គ្រប់ប្រភេទ និងគ្រប់កម្រិតនៅទូទាំងប្រទេស។

**ទី៣- ក្រសួងពាណិជ្ជកម្ម** បន្តចូលរួមពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស ដោយអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មយន្តការច្រកចេញ ចូលតែមួយឱ្យមានប្រសិទ្ធភាព និងរហ័សក្នុងការផ្តល់សេវាពាណិជ្ជកម្ម វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងសេវាគាំទ្រផ្សេងៗនៅនឹងកន្លែង ព្រមទាំងតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មសេវាសាធារណៈនានារបស់ក្រសួងពាណិជ្ជកម្មទៅតាមគ្រប់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្មនានា ដើម្បីទាក់ទាញវិនិយោគពីបរទេស និងលើកកម្ពស់ឧស្សាហូបនីយកម្ម និងជំរុញការនាំចេញ។

### ៣.៤.៥- ការធ្វើទំនើបកម្មយន្តការហិរញ្ញប្បទាននិងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ

ការធ្វើទំនើបកម្មយន្តការហិរញ្ញប្បទាននិងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ មានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការរៀបចំនិងការកែលម្អ ក្របខ័ណ្ឌ និងយន្តការហិរញ្ញប្បទាន និងការធ្វើពិពិធកម្ម

ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ ដែលធានាបានសន្ទនីយភាព(Liquidity) ក្នុងទីផ្សារ និងជម្រើសហិរញ្ញប្បទានសម្រាប់ការវិនិយោគ សំដៅរួមចំណែកជំរុញការវិនិយោគ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ក្រសួងស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តជំរុញការធ្វើពិពិធកម្មផលិតផលក្នុងវិស័យមូលបត្រ តាមរយៈការលើកកម្ពស់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម សញ្ញាបណ្ណនិរន្តរភាព និងសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព សម្រាប់វិស័យឯកជន ការដាក់ឱ្យដំណើរការផលិតផលទ្រព្យឌីជីថល មូលបត្រអនាគត ការប្តូរមូលបត្រ(SWAP Securities) និងគម្រោងនៃការវិនិយោគរួម(Collective Investment Scheme) និងការជំរុញការអភិវឌ្ឍយន្តការបរធនបាលកិច្ច។

ទី២- ការរៀបចំក្របខ័ណ្ឌគតិយុត្តនិង/ឬផែនការចង្អុលផ្លូវ ក្នុងការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុសាធារណៈ ដូចជាមូលបត្ររដ្ឋ មូលបត្ររដ្ឋបៃតង មូលបត្ររដ្ឋអាកាសធាតុ និងមូលបត្ររដ្ឋសង្គមជាដើម ដើម្បីលើកកម្ពស់ការវិនិយោគសាធារណៈ និងវិស័យអាទិភាព។

ទី៣- ការលើកកម្ពស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងរបៀបវារៈនានា ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច តាមរយៈការជំរុញការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន និតិវិធីប្រតិបត្តិការនិងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ។

ទី៤- ការដាក់ចេញក្របខ័ណ្ឌយុទ្ធសាស្ត្រ ក្នុងការគាំទ្រការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច មធ្យម និងធំ តាមរយៈការគាំទ្រឱ្យមានការចុះបញ្ជីលក់មូលបត្រ ការរៀបចំក្របខ័ណ្ឌគតិយុត្ត និងការបង្កើតបរិយាកាសអំណោយផល សម្រាប់ដាក់ឱ្យដំណើរការនូវយន្តការ និងឧបករណ៍ហិរញ្ញវត្ថុថ្មីៗ។

ទី៥- ការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗ ស្របតាមតម្រូវការទីផ្សារ ដូចជាឥណទានកសិកម្មដែលមានជម្រើសក្នុងការទូទាត់សង សមស្របទៅនឹងចំណូលតាមរដូវកាលជាដើម ព្រមទាំងការជំរុញការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន ដែលផ្សារភ្ជាប់រវាងហិរញ្ញប្បទានទៅនឹងផលិតផលសេវាធានារ៉ាប់រង ជាពិសេសក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញប្បទាន។

ទី៦- ការជំរុញការចុះបញ្ជីផ្លូវការរបស់ធុរកិច្ច ជាពិសេសសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីបង្កភាពងាយស្រួលដល់គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ ក្នុងការផ្តល់សេវាឥណទាន ប្រកបដោយសុវត្ថិភាព ក៏ដូចជាអនុញ្ញាតឱ្យធុរកិច្ចទាំងនោះ អាចទទួលបានការលើកទឹកចិត្ត និងជំនួយអន្តរាគមន៍នានា។

ទី៧- ការជំរុញការធ្វើពិពិធកម្ម យន្តការ និងសេវាហិរញ្ញវត្ថុ ដែលប្រើប្រាស់បច្ចេកវិទ្យា និងគិតគូរអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច។

ទី៨- ការរៀបចំក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការចង្អុលផ្លូវ ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទានជាតិ ដើម្បីកៀរគរហិរញ្ញប្បទាន និងស្វែងរកប្រភពធនធានហិរញ្ញប្បទាន សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងរបៀបវារៈនានា របស់រាជរដ្ឋាភិបាល។

ទី៩- ការជំរុញនិងការរៀបចំយន្តការលើកទឹកចិត្ត ឱ្យប្រជាពលរដ្ឋនិងសហគ្រាសនានា បង្កើនការដាក់សន្សំប្រាក់ក្នុងស្រុកឱ្យបានច្រើននៅក្នុងប្រព័ន្ធធនាគារ ដើម្បីអនុញ្ញាតឱ្យវិស័យឯកជនមានលទ្ធភាពកៀរគរហិរញ្ញប្បទានសម្រាប់ការវិនិយោគបន្ថែម។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងពាណិជ្ជកម្ម** បន្តចូលរួមអនុវត្តយន្តការហិរញ្ញប្បទាននិងផលិតផលហិរញ្ញវត្ថុតាមរយៈការគ្រប់គ្រង និងការទទួលតម្កល់លិខិតជូនដំណឹងស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និងលើកទឹកចិត្តដល់វិស័យឯកជន ឱ្យចូលរួមអនុវត្តច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា សំដៅលើកកម្ពស់ការទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្មនិងវិនិយោគ។

**ទី២- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ចូលរួមសម្របសម្រួលដល់ការលើកលែងការផាកពិន័យនិងបំណុល ក្នុងឆ្នាំ២០២៣-២០២៨ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមក ដើម្បីបើកផ្លូវឱ្យសហគ្រាសដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចធ្វើអន្តរកាលនិងចាប់ផ្ដើមអាជីវកម្មថ្មីនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធដោយពុំមានការព្រួយបារម្ភ
- ជួយសម្របសម្រួលបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មីៗ ក្នុងទីផ្សារឥណទាននិងទីផ្សារហិរញ្ញវត្ថុ ការផ្ដល់ជំនួយហិរញ្ញប្បទានឥតសំណង និងការពិចារណាចូលរួមវិនិយោគក្នុងក្រុមហ៊ុន ការបន្តពង្រីកមូលនិធិអភិវឌ្ឍសហគ្រិនភាព និងការលើកទឹកចិត្តដល់វិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី
- ពង្រឹងការងារកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិន តាមរយៈការបង្កើតទីផ្សារនិងផ្ដល់ហិរញ្ញប្បទាន
- ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹងនិងការពារសិទ្ធិប្រយោជន៍ ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចសាជីវកម្ម ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គមនិងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈការផ្ដល់ការបណ្ដុះបណ្ដាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ពង្រឹងការប្រើប្រាស់ស្តង់ដារូបនីយកម្មនិងការវាយតម្លៃទទួលស្គាល់អនុលោមភាព ដោយផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការលើកទឹកចិត្តនិងការជួយឧបត្ថម្ភផ្សេងៗ។

**ទី៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ សម្រាប់ជាត្រីវិស័យតម្រង់ទិសការកៀរគរហិរញ្ញប្បទាននិងវិនិយោគ
- សិក្សារៀបចំគោលការណ៍ណែនាំសម្រាប់បោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ(Themetic Bonds) ដោយគ្របដណ្តប់លើគ្រប់ដំណាក់កាល ទាំងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព ដំណាក់កាលមុនពេលបោះផ្សាយ ដំណាក់កាលបោះផ្សាយ និងដំណាក់កាលក្រោយពេលបោះផ្សាយ
- បន្តដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានពិសេស ដែលមានលក្ខខណ្ឌអនុគ្រោះខ្ពស់ តាមរយៈធនាគារសហគ្រាសធុនតូចនិងមធ្យម និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

**ទី៤- អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ធ្វើការសិក្សានិងលើកកម្ពស់ការចំហទិន្នន័យ ដើម្បីផ្តល់កាលានុវត្តភាពថ្មីៗដល់ការអភិវឌ្ឍនិងនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់សហគ្រាស និងធុរកិច្ចថ្មី ដែលធ្វើអាជីវកម្មក្នុងវិស័យពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការកំណត់នូវសកម្មភាព កម្មវិធីនិងគម្រោងសំខាន់ៗ ដូចជា (១) ការសិក្សាស្រាវជ្រាវនិងការចូលរួមរៀបចំក្របខ័ណ្ឌនៃការចែករំលែក និងការបើកចំហទិន្នន័យពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង (២) ការរៀបចំកិច្ចប្រជុំនិង/ឬសិក្ខាសាលាប្រមូលធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌនៃការចែករំលែក និងការបើកចំហទិន្នន័យពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## ៣.៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

### ៣.៥.១- ការអភិវឌ្ឍទីផ្សារការងារ

គោលដៅជាយុទ្ធសាស្ត្រ គឺការជំរុញការអភិវឌ្ឍទីផ្សារការងារ តាមរយៈការបង្កើត ការរក្សា និងការបង្កើន ការងារដល់កម្មករនិយោជិត ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ សំដៅបង្កើនប្រាក់ចំណូល ទ្រទ្រង់ជីវភាពសមរម្យ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការរៀបចំផែនការវិនិយោគបន្ថែមនិងយន្តការតាមដាននិងវាយតម្លៃ គ្រឹះស្ថានបណ្តុះបណ្តាល និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបណ្តុះបណ្តាលវិទ្យាសាស្ត្រអនុវត្តនិងបច្ចេកវិទ្យា។

ទី២- ការបន្តបង្កើនឱកាសការងារ ការពង្រីកសេវាជួយស្វែងរកការងារ ប្រឹក្សាយោបល់ និងមគ្គុទ្ទេសក៍ការងារ ការបន្តរៀបចំវេទិកាការងារ និងការរៀបចំឱ្យមានគ្រូបង្គោលនិងជនបង្គោលផ្នែកអាជីពសម្រាប់ជួយស្វែងរកការងារនៅតាមគ្រឹះស្ថានសិក្សា។

ទី៣- ការពង្រឹងអនុលោមភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងហត្ថពលកម្មបរទេស ស្របតាមបទដ្ឋានអន្តរជាតិ ការរៀបចំយន្តការផ្ទេរជំនាញមកឱ្យយុវជនខ្មែរ និងការបង្ការការជួញដូរកម្លាំងពលកម្មឆ្លងដែនខុសច្បាប់។

ទី៤- ការបន្តពង្រឹងការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ដោយរួមបញ្ចូលកម្មវិធីហាត់ការ កម្មសិក្សា ការបង្កើនជំនាញ និងការរៀបចំជំនាញឡើងវិញ ដើម្បីលើកកម្ពស់ផលិតភាពការងារ។

ទី៥- ការបន្តពង្រឹងគុណភាពនិងប្រសិទ្ធភាពអធិការកិច្ចការងារ ការធ្វើវិជ្ជាជីវូបនីយកម្មអធិការការងារ និងការជំរុញនិងការពង្រឹង យន្តការអធិការកិច្ចអន្តរស្ថាប័ន។

ទី៦- ការបន្តលើកកម្ពស់ជីវភាពរបស់កម្មករ និយោជិត ការបន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ ការពិនិត្យលទ្ធភាពពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅកាន់វិស័យផ្សេងៗ ការបន្តការតបណ្ដាញអគ្គិសនីនិងទឹកស្អាត ក្នុងតម្លៃសមរម្យ និងការជំរុញអនុវត្តច្បាប់ស្ដីពីភតិសន្យាពិសេស។

ទី៧- ការបន្តការលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ ការរៀបចំច្បាប់ស្ដីពីសុវត្ថិភាព និងសុខភាពការងារ ការកែលម្អគុណភាពមធ្យោបាយដឹកជញ្ជូន និងការជំរុញឱ្យមានទារកដ្ឋាន កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ/អាហារដ្ឋាន ដែលមានថ្លៃសមរម្យ ក្នុងតំបន់ប្រមូលផ្ដុំរោងចក្រនិងតំបន់សេដ្ឋកិច្ចពិសេស។

ទី៨- ការបន្តពង្រឹងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការពង្រឹងសមត្ថភាព និងការធ្វើវិជ្ជាជីវូបនីយកម្មដល់មន្ត្រីផ្សះផ្សាវិវាទការងារនិងបុគ្គលដែលទទួលផ្នែកបុគ្គលិក ការពង្រឹងយន្តការដោះស្រាយវិវាទការងារ ការធានានិរន្តរភាពក្រុមប្រឹក្សាអាជ្ញាកណ្ដាល ការជំរុញដាក់ឱ្យដំណើរការតុលាការការងារ ការរៀបចំបង្កើតមូលនិធិអភិវឌ្ឍន៍ទំនាក់ទំនងវិជ្ជាជីវៈ និងការជំរុញយុទ្ធនាការថ្នាក់ជាតិស្ដីពី«**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**»។

ទី៩- ការបន្តពង្រីកទីផ្សារការងារនៅក្រៅប្រទេស ការទប់ស្កាត់ទេសន្តរប្រវេសន៍ការងារខុសច្បាប់ ការបណ្ដុះបណ្ដាល និងការលើកកម្ពស់សិទ្ធិ ផលប្រយោជន៍ និងសេចក្ដីថ្លៃថ្នូរ របស់ពលករទេសន្តរប្រវេសន៍ខ្មែរ ការរៀបចំយន្តការទទួលស្គាល់ជំនាញ និងការធ្វើចល័តភាពបេបសន្តិសុខសង្គម។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៥ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម តាមរយៈការពង្រឹងការអនុវត្តគោលនយោបាយ កម្មវិធីនានាពាក់ព័ន្ធវិស័យការងារ និងពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយនិងកម្មវិធីទាំងនោះ ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្ដល់សេវាស្វែងរកការងារនិងវេទិកាការងារ ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទ្ទេសក៍

អាជីពការងារ និងវិជ្ជាជីវៈ ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្ម ការពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ និងកម្មវិធីជំរុញការលើកកម្ពស់ផលិតភាពការងារ

- អភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព សុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈស្របតាមការវិវត្តនៃទីផ្សារការងារ តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ការពង្រឹងការអនុវត្តគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារ ការលុបបំបាត់ពលកម្មកុមារនិងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ការពង្រឹងសមត្ថភាពស្ថាប័ននិងតួអង្គពាក់ព័ន្ធ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈដើម្បីប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្ត
- ពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាពតាមរយៈការពង្រឹងនិងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ ការពង្រឹងយន្តការតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួលដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ការពង្រឹងយន្តការនៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ និងការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា។

**ទី២- ក្រសួងពាណិជ្ជកម្ម** បន្តចូលរួមអភិវឌ្ឍទីផ្សារការងារ តាមរយៈការចុះបញ្ជីបង្កើតក្រុមហ៊ុន/សហគ្រាសថ្មីៗ និងការផ្តល់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីផ្តល់ភាពងាយស្រួល និងរហ័សដល់វិនិយោគ សហគ្រិន និងធុរជនថ្មីៗ ព្រមទាំងការលើកកម្ពស់ការចងក្រងសមាគម/សម្ព័ន្ធអាជីវកម្ម សភាពាណិជ្ជកម្ម ដើម្បីដំណើរការនៃអាជីវកម្មប្រកបដោយរលូន និងប្រកបដោយចលនការ។

**ទី៣- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តលើកកម្ពស់និងលើកទឹកចិត្តការបណ្តុះបណ្តាលសមត្ថភាពនិងជំនាញគ្រប់គ្រងធុរកិច្ច និងសហគ្រិនភាពដល់ម្ចាស់រោងចក្រនិងបុគ្គលិករបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី ព្រមទាំងគាំទ្រការរៀបចំកម្មវិធីចែករំលែកបទពិសោធនៃសហគ្រិនភាព
- ចូលរួមសហការអនុវត្តកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សនិងជំនាញ ដើម្បីលើកកម្ពស់ចល័តភាពក្នុងតំបន់ ព្រមទាំងពង្រឹងនិងពង្រីកវិសាលភាពនៃទីភ្នាក់ងារជាតិមុខរបរនិងការងារ។

**ទី៤- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញការភ្ជាប់បណ្តាញអគ្គិសនីដល់ឧស្សាហកម្ម អាជីវកម្ម និងលំនៅឋានដែលមិនទាន់មានអគ្គិសនីប្រើប្រាស់ ព្រមទាំងពង្រីកការអនុវត្តគម្រោង«អគ្គិសនីសម្រាប់គ្រួសារក្រីក្រ» និងពង្រឹង

ការត្រួតពិនិត្យដោះស្រាយឱ្យមានប្រសិទ្ធភាពចំពោះការស្នើសុំភ្ជាប់បណ្តាញអគ្គិសនីដំបូង

- រៀបចំការអនុវត្តផែនការបន្ថយថ្លៃអគ្គិសនី ដើម្បីជួយសម្រួលបន្ថែមចំពោះគេហកិច្ច ដែលមានចំណូលទាបនិងមធ្យម និងបន្ថយថ្លៃអគ្គិសនីសម្រាប់ឧស្សាហកម្មនិងពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យឧស្សាហកម្មនិងពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងបន្តសិក្សារកលទ្ធភាពបន្ថយថ្លៃអគ្គិសនីបន្ថែមទៀត។

**ទី៥- ក្រសួងអភិវឌ្ឍន៍ជនបទ** ផ្តោតអនុវត្តសកម្មភាពអាទិភាពពាក់ព័ន្ធនឹងការលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ចជនបទ តាមរយៈការជំរុញបង្កើតការងារនិងមុខរបរនៅជនបទ ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនិងទីផ្សារនៅជនបទ ការបណ្តុះបណ្តាលធនធានមនុស្សនិងជំនាញអាជីព និងគាំទ្រមជ្ឈមណ្ឌលបណ្តុះបណ្តាលវិស័យអភិវឌ្ឍន៍ជនបទ។

## ៣.៥.២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តជំរុញការអភិវឌ្ឍបរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូ តូចនិងមធ្យម និងធុរកិច្ចថ្មី ឱ្យរីកលូតលាស់ ធន់នឹងវិបត្តិ និងមាននវានុវត្តន៍ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងការបង្កើតការងារ ព្រមទាំងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្លងអន្តរកាលចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តរៀបចំនិងការដាក់ឱ្យអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិនានា ការជានាកែលម្អអភិបាលកិច្ចសាធារណៈ ការលើកស្ទួយបរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូ តូចនិងមធ្យម និងធុរកិច្ចថ្មី និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ដល់គ្រប់តួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព។

ទី២- ការបន្តលើកកម្ពស់និងការលើកទឹកចិត្ត ការបណ្តុះបណ្តាលសមត្ថភាពនិងជំនាញគ្រប់គ្រងធុរកិច្ច និងសហគ្រិនភាព ដល់ម្ចាស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី ការគាំទ្រការរៀបចំកម្មវិធីចែករំលែករបស់សហគ្រិនដែលមានបទពិសោធ(Mentorship) និងការបណ្តុះបណ្តាលសមត្ថភាពនិងជំនាញរបស់បុគ្គលិកបម្រើការក្នុងសហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី។

ទី៣- ការបន្តពង្រឹងនិងការពង្រីកទីផ្សារក្នុងស្រុកនិងសកល សម្រាប់សហគ្រាសធុនមីក្រូ តូចនិងមធ្យម និងធុរកិច្ចថ្មី តាមរយៈការដាក់ឱ្យអនុវត្តយន្តការគាំទ្ររបស់រដ្ឋនានានិងលទ្ធកម្មសាធារណៈព្រមទាំងការផ្តល់ ការគាំទ្រ និងការលើកទឹកចិត្តដល់ការបង្កើតបណ្តាញធុរកិច្ច(Business Networking)។

ទី៤- ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសធុន មីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី ដែលមានសក្តានុពល តាមរយៈការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុថ្មីៗ ក្នុងទីផ្សារឥណទាននិងទីផ្សារហិរញ្ញវត្ថុ ការផ្តល់ជំនួយឥតសំណង(Grants) និងការពិចារណាចូលរួមវិនិយោគក្នុងក្រុមហ៊ុន ការបន្ត

ពង្រីកមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងការលើកទឹកចិត្តដល់វិស័យឯកជន ឱ្យវិនិយោគលើសហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី។

ទី៥- ការបង្កើនវិនិយោគសាធារណៈលើថ្នាលបច្ចេកវិទ្យាឌីជីថល ប្រព័ន្ធឡូជីស្ទិក និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី ដែលតភ្ជាប់និងស្ថិតនៅក្នុងសួនបណ្ដុំសហគ្រាសធុនមីក្រូ តូច និងមធ្យម តំបន់សេដ្ឋកិច្ចពិសេស ឬទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្រនានា និងការលើកទឹកចិត្តវិស័យឯកជនឱ្យវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។

ទី៦- ការរៀបចំនិងការដាក់ឱ្យអនុវត្តយន្តការលើកកម្ពស់វប្បធម៌សហគ្រិនភាពនិងធុរកិច្ច តាមរយៈការបញ្ជ្រាបការយល់ដឹងនិងគុណតម្លៃសហគ្រិនភាព ការច្នៃប្រឌិត ការបង្កើតថ្មី និងការទទួលយកហានិភ័យធុរកិច្ចដល់សាធារណជន។

ទី៧- ការរៀបចំនិងការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨។

### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងយន្តការផ្ដល់លិខិតអនុញ្ញាតបើកសហគ្រាសនិងសេវាសាធារណៈដទៃទៀតដែលគាំទ្រដល់អាជីវកម្មរបស់សហគ្រាស តាមរយៈប្រព័ន្ធអេឡិចត្រូនិក ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨
- បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ននិងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រនិងស្តង់ដា ដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្តនិងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដាកម្ពុជា
- ពិនិត្យលទ្ធភាពផ្ដល់ការបណ្ដុះបណ្ដាលនិងការវិនិយោគលើគ្រឿងម៉ាស៊ីននិងគ្រឿងបរិក្ខារផលិតកម្ម ដល់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងផ្ដល់ការលើកទឹកចិត្តផ្សេងទៀតដល់សហគ្រាសធុនតូចនិងមធ្យម ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មកែច្នៃខ្សែច្រវាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងក្រុមហ៊ុន/សាជីវកម្មពហុជាតិ

- ពង្រឹងសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ជួយគាំទ្រលើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រនិងស្តង់ដា ក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងអភិបាលកិច្ច
- បន្តកសាងនិងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះរួមនិងថ្នាលនវានុវត្តន៍ឌីជីថល ព្រមទាំងរៀបចំយន្តការផ្សេងៗ ដើម្បីដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស
- លើកកម្ពស់ការប្រើប្រាស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ក៏ដូចជាអភិវឌ្ឍវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យក្លាយជាកន្លែងប្រមូលផ្តុំគំនិតច្នៃប្រឌិត ការបង្កើតថ្មី និងនវានុវត្តន៍សម្រាប់បម្រើប្រយោជន៍ដល់វិស័យឧស្សាហកម្មនិងសិប្បកម្ម ជាពិសេសសហគ្រាសធុនមីក្រូ តូច និងមធ្យម។

**ទី២- ក្រសួងពាណិជ្ជកម្ម** បន្តពង្រឹងនិងពង្រីកទីផ្សារក្នុងស្រុកនិងអន្តរជាតិ សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មីៗ និងអាជីវកម្មនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មក្នុងការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាបណ្ណ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងចូលរួមលើកកម្ពស់វប្បធម៌សហគ្រិនភាព ធុរកិច្ច និងអាជីវកម្មនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការផ្តល់ការអនុគ្រោះគាំទ្រនានាដល់អាជីវកម្មទាំងនោះ រួមទាំងសេវាប្រឹក្សាយោបល់ សេវាសាធារណៈផ្សេងៗ ការបង្កើតក្រុមប្រឹក្សាធុរកិច្ច ការផ្តល់ការបណ្តុះបណ្តាលសមត្ថភាព និងការផ្តល់ព័ត៌មានទីផ្សារដល់វិស័យឯកជន។

**ទី៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី
- បន្តអនុវត្តកម្មវិធីថ្នាក់ជាតិស្តីអំពីធុរកិច្ចថ្មីកម្ពុជា ចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និងបន្តរៀបចំកម្មវិធីគាំទ្រដល់ធុរកិច្ចថ្មី ដូចជាការរៀបចំកម្មវិធីបណ្តុះពន្លកអាជីវកម្ម កម្មវិធីពន្លឿនអាជីវកម្មជាដើម
- បន្តអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ដើម្បីជំរុញការចាប់យកឌីជីថលរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម
- ផ្តល់ហិរញ្ញប្បទានដល់សហគ្រាស និងធុរកិច្ចថ្មី ដែលធ្វើសកម្មភាពអាជីវកម្មសហគ្រិនភាព និងនវានុវត្តន៍
- ផ្តល់ហិរញ្ញប្បទានសម្រាប់អភិវឌ្ឍជំនាញដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនពាក់ព័ន្ធនឹងការអភិវឌ្ឍអាជីវកម្ម និងជំនាញឌីជីថលជាដើម
- បន្តរៀបចំនិងអនុវត្តយន្តការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាស ធុរកិច្ចថ្មី និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

### ៣.៥.៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលជាយន្តការមិនអាចខ្វះបាននិងមានប្រសិទ្ធភាព ក្នុងការគាំទ្រពិពិធកម្មនិងកំណើន និងការបន្តពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ចំពោះការអនុវត្តគម្រោងវិនិយោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកធ្វើឱ្យសម្រេចទិសដៅគោលនយោបាយអាទិភាពសំខាន់ៗដូចខាងក្រោម៖

ទី១- ការបន្តបញ្ជ្រាបការយល់ដឹងនិងការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្ស នៅតាមក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងការរៀបចំ ការអភិវឌ្ឍ ការអនុវត្ត និងការគ្រប់គ្រង គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ទី២- ការជំរុញនិងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រទីផ្សារភាពជាដៃគូរវាងរដ្ឋនិងឯកជនតាមរយៈការរៀបចំបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុនិងការគាំទ្រពីរដ្ឋ ដែលកំណត់ដោយច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទី៣- ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ដោយផ្តោតលើគម្រោងផ្តួចផ្តើមដោយរដ្ឋ សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការផ្តល់សេវាសាធារណៈកាន់តែប្រសើរ សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការបន្ថយសម្ពាធថវិកាជាតិនិងបន្ទុកបំណុលសាធារណៈ។

ទី៤- ការបន្តជំរុញយន្តការសម្របសម្រួលកម្រិតអន្តរស្ថាប័ន ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យគម្រោង សំដៅពង្រឹងការវិភាគនិងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុសាធារណៈ។

ទី៥- ការបន្តរៀបចំយន្តការពិនិត្យនិងតាមដាន ការអនុវត្តកាតព្វកិច្ចរបស់រដ្ឋនិងឯកជនដោយអនុលោមតាមកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

#### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន២ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងពាណិជ្ជកម្ម** បន្តពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យឯកជននិងទីផ្សារ ធានាបាននូវចរាចរណ៍ទំនិញ និងនិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលលើទីផ្សារ តាមរយៈការបង្កើតទីផ្សារលក់ដុំ ការរៀបចំឱ្យមានអនុស្សរណៈយោគយល់គ្នារវាងរដ្ឋនិងឯកជនដើម្បីកែច្នៃផលិតផលកសិកម្មសម្រាប់បម្រើទីផ្សារក្នុងស្រុកនិងការនាំចេញ និង

ការបង្កើតឱ្យមានមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេសសម្រាប់ផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម វិនិយោគ វប្បធម៌ ទេសចរណ៍ និងផលិតផលសក្តានុពលកម្ពុជា។

**ទី២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តពិនិត្យនិងកែសម្រួលតាមការចាំបាច់នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ យន្តការស្ថាប័ន នីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរដ្ឋនិងឯកជន
- ពិនិត្យលទ្ធភាពលើការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងវិស័យសង្គមកិច្ច រួមមានហេដ្ឋារចនាសម្ព័ន្ធសេវាសុខភាពសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធអប់រំនិងកីឡាជាដើម។

## ៣.៥.៤- ការពង្រឹងការប្រកួតប្រជែង

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តជំរុញការប្រកួតប្រជែងស្មើភាព តាមរយៈការបន្តបង្កើតបរិយាកាសធ្វើធុរកិច្ចដោយស្មើភាព គ្មានការរើសអើង តាមនីតិវិធីដោយយុត្តិធម៌ និងស្របតាមអភិក្រម«**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**» សំដៅរួមចំណែកដល់ការបង្កើតមុខទំនិញនិងសេវាកម្មថ្មីៗ និងការបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចកម្ពុជា។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ការការពារកម្មសិទ្ធិឯកជនស្របច្បាប់ និងការទប់ស្កាត់រាល់ប្រតិបត្តិការនិងសកម្មភាពធុរកិច្ចទាំងឡាយ ដែលរារាំង រឹតត្បិត ឬបង្ខូច ដល់ការប្រកួតប្រជែងស្មើភាពនិងយុត្តិធម៌។

ទី២- ការបន្តពង្រឹងសមត្ថភាពស្ថាប័ន រៀបចំ និងអនុវត្ត គោលនយោបាយ និងនិយ័តកម្មទីផ្សារ និងរៀបចំយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើចរិតធុរកិច្ច និងលើការរួមបញ្ចូលគ្នានៃធុរកិច្ចរបស់សហគ្រាសដែលមាន ឬអាចមាន កម្មវត្ថុ ឬអានុភាព រារាំង រឹតត្បិត ឬបង្ខូច ដល់ការប្រកួតប្រជែង ឬបង្កើនអំណាចផ្តាច់មុខក្នុងទីផ្សារ(Monopoly Power)។

ទី៣- ការរៀបចំនិងការដាក់ចេញ យន្តការ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់ សម្រាប់គ្រប់គ្រងនិងដោះស្រាយ ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព ចំពោះការបង្កើត ឬការព្រមព្រៀង ឬសកម្មភាពឃុបឃិតនៃសហគ្រាស(Collusion) ក្នុងការកំណត់ភូមិសាស្ត្រលក់ទំនិញ ឬសេវាកម្ម ការរក្សា ឬការកំណត់ថ្លៃឱ្យខ្ពស់ជាងថ្លៃទីផ្សារប្រកួតប្រជែង ដែលប៉ះពាល់ដល់ការផលិតទំនិញនិងសេវាថ្មីៗ។

ទី៤- ការបន្តពង្រឹងការការពារ កម្មសិទ្ធិបញ្ញា និងទ្រព្យសម្បត្តិឯកជនស្របច្បាប់ ដើម្បីលើកកម្ពស់ការបង្កើតផលិតផលនិងសេវាកម្មថ្មីៗ ការច្នៃប្រឌិតនិងការធ្វើនវានុវត្តន៍ ក្នុងគោលបំណងធានាឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារ។

ទី៥- ការបន្តជំរុញ ការរៀបចំ ការអភិវឌ្ឍ ការធ្វើវិសោធនកម្ម និងការអនុវត្ត គោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការប្រកួតប្រជែង និងការបន្តពង្រឹងសមត្ថភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា យន្តការដោះស្រាយជម្លោះធុរកិច្ចនិងយន្តការការពារសិទ្ធិអ្នកប្រើប្រាស់ ស្របតាមស្តង់ដាគុណភាព សុវត្ថិភាព និងសុខភាព។

ទី៦- ការរៀបចំនិងការដាក់ចេញយន្តការការពារសិទ្ធិអ្នកប្រើប្រាស់ ឱ្យដើរតួនាទីចម្បងក្នុងការដោះស្រាយបញ្ហាជំនួសអ្នកប្រើប្រាស់ ក្នុងករណីមានវិវាទប្រតិបត្តិការទិញ លក់ ទំនិញ និងសេវាគ្រប់ប្រភេទ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័ន ទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន២ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងពាណិជ្ជកម្ម** បន្តពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងទីផ្សារជាតិនិងអន្តរជាតិ ដោយបង្កើតបរិយាកាសធុរកិច្ចស្មើភាពគ្មានការរើសអើង ដែលមានសុចរិតភាពក្នុងអាជីវកម្ម អនុលោមតាមនីតិវិធីត្រឹមត្រូវ ការពារកម្មសិទ្ធិឯកជនស្របច្បាប់ ការទប់ស្កាត់សកម្មភាពធុរកិច្ចទាំងឡាយដែលរារាំង រឹតត្បិតឬបង្ខូចដល់ការប្រកួតប្រជែងស្មើភាពនិងត្រឹមត្រូវ តាមរយៈការពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពទំនិញនិងសេវា ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ការរៀបចំយន្តការដោះស្រាយជម្លោះធុរកិច្ច និងការពារសិទ្ធិធុរជននិងអ្នកប្រើប្រាស់ ការពង្រឹងសមត្ថភាពគណៈកម្មការប្រកួតប្រជែងកម្ពុជា និងគណៈកម្មការកិច្ចការពារសិទ្ធិអ្នកប្រើប្រាស់ ការលើកកម្ពស់ពិពិធកម្មផលិតផលនិងសេវាកម្មថ្មីៗ ការច្នៃប្រឌិតនិងនវានុវត្តន៍ ដើម្បីធានាភាពប្រកួតប្រជែងក្នុងទីផ្សារនិងការបង្កើតយន្តការលើកស្ទួយម៉ាកទំនិញកម្ពុជា ពិសេសម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាព សំដៅជំរុញបង្កើនការនាំចេញ។

**ទី២- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ** បន្តជំរុញអនុវត្តគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ឆ្នាំ២០១៦-២០២៦ ដោយផ្តោតលើយុទ្ធសាស្ត្រជាអាទិភាពចំនួន៥ រួមមាន ១) ការអភិវឌ្ឍក្របខ័ណ្ឌឯកសារគតិយុត្ត ស្ថាប័ន និងធនធានមនុស្ស ២) ការស្រាវជ្រាវ ការអភិវឌ្ឍ ការចងក្រងផលិតផល និងការរៀបចំស្តង់ដាផលិតផល ៣) ការលើកកម្ពស់ការយល់ដឹង បទពិសោធ និងការផ្លាស់ប្តូរផ្នត់គំនិត ៤) ការជំរុញទីផ្សារសម្រាប់ផលិតផលភូមិមួយផលិតផលមួយ និង

ផលិតផលសក្ដានុពលក្នុងស្រុក និង៥) ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការលើកកម្ពស់ការចូលរួមពីភាគីពាក់ព័ន្ធ។

### ៣.៥.៥- ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យកាន់តែមានស័ក្តិសិទ្ធិភាព ភាពធន់នឹងវិបត្តិ បរិយាបន្ន ពិពិធភាព និងភាពទំនើប តាមរយៈការបន្តអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ជំរុញភាពស៊ីជម្រៅហិរញ្ញវត្ថុ ពង្រឹងសមត្ថភាពស្ថាប័ន និងអក្ខរកម្មហិរញ្ញវត្ថុ និងលើកស្ទួយឌីជីថលូបនីយកម្មក្នុងវិស័យហិរញ្ញវត្ថុ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ព្រមទាំងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ ដើម្បីបន្តអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងយន្តការសម្របសម្រួលនយោបាយ និងលើកស្ទួយតួនាទីអន្តរការិយកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ ការពង្រឹងសមត្ថភាពស្ថាប័ននិងមូលធនមនុស្ស ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុមិនមែនធនាគារ និងការធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុ។

ទី២- ការបន្តធានាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងយន្តការគ្រប់គ្រងនិងត្រួតពិនិត្យវិស័យធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ការបន្តប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការកាត់បន្ថយធនាគារស្រមោល និងការជំរុញបន្ថែមដល់ការប្រើប្រាស់ប្រាក់រៀល។

ទី៣- ការបន្តពង្រឹងអក្ខរកម្មហិរញ្ញវត្ថុ តាមរយៈការបន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន ការរៀបចំ កម្មវិធីសិក្សា និងការបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុ ដល់ម្ចាស់និងអ្នកគ្រប់គ្រងសហគ្រាស ជាពិសេសសហគ្រាសធុនមីក្រូ តូច និងមធ្យម និងការបន្តជំរុញការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS)។

ទី៤- ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈការជំរុញនិងការលើកទឹកចិត្ត ដល់ក្រុមហ៊ុនក្នុងស្រុក ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ ការបង្កើតយន្តការលើកទឹកចិត្តដល់វិនិយោគិនស្ថាប័ន ការបង្កើតប្រតិបត្តិករទីផ្សារមូលបត្រអនាគត និងការបង្កើតយន្តការគ្រប់គ្រងការជួញដូរទ្រព្យឌីជីថល។

ទី៥- ការជំរុញការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទ ដែលជាថ្នាលលើកកម្ពស់ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងយន្តការកំណត់អត្រាការប្រាក់អនាគត តាមរយៈការរៀបចំក្របខ័ណ្ឌគតិយុត្ត ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការទាក់ទាញតួអង្គផ្តល់សន្ទនីយភាព។

ទី៦- ការបន្តពង្រីកផលិតផលធានារ៉ាប់រង ជាពិសេសសេវាធានារ៉ាប់រងអាយុជីវិតនិងសេវាធានារ៉ាប់រងខ្នាតតូច តាមរយៈការកែសម្រួលក្របខ័ណ្ឌគតិយុត្ត ការរៀបចំស្តង់ដាចាំបាច់នានា ការពង្រឹងសមត្ថភាពនិយ័តករធានារ៉ាប់រង និងការបង្កើនការចូលរួមក្នុងទីផ្សារធានារ៉ាប់រង។

ទី៧- ការបន្តពង្រឹងវិស័យអភិវឌ្ឍអចលនវត្ថុ ជាពិសេសអាជីវកម្មអភិវឌ្ឍលំនៅឋាននិងអាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុនិងវិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន តាមរយៈការរៀបចំនិងការកែសម្រួលក្របខ័ណ្ឌគតិយុត្ត ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា ការពង្រឹង សមត្ថភាពមន្ត្រីជំនាញ និងអ្នកចូលរួមទីផ្សារ។

ទី៨- ការបន្តអភិវឌ្ឍវិស័យបរធនបាលកិច្ច ដោយជំរុញនិងពង្រឹងការអនុវត្តច្បាប់ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការអភិវឌ្ឍទីផ្សារ ប្រតិបត្តិករ និងផលិតផលបរធនបាលកិច្ចថ្មីៗ ព្រមទាំងការសិក្សា និងការបង្កើតយន្តការគ្រប់គ្រងនិងប្រតិបត្តិការ តាមនវានុវត្តន៍បច្ចេកវិទ្យា។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានស្ថាប័នចម្បងៗចំនួន៨ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ធនាគារជាតិនៃកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

**វិស័យធនាគារ**

- បន្តរក្សាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងអភិបាលកិច្ច ជំនាញ និងសមត្ថភាពរបស់ក្រុមការងារតាមដានស្ថិរភាពហិរញ្ញវត្ថុ ការពង្រឹងប្រព័ន្ធផ្តល់សញ្ញាជាមុន និងការរៀបចំនិងការវិភាគទិន្នន័យ និងព័ត៌មានចាំបាច់នានា
- ត្រៀមបង្ការនិងដោះស្រាយវិបត្តិ តាមរយៈការពង្រឹងការត្រួតពិនិត្យនានា ការរៀបចំក្របខ័ណ្ឌនីតិវិធីសហប្រតិបត្តិការដោះស្រាយវិបត្តិ និងការបង្កើតផែនការយថាភាពជាតិ
- សិក្សាពីលទ្ធភាពបង្កើតយន្តការការពារប្រាក់បញ្ញើរបស់អតិថិជន ដើម្បីបង្កើនជំនឿទុកចិត្តលើប្រព័ន្ធធនាគារកម្ពុជា
- អនុវត្តគោលការណ៍គ្រឹះស្នូលបាសែល(Basel) ស្តីពីការត្រួតពិនិត្យធនាគារនិងស្តង់ដាសកលដែលជាធាតុដ៏សំខាន់ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យវិស័យធនាគារ ដើម្បីគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធភាព
- ពង្រឹងបទប្បញ្ញត្តិស្តីពីអនុបាតភាពគ្រប់គ្រាន់នៃដើមទុននិងបទប្បញ្ញត្តិស្តីពីសកម្មភាពកែតម្រូវបន្ទាន់ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យធនាគារ សំដៅអនុវត្តឱ្យបានពេញលេញនូវវិធីសាស្ត្រត្រួតពិនិត្យធនាគារផ្អែកលើហានិភ័យ និងទស្សនៈអនាគត
- ជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត តាមរយៈការដាក់ចេញនូវគោលនយោបាយ និងវិធានការថ្មីៗសមស្របនិងមានប្រសិទ្ធភាព ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យបានជាអតិបរមា

- អភិវឌ្ឍទីផ្សារអន្តរធនាគារនិងបង្កើតឧបករណ៍រូបិយវត្ថុថ្មីៗ ដើម្បីកាត់បន្ថយការចំណាយលើថ្លៃដើមនិងលើកកម្ពស់ប្រសិទ្ធភាពនៃនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ
- លើកកម្ពស់ហិរញ្ញប្បទានដល់វិស័យដែលមានផលិតភាពខ្ពស់និងសហគ្រាសធុនតូចនិងមធ្យម
- គ្រប់គ្រងហានិភ័យនៃការសម្អាតប្រាក់ ដោយពង្រឹងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាលើការវាយតម្លៃហានិភ័យស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការត្រួតពិនិត្យពាក់ព័ន្ធនឹងអនុលោមភាពនានា
- លើកកម្ពស់សន្តិសុខសាយប័រនិងសុវត្ថិភាពនៃការគ្រប់គ្រងទិន្នន័យ ដើម្បីរក្សាស្ថិរភាព និងធានានូវការរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជា
- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីកាត់បន្ថយចំណាយក្នុងការធ្វើប្រតិបត្តិការនិងបង្កើនប្រសិទ្ធភាពនិងសុវត្ថិភាពនៃការទូទាត់ ដើម្បីលើកកម្ពស់អាជីវកម្ម ពាណិជ្ជកម្ម ការវិនិយោគ និងប្រតិបត្តិការទូទាត់ឆ្លងដែន
- ពិនិត្យឡើងវិញនូវតម្រូវការនៃការពង្រីកគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់ នៅក្នុងបទប្បញ្ញត្តិដែលមានស្រាប់ ដោយកំណត់ឱ្យច្បាស់នូវលក្ខខណ្ឌនានាចំពោះផលិតផលឥណទាន ការផ្សព្វផ្សាយពាណិជ្ជកម្ម នីតិវិធីប្តឹង និងតវ៉ា កម្រៃសេវា ការគណនាការប្រាក់ និងនីតិវិធីនៃការប្រមូលឥណទាន
- លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយ (១) ពង្រីកផលិតផលនិងសេវាហិរញ្ញវត្ថុទៅកាន់ទីជនបទ (២) ធ្វើទំនើបកម្មសេវាហិរញ្ញវត្ថុនានា ដើម្បីឱ្យអតិថិជននៅគ្រប់ទីកន្លែងមានលទ្ធភាព និងភាពងាយស្រួល ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និង(៣) លើកកម្ពស់ចំណេះដឹងឌីជីថល និងហិរញ្ញវត្ថុ ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានអត្ថប្រយោជន៍ពេញលេញពីបរិយាបន្នហិរញ្ញវត្ថុ
- ជំរុញហិរញ្ញវត្ថុបៃតង តាមរយៈ (១) ការរៀបចំផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុបៃតង (២) ការអភិវឌ្ឍប្រព័ន្ធវដ្តករសាស្ត្រ និងទីផ្សារហិរញ្ញវត្ថុបៃតង (៣) ការលើកទឹកចិត្តគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ហិរញ្ញប្បទានដល់គម្រោងបៃតង (៤) ការរៀបចំក្របខ័ណ្ឌវិភាគ និងវាយតម្លៃហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ និង(៥) ការកសាងសមត្ថភាព និងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធហិរញ្ញវត្ថុបៃតងជាដើម។

**វិស័យមីក្រូហិរញ្ញវត្ថុ**

- ធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិស្តីពីវិស័យមីក្រូហិរញ្ញវត្ថុនិងយុទ្ធសាស្ត្រស្តីពីបរិយាបន្នហិរញ្ញវត្ថុ
- ពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងរៀបចំផែនការលើកកម្ពស់ការប្រតិបត្តិតាមគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព សម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុរបស់គណៈកម្មាធិការបាសែល តាមរយៈការត្រួតពិនិត្យនិងការដាក់ចេញបទប្បញ្ញត្តិចាំបាច់នានាស្របតាមស្តង់ដាអន្តរជាតិ
- បន្តពង្រឹងការអនុវត្តច្បាប់ ដោយចាត់វិធានការតឹងរឹងចំពោះប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ដែលមិនព្រមចុះបញ្ជី និងបន្តធ្វើអាជីវកម្មខុសច្បាប់

- បន្តពង្រឹងចំណេះដឹងហិរញ្ញវត្ថុ ដោយបន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន ជាពិសេសប្រជាពលរដ្ឋនៅតំបន់ជនបទ ដើម្បីជំរុញឱ្យមានការយល់ដឹងអំពីវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ
- សិក្សាស្វែងរកប្រភពទុនដែលមានថ្លៃទាបនិងសិក្សាពីកត្តារួមផ្សំទាំងឡាយដែលធ្វើឱ្យថ្លៃដើមទុនខ្ពស់ និងរិះរកមធ្យោបាយ ដើម្បីបញ្ចុះអត្រាការប្រាក់ ដោយគោរពតាមយន្តការទីផ្សារ
- រៀបចំនិងដាក់ចេញឯកសារគតិយុត្តនានា ដើម្បីកាត់បន្ថយនិងឈានដល់ការលុបបំបាត់សកម្មភាពធនាគារស្រមោល ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុកម្ពុជា។

**ទី២- អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយយុទ្ធសាស្ត្រនិងអភិវឌ្ឍស្ថាប័ន តាមរយៈការបន្តសិក្សាស្រាវជ្រាវនិងអភិវឌ្ឍសូចនាករសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារជាប្រចាំ ព្រមទាំងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរហិរញ្ញវត្ថុក្នុងតំបន់
- បន្តអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការរៀបចំបទប្បញ្ញត្តិសំខាន់ៗ លើកកម្ពស់កំណើនទីផ្សារនវានុវត្តន៍ និងពិពិធកម្មផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ
- រៀបចំប្រព័ន្ធកិច្ចការពារអតិថិជន/អ្នកប្រើប្រាស់ តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់/លិខិតបទដ្ឋានគតិយុត្តកិច្ចការពារអតិថិជន/អ្នកប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- បន្តចូលរួមធានាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការរៀបចំច្បាប់ស្តីពីស្ថិរភាពហិរញ្ញវត្ថុ រៀបចំឱ្យមានប្រព័ន្ធផ្តល់សញ្ញាជាមុនក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងបន្តជំរុញអនុលោមភាព និងប្រសិទ្ធភាព ក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បន្តជំរុញប្រសិទ្ធភាពនៃប្រតិបត្តិការរបស់អ.ស.ហ. តាមរយៈការរៀបចំក្របខ័ណ្ឌបច្ចេកទេសបម្រើឱ្យការអនុវត្តការងារតាមដានត្រួតពិនិត្យនិងពង្រឹងសមត្ថភាពរបស់មន្ត្រី។

**ទី៣- និយ័តករធានារ៉ាប់រងកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់ការយល់ដឹងធានារ៉ាប់រងនិងអក្ខរកម្មស្តីពីធានារ៉ាប់រង
- អភិវឌ្ឍទីផ្សារធានារ៉ាប់រង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការអនុវត្តធានារ៉ាប់រងខ្នាតតូច និងពង្រីកផលិតផលធានារ៉ាប់រង
- រៀបចំនិងបន្តកែលម្អក្របខ័ណ្ឌត្រួតពិនិត្យ ជាពិសេសក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ
- រៀបចំបច្ចេកវិទ្យាធានារ៉ាប់រង តាមរយៈការសម្របសម្រួលប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យា និងអនុវត្តប្រព័ន្ធព័ត៌មានត្រួតពិនិត្យ
- កសាងសមត្ថភាព តាមរយៈការពន្លឿនការបង្កើតវិទ្យាស្ថានធានារ៉ាប់រងកម្ពុជា។

**ទី៤- និយ័តករមូលបត្រកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តកសាងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ
- បន្តពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យ ជាពិសេសបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសក្នុងវិស័យមូលបត្រ

- បន្តពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជាហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធជួញដូរនិងទូទាត់
- បន្តលើកកម្ពស់អ្នកចូលរួមទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការលើកទឹកចិត្តវិនិយោគិនផលបត្របរទេស និងជំរុញការអភិវឌ្ឍទីផ្សារមូលបត្រនិងទីផ្សារមូលបត្ររដ្ឋ។

**ទី៥- និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តរៀបចំបទប្បញ្ញត្តិនិងគោលនយោបាយពាក់ព័ន្ធ
- បន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន ជាពិសេសលើមុខងារនិយ័តកម្ម ដូចជាការបន្តតាមដាន និងការពង្រឹងអនុលោមភាពរបស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ
- ធ្វើទំនើបកម្មនិងកសាងប្រព័ន្ធទិន្នន័យគ្រប់ជ្រុងជ្រោយ ជាពិសេសតាមរយៈការរៀបចំប្រព័ន្ធបច្ចេកវិទ្យា ដើម្បីបំពេញរបាយការណ៍និងឯកសារផ្សេងៗពីក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងក្រុមហ៊ុនផ្ដល់សេវាអចលនវត្ថុ និងក្រុមហ៊ុន/សហគ្រាសបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន
- ពង្រឹងការបណ្ដុះបណ្ដាលនិងផ្សព្វផ្សាយ ជាពិសេសលើការយល់ដឹងពាក់ព័ន្ធដំណើរការនៃការទិញ លក់ ឬជួលអចលនវត្ថុ និងអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន និងពង្រឹងកិច្ចសហប្រតិបត្តិការ។

**ទី៦- និយ័តករគណនេយ្យនិងសវនកម្ម** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- កសាងសមត្ថភាពនិងជំរុញការផ្សព្វផ្សាយ ជាពិសេសលើការលើកកម្ពស់កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកិច្ចសហប្រតិបត្តិការក្នុងការដាក់បញ្ចូលកម្មវិធីសិក្សាជំនាញគណនេយ្យ
- អនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ
- ជំរុញការអនុវត្តស្តង់ដារបាយការណ៍អន្តរជាតិនៃកម្ពុជានិងស្តង់ដារបាយការណ៍ពាក់ព័ន្ធនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម
- រៀបចំប្លង់គណនីរួមនិងបង្កើតថ្នាលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

**ទី៧- និយ័តករបរធនបាលកិច្ច** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តកសាងសមត្ថភាពស្ថាប័ន តាមរយៈការរៀបចំនិងអនុវត្តសេចក្ដីណែនាំស្ដីពីនីតិវិធី និងទម្រង់បែបបទនៃលិខិតរដ្ឋបាលសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃនិយ័តករបរធនបាលកិច្ច និងរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងមន្ត្រីនិងឯកសារពាក់ព័ន្ធ
- បន្តពង្រឹងមុខងារស្ថាប័ន តាមរយៈការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យវិស័យបរធនបាលកិច្ច ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច និងបរធនបាល និងការលើកកម្ពស់និងការពង្រឹងការអនុវត្តច្បាប់
- លើកកម្ពស់ការបណ្ដុះបណ្ដាល ការអប់រំ និងការផ្សព្វផ្សាយ និងពង្រឹងកិច្ចសហប្រតិបត្តិការ។

**ទី៨- និយ័តករសន្តិសុខសង្គម** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃរបបសន្តិសុខសង្គមផ្នែកសោធនឱ្យស្របទៅនឹងស្តង់ដាអន្តរជាតិ ព្រមទាំងកែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់វិស័យសាធារណៈ តាមរយៈការរៀបចំផែនការសម្រាប់ការគ្រប់គ្រងរបបសន្តិសុខផ្នែកប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈ
- បន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន តាមរយៈការពង្រឹងកសាងសមត្ថភាពនិងការបណ្តុះបណ្តាលផ្ទៃក្នុងដល់មន្ត្រី ជាពិសេសលើគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ
- ពង្រីកវិសាលភាពរបបសន្តិសុខសង្គមឱ្យគ្របដណ្តប់ដល់បុគ្គល ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការរៀបចំនិងការបង្កើតរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ ជាពិសេសលើការអប់រំលើប្រព័ន្ធសន្តិសុខសង្គម។

## ៣.៦- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន

### ៣.៦.១-ការធ្វើសុកបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ

ការធ្វើសុកបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ មានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការជំរុញការទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមាពីភាគលាភប្រជាសាស្ត្រនិងការពង្រឹងភាពធន់ប្រជាសាស្ត្រ ដោយបន្តជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជននិងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារដឹកនាំ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួនដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តជំរុញពិពិធកម្មការងារដើម្បីស្រូបយកកម្លាំងពលកម្មរបស់យុវជន តាមរយៈការអភិវឌ្ឍជំនាញបច្ចេកទេស ការបង្កើនការវិនិយោគ និងការអភិវឌ្ឍវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយគិតគូរដល់ការអភិវឌ្ឍសហគ្រិនវ័យក្មេង សមភាពយេនឌ័រ និងស្វ័យធុរកិច្ច។

ទី២- ការបន្តពង្រឹងនិងការពង្រីកវិសាលភាពសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ ជាពិសេសស្ត្រីនិងក្មេងស្រី ការបន្តអនុវត្តកម្មវិធីគាំពារសង្គមដល់ស្ត្រីមានផ្ទៃពោះនិងកុមារនៃគ្រួសារក្រីក្រនិងការបន្តលើកកម្ពស់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះនិងកុមារ។

ទី៣- ការបង្កើតយន្តការនិងគម្រោងសន្សំប្រាក់ដើម្បីកាត់បន្ថយហានិភ័យអសន្តិសុខផ្នែកហិរញ្ញវត្ថុសម្រាប់វ័យចាស់និងដើម្បីជំរុញការវិនិយោគនាវ័យចាស់។

ទី៤- ការបង្កើនការវិនិយោគលើយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី នៅក្នុងវិស័យសេដ្ឋកិច្ច អប់រំ សុខភាព និងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័របង្កលក្ខណៈអំណោយផលដល់ស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិលើការសម្រេចចិត្តអំពីគ្រួសារនិងចំនួនកូន

កាត់បន្ថយភាពងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅលើស្ត្រីនិងក្មេងស្រី និងលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់។

ទី៥- ការជំរុញការដាក់ចេញនូវវិធានការគោលនយោបាយសមស្របនិងទាន់ពេល ដោយផ្តោតការគិតគូរដល់បម្រែបម្រួលប្រជាសាស្ត្រ ដែលស្តែងឡើងតាមបម្រែបម្រួលរចនាសម្ព័ន្ធអាយុប្រជាជន សំដៅធានាឱ្យអត្រាកំណើត អត្រាមរណភាព និងទេសន្តរប្រវេសន៍ ស្ថិតក្នុងស្ថានភាពអំណោយផលដោយមានកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងកិច្ចការនារី** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

**ក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រ**

- រៀបចំនិងដាក់ចេញនូវអភិក្រមបរិវត្តកម្មយេនឌ័រជាដំណាក់កាលទី៣នៃក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រ ព្រមទាំងរៀបចំគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ការធ្វើស្ថាបនូបនីយកម្មយេនឌ័រនិងការពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ
- លើកកម្ពស់កម្មវិធីសិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រនៅតាមវិស័យ និងស្របតាមការវិវត្តនៃសង្គម ព្រមទាំងរៀបចំគំនិតផ្តួចផ្តើមលើវិធានការគាំទ្រ និងកម្មវិធីនានា
- ពង្រឹងនិងពង្រីកការបញ្ជ្រាបយេនឌ័រ នៅក្នុងដំណើរការរៀបចំនិងអនុវត្តគោលនយោបាយ និងកម្មវិធីតាមវិស័យ រួមទាំងការអនុវត្តកម្មវិធីរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ
- ពង្រីកកម្មវិធីនិងវិសាលភាពក្នុងការផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថរបស់សង្គម ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
- ពង្រឹងប្រព័ន្ធនិងយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការបញ្ជ្រាបយេនឌ័រតាមវិស័យ

**ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី**

- ពង្រីកបរិយាកាសគាំទ្រនិងការវិនិយោគប្រកបដោយបរិយាបន្ន ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី
- ការអភិវឌ្ឍសហគ្រិនភាពស្ត្រីនិងគាំទ្រដល់ស្ត្រីដឹកនាំនិងគ្រប់គ្រងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ប្រកបដោយនវានុវត្តន៍ ច្នៃប្រឌិត និងបរិយាបន្ន
- ពង្រីកបរិយាកាសអំណោយផលសម្រាប់ស្ត្រី តាមរយៈការដោះស្រាយគម្លាតយេនឌ័រក្នុងជំនាញនិងមុខរបរ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈជូនតានិងជំនាញផ្សេងៗដល់ស្ត្រី ស្របតាមតម្រូវការទីផ្សារនិងការវិវត្តនៃសង្គម

- ជំរុញនិងលើកកម្ពស់ការគិតគូរពីសុខុមាលភាព កម្មវិធីតុល្យភាពជីវិត គ្រួសារ ការងារ និងបរិយាកាសមេត្រីភាពនៅកន្លែងការងារសម្រាប់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច
- លើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រីនៅតាមសហគមន៍ តាមរយៈ បច្ចេកវិទ្យាឌីជីថល ការអភិវឌ្ឍអាជីវកម្ម និងបរិយាបន្នហិរញ្ញវត្ថុ។

**ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ**

- ដឹកនាំនិងសម្របសម្រួលយន្តការអន្តរស្ថាប័ននៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងការលើកកម្ពស់ការអនុវត្តវិធានការពហុវិស័យ ដើម្បីបង្ការនិងទប់ស្កាត់គ្រប់ទិដ្ឋភាពអវិជ្ជមាន តាមរយៈការអនុវត្តវិធានការចាំបាច់នានា សំដៅចូលរួមលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- រៀបចំនិងសម្របសម្រួល ក្នុងការអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយលើការលើកកម្ពស់សីលធម៌តម្លៃស្ត្រីនិងគ្រួសារខ្មែរ តាមប្រព័ន្ធទំនើបនិងគ្រប់រូបភាព
- លើកកម្ពស់សុខុមាលភាពគ្រួសារ តាមរយៈកម្មវិធីចិញ្ចឹមកូនតាមបែបវិជ្ជមាននិងកម្មវិធីទារកដ្ឋាននៅកន្លែងធ្វើការ នៅតាមគ្រឹះស្ថានសាធារណៈនិងឯកជន ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ។

**ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រីនិងក្មេងស្រី**

- ធ្វើបរិវត្តកម្មយេនឌ័រនៅក្នុងវិស័យសុខាភិបាល រួមមានគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានា ដូចជាកម្មវិធីសុខភាពបន្តពូជ សុខភាពមាតាទារក សុខភាពផ្លូវចិត្ត សុខភាពភ្នែក អាហារូបត្ថម្ភ សន្តិសុខស្បៀង ជំងឺឆ្លង និងជំងឺមិនឆ្លង គ្រឿងញៀន និងគ្រឿងស្រវឹង
- លើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីយេនឌ័រនិងសុខភាព និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីឱ្យទៅទទួលយកសេវាសុខភាពប្រកបដោយគុណភាព
- អភិវឌ្ឍសមត្ថភាពមន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការទទួលខុសត្រូវលើការងារអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយេនឌ័រ និងសុខភាព
- ចូលរួមក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការរៀបចំនិងអនុវត្តក្របខ័ណ្ឌកិច្ចគាំពារសង្គម។

**កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី**

- បញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការតាក់តែងនិងអនុវត្តច្បាប់ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- រៀបចំនិងជំរុញការអនុវត្តក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងក្មេងស្រី
- រៀបចំសម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០២៤-២០៣០ ផែនការថ្នាក់ជាតិ តំបន់ និងអនុតំបន់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចនានា និងការប្រើប្រាស់គ្រឿងញៀន និងយន្តការឆ្លើយតបសេវាពហុវិស័យជួយជនរងគ្រោះនៅថ្នាក់ជាតិនិងក្រោមជាតិ

- ពង្រឹងការគ្រប់គ្រងករណីហិង្សាលើស្ត្រីនិងក្មេងស្រី និងពង្រឹងការអនុវត្តនិយាមប្រតិបត្តិបន្ទប់ផ្តល់សេវាចម្រុះនៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព
- ពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីពង្រឹងសមត្ថភាពនិងយុទ្ធនាការបង្ការទប់ស្កាត់អំពីហិង្សាលើស្ត្រីនិងក្មេងស្រី និងកម្មវិធីតាមប្រព័ន្ធឌីជីថល ដើម្បីទប់ស្កាត់និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះសេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- រៀបចំសម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារនិងការមានផ្ទៃពោះវ័យជំទង់។

**ស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច**

- ពង្រឹងការគាំទ្រផ្នែកគោលនយោបាយ យន្តការគាំទ្រ និងបរិយាកាសអំណោយផល ព្រមទាំងពង្រីកកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំនិងបណ្តាញរបស់ស្ត្រី ដើម្បីលើកកម្ពស់ស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់កម្រិតក្នុងវិស័យសាធារណៈនិងឯកជន
- លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី តាមរយៈការអនុវត្តកម្មវិធីនិងការផ្តួចផ្តើមថ្មីៗស្តីពីភាពជាអ្នកដឹកនាំរបស់ក្មេងស្រីនៅតាមគ្រឹះស្ថានសិក្សានិងសហគមន៍។

**ស្ត្រីនិងការប្រែប្រួលអាកាសធាតុ**

- បន្តបញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែងនិងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ព្រមទាំងពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ
- គាំទ្រនិងបង្កើតគំនិតផ្តួចផ្តើម ក្នុងការលើកកម្ពស់តួនាទីស្ត្រីនិងការឆ្លើយតបនឹងតម្រូវការស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងក្របខ័ណ្ឌកិច្ចគាំពារសង្គម
- រៀបចំកម្មវិធីគ្រប់គ្រងនិងចែករំលែកព័ត៌មានស្តីពីផលប៉ះពាល់យេនឌ័រ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

**ទី២- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំបណ្តុះបណ្តាលបុគ្គលិកអប់រំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ស្តីពីជំនាញបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ
- បង្កើនការយល់ដឹងនិងការផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃស្តង់ដា មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញការចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន
- រៀបចំផែនការរយៈពេលមធ្យម និងក្របខ័ណ្ឌសកម្មភាពចាំបាច់ដាក់ស្តែងសម្រាប់អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ជាពិសេសសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ

អភិវឌ្ឍផលិតផលថ្មី និងភ្ជាប់ខ្សែចង្វាក់តម្លៃទៅនឹងសាជីវកម្មពហុជាតិ និងបណ្តាញផលិតកម្មតំបន់

- បន្តរៀបចំយន្តការនិងយុទ្ធសាស្ត្រពង្រីកការបញ្ជ្រាបព័ត៌មាន ដើម្បីបង្កើនឱកាសក្លាយជាសហគ្រិនដល់សាធារណជន តាមរយៈការចែករំលែកព័ត៌មាន ក្នុងបណ្តុំអ្នកផលិត ធុរជន និងអ្នកប្រើប្រាស់
- រៀបចំនិងដាក់ឱ្យអនុវត្តយន្តការលើកកម្ពស់វប្បធម៌សហគ្រិន និងធុរកិច្ច តាមរយៈការបញ្ជ្រាបការយល់ដឹងនិងគុណតម្លៃសហគ្រិនភាព ការច្នៃប្រឌិត ការបង្កើតថ្មី និងការទទួលយកហានិភ័យធុរកិច្ចដល់សាធារណជន។

**ទី៣- ក្រសួងផែនការ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តជំរុញនិងសម្របសម្រួលការអនុវត្តគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ តាមរយៈការពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាព តាមដំណាក់កាល និងការពិនិត្យអំពីវឌ្ឍនភាពពាក់កណ្តាលអាណត្តិ ការផ្សព្វផ្សាយអំពីគោលនយោបាយប្រជាជន និងប្រជាសាស្ត្រ និងការលើកកម្ពស់ការយល់ដឹងអំពីការអភិវឌ្ឍសហគមន៍
- ជំរុញនិងសម្របសម្រួលការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាពសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ សំដៅ (១) បញ្ចប់តម្រូវការមិនបានឆ្លើយតបអំពីព័ត៌មាននិងសេវាផែនការគ្រួសារ (២) បញ្ចប់មរណភាពមាតាដែលអាចបង្ការបាន និងជំងឺទាក់ទងនឹងការមានកូន និង(៣) បញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនិងផ្លូវភេទ និងការអនុវត្តប្រកបដោយគ្រោះថ្នាក់នានា រួមទាំងការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រីនិងក្មេងស្រី
- ពង្រឹងសមត្ថភាពមន្ត្រីរបស់អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ តាមរយៈការបណ្តុះបណ្តាលជំនាញវិភាគ និងគណនាសូចនាករប្រជាសាស្ត្រសំខាន់ៗ និងសូចនាករភាគលាភប្រជាសាស្ត្រ និងសសរស្តម្ភទាំង៥ នៃភាគលាភប្រជាសាស្ត្រ(ការអប់រំ សុខភាព ការងារ សេដ្ឋកិច្ច និងអភិបាលកិច្ច) សម្រាប់គោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីភាគលាភប្រជាសាស្ត្រនិងបង្កើនសមត្ថភាពជំនាញស្រាវជ្រាវ។

## ៣.៦.២- ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព

គោលដៅជាយុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព គឺការផ្តោតលើការអភិរក្សដើម្បីការអភិវឌ្ឍ សំដៅលើកកម្ពស់វិភាគទានកិច្ចការនេះចំពោះ ការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ ការធានាចីរភាពធនធានព្រៃឈើ ជលផល និងគុណភាពដី ព្រមទាំងការការពារ ការអភិវឌ្ឍ និងការទាញយកប្រយោជន៍ ឱ្យអស់សក្តានុពលពីបេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព

ទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តជំរុញការអនុវត្ត«គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨» ដោយបន្តជំរុញ ការវិនិយោគក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម និងឧស្សាហកម្មគាំទ្រ ការរៀបចំផែនទី និងការកំណត់តំបន់សក្តានុពលធនធានរ៉ែនិងប្រេងកាត និងកិច្ចដំណើរការឡើងវិញនូវអណ្តូងប្រេងកាត ការបង្កើនប្រសិទ្ធភាពការប្រមូលចំណូលជាតិ ការលើកកម្ពស់អភិបាលកិច្ចក្នុងការគ្រប់គ្រងធនធាន និងការធ្វើអាជីវកម្មរ៉ែ ការបង្កើនការចូលរួម និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និងការកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់បរិស្ថាននិងសង្គម និងការពង្រឹងយន្តការអភិរក្សនិងគ្រប់គ្រងអាជីវកម្មខ្សាច់ ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថាន ជាពិសេសការបាក់ច្រាំងទន្លេ។

ទី២- ការពង្រឹងការគ្រប់គ្រង ការអភិរក្ស ការការពារ និងការអភិវឌ្ឍ ប្រកបដោយសុខដុមនីយកម្ម និងចីរភាពនូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗរបស់កម្ពុជា តាមរយៈការបន្តគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ ដោយរក្សាគម្របព្រៃឈើឱ្យលើស៦០% នៃផ្ទៃប្រទេស ការស្តារព្រៃឈើឡើងវិញ ការទប់ស្កាត់ និងការឆ្លើយតបទាន់ពេលទៅនឹងភ្លើងឆេះព្រៃ និងការអភិរក្សតំបន់ដីមមោក ការលើកកម្ពស់ការអភិវឌ្ឍចម្ការដែលមានភាតរបរិស្ថាននិងប្រកបដោយចីរភាព ការកាត់បន្ថយការពឹងផ្អែកលើការដកហូតអនុផលព្រៃឈើដោយចីរភាព ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីព្រៃ និងដីតំបន់ការពារធម្មជាតិធ្វើជាកម្មសិទ្ធិ ការលើកកម្ពស់ការអភិរក្សតំបន់ការពារធម្មជាតិ ព្រៃឈើ និងសត្វព្រៃ និងការបង្ក្រាបបទល្មើសព្រៃឈើ ការជួញដូរសត្វព្រៃ និងបទល្មើសធនធានធម្មជាតិ។

ទី៣- ការលើកកម្ពស់ការគ្រប់គ្រងធនធានជលផល តាមរយៈការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រ វិស័យជលផល ការជំរុញការបង្កើនវារីវប្បកម្ម ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍នេសាទ ការជំរុញការអភិវឌ្ឍសមត្ថភាព និងបច្ចេកវិទ្យា ដើម្បីកែលម្អគុណភាពជលផល ការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល និងការលើកកម្ពស់ការនាំចេញ និងការពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់។

ទី៤- ការលើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម តាមរយៈការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ទប់ស្កាត់ការរេចរឹលដី និងបង្កើនផលិតភាពដី។

ទី៥- ការជំរុញការប្រើប្រាស់ធនធានដី ប្រកបដោយចីរភាព តាមរយៈការពង្រឹងការអនុវត្តផែនការប្រើប្រាស់ដីថ្នាក់ជាតិ ការបោះបង្គោលព្រំ និងការកំណត់បែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីតំបន់ការពារធម្មជាតិ ក៏ដូចជាការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ស្របតាមផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ទី៦- ការជំរុញការថែរក្សាប្រព័ន្ធអេកូឡូស៊ី ការការពារជីវចម្រុះ និងការការពារតំបន់ធម្មជាតិ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ការធ្វើទំនើបកម្ម និងឌីជីថលូបនីយកម្មទិន្នន័យព័ត៌មាន និងភូមិសាស្ត្រតំបន់ការពារធម្មជាតិ ការលើកទឹកចិត្តឱ្យមានការទូទាត់

សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាបាននូវនិរន្តរភាពហិរញ្ញវត្ថុក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសធនធានធម្មជាតិ ការប្រើប្រាស់ដំណោះស្រាយតាមបែបធម្មជាតិ និងការធ្វើបច្ចុប្បន្នកម្មគម្របព្រៃឈើ តំបន់ដីសើម តំបន់ដីមមោក ព្រៃកោងកាង ដីលិចទឹកធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗផ្សេងទៀត។

ទី៧- ការជំរុញការអភិវឌ្ឍជីវភាពសហគមន៍ ក្នុងតំបន់ការពារធម្មជាតិ ដោយផ្សារភ្ជាប់ទៅនឹងទេសចរណ៍ តាមរយៈការប្រែក្លាយតំបន់ការពារធម្មជាតិទៅជាតំបន់ទេសចរណ៍ ការពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នៅក្បែរតំបន់ការពារធម្មជាតិ និងសមភាពនៃការបែងចែកប្រយោជន៍។

ទី៨- ការអនុវត្តអភិក្រមនៃការគ្រប់គ្រងធនធានវប្បធម៌ ដោយរក្សាតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស ជាពិសេសការអភិវឌ្ឍវប្បធម៌មានភាពច្នៃប្រឌិត ដែលមានរួមបញ្ចូលសមាសធាតុនៃវប្បធម៌បែបប្រពៃណី ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការអភិរក្ស។

ទី៩- ការបន្តពង្រឹងប្រសិទ្ធភាពនៃការអភិរក្សមរតកវប្បធម៌ ទាំងរូបីនិងអរូបី តាមរយៈការជួសជុល ការថែរក្សានៅទីមានសុវត្ថិភាព ការសម្អាត ការចុះបញ្ជីសារពើភណ្ឌ ការចុះបញ្ជីក្នុងប្រព័ន្ធទិន្នន័យ និងការរៀបចំសលាកបត្រកាន់កាប់និងប្លង់កម្មសិទ្ធិរដ្ឋ ការរៀបចំស្នើចុះបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងបេតិកភណ្ឌធម្មជាតិ និងភូគព្ភឧទ្យានទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ និងបញ្ជីបេតិកភណ្ឌសកលលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ បញ្ជីស្មារតីចងចាំសកលលោក និងបញ្ជីបេតិកភណ្ឌផ្សេងៗទៀតរបស់អង្គការយូណេស្កូនិង/ឬស្ថាប័នអន្តរជាតិផ្សេងទៀត ការជំរុញយុទ្ធនាការផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ទាំងនេះ នៅក្នុងតំបន់និងសកលលោក និងការបន្តយកចិត្តទុកដាក់ស្តារនិងពង្រឹងមរតកវប្បធម៌អរូបី ដែលបានបាត់បង់ឬកំពុងប្រឈមនឹងការបាត់បង់។

ទី១០- ការរៀបចំនិងការអនុវត្ត គោលនយោបាយអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងវប្បធម៌កម្ពុជាសម្រាប់រយៈពេលមធ្យមនិងវែង ក្រោមអភិក្រម«**អភិវឌ្ឍដើម្បីអភិរក្សនិងអភិរក្សដើម្បីអភិវឌ្ឍ**» ដើម្បីធ្វើសុភបរមូបនីយកម្មនៃការទាក់ទាញភ្ញៀវទេសចរ និងរយៈពេលស្នាក់នៅ តាមរយៈទេសចរណ៍ផ្សារភ្ជាប់ទឹក ដី និងធម្មជាតិ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៧ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងបរិស្ថាន** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ តាមរយៈការវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ការវាយតម្លៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការពង្រឹងយន្តការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ

និងវិស័យឯកជន និងការផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព សេចក្តីណែនាំ សេចក្តីសម្រេច និងរបាយការណ៍បច្ចេកទេសស្តីពីបរិស្ថាន

- លើកកម្ពស់ការផ្សព្វផ្សាយ តាមរយៈការបង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ការពង្រឹងមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធទិន្នន័យបរិស្ថាន ការលើកទឹកចិត្តសាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន នីតិបុគ្គល និងរូបវន្តបុគ្គល ដែលបានចូលរួមក្នុងសកម្មភាពមេត្រីបរិស្ថាន និងការលើកកម្ពស់ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក
- ពង្រឹងការត្រួតពិនិត្យការបំពុល តាមរយៈការបង្កើនការតាមដានការអនុវត្តច្បាប់និងផែនការគ្រប់គ្រង និងកិច្ចសន្យាទាំងឡាយណាដែលទាក់ទងនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ការតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ផែនការគ្រប់គ្រង និងកិច្ចសន្យាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ ការធ្វើទំនើបកម្មនៃការគ្រប់គ្រងគុណភាពបរិស្ថាន ជំរុញការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាមផ្សារភ្ជាប់ទៅនឹងការអនុវត្តគោលនយោបាយ វិមជ្ឈការនិងវិសហមជ្ឈការ និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល និងការពង្រឹងការសិក្សាស្រាវជ្រាវលើទីតាំងបុរាណវត្ថុនិងស្ថានីយផូស៊ីល ទាំងក្នុងនិងក្រៅតំបន់ការពារ
- លើកកម្ពស់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ តាមរយៈការពង្រឹងការគ្រប់គ្រងឧទ្យានជាតិដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់បេតិកភណ្ឌធម្មជាតិ និងឧទ្យានជាតិសមុទ្រ ការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ ការពង្រឹងយន្តការតាមដានការផ្លាស់ប្តូរគម្របព្រៃឈើ ការពង្រីកគម្របព្រៃឈើ និងការស្តារគម្របព្រៃឈើ ការរៀបចំ និងការកែសម្រួលឯកសារច្បាប់សម្រាប់គាំទ្រនិងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនិងបេតិកភណ្ឌវប្បធម៌ ការពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិនិងគណៈកម្មាធិការសហគមន៍លើការអនុវត្តកសិរុក្ខផល ការប្រមូលផលនិងការកែច្នៃព្រៃឈើប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងសហគមន៍លើតំបន់ការពារធម្មជាតិ និងការពង្រឹងប្រតិបត្តិការនិងការគ្រប់គ្រងបណ្តាញសហគមន៍តំបន់ការពារនិងបណ្តាញស្ត្រីក្នុងតំបន់ការពារ
- ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន តាមរយៈការលើកកម្ពស់សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការរស់នៅស្អាតរបស់ប្រជាសហគមន៍ ការផ្សព្វផ្សាយនិងការបង្កើតគោលដៅកម្សាន្តបៃតង ការពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ ការលើកកម្ពស់ការអភិរក្សប្រពៃណីនិងទំនៀមទម្លាប់របស់សហគមន៍មូលដ្ឋាន ជាពិសេសជនជាតិដើមភាគតិចនៅតំបន់ការពារ និងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើការផ្សព្វផ្សាយការបង្កើត ការគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍតំបន់បេតិកភណ្ឌធម្មជាតិនិងធនធានធម្មជាតិ។

**ទី២- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពង្រឹងការការពារដីរដ្ឋ តាមរយៈការបន្តការចុះបញ្ជីដីរដ្ឋនិងការពង្រឹងការគ្រប់គ្រងដីព្រៃ ព្រៃលិចទឹក ព្រៃកោងកាង និងតំបន់គ្រប់គ្រងជលផល ដីសម្បទាន ក៏ដូចជាការលើកកម្ពស់ការគ្រប់គ្រង និងការថែរក្សាធនធានដីកសិកម្ម ដើម្បីទប់ស្កាត់ការធ្លាក់ចុះគុណភាពដី ការរេចរឹលដី ការហូរច្រោះដី ការខ្សោះជីវជាតិ គុណភាពទឹក ស្ថានីយជម្រាល សេវាកម្មអេកូឡូស៊ី និងផលិតភាព និងសុខភាពដី និងកាបូនស្តុកក្នុងដី
- ពង្រឹងយន្តការស៊ើបអង្កេតប្រឆាំងបទល្មើសធនធានធម្មជាតិ តាមរយៈការពង្រឹងបណ្តាញបញ្ជូនព័ត៌មានរហ័សពាក់ព័ន្ធបទល្មើសធនធានធម្មជាតិ ការកំណត់អត្តសញ្ញាណជនល្មើស ការអង្កេតដានបទល្មើស ការស្រាវជ្រាវ និងការស៊ើបអង្កេត ដើម្បីធ្វើការព្រមាននិងចាត់វិធានការ និងការពង្រឹងការអនុវត្តច្បាប់ឱ្យម៉ឺងម៉ាត់ និងចាត់វិធានការទាន់ពេល
- ដោះស្រាយបញ្ហាតម្រូវការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈការសិក្សាលើតម្រូវការប្រើប្រាស់ធនធានធម្មជាតិ ការកំណត់យន្តការដោះស្រាយតាមតម្រូវការប្រើប្រាស់និងទីផ្សារ ការពង្រឹងការសិក្សាស្រាវជ្រាវ ការវាយតម្លៃ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានធម្មជាតិកសិកម្ម និងការកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិ ដោយបង្វែរទៅជាការអនុវត្តប្រព័ន្ធកសិរុក្ខកម្ម
- បង្កើតមូលនិធិអភិរក្សធនធានកសិកម្ម តាមរយៈការកំណត់ប្រភពមូលនិធិអភិរក្សធនធានកសិកម្ម ការកៀរគរ និងការប្រមូលមូលនិធិពីគ្រប់ប្រភព រួមទាំងវិស័យឯកជននិងដៃគូអភិវឌ្ឍ និងការពង្រឹងការគ្រប់គ្រងមូលនិធិអភិរក្សរបស់សហគមន៍កសិកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ។

**ទី៣- ក្រសួងរ៉ែនិងថាមពល** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- សិក្សាស្រាវជ្រាវភូគព្ភសាស្ត្រនិងចងក្រងទិន្នន័យធនធានរ៉ែ ដើម្បីធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃសក្តានុពលសេដ្ឋកិច្ចធនធានរ៉ែ សម្រាប់ជាប្រយោជន៍ដល់ការផ្សព្វផ្សាយទាក់ទាញវិនិយោគ ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់កំណត់តំបន់ផ្តល់អាជ្ញាបណ្ណធនធានរ៉ែនិងរៀបចំតំបន់សក្តានុពលរ៉ែ ថ្មសំណង់ និងខ្សាច់សំណង់
- កសាងផែនទីបង្ហាញទីតាំងប្រតិបត្តិការធនធានរ៉ែនិងទីតាំងដែលមានសក្តានុពលសម្រាប់ប្រតិបត្តិការធនធានរ៉ែ ដើម្បីសម្រួលដល់វិនិយោគិន ដែលមានបំណងវិនិយោគក្នុងវិស័យរ៉ែ
- បន្តរៀបចំធ្វើបច្ចុប្បន្នកម្មនិងពង្រឹងអនុលោមភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពនៃការដ្ឋានអណ្តូងរ៉ែ
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងអាជ្ញាបណ្ណនិងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ និងសម្រាប់ការប្រកាសបង់កាតព្វកិច្ចហិរញ្ញវត្ថុពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការធនធានរ៉ែតាមប្រព័ន្ធអនឡាញ

- បន្តពង្រឹងការគ្រប់គ្រងនិងត្រួតពិនិត្យការធ្វើប្រតិបត្តិការធនធានរ៉ែ និងសហការជាមួយក្រសួង ស្ថាប័នអង្គភាពពាក់ព័ន្ធ ពង្រឹងការកៀរគរចំណូលនិងទប់ស្កាត់ការលេចធ្លាយចំណូលជាតិពីវិស័យរ៉ែ
- លើកកម្ពស់លទ្ធភាពទទួលផលនិងឱកាសសេដ្ឋកិច្ចរបស់សហគមន៍ ក្នុងតំបន់ប្រតិបត្តិការធនធានរ៉ែ តាមរយៈការកសាងសមត្ថភាព ការប្រើប្រាស់ផលិតផលសេវា និងកម្លាំងពលកម្មក្នុងស្រុក
- បន្តជំរុញការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន ដើម្បីអភិវឌ្ឍសហគមន៍មូលដ្ឋានដែលមានប្រតិបត្តិការធនធានរ៉ែ
- សិក្សាវាយតម្លៃធនធានប្រេងកាតនិងកសាងផែនទីភូគព្ភសាស្ត្រប្រេងកាត។

**ទី៤- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តការងារអភិរក្សសំណង់បេតិកភណ្ឌ តាមរយៈការជួសជុលនិងវិធីសាស្ត្រផ្សេងៗ ជាពិសេសការស្តារឱ្យមានរូបរាងឡើងវិញរបស់សំណង់បេតិកភណ្ឌសំខាន់ៗ ដែលបាត់រូបរាងឬស្ទើរតែបាត់រូបរាង ដោយសារកត្តាមនុស្ស ធម្មជាតិ និងអាយុកាល
- បន្តការអភិរក្សវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រ តាមរយៈការជួសជុលនិងវិធីផ្សេងៗ រួមទាំងការតាមដាននិងសិក្សាស្រាវជ្រាវទិដ្ឋភាពច្បាប់ ដើម្បីទាមទារយកត្រឡប់មកវិញនូវវត្ថុបុរាណ ដែលកំពុងរក្សាទុកឬចរាចរ ដោយខុសច្បាប់ ទាំងនៅក្នុងនិងក្រៅប្រទេស
- បន្តការងារអភិរក្សបុរាណដ្ឋាន តាមរយៈការបង្កើននិងពន្លឿនការធ្វើបណ្ណកម្មសិទ្ធិរដ្ឋ ការបោះបង្គោលការពារ ការកាត់បន្ថយបទល្មើសតាមបុរាណដ្ឋាន និងការរៀបចំគោលការណ៍ណែនាំស្តីពីការអភិរក្ស
- បន្តយកចិត្តទុកដាក់លើការងារអភិរក្សនិងលើកស្ទួយមរតកវប្បធម៌អរូបី ដោយផ្តោតលើការស្តារនិងការពង្រឹងមរតកវប្បធម៌អរូបីដែលបានបាត់បង់ឬកំពុងប្រឈមនឹងការបាត់បង់ឱ្យរស់ឡើងវិញ និងបន្តមានវត្តមានដោយចីរភាពនៅក្នុងសង្គម ការពង្រឹងស្នាដៃសិល្បៈវប្បធម៌ឱ្យបានត្រឹមត្រូវតាមក្បួនខ្នាតខ្មែរ ការដំឡើងស្នាដៃសិល្បៈទស្សនីយភាពបុរាណនិងប្រពៃណី ការថែរក្សា និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ជាពិសេសសិល្បៈវប្បធម៌របស់ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ ជាដើម
- បន្តលើកកម្ពស់ការផ្សព្វផ្សាយសិល្បៈវប្បធម៌កម្ពុជា តាមរយៈការបញ្ជូនក្រុមសិល្បៈទៅសម្តែងក្នុងកម្មវិធីនានា រួមទាំងការជំរុញគាំទ្រអ្នកមានទេពកោសល្យនិងអ្នកមានជំនាញផ្នែកសិល្បៈគ្រប់ទម្រង់របស់កម្ពុជា ដើម្បីចូលរួមលើកកម្ពស់អត្តសញ្ញាណជាតិ កិត្យានុភាពជាតិ អំណាចទន់ និងមុខមាត់របស់ជាតិ
- បន្តពិនិត្យលទ្ធភាពនិងរៀបចំឯកសារស្នើសុំចុះបេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រកម្ពុជាទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ បញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

បញ្ជីស្មារតីចងចាំពិភពលោក បញ្ជីបណ្តាញទីក្រុងដែលមានភាពច្នៃប្រឌិត បញ្ជីត្រៀម និងបញ្ជីពាក់ព័ន្ធវិស័យវប្បធម៌ផ្សេងៗទៀតរបស់អង្គការយូណេស្កូ រួមទាំងរបស់ស្ថាប័នអន្តរជាតិនានា

- បន្តពង្រឹងនិងពង្រីកប្រព័ន្ធនិងយន្តការការងារឱ្យមានភាពប្រទាក់ក្រឡាគ្នាជាយុទ្ធសាស្ត្រ រួមទាំងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ជាពិសេស យន្តការអោយស៊ីស៊ីអង្គរ ព្រះវិហារ និងសម្បូណ៌ព្រៃគុក ដើម្បីកៀរគរថវិកានិងបច្ចេកទេសសម្រាប់គាំទ្រដល់ការងារអភិរក្ស និងការលើកស្ទួយមរតកវប្បធម៌ជាតិ ដោយផ្តោតលើគម្រោងវិនិយោគសាធារណៈនិងគម្រោងជំនួយបច្ចេកទេសសំខាន់ៗ។

**ទី៥- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈការបង្កើនចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយដល់សាធារណជននិងភាគីពាក់ព័ន្ធ ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការពង្រឹងគុណភាពនិងការពង្រីកបន្ថែមនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ និងការវាយតម្លៃហានិភ័យពហុមុខសញ្ញាគ្រោះថ្នាក់
- ពង្រឹងអភិបាលកិច្ច ដើម្បីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការរៀបចំស្ថាប័ន និងថវិកាសម្រាប់គ្រប់គ្រង និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការចាត់បញ្ចូលនិងសម្របសម្រួលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការអនុវត្តកម្មវិធីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការគាំទ្របច្ចេកទេសនិងធានាលើផ្នែកហិរញ្ញវត្ថុសមស្របក្នុងការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការលើកកម្ពស់យន្តការសម្រាប់បរិយាបន្នហិរញ្ញវត្ថុ
- បង្កើនការវិនិយោគក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់ភាពធន់ តាមរយៈ ការលើកកម្ពស់ភាពធន់ការងារសាងសង់និងស្តង់ដាហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងសមត្ថភាពសេវាកម្មនៃភ្នាក់ងារផ្តល់សេវាសង្គម រួមទាំងការគាំពារសង្គមនិងសំណាញ់សុវត្ថិភាព ការលើកកម្ពស់ការចូលរួមពីវិស័យឯកជន ធុរកិច្ច សម្រាប់ភាពធន់អាកាសធាតុ និងគ្រោះមហន្តរាយ
- បង្កើនការត្រៀមខ្លួនជាស្រេចទៅនឹងគ្រោះមហន្តរាយសម្រាប់ប្រសិទ្ធភាពនៃការឆ្លើយតប ការស្តារឡើងវិញ ការធ្វើឱ្យមានប្រក្រតីភាព និងការកសាងឡើងវិញ ដោយបង្កើនប្រព័ន្ធប្រកាសឱ្យដឹងមុនអំពីពហុមុខសញ្ញាគ្រោះថ្នាក់ ពង្រឹងសមត្ថភាពឆ្លើយតបគ្រោះមហន្តរាយ និងការស្តារឡើងវិញ ពង្រឹងការត្រៀមខ្លួនជាស្រេចសម្រាប់ការឆ្លើយតបគ្រោះអាសន្នពាក់ព័ន្ធសុខភាពសាធារណៈ និងកិច្ចគាំពារសង្គម ពង្រឹងសមត្ថភាពមន្ត្រីលើការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបង្កើនប្រសិទ្ធភាពការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

**ទី៦- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- គាំទ្រនិងពង្រឹងកិច្ចប្រតិបត្តិការការងារ និងការគ្រប់គ្រងធនធានទឹកនិងអាងទន្លេ ប្រកបដោយប្រសិទ្ធភាព

- លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ ដើម្បីធានាបានការអភិវឌ្ឍនិងការគ្រប់គ្រងអាងទន្លេប្រកបដោយចីរភាព
- លើកកម្ពស់ការយល់ដឹងជាសាធារណៈនិងការផ្សព្វផ្សាយ ដើម្បីពង្រឹងការចូលរួមនិងការប្រើប្រាស់ផលិតផលគណៈកម្មការទន្លេមេគង្គសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍតាមវិស័យ។

**ទី៧- ក្រសួងទេសចរណ៍** នឹងអនុវត្តសកម្មភាពដូចខាងក្រោម៖

- លើកកម្ពស់និរន្តរភាពសង្គមពីទេសចរណ៍ តាមរយៈការបង្កើនប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន និងការបង្កើតបច្ច័យវិជ្ជមានដល់វិស័យដទៃទៀត ពិសេសវិស័យកសិកម្ម ជលផល និងសិប្បកម្ម ការលើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ការអភិវឌ្ឍសហគ្រិនភាពនិងជំនាញវិជ្ជាជីវៈទេសចរណ៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីទាញយកផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍ចាំបាច់និងផ្តល់ប្រជាពលរដ្ឋនិងយុវជននូវជំនាញច្បាស់លាស់ និងការពង្រឹងគុណភាពបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍
- អភិរក្សនិងលើកកម្ពស់វប្បធម៌ផ្សារភ្ជាប់នឹងវិស័យទេសចរណ៍ តាមរយៈការពង្រឹងយន្តការគ្រប់គ្រងលំហូរភ្ញៀវទេសចរនៅតំបន់បេតិកភណ្ឌវប្បធម៌និងការគ្រប់គ្រងសម្បត្តិបេតិកភណ្ឌវប្បធម៌ ការរៀបចំផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍តំបន់បេតិកភណ្ឌវប្បធម៌ ការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ការបញ្ជ្រាបការយល់ដឹងដល់ភ្ញៀវទេសចរអំពីវប្បធម៌បេតិកភណ្ឌ និងការបំផុសចលនាទេសចរណ៍ក្នុងស្រុកផ្សារភ្ជាប់នឹងទេសចរណ៍វប្បធម៌
- គ្រប់គ្រងផលប៉ះពាល់អវិជ្ជមានពីវិស័យទេសចរណ៍ តាមរយៈការពង្រឹងការអប់រំ និងការយល់ដឹងជាសាធារណៈអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តដល់ប្រតិបត្តិករទេសចរណ៍និងទេសចរនិងការពង្រឹងប្រព័ន្ធគ្រប់គ្រងការអនុវត្តច្បាប់និងការត្រួតពិនិត្យលើសកម្មភាពទេសចរណ៍ ប្រកបដោយការទទួលខុសត្រូវ
- ជំរុញអភិវឌ្ឍផលិតផលទេសចរណ៍បៃតង តាមរយៈការជំរុញការអភិវឌ្ឍអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍ ការជំរុញចលនាប្រឡងប្រណាំង «ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ» ការជំរុញយុទ្ធនាការដាំដើមឈើនិងការបង្កើតសួនទេសចរណ៍ ការអនុវត្តស្តង់ដាបៃតងក្នុងឧស្សាហកម្មទេសចរណ៍ឱ្យស្របតាមស្តង់ដាបៃតងកម្ពុជានិងអាស៊ាននិងការរៀបចំអភិវឌ្ឍន៍គោលដៅទេសចរណ៍បៃតង
- លើកកម្ពស់យុទ្ធនាការ «កម្ពុជាជាគោលដៅស្អាតនិងបៃតង» តាមរយៈការបង្កើនការអប់រំនិងការយល់ដឹងអំពីចីរភាពបរិស្ថាន ភាពស្អាត បៃតង សណ្តាប់ធ្នាប់ និងអនាម័យល្អ ការពង្រឹងពង្រីកយុទ្ធនាការកាត់បន្ថយសំរាមប្លាស្ទិកនិងបង្គន់សាធារណៈស្អាត និងការលើកកម្ពស់ការបញ្ចូលភាពបៃតងក្នុងឧស្សាហកម្មទេសចរណ៍ និងការប្រើប្រាស់បច្ចេកវិទ្យាបៃតង។

### ៣.៦.៣- ការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ

គោលដៅជាយុទ្ធសាស្ត្រនៃការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ គឺការបន្តពង្រឹងតួនាទី និងការអភិវឌ្ឍវិស័យកសិកម្មឱ្យទំនើប សម្បូរបែប និងមានភាពធន់ ដែលគាំទ្រដល់ការអភិវឌ្ឍជនបទ សំដៅធានាសន្តិសុខនិងសុវត្ថិភាពស្បៀង បង្កើនតម្លៃបន្ថែមខ្ពស់ ជំរុញភាពប្រកួតប្រជែង និងលើកកម្ពស់គុណភាពជីវភាពនៅជនបទ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តកសាងក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងពង្រឹងស្ថាប័ន ដើម្បីគាំទ្រនិងបង្កបរិយាកាសអំណោយផល សម្រាប់វិស័យកសិកម្ម។

ទី២- ការជំរុញផលិតកម្មកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព គុណភាព សុវត្ថិភាព ពិពិធភាព តម្លៃបន្ថែម និងភាពធន់ តាមរយៈការស្រាវជ្រាវនិងការអភិវឌ្ឍ ពូជដំណាំ ពូជសត្វ និងវារីវប្បកម្ម ដែលធន់នឹងអាកាសធាតុនិងឆ្លើយតបនឹងតម្រូវការទីផ្សារ ការគ្រប់គ្រងនិងការពង្រឹងគុណភាពដី ការកំណត់តំបន់ដាំដុះនិងការកសាងផែនទីដាំដុះ ការបន្តជំរុញសេវាធានារ៉ាប់រងកសិផល ការពង្រឹងសហគ្រិនភាពនៃសហគមន៍កសិកម្ម ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មនៅមូលដ្ឋាន និងការពង្រឹងបច្ចេកទេសកសិកម្មទំនើប វៃឆ្លាត ឱជីថល និងមានសុវត្ថិភាព។

ទី៣- ការពង្រឹងកិច្ចសហការក្នុងការធ្វើវិចារណកម្មការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាសន្តិសុខទឹក សម្រាប់វិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។

ទី៤- ការកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការពង្រឹងការយល់ដឹងអំពីការប្រើប្រាស់ធាតុចូល និងការគ្រប់គ្រងគុណភាពធាតុចូល ការបន្តផ្តល់ឥណទានការប្រាក់ទាប និងការលើកទឹកចិត្តផលិតកម្មធាតុចូលក្នុងស្រុក។

ទី៥- ការធានាស្ថិរភាពថ្លៃផលិតផលកសិកម្ម តាមរយៈការបង្កើតនិងការពង្រឹងនូវយន្តការសម្របសម្រួលតាមដាននិងត្រួតពិនិត្យ និងការបន្តពង្រីកវិសាលភាពកញ្ចប់ហិរញ្ញប្បទានពិសេស ដើម្បីរក្សាលំនឹងថ្លៃផលិតផលកសិកម្មនិងលើកកម្ពស់ខ្សែច្រវាក់តម្លៃ ក្នុងវិស័យកសិកម្មទាំងមូល។

ទី៦- ការលើកកម្ពស់ការកែច្នៃផលិតផលកសិកម្ម តាមរយៈការធ្វើឱ្យប្រសើរឡើង និងការធ្វើទំនើបកម្មផ្នែកកសិឧស្សាហកម្ម ការជំរុញឱ្យមានការវិនិយោគលើកសិផលកែច្នៃ ការសិក្សានិងការបង្កើត «សួនកសិឧស្សាហកម្មនៅកម្ពុជា» សម្រាប់ប្រមូលផ្តុំសហគ្រាសកែច្នៃ ការជំរុញស្ថិរភាពនៃការផ្គត់ផ្គង់ផលិតផលកសិកម្ម និងការបន្តផ្តល់ហិរញ្ញប្បទានសម្បទានសម្រាប់ការវិនិយោគ។

ទី៧- ការបន្តលើកកម្ពស់ការតភ្ជាប់ទីផ្សារក្នុងស្រុកនិងការជំរុញការនាំចេញ តាមរយៈការលើកកម្ពស់ការគាំទ្រផលិតផលក្នុងស្រុក ដោយការប្រើប្រាស់ដោយផ្ទាល់ក្នុងចំណោមស្ថាប័នសាធារណៈនិងប្រជាជនទូទៅ ការពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើតទីផ្សារបោះដុំ និងចែកចាយ

ផលិតផលកសិកម្មក្នុងស្រុក ការពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងការទាញយកប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ។

ទី៨- ការបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍជនបទ តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ ការលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ជាពិសេសការកសាងផ្លូវជនបទតភ្ជាប់ទៅកសិដ្ឋាននិងផ្លូវជាតិ ឱ្យក្លាយទៅជាជនបទសមាហរណកម្ម ការកែលម្អលក្ខខណ្ឌជីវភាពរបស់សហគមន៍ជនបទនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទនិងការអភិវឌ្ឍសហគមន៍ជនបទ ជាពិសេសការជំរុញការអភិវឌ្ឍចម្រុះនិងការបន្តអនុវត្ត **«ចលនាភូមិមួយ ផលិតផលមួយ»** និង**«ចលនាភូមិគំរូ»**។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៧ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញយុទ្ធសាស្ត្រសម្រាប់កសាងសហគមន៍កសិកម្មទំនើប តាមរយៈកិច្ចសម្របសម្រួលហិរញ្ញប្បទាន ឬឥណទានការប្រាក់ទាប និងការផ្តល់ប្រឹក្សាយោបល់និងធនធានមនុស្សសម្រាប់សហគមន៍
- ជំរុញយុទ្ធសាស្ត្រសហគមន៍ចិញ្ចឹមសហគមន៍ តាមយៈការរៀបចំផែនការអាជីវកម្ម ដើម្បីទទួលបានការគាំទ្រពីគ្រឹះស្ថានហិរញ្ញវត្ថុ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានរបស់សហគមន៍ឱ្យមានប្រសិទ្ធភាព ការបង្កើត និងការពង្រីកមុខរបរបន្ថែមសហគមន៍ ការគាំទ្រហិរញ្ញប្បទាន និងឥណទានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ ការបង្កើតបណ្តាញទំនាក់ទំនង និងការកសាងទំនុកចិត្តរវាងសហគមន៍កសិកម្មជាមួយដៃគូអាជីវកម្មនានា ដើម្បីប្រសិទ្ធភាពនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ជំរុញយុទ្ធសាស្ត្រសម្រាប់សេវាទ្រទ្រង់បច្ចេកទេសកសិកម្មដល់កសិករ តាមរយៈការពង្រាយមន្ត្រីកសិកម្មដល់ឃុំសង្កាត់ ដែលមានសកម្មភាពផ្នែកកសិកម្ម និងការស្រាវជ្រាវបច្ចេកទេសកសិកម្មសម្រាប់បង្កើនផលិតភាពកសិកម្ម
- លើកកម្ពស់ប្រសិទ្ធភាពយុទ្ធសាស្ត្ររក្សាលំនឹងថ្លៃកសិផលសំខាន់ៗ តាមរយៈបុរេសកម្មក្នុងការតាមដានរក្សាលំនឹងតុល្យភាពនៃតម្រូវការនិងការផ្គត់ផ្គង់ ក៏ដូចជាការព្យាករផលិតកម្មកសិកម្ម និងតម្រូវការកសិផលតាមអនុវិស័យក្នុងស្រុកនិងអន្តរជាតិសម្រាប់ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កសិករ អន្តរសកម្មដោយសហការជាមួយនឹងអង្គភាពនិងស្ថាប័នពាក់ព័ន្ធនឹងផលិតកម្ម ការកែច្នៃគុណភាព ការត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ និងការធ្វើអន្តរាគមន៍លើហិរញ្ញប្បទាន។

**ទី២- ក្រសួងអភិវឌ្ឍន៍ជនបទ** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទប្រកបដោយភាពធន់ តាមរយៈការពង្រីកវិសាលភាពនៃការស្ដាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទនិងការសិក្សាស្រាវជ្រាវបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននានា
- ជំរុញអភិវឌ្ឍសហគមន៍ជនបទនិងចលនាភូមិគំរូ តាមរយៈការបង្កើនប្រសិទ្ធភាពសកម្មភាពអភិវឌ្ឍសហគមន៍ជនបទ ការលើកកម្ពស់គុណភាព គុណតម្លៃ និងនវានុវត្តន៍សហគមន៍ជនបទ ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលសហគមន៍ជនបទ និងការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច។

**ទី៣- ក្រសួងពាណិជ្ជកម្ម** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ផលិតផលខ្មែរនៅក្នុងទីផ្សារក្នុងស្រុកនិងទីផ្សារអន្តរជាតិ តាមរយៈការរៀបចំពិព័រណ៍ក្នុងស្រុកនិងក្រៅប្រទេស ការរៀបចំព្រឹត្តិការណ៍ជំនួបពាណិជ្ជកម្ម និងផ្គូរផ្គងដៃគូ ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មដើម្បីពង្រីកទីផ្សារថ្មីៗ ការជំរុញលើកស្ទួយគុណភាពនិងការផ្គត់ផ្គង់ទំនិញផលិតផលកម្ពុជាទៅកាន់ទីផ្សារក្នុងស្រុកនិងអន្តរជាតិ ការបន្តចូលរួមអនុវត្ត «ចលនាភូមិមួយផលិតផលមួយ» ឱ្យបានទូលំទូលាយនិងមានប្រសិទ្ធភាពដោយជំរុញឱ្យប្រជាពលរដ្ឋផលិតទំនិញស្របតាមលក្ខខណ្ឌភូមិសាស្ត្រនិងលក្ខខណ្ឌតម្រូវការទីផ្សារ និងការផលិតទំនិញមានគុណភាពល្អឱ្យបានច្រើនមុខ ដើម្បីលក់បានថ្លៃខ្ពស់ដោយប្រើប្រាស់គំនិតច្នៃប្រឌិតនិងបច្ចេកទេសទំនើប
- រៀបចំយុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងទីផ្សារ ដើម្បីរក្សាស្ថិរភាពថ្លៃ ធានានិងការពារផលប្រយោជន៍អ្នកផលិតនិងអ្នកប្រើប្រាស់ តាមរយៈការចងក្រងនិងគ្រប់គ្រងទិន្នន័យស្ថិតិពាណិជ្ជកម្មសម្រាប់ជាមូលដ្ឋានក្នុងការវិភាគ ការបង្កើនប្រសិទ្ធភាពយន្តការតាមដានថ្លៃទំនិញនិងតុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការទីផ្សារ ពិសេសលើបណ្ដាទំនិញយុទ្ធសាស្ត្រសំខាន់ៗ ការជំរុញបង្កើតទីផ្សារមូលដ្ឋាន ផ្សារលក់ដុំ ផ្សារចុងសប្ដាហ៍សម្រាប់អាជីវករ សហគ្រិន កសិករខ្នាតតូច ការកសាង និងការអនុវត្តផែនការសកម្មភាពសាងសង់ផ្សារតាមព្រំដែននិងតាមបណ្ដាខេត្ត និងការរៀបចំផ្សារលក់ទំនិញអនឡាញតាមថ្នាលពាណិជ្ជកម្មអេឡិចត្រូនិក។

**ទី៤- ក្រសួងធនធានទឹកនិងឧតុនិយម** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បង្កើនប្រសិទ្ធភាពសំណង់ការងារទឹកនិងអនុត្តរភាពប្រព័ន្ធធារាសាស្ត្រប្រកបដោយគុណភាព និងភាពធន់ តាមរយៈការបង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹកតាមវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះក្នុងក្របខ័ណ្ឌអាងទន្លេ ស្ទឹង និងការគ្រប់គ្រង ការអភិវឌ្ឍ និងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ
- ពង្រឹងសន្តិសុខទឹកនិងគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបង្កើតភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងការគ្រប់គ្រងនិងការកាត់បន្ថយផលប៉ះពាល់ ដោយប្រើប្រាស់វិធានការហេដ្ឋារចនាសម្ព័ន្ធនិងវិធានការមិនមែនហេដ្ឋារចនាសម្ព័ន្ធ

- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនិងនវានុវត្តន៍លើប្រព័ន្ធព័ត៌មាននិងទិន្នន័យធនធានទឹកនិងឧតុនិយម តាមរយៈការបង្កើតនិងការគាំទ្រកិច្ចដំណើរការមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យធនធានទឹកនិងឧតុនិយម ការលើកកម្ពស់និងការកែលម្អការគ្រប់គ្រងប្រព័ន្ធព័ត៌មានទិន្នន័យធនធានទឹកនិងទិន្នន័យប្រព័ន្ធធារាសាស្ត្រ និងការកែលម្អនិងការលើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានទិន្នន័យជលសាស្ត្រ ឧតុនិយម និងនវានុវត្តន៍
- **បង្កើនប្រសិទ្ធភាពការការពារនិងការអភិរក្សវិស័យធនធានទឹក** តាមរយៈការរៀបចំនិងការធ្វើបច្ចុប្បន្នភាពលើច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធនានា និងការពង្រឹងវិធានការទប់ស្កាត់ការការពារ និងការអភិរក្សធនធានទឹក។

**ទី៥- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធ្វើឱ្យប្រសើរឡើងនូវយន្តការគាំទ្រផ្តោតលើវិស័យកសិចំណីអាហារនិងរៀបចំតុវិនិយោគកសិចំណីអាហារ
- រៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ ជំរុញ និងទាក់ទាញវិនិយោគក្នុងវិស័យកសិកម្មនិងកសិឧស្សាហកម្មនៅកម្ពុជា
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការបង្កើត «សួនកសិឧស្សាហកម្មនៅកម្ពុជា» និងជំរុញលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការបង្កើតតំបន់ផលិតកែច្នៃនាំចេញកសិផល។

**ទី៦- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញនិងពង្រឹងការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការពហុវិស័យនិងពហុភាគីដែលមានស្រាប់ ព្រមទាំងពង្រឹងភាពជាដៃគូនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ចូលរួមជំរុញគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការកសាងសមត្ថភាពមន្ត្រីកសិកម្មឃុំ ការគាំទ្រសហគមន៍កសិកម្មទំនើប ការរក្សាស្ថិរភាពតម្លៃផលិតផលកសិកម្ម និងការរួមចំណែកដល់ការរៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ
- លើកកម្ពស់សុវត្ថិភាពម្ហូបអាហារ តាមរយៈវិធីសាស្ត្រសម្របសម្រួលសម្រាប់ការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារ
- គាំទ្រការអនុវត្តគោលនយោបាយនិងផែនការនានា តាមរយៈក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភថ្នាក់រាជធានីខេត្ត និងក្រុមការងារស្នូលថ្នាក់ខេត្តសម្រាប់សម្របសម្រួលកិច្ចអន្តរាគមន៍សេវាផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យដែលគិតគូរពីអាហារូបត្ថម្ភ
- លើកកម្ពស់កិច្ចសន្ទនាគោលនយោបាយ ការសិក្សាស្រាវជ្រាវនិងការគ្រប់គ្រងចំណេះដឹង រួមទាំងការប្រើប្រាស់ប្រព័ន្ធឌីជីថលនិងបច្ចេកវិទ្យានានាប្រកបដោយប្រសិទ្ធភាព។

**ទី៧- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំឯកសារគតិយុត្ត បទដ្ឋានបច្ចេកទេស និងយន្តការពាក់ព័ន្ធទៅតាមតម្រូវការចាំបាច់ ព្រមទាំងលើកកម្ពស់សមត្ថភាពស្ថាប័ននៅគ្រប់កម្រិតនិងធ្វើឌីជីថលូបនីយកម្ម សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាដល់ផលិតករ
- បង្កើនការចងក្រងផលិតផលភូមិមួយផលិតផលមួយនិងបណ្តុំអ្នកផលិតភូមិមួយផលិតផលមួយ ព្រមទាំងបន្តរៀបចំព្រឹត្តិការណ៍សំខាន់ៗនិងទិវាជាតិលើកកម្ពស់ផលិតផលខ្មែរ ការតាំងពិព័រណ៍ ការតាំងលក់បង្ហាញក្នុងពិធីបុណ្យជាតិនានា និងវេទិកាជំនួបអ្នកផលិត អ្នកទិញជាដើម ដើម្បីផ្សព្វផ្សាយនិងលើកកម្ពស់ទីផ្សារផលិតផលភូមិមួយផលិតផលមួយ និងផលិតផលក្នុងស្រុក
- រៀបចំស្តង់ដាផលិតផលភូមិមួយផលិតផលមួយ ដោយមានការដាក់ចំណាត់ថ្នាក់គុណភាពផលិតផលតាមកម្រិត ក៏ដូចជាបង្កើនការលក់និងការស្វែងរកទីផ្សារ តាមប្រព័ន្ធអនឡាញ
- បង្កើនការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធដល់ផលិតករនិងជំរុញការផ្លាស់ប្តូរបទពិសោធរវាងសហគមន៍ឬអ្នកផលិត សំដៅបង្កើនឧត្តមភាពទីផ្សារនិងនិរន្តរភាពនៃការផលិតនិងការផ្គត់ផ្គង់
- បង្កើនទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងស្វែងរកដៃគូ ទាំងដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីជួយជំរុញចលនាភូមិមួយផលិតផលមួយនៅកម្ពុជា។

## ៣.៦.៤- ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម

ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម មានគោលដៅជាយុទ្ធសាស្ត្រក្នុងការពង្រីកទីក្រុងនិងការអភិវឌ្ឍទីក្រុងថ្មីៗបន្ថែម នៅតាមបណ្តារាជធានី ខេត្ត ការបង្កើតសួនសាធារណៈ និងឧទ្យានបៃតងនិងការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម ដើម្បីធានាសុវត្ថិភាព សោភ័ណភាព បរិស្ថានល្អ និងសុខុមាលភាព សម្រាប់ការរស់នៅនិងប្រសិទ្ធភាពក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តដំណើរការកែទម្រង់ដីធ្លី ដោយជំរុញការចុះបញ្ជីនិងការដោះស្រាយវិវាទដីធ្លី នៅក្រៅប្រព័ន្ធតុលាការ និងការកសាងផែនការរៀបចំដែនដីនិងនគរូបនីយកម្ម ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងគោលដៅគ្រប់គ្រងនិងអភិវឌ្ឍវិស័យដីធ្លី ឱ្យបានត្រឹមត្រូវនិងឱ្យកាន់តែមានប្រសិទ្ធភាព។

ទី២- ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម ការងារកសាងផែនការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងរាជធានី ខេត្ត ការរៀបចំយុទ្ធសាស្ត្រតម្រង់ទិស ក្នុងការកំណត់បែងចែកតំបន់ប្រើប្រាស់ និងការគ្រប់គ្រងលំនៅឋានដោយប្រើប្រាស់បច្ចេកទេសឋានលេខានិងបច្ចេកវិទ្យាព័ត៌មាន។

ទី៣- ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិងទីប្រជុំជនសំខាន់ៗ ប្រកបដោយភាពធន់និងសោភ័ណភាព ការជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងទីក្រុង ការគ្រប់គ្រងទុកដាក់និងកែច្នៃសំរាម ការរៀបចំផ្លូវថ្មើរជើង ទីធ្លាចំណត ស្លាកសញ្ញា កាមេរ៉ាសុវត្ថិភាព និងភ្លើងសញ្ញាចរាចរណ៍ និងការពង្រីកបណ្ដាញអគ្គិសនី ភ្លើងបំភ្លឺទីក្រុង បណ្ដាញទឹកស្អាត ប្រព័ន្ធលូរំដោះទឹកភ្លៀង ប្រព័ន្ធចម្រោះនិងប្រព្រឹត្តកម្មទឹកកខ្វក់ និងប្រព័ន្ធពន្លត់អគ្គិភ័យទីប្រជុំជន ការអភិរក្សសំណង់ដែលមានតម្លៃប្រវត្តិសាស្ត្រ ការស្នើឱ្យមានការគិតគូររៀបចំសួនសាធារណៈប្រចាំរាជធានី ខេត្តឬតំបន់ដែលមិនទាមទារឱ្យមានចំណាយប្រតិបត្តិការឬការថែទាំខ្ពស់ ដោយយកលក្ខណៈបែបធម្មជាតិ និងវប្បធម៌ជាគោល។

ទី៤- ការជំរុញការវិនិយោគស្ដារឡើងវិញនូវគម្រោងសាងសង់ឬសំណង់អគារដែលទំនេរមិនដំណើរការក្នុងក្រុងព្រះសីហនុ ការលើកទឹកចិត្តឱ្យប្រែក្លាយមកជាគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ និងការផ្ដោតលើការអនុវត្តបន្ថែមលើការដាក់ចេញគោលនយោបាយ ដោយស្នើឱ្យមានការគិតគូរលើយន្តការលើកទឹកចិត្តដល់វិស័យឯកជន ឱ្យចូលរួមក្នុងកិច្ចការរៀបចំទីក្រុង ជាពិសេសពាក់ព័ន្ធទៅនឹងការអភិវឌ្ឍទីក្រុងវៃឆ្លាត ឬទីក្រុងបៃតង ឬទីក្រុងដែលគួរឱ្យចង់រស់នៅ។

ទី៥- ការសិក្សាលើវិសោធនកម្មក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវបានដាក់ចេញតាំងពីឆ្នាំ១៩៩៤ ឱ្យមានការផ្សារភ្ជាប់នគរូបនីយកម្មទៅនឹងស្ថានភាពសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ការស្ដារអាងស្តុកទឹក ឬប្រភពទឹក ការរៀបចំច្បាប់ស្ដីពីប្រព័ន្ធទឹកកខ្វក់ សំដៅកាត់បន្ថយការបំពុលទឹក និងការសិក្សាពាក់ព័ន្ធការបាក់ច្រាំងអាងទន្លេ សម្រាប់ការអភិវឌ្ឍ និងការធ្វើទំនើបកម្មនគរូបនីយកម្ម។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ផ្ដោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពន្លឿនការងាររដ្ឋបាលដីធ្លី តាមរយៈការអនុវត្តផែនការចុះបញ្ជីដីធ្លីជំហាន២ ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព ពន្លឿនការចុះបញ្ជីដីរដ្ឋ ការរៀបចំបទដ្ឋានគតិយុត្តនិងបច្ចេកទេស ដើម្បីបញ្ចូលព័ត៌មានស្ដីពីសំណង់លើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ការពន្លឿនការដោះស្រាយវិវាទដីធ្លីតាមគ្រប់យន្តការ ការពង្រីកបណ្ដាញស្ថានីយវាស់វែងអចិន្ត្រៃយ៍ដោយផ្កាយរណប ដើម្បីសម្រួលដល់ការកសាងផែនទី និងការចុះបញ្ជីដីធ្លីនៅទូទាំងប្រទេស ការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យនិងមជ្ឈមណ្ឌលព័ត៌មាន និងការបន្តធ្វើបច្ចុប្បន្នកម្មបញ្ជីរាយនាមភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ភូមិ ឃុំ សង្កាត់ ដែលបង្កើតថ្មី
- ជំរុញការងាររៀបចំដែនដីនិងនគរូបនីយកម្ម តាមរយៈការជំរុញអនុវត្តគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និង

អភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជាជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡាគ្នា ព្រមទាំងជំរុញការរៀបចំផែនការរៀបចំដែនដីនិងនគរូបនីយកម្មតាមលំដាប់អាទិភាព ការលើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍដែនដី និងនគរូបនីយកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ ការអភិវឌ្ឍធនធានមនុស្ស អភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចល្អ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ការស្រាវជ្រាវនិងការអភិវឌ្ឍប្រព័ន្ធទិន្នន័យរៀបចំដែនដីនិងនគរូបនីយកម្មឌីជីថល និងការពន្លឿនការរៀបចំផែនការរូបវន្តគ្រប់លំដាប់ថ្នាក់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ការរៀបចំដែនដីនិងការគ្រប់គ្រងនគរូបនីយកម្ម

- លើកកម្ពស់ការងារគ្រប់គ្រងនិងអភិវឌ្ឍវិស័យសំណង់ តាមរយៈការបន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់សំណង់ ការគ្រប់គ្រង និងការពង្រឹងការផ្តល់សេវាសាធារណៈលើវិស័យសំណង់ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងទិន្នន័យសំណង់ ការបន្តអភិវឌ្ឍកម្មវិធីកសាងផែនទីនេត្រាទស្សន៍ឌីជីថលទីក្រុង និងការដាក់ឱ្យដំណើរការសាកល្បងការស្នើសុំចុះបញ្ជីលើកដំបូងសម្រាប់សហគ្រាសឬក្រុមហ៊ុនអាជីវកម្មសិក្សាគម្រោងប្លង់តាមប្រព័ន្ធឌីជីថល
- ពន្លឿនការងារលំនៅឋាននិងសម្បទានដីសង្គមកិច្ច ដោយបន្តកៀរគរវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីវិនិយោគលើការសាងសង់លំនៅឋានតម្លៃសមរម្យ និងលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុ កៀរគរហិរញ្ញប្បទានសម្រាប់បង្កើត និង/ឬគ្រប់គ្រងមូលនិធិនិងឥណទានលំនៅឋាន ជំរុញការកសាងព័ត៌មានសេវាកម្មឥណទានលំនៅឋាន នៅបណ្តារាជធានី ខេត្ត បន្តជំរុញការងារបែងចែកដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ គ្រួសារប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ គ្រួសារយោធិន និងនគរបាលជាតិតាមបណ្តោយព្រំដែន បន្តសហការជាមួយរដ្ឋបាលខេត្តក្នុងការស្វែងរកដីសម្រាប់ចែកជូនប្រជាពលរដ្ឋ ក្រីក្រគ្មានដីឬខ្វះដីនិងគ្រួសារឬអតីតកងកម្លាំងប្រដាប់អាវុធ បន្តចុះបញ្ជីដីនិងផ្តល់បណ្ណកម្មសិទ្ធិជូនសម្បទានិកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌ និងអនុវត្តកម្មវិធីផ្តល់ដីសម្បទានសង្គមកិច្ច គឺ «**កម្មវិធីផ្តល់ដីការពារព្រៃ ដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព**»
- ជំរុញការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយរៀបចំផែនការរៀបចំដែនដីតំបន់ឆ្នេរសមុទ្រកម្ពុជាចក្ខុវិស័យឆ្នាំ២០៥០ កសាងផែនការរៀបចំដែនដីខេត្តកំពត កែប និងខេត្តកោះកុង និងធ្វើបច្ចុប្បន្នកម្មផែនការរៀបចំដែនដីខេត្តព្រះសីហនុ រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីកោះនិងដីចំណីឆ្នេរសមុទ្រ កសាងនិងបោះបង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រ ដៃសមុទ្រ ស្ទឹង ព្រែក អូរ បឹងបួ ផ្លូវទឹកនិងផ្ទៃទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ ត្រួតពិនិត្យនិងវាយតម្លៃឆ្នេរខ្សាច់កម្សាន្តនិងព្រែកកម្សាន្តស្អាត និងរៀបចំកម្មវិធីប្រឡងប្រណាំងឆ្នេរខ្សាច់និងព្រែកកម្សាន្តស្អាត ជំរុញអភិវឌ្ឍផ្លូវសាធារណៈនិង/ឬផ្លូវទេសចរណ៍តាមបណ្តោយដីចំណីឆ្នេរសមុទ្រ សិក្សាជីវៈចម្រុះ និងកំណត់តំបន់សក្តានុពលធនធាននៅឧទ្យានជាតិសមុទ្រកោះរ៉ុង និងនៅដែនសមុទ្រខេត្តកែប និងកោះកុងក្រៅ បន្តអនុវត្តគម្រោងកែលម្អឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈ និងបន្តរៀបចំប្លង់លម្អិតនិងផែនការកែលម្អឆ្នេរខ្សាច់កម្សាន្តសម្រាប់សាធារណជនបន្ថែម និងតាមដាន

ត្រួតពិនិត្យតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីពង្រឹងការអនុវត្តសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន

- អភិវឌ្ឍនិងពង្រឹងបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដោយរៀបចំបទដ្ឋានបច្ចេកទេសសំណង់លើផ្នែកគ្រឿងផ្គុំសំណង់បេតុង ផ្នែកសំណង់ដែក ផ្នែកបន្ទុកគណនា ភូគព្ភសាស្ត្រផ្នែកដី និងគ្រឹះ ផ្នែកសុវត្ថិភាពអគ្គិភ័យ ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹកស្អាត និងទឹកកខ្វក់ ផ្នែកប្រព័ន្ធសុវត្ថិភាពអគ្គិភ័យរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ បង្កើតកម្មវិធី «សន្ទានុក្រមបច្ចេកទេសសំណង់»និងកម្មវិធី«ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យសំណង់» សម្រាប់ប្រើប្រាស់លើទូរសព្ទវៃឆ្លាត ស្រាវជ្រាវ អភិវឌ្ឍ និងអនុវត្តបច្ចេកវិទ្យាទីក្រុងវៃឆ្លាត ក្នុងវិស័យសំណង់
- ពង្រឹងការងារមន្ទីរពិសោធន៍ជាតិសំណង់ ដោយឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងរហ័សទៅនឹងការស្នើសុំសេវាពិសោធន៍សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ គ្រប់គ្រងនិងពង្រឹងគុណភាពសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ គ្រប់គ្រងការងារពិសោធន៍សំណង់ ដើម្បីធានាសុក្រិតភាពនៃលទ្ធផលពិសោធន៍ សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ក្នុងស្រុក គ្រប់គ្រង និងពង្រឹងការផ្តល់សេវាសាធារណៈលើការងារពិសោធន៍ រៀបចំនិងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងផ្នែកភូគព្ភសាស្ត្រ ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់
- រៀបចំគោលនយោបាយ ច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ តាមរយៈការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យសំណង់ គោលនយោបាយជាតិស្តីពីនគរូបនីយកម្ម គោលនយោបាយជាតិស្តីពីស្ថាបត្យកម្ម ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីការជំរុញការប្រើប្រាស់សម្ភារៈសំណង់ក្នុងស្រុក ផែនការរៀបចំដែនដី និងនគរូបនីយកម្មផ្សារភ្ជាប់របៀងសេដ្ឋកិច្ច និងការរៀបចំច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម ច្បាប់ស្តីពីលំនៅឋាន ច្បាប់ស្តីពីការវាស់វែងនិងការផលិតផែនទី ច្បាប់ស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងការរៀបចំអនុក្រឹត្យនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងាររៀបចំដែនដីនគរូបនីយកម្មនិងសំណង់។

**ទី២- ក្រសួងសាធារណការនិងដឹកជញ្ជូន** បន្តជំរុញការធ្វើវិសោធនកម្ម ការរៀបចំសេចក្តីព្រាងច្បាប់ និងការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដូចជាច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវគោក ច្បាប់ផ្លូវដែក ច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ និងច្បាប់ស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យភស្តុភារកម្ម គោលនយោបាយស្តីពីការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យយានយន្តអគ្គិសនី ឆ្នាំ២០២៤-២០៣០ និងគោលនយោបាយស្តីពីភស្តុភារកម្មជាដើម។

**ទី៣- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តអភិវឌ្ឍការផ្គត់ផ្គង់ពីបណ្តាញចែកចាយអគ្គិសនីឱ្យបានគ្រប់ទីកន្លែង ដើម្បីឱ្យលំនៅឋាននិងការធ្វើអាជីវកម្មទូទាំងប្រទេសទទួលបានការផ្គត់ផ្គង់ថាមពលទៅតាមទំហំនៃសេចក្តីត្រូវការ

- បំពាក់នាឡិកាស្ទង់មេកានិក ប្រព័ន្ធនាឡិកាស្ទង់អេឡិចត្រូនិក និងប្រព័ន្ធកត់ត្រាតាមបច្ចេកទេសថ្មី ដែលធានាបានសុក្រឹតភាពនិងប្រសិទ្ធភាពខ្ពស់
- ជំរុញការដោះស្រាយមន្ទិលសង្ស័យរបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការកើនឡើងនៃបរិមាណប្រើប្រាស់ ដើម្បីធានាបាននូវភាពត្រឹមត្រូវនិងយុត្តិធម៌រវាងអ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់។

### ៣.៦.៥- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

គោលដៅជាយុទ្ធសាស្ត្រ គឺការកាត់បន្ថយការបំពុលនិងផលប៉ះពាល់បរិស្ថានជាអតិបរមា ការពង្រឹងការគ្រប់គ្រងទឹកនិងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាសំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាលដូចខាងក្រោម៖

ទី១- ការលើកកម្ពស់ការអភិវឌ្ឍបៃតងនិងសេដ្ឋកិច្ចចក្រា តាមរយៈការអនុវត្តគោលនយោបាយថាមពលស្អាតនិងប្រសិទ្ធភាពថាមពល ដោយបន្តលើកទឹកចិត្តនិងបង្កើនការវិនិយោគលើថាមពលស្អាតដែលមានតម្លៃសមរម្យ គោលនយោបាយកសិកម្មវៃឆ្លាតនិងបៃតង គោលនយោបាយនវានុវត្តក្នុងដំណើរការឧស្សាហកម្មនិងការប្រើប្រាស់ផលិតផល គោលនយោបាយទីក្រុងវៃឆ្លាតនិងការដឹកជញ្ជូនបៃតងនិងគោលនយោបាយគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និងសំណល់គ្រោះថ្នាក់ និងការពង្រឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងអភិវឌ្ឍ ទាំងនៅក្នុងស្រុកនិងឆ្លងដែន ប្រកបដោយប្រសិទ្ធភាព។

ទី២- ការបន្តជំរុញនិងកសាងហេដ្ឋារចនាសម្ព័ន្ធទឹក រួមទាំងប្រព័ន្ធប្រព្រឹត្តកម្ម ដើម្បីធានានូវសន្តិសុខទឹកនិងចីរភាពបរិស្ថាន និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ទី៣- ការបន្តបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ភាគរបរិស្ថាន និងភាគរអាកាសធាតុ ដូចជាបច្ចេកវិទ្យាដំណោះស្រាយតាមបែបធម្មជាតិ និងការប្រើប្រាស់ម៉ូដែលនិងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ទៅក្នុងការគ្រប់គ្រងសុវត្ថិភាពទឹកនិងបរិស្ថាន ជាដើម។

ទី៤- ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្តនិងគោលនយោបាយពាក់ព័ន្ធបរិស្ថាន ទឹក និងគ្រោះមហន្តរាយធម្មជាតិ ក៏ដូចជាការងារការទូតបៃតង ដើម្បីធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ីនិងការរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ទី៥- ការបន្តអភិវឌ្ឍ សមត្ថភាពជំនាញនិងចំណេះដឹងបច្ចេកទេស ព្រមទាំងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង សន្តិសុខទឹក ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនិងការចងក្រង ផលិតឯកសារឧបទេស សម្រាប់ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីជំរុញនិង

លើកទឹកចិត្តការចូលរួមអនុវត្តសាលារៀននិងអារាម ភាគរបរិស្ថាន និងគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ប្រកបដោយអនាម័យ សោភ័ណភាពនិងបរិស្ថានល្អ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាព និងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងបរិស្ថាន** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ធ្វើប្រតិភូកម្មមុខងារនិងធនធានដល់ថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការទទួលខុសត្រូវភាពម្ចាស់សំដៅជានានិរន្តរភាពធនធានធម្មជាតិនិងបរិស្ថាន
- លើកកម្ពស់ការចូលរួមជាសាធារណៈនិងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីភាពស្អាត ភាពបៃតងនិងចីរភាពនៅកម្ពុជា
- ជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងបង្កលក្ខណៈងាយស្រួលសម្រាប់វឌ្ឍនភាពនៃការកសាងសង្គមមួយដែលបញ្ចេញកាបូនតិច ព្រមទាំងជំរុញចីរភាពក្នុងការអភិវឌ្ឍដែលជានាវិបុលភាពសេដ្ឋកិច្ច និងការរក្សាការពារគុណភាពបរិស្ថានសម្រាប់ការរស់នៅដោយចីរភាព
- កៀរគរធនធានហិរញ្ញប្បទានអាកាសធាតុពីប្រភពខាងក្រៅ ដូចជាពីមូលនិធិអាកាសធាតុបៃតង មូលនិធិបន្សាំនិងមូលនិធិការខូតខាត និងបាត់បង់ជាដើម ដើម្បីការគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូននៅកម្ពុជា
- ផ្សព្វផ្សាយគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានាដល់វិស័យឯកជន ដើម្បីលើកកម្ពស់វិនិយោគដែលវៃឆ្លាតខាងអាកាសធាតុ
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនការចូលរួមចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះរបស់កម្ពុជា
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងវិស័យឯកជន លើការងារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

**ទី២- ក្រសួងធនធានទឹកនិងឧតុនិយម** បន្តបង្កើនប្រសិទ្ធភាពសំណង់ការងារទឹក និងអនុត្តរភាពប្រព័ន្ធជារាសាស្ត្រ ប្រកបដោយគុណភាពនិងភាពធន់ និងពង្រឹងសន្តិសុខទឹកនឹងគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបង្កើតភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

**ទី៣- ក្រសួងរ៉ែនិងថាមពល** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- លើកកម្ពស់យន្តការវិនិយោគ តាមរយៈ ១) ការទាក់ទាញវិស័យឯកជនឱ្យចូលរួមវិនិយោគបន្ថែមពីលើលទ្ធភាពវិនិយោគរបស់រដ្ឋសម្រាប់អភិវឌ្ឍគម្រោងនានា ស្របតាមផែនការមេសម្រាប់អភិវឌ្ឍវិស័យថាមពលអគ្គិសនី ឆ្នាំ២០២២-២០៤០ ផែនការអភិវឌ្ឍន៍ប្រសិទ្ធភាពថាមពលនៅកម្ពុជា និង

ផែនការឆ្ពោះទៅរកអព្យាក្រឹតភាពកាបូនរបស់ព្រះរាជាណាចក្រកម្ពុជា និង២) ការអនុវត្តការវិនិយោគគម្រោងនានានៅក្នុងវិស័យថាមពល ស្របតាមច្បាប់និងនីតិវិធីជាធរមាននៅកម្ពុជា ប្រកបដោយភាពច្នៃប្រឌិតនិងរស់រវើក ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា

- លើកកម្ពស់យន្តការអាជីវកម្ម តាមរយៈ ១) ការបើកឱ្យឯកជនចូលរួមធ្វើអាជីវកម្មផលិត បញ្ជូន និងចែកចាយអគ្គិសនី ដើម្បីទាក់ទាញការវិនិយោគវិស័យឯកជន កាត់បន្ថយគម្លាតថ្លៃអគ្គិសនីរវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ព្រមទាំងធ្វើឯកភាពអត្រាថ្លៃលក់អគ្គិសនីនៅទូទាំងប្រទេស ២) ការពិនិត្យលទ្ធភាពបន្ថយថ្លៃអគ្គិសនីបន្ថែមទៀត ដើម្បីបំពេញគោលដៅសេដ្ឋកិច្ចនិងសង្គម ដោយរក្សាលំនឹងអាជីវកម្មអគ្គិសនីក្នុងប្រទេសកម្ពុជាទាំងមូល និង៣) ការពិនិត្យលទ្ធភាពធ្វើវិភាជន៍ទុនវិនិយោគសម្រាប់អភិវឌ្ឍការផ្គត់ផ្គង់ថាមពលនៅតំបន់ដាច់ស្រយាលប្រកបដោយបរិយាបន្ន
- លើកកម្ពស់យន្តការពាក់ព័ន្ធផ្សេងទៀត រួមមាន ១)ការចូលរួមកាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិនិងសង្គមឱ្យបានជាអតិបរមានៅក្នុងការអភិវឌ្ឍវិស័យថាមពល ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ២)ការជួយដោះស្រាយដល់ការបំពេញលក្ខខណ្ឌបរិស្ថាននិងការប្រែប្រួលអាកាសធាតុរបស់អ្នកប្រើប្រាស់អគ្គិសនី ៣) ការពង្រឹងនិងការពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងនិងក្រៅតំបន់ ដើម្បីផ្លាស់ប្តូរពាណិជ្ជកម្មអគ្គិសនី បង្កើនភាពចម្រុះនៃប្រភពអគ្គិសនី និងភាពបំពេញឱ្យគ្នាទៅវិញទៅមក ផ្លាស់ប្តូរបទពិសោធ ចែករំលែកបច្ចេកវិទ្យាថ្មីៗ និងបង្កើនប្រភពហិរញ្ញប្បទាន និង៤) ការចូលរួមជាមួយអង្គការអន្តរជាតិក្នុងយន្តការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងអព្យាក្រឹតភាពកាបូន។

## ៣.៧- ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល

### ៣.៧.១- ការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការដឹកនាំការធ្វើបរិវត្តកម្មឌីជីថល ដោយរាជរដ្ឋាភិបាលធ្វើជាគំរូ និងដឹកមុខក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការធ្វើឌីជីថលភាវូបនីយកម្មកិច្ចការសាធារណៈរបស់រដ្ឋ ដើម្បីពង្រឹងប្រសិទ្ធភាពការងារនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាជននិងវិស័យឯកជន និងការពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ។ ក្រសួង ស្ថាប័នត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការពង្រឹងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលដែលមានស្រាប់ឱ្យអស់លទ្ធភាព និងការបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល ដែលមានលក្ខណៈចាំបាច់និងជាអាទិភាព។

ទី២- ការបន្តកសាងនិងអភិវឌ្ឍប្រព័ន្ធទិន្នន័យគោល ក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយគុណភាព និងមានស្តង់ដាបច្ចេកទេសខ្ពស់។

ទី៣- ការបន្តពង្រីកការធ្វើឌីជីថលភាវូបនីយកម្មសេវាសាធារណៈ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ទី៤- ការអភិវឌ្ឍស្តង់ដាបច្ចេកទេសរួមនៃការផ្តល់សេវាសាធារណៈឌីជីថល ក្របខ័ណ្ឌអន្តរប្រតិបត្តិការ ស្តង់ដាសន្តិសុខ និងស្តង់ដាបច្ចេកទេសរួមពាក់ព័ន្ធផ្សេងៗ សម្រាប់ក្រសួង ស្ថាប័ន។

ទី៥- ការបន្តកសាងនិងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះរួម ដែលដើរតួនាទីជាឃ្នាស់ ក្នុងការជំរុញការកសាងប្រព័ន្ធរដ្ឋាភិបាលឌីជីថលជាអង្គតែមួយ។

ទី៦- ការបន្តពង្រឹងសមត្ថភាពមន្ត្រីលើជំនាញឌីជីថល តាមរយៈការបណ្តុះបណ្តាលជាប្រចាំ និងការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល ដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ និងការពិនិត្យលទ្ធភាពបង្កើតអង្គភាព បរិវត្តកម្មឌីជីថលតាមអង្គភាពការងារនៃក្រសួង ស្ថាប័ន។

ទី៧- ការកសាងមូលធនមនុស្សដែលមានជំនាញឌីជីថល តាមរយៈការធ្វើទំនើបកម្មនិងការធ្វើសុវុឌ្ឍិកម្មកម្មវិធីសិក្សានិងកម្មវិធីបណ្តុះបណ្តាល ជំនាញឌីជីថល និងការកៀរគរ និងការទាក់ទាញធនធានមនុស្ស ដែលមានទេពកោសល្យឌីជីថលពីបរទេស។

ទី៨- ការបន្តលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមប្រជាពលរដ្ឋទូទៅ ដោយរួមបញ្ចូលទាំងការបញ្ចូលជំនាញឌីជីថលជាមូលដ្ឋានក្នុងកម្មវិធីសិក្សា និងការរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថលតាមវិស័យ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៧ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំអង្គភាពបរិវត្តកម្មឌីជីថលនិងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជំនាញដែលបម្រើការងារក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយជាអ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
- បន្តរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញអ៊ីនធឺណិតល្បឿនលឿន រៀបចំតភ្ជាប់បណ្តាញខ្សែកាបអុបទិក និងរៀបចំបណ្តាញផ្ទៃក្នុងរបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងថ្នាក់ក្រោមជាតិ
- រៀបចំនិងបំពាក់កុំព្យូទ័រនិងឧបករណ៍ឌីជីថលតាមតម្រូវការចាំបាច់និងប្រើសុសវែរដែលមានអាជ្ញាបណ្ណត្រឹមត្រូវ និងផ្តល់ប្រព័ន្ធអ៊ីមែល ប្រព័ន្ធគ្រប់គ្រងឯកសារនិងលំហូរការងារ និងប្រព័ន្ធផ្សេងទៀត ជាពិសេសការរៀបចំប្រព័ន្ធការពារសន្តិសុខ
- រៀបចំមជ្ឈមណ្ឌលទិន្នន័យជាតិ ដែលគ្រប់គ្រងដោយក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ ហើយក្រសួង ស្ថាប័ននីមួយៗ អាចគ្រប់គ្រងទិន្នន័យខ្លួនឯងដោយផ្ទាល់
- រៀបចំថ្នាលបច្ចេកវិទ្យានិងកម្មវិធីសុសវែរផ្សេងទៀតរបស់ក្រសួង ស្ថាប័ន តាមរយៈយន្តការរដ្ឋាភិបាលជាមួយរដ្ឋាភិបាល រដ្ឋាភិបាលជាមួយធុរកិច្ច និងរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ

- បណ្តុះបណ្តាលនិស្សិតលើជំនាញបច្ចេកវិទ្យាឌីជីថល ជំរុញការសិក្សាលើជំនាញបច្ចេកវិទ្យាឌីជីថល និងពង្រឹងសមត្ថភាពបន្ថែមអ្នកមានសញ្ញាបត្រជំនាញបច្ចេកវិទ្យាឌីជីថលដែលកំពុងបំពេញការងារនៅគ្រប់ស្ថាប័នសាធារណៈ អង្គការសង្គមស៊ីវិល និងស្ថាប័នឯកជនផ្សេងៗ
- លើកកម្ពស់ការយល់ដឹងរបស់សិស្សានុសិស្សនិងប្រជាពលរដ្ឋទូទៅ លើបច្ចេកវិទ្យាឌីជីថល តាមរយៈការផ្តល់អាហាររូបករណ៍ «**ទេពកោសល្យតេជោ**» ការបង្កើតកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល និងមជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថលសហគមន៍
- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលនិងប្រព័ន្ធគ្រប់គ្រងឌីជីថល នៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បង្កើតថ្នាលសហគមន៍ឌីជីថលកម្ពុជា ដើម្បីប្រមូលផ្តុំអ្នកជំនាញឌីជីថលនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ផ្សព្វផ្សាយបច្ចេកវិទ្យាឌីជីថលដល់សហគមន៍ និងប្រជាពលរដ្ឋទូទៅ និងរៀបចំបង្កើតសមាគមអ្នកវិជ្ជាជីវៈឌីជីថល ដើម្បីប្រមូលផ្តុំធនធានមនុស្ស និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈក្នុងវិស័យឌីជីថល។

**ទី២- ក្រសួងអប់រំ យុវជន និងកីឡា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពៈ
- ជំរុញការបណ្តុះបណ្តាលនិស្សិតផ្នែកបច្ចេកវិទ្យានិងបច្ចេកវិទ្យាឌីជីថល
- អភិវឌ្ឍនិងបង្កើតមហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល ស្របតាមនិន្នាការសេដ្ឋកិច្ចនិងសង្គមឌីជីថល
- ជំរុញការសិក្សាស្រាវជ្រាវនិងនវានុវត្តន៍ ដោយបង្កលក្ខណៈឱ្យគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ បង្កើតមជ្ឈមណ្ឌលឧត្តមភាព និងលើកកម្ពស់ការស្រាវជ្រាវផ្អែកលើសក្តានុពលនិងឯកទេសកម្មរបស់ខ្លួន
- បង្កើតមជ្ឈមណ្ឌលសហគ្រិនភាពនិងធុរកិច្ច សម្រាប់បណ្តុះបណ្តាលសហគ្រិនវ័យក្មេង និងលើកទឹកចិត្តក្នុងការបង្កើតអាជីវកម្មដោយខ្លួនឯង និងអភិវឌ្ឍសមត្ថភាពអ្នកស្រាវជ្រាវវ័យក្មេង
- បង្កើតមជ្ឈមណ្ឌលបញ្ញាសិប្បនិម្មិតនៅតាមសាកលវិទ្យាល័យ។

**ទី៣- ក្រសួងមុខងារសាធារណៈ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាពៈ
- រៀបចំនិងជំរុញការអភិវឌ្ឍអភិបាលកិច្ចរដ្ឋបាលឌីជីថលនិងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ព្រមទាំងពន្លឿនការធ្វើបរិវត្តកម្មរដ្ឋបាលឌីជីថលនិងសេវាសាធារណៈ រួមទាំងការរៀបចំថ្នាលសេវាច្រកចេញចូលតែមួយ
- កសាងអភិវឌ្ឍមូលធនមនុស្សឌីជីថល តាមរយៈការអភិវឌ្ឍសមត្ថភាពបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង ការបណ្តុះបណ្តាល ការរៀបចំកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំអំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់សេវាសាធារណៈឌីជីថល
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពព័ត៌មានវិទ្យានិងឌីជីថល រួមមានការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនិងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៤- ក្រសួងពាណិជ្ជកម្ម** ជំរុញការកសាងរដ្ឋាភិបាលឌីជីថល ពលរដ្ឋឌីជីថល និងធុរកិច្ចឌីជីថលក្នុងវិស័យពាណិជ្ជកម្ម តាមរយៈការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធស្វ័យប្រវត្តកម្មក្នុងការផ្តល់សេវាសាធារណៈ ការងាររដ្ឋបាលពាណិជ្ជកម្ម និងការងារគ្រប់គ្រងទិន្នន័យព័ត៌មានពាណិជ្ជកម្ម ការចែករំលែកព័ត៌មានពាណិជ្ជកម្ម តាមរយៈថ្នាលអេឡិចត្រូនិក ការតភ្ជាប់ប្រព័ន្ធផ្តល់សេវានានាទៅនឹងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់រាជរដ្ឋាភិបាល និងការលើកកម្ពស់ការកសាងសមត្ថភាពមន្ត្រីក្នុងផ្នែកឌីជីថលនីយកម្ម ដើម្បីបង្កបរិយាកាសអំណោយផលដល់ធុរកិច្ចនិងសម្រួលពាណិជ្ជកម្ម។

**ទី៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- បន្តជំរុញការប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) សម្រាប់ការផ្លាស់ប្តូរទិន្នន័យពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតរបស់ក្រសួង ស្ថាប័ន
- បន្តជំរុញការប្រើប្រាស់ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (CamDigiKey) សម្រាប់ជាការសម្គាល់អត្តសញ្ញាណអ្នកប្រើប្រាស់ឌីជីថល នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងស្ថាប័ន
- បន្តវិនិយោគលើការថែទាំនិងការរៀបចំអភិវឌ្ឍប្រព័ន្ធទិន្នន័យគោលរបស់បណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។

**ទី៦- គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** សម្របសម្រួលជាមួយក្រសួងផែនការលើការរៀបចំក្របខ័ណ្ឌគណនីរណបសេដ្ឋកិច្ចឌីជីថល (Digital Economy Satellite Account) សម្រាប់វាស់វែងទំហំសេដ្ឋកិច្ចឌីជីថល។

**ទី៧- គណៈកម្មការរដ្ឋាភិបាលឌីជីថល** សម្របសម្រួលជាមួយក្រសួង ស្ថាប័នក្នុងការអនុវត្តផែនការអាទិភាពនៃគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥។

### ៣.៧.២- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការជំរុញការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច ការបង្កើតធុរកិច្ចថ្មីឌីជីថល (Digital Startups) ការជំរុញការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស ការជំរុញការអភិវឌ្ឍខ្សែច្រវាក់ឌីជីថល និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការជំរុញការកសាងនិងការអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ឌីជីថល ដើម្បីសម្រួលធុរកិច្ចនិងពាណិជ្ជកម្ម សំដៅជំរុញសម្ទុះកំណើនសេដ្ឋកិច្ច។ ក្រសួង ស្ថាប័នត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តកសាងនិងអភិវឌ្ឍប្រព័ន្ធទិន្នន័យគោល ដែលជាអាទិភាពក្នុងវិស័យសេដ្ឋកិច្ចនិងធុរកិច្ចប្រកបដោយគុណភាពនិងមានស្តង់ដាបច្ចេកទេសខ្ពស់ និងការបន្តពង្រីកការធ្វើឌីជីថលភាវូបនីយកម្មសេវាសាធារណៈ សម្រាប់គាំទ្រដល់វិស័យសេដ្ឋកិច្ច និងធុរកិច្ច។

ទី២- ការបន្តកសាងនិងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះរួមនិងថ្នាលនវានុវត្តឌីជីថល។

ទី៣- ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ធុរកិច្ចឌីជីថល និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យកាន់តែរស់រវើកនិងបំពេញឱ្យគ្នា តាមរយៈការតភ្ជាប់និងការពង្រីកទីផ្សារ ការពង្រីកការវិនិយោគ ការផ្តល់ហិរញ្ញប្បទាននិងកម្មវិធីគាំទ្រសំខាន់ដទៃទៀត។

ទី៤- ការរៀបចំនិងការដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស។

ទី៥- ការបង្កើនភាពជឿទុកចិត្ត ការពង្រឹងអនុលោមភាព និងការបន្តដោះស្រាយបញ្ហាប្រឈមជាយុទ្ធសាស្ត្រ នៃខ្សែច្រវាក់ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ទី៦- ការលើកកម្ពស់សហគ្រិនភាពនិងការធ្វើនវានុវត្តន៍ ដើម្បីបង្កើនសកម្មភាពនៃការធ្វើធុរកិច្ចការចាប់ដៃគូ និងការជំរុញការតភ្ជាប់ក្នុងខ្សែច្រវាក់តម្លៃផលិតកម្ម។

ទី៧- ការពង្រឹងសមត្ថភាពនវានុវត្តឌីជីថល តាមរយៈការអភិវឌ្ឍធនធានមនុស្សនិងបុគ្គលមានទេពកោសល្យក្នុងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវានុវត្តន៍ ក៏ដូចជាការអភិវឌ្ឍសមត្ថភាពនៃការស្រាវជ្រាវ ការអភិវឌ្ឍ និងការធ្វើនវានុវត្តន៍នៅតាមគ្រឹះស្ថានសិក្សានិងបណ្តុះបណ្តាល។

ទី៨- ការរៀបចំច្បាប់ស្តីពីសេដ្ឋកិច្ចឌីជីថលនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការដាក់សេដ្ឋកិច្ចឌីជីថលទៅក្នុងអនុវិស័យនៃប្រព័ន្ធគណនីជាតិ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៤ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញនិងអភិវឌ្ឍវិស័យដឹកជញ្ជូនគោលដៅចុងក្រោយ( Last-Mile Delivery ) ដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីនិងយន្តការដាក់លាក់ក្នុងវិស័យនេះ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព នវានុវត្តន៍ ចីរភាព ភាពធន់នឹងវិបត្តិ និងអន្តរទំនាក់ទំនង
- ជំរុញការប្រើប្រាស់អត្តសញ្ញាណឌីជីថលនិងហត្ថលេខាឌីជីថល ក្នុងការកំណត់និងការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលឱ្យបានទូលំទូលាយសម្រាប់ប្រជាពលរដ្ឋ ស្ថាប័នឯកជននិងស្ថាប័នសាធារណៈ
- លើកកម្ពស់វប្បធម៌សហគ្រិនភាព ការយល់ដឹងពីទីផ្សារឌីជីថល និងផ្នត់គំនិតច្នៃប្រឌិត កាលានុវត្តភាពធុរកិច្ចឌីជីថល សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយសាកល្បងនិងអភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងវិស័យអាទិភាព។

**ទី២- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំបង្កើតប្រព័ន្ធនីតិវិធីនៃការវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាពនិងសមត្ថកិច្ចដល់អង្គភាពវាយតម្លៃអនុលោមភាពនិងការងារចុះបញ្ជីផ្សេងៗ តាមប្រព័ន្ធឌីជីថល ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មជាតិនិងអន្តរជាតិ
- បង្កើតយន្តការប្រឡងប្រណាំងអ្នកបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករ ដែលមានទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករដែលមានទេពកោសល្យនិងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករនិងសហគ្រិនវ័យក្មេង

- រៀបចំសិក្ខាសាលាស្តីពីការអនុវត្តបច្ចេកវិទ្យាឌីជីថល ដើម្បីដំណើរការអាជីវកម្មដល់សហគ្រាសធុនតូចនិងមធ្យម
- ជំរុញនិងលើកទឹកចិត្តផ្ទេរបច្ចេកវិទ្យាថ្មីក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម ដើម្បីបង្កើនសមត្ថភាពសហគ្រាសធុនតូចនិងមធ្យម សម្រាប់ការផ្ទេរនិងផ្គត់ផ្គង់បច្ចេកវិទ្យា
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញបន្ថែមឱ្យដើរទាន់ការរីកចម្រើននៃបច្ចេកវិទ្យា ក្នុងការផ្តល់សេវាព្យាសកម្ម ត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យមានគុណភាពនិងប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រនិងអនុវត្តសកម្មភាពការងារតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រឆ្នាំ២០២៣-២០២៧។

**ទី៣- ក្រសួងពាណិជ្ជកម្ម** ជំរុញលើកទឹកចិត្តធុរកិច្ចឌីជីថល ការធ្វើបរិវត្តកម្មឌីជីថលសហគ្រាសនិងខ្សែច្រវាក់ឌីជីថលនិងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលដៅបង្កើតចំណងទាក់ទងរវាងទីផ្សារធំៗជាមួយសហគ្រាសក្នុងស្រុកនិងអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមក្របខ័ណ្ឌច្បាប់និងកិច្ចព្រមព្រៀងជាតិនិងអន្តរជាតិ ពិសេសការប្រើប្រាស់ទម្រង់ឌីជីថលភាវូបនីយកម្ម ដើម្បីសម្រួលពាណិជ្ជកម្ម។

**ទី៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ជំរុញការចែករំលែកទិន្នន័យពីរាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន ដើម្បីរួមចំណែកដល់ការបង្កើតថ្មីនិងនវានុវត្តន៍
- បន្តអភិវឌ្ឍនិងជំរុញការប្រើប្រាស់ថ្នាលធុរកិច្ចថ្មីកម្ពុជា ដើម្បីគាំទ្រដល់ធុរកិច្ចថ្មីនិងជំរុញការចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពជាតិឱ្យមានភាពរស់រវើក
- ជំរុញការអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសឱ្យមានវិសាលភាពទូលំទូលាយនិងមានប្រសិទ្ធភាព
- បន្តរៀបចំកម្មវិធីគាំទ្រនិងលើកកម្ពស់សហគ្រិនភាពនិងនវានុវត្តន៍ ដើម្បីរួមចំណែកដល់ការកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីរស់រវើក
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំច្បាប់ស្តីពីសេដ្ឋកិច្ចឌីជីថលនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ៣.៧.៣- ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាងនិងការពង្រឹកហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមានការតភ្ជាប់ឌីជីថលនិងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងក្លោដឬមជ្ឈមណ្ឌលទិន្នន័យ សំដៅពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃបណ្តាញតភ្ជាប់ឌីជីថល ការចែករំលែកព័ត៌មាន និងការផ្តល់សេវាទូរគមនាគមន៍។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការជំរុញឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតនិងទូរគមនាគមន៍ ពង្រឹងគុណភាពនៃសេវាឱ្យបានល្អនិងគ្របដណ្តប់គ្រប់ទីកន្លែង តាមរយៈការវិនិយោគបន្ថែម ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនពិសេសនៅតំបន់ដែលមានសក្តានុពល។

ទី២- ការបន្ត កសាងនិងអភិវឌ្ឍបណ្ដាញ និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ផ្នែកបណ្ដាញឆ្អឹងខ្នង និងបណ្ដាញចែកចាយ និងការជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ទី៣- ការជំរុញការវិនិយោគនិងការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីកសាងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធ បណ្ដាញទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ សម្រាប់អ៊ីនធឺណិតល្បឿនលឿន ដើម្បីជួយកាត់បន្ថយគម្លាតឌីជីថល។

ទី៤- ការពិនិត្យលទ្ធភាព បង្កើនសមត្ថភាពប្រតិបត្តិការ ខ្សែកាបអុបទិកក្រោមបាតសមុទ្រ និងខ្សែកាបអុបទិកឆ្លងព្រំដែនគោកដែលមានស្រាប់ និងការពង្រីកការសាងសង់ខ្សែកាបអុបទិកក្រោមបាតសមុទ្រថ្មី និងខ្សែកាបអុបទិកឆ្លងព្រំដែនគោកបន្ថែម តាមការចាំបាច់។

ទី៥- ការបន្តធ្វើបច្ចុប្បន្នកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងការគ្រប់គ្រងធនធានវិសាលគមន៍វិទ្យុ។

ទី៦- ការបន្តជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍រួម អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

ទី៧- ការរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្លោដ តាមវិស័យនិងតាមប្រភេទទិន្នន័យ។

ទី៨- ការជំរុញការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យជាតិ សម្រាប់បម្រើដល់ប្រព័ន្ធឌីជីថលរបស់ក្រសួង ស្ថាប័ន ដែលមិនមានមជ្ឈមណ្ឌលទិន្នន័យ និងការជំរុញប្រតិបត្តិករឯកជន ឱ្យវិនិយោគលើការកសាងមជ្ឈមណ្ឌលទិន្នន័យ ដោយផ្ដោតលើស្តង់ដានិងសុវត្ថិភាពខ្ពស់របស់ទិន្នន័យ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមាន**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

- រៀបចំឱ្យបានល្អហេដ្ឋារចនាសម្ព័ន្ធបណ្ដាញរដ្ឋាភិបាលឌីជីថល ដើម្បីតភ្ជាប់នៅគ្រប់ក្រសួង ស្ថាប័ន និងស្ថានតំណាងកម្ពុជានៅបរទេសលើបណ្ដាញដាច់ដោយឡែករបស់រដ្ឋាភិបាល ដោយកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់និងវិនិយោគលើបណ្ដាញថ្មីៗបន្ថែមទៀត
- ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅថ្នាក់ក្រោមជាតិ ចាប់ពីកម្រិតរាជធានី ខេត្ត ដល់ឃុំ សង្កាត់ ដូចជា រដ្ឋបាលឃុំសង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល សាលារៀន មណ្ឌលសុខភាព និងទីប្រជុំជន ដើម្បីគាំទ្រការបម្រើសេវាសាធារណៈឌីជីថល ការអប់រំនិងបណ្ដុះបណ្ដាលតាមប្រព័ន្ធអនឡាញ ការទទួលបានព័ត៌មានអំពីទីផ្សារ និងផលិតផលកសិកម្ម ជាដើម
- កសាងមជ្ឈមណ្ឌលទិន្នន័យជាតិ រួមមានមជ្ឈមណ្ឌលប្រតិបត្តិការនិងសង្គ្រោះទិន្នន័យ ដោយប្រើបច្ចេកវិទ្យាក្លោដ សម្រាប់បម្រើសេវាហេដ្ឋារចនាសម្ព័ន្ធ ថ្នាល សុសវែរ និងទិន្នន័យសម្រាប់រដ្ឋាភិបាល និងវិស័យឯកជន

- រៀបចំប្រព័ន្ធមូលទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ ដើម្បីគ្រប់គ្រង តាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនិងតម្រូវការនៃហេដ្ឋារចនាសម្ព័ន្ធជាតិ។

## ៣.៧.៤- ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល

គោលដៅជាយុទ្ធសាស្ត្រគឺការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងយន្តការស្ថាប័នសន្តិសុខឌីជីថល និងការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការបន្តកសាងនិងពន្លឿនការរៀបចំនិងការអនុម័តសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ទី២- ការបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថលនិងមជ្ឈមណ្ឌលសន្តិសុខឌីជីថលជាតិ និងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធសន្តិសុខឌីជីថល។

ទី៣- ការរៀបចំវិធានអនុវត្តឬវិធានប្រតិបត្តិ ស្តង់ដា ក្របខ័ណ្ឌបច្ចេកទេស គោលការណ៍ណែនាំក្រមប្រតិបត្តិ និងនីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធសន្តិសុខឌីជីថល។

ទី៤- ការរៀបចំក្របខ័ណ្ឌវាយតម្លៃឡើងវិញនូវចន្លោះប្រហោងនិងការពង្រឹងប្រព័ន្ធសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់។

ទី៥- ការបណ្តុះបណ្តាលនិងការបង្កើនការអភិវឌ្ឍ ជំនាញសន្តិសុខឌីជីថល និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសន្តិសុខឌីជីថល ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីបញ្ហាសន្តិសុខឌីជីថលនិងកិច្ចការពារខ្លួននិងការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

ទី៦- ការបង្កើតយន្តការនៃកិច្ចសហការនិងកិច្ចសហប្រតិបត្តិការ ជាមួយនឹងស្ថាប័នពាក់ព័ន្ធ ទាំងរដ្ឋ វិស័យឯកជន និងប្រជាជន ដើម្បីចូលរួមរាយការណ៍ ទប់ស្កាត់ បំពាក់សុវត្ថិភាពក្នុងប្រព័ន្ធឌីជីថលនិងឈានឆ្ពោះទៅដល់ការបង្ក្រាបទាន់ពេលនូវបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

ទី៧- ការបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ទាំងក្នុងតំបន់ និងជាសកល ក្នុងការចែករំលែកព័ត៌មាននិងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល ក្នុងបរិការណ៍តំបន់និងសកល។

### សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានក្រសួង ស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ក្រសួងមហាផ្ទៃ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- រៀបចំនិងអនុវត្តយន្តការការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល រួមមានគោលនយោបាយ បទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រង ការពារសន្តិសុខសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល បទដ្ឋានគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពព័ត៌មាននិងប្រព័ន្ធផ្ទៀងផ្ទាត់សារតារ និងសុក្រឹតភាពទិន្នន័យសម្រាប់ការប្រើប្រាស់ និងលំហូរទិន្នន័យ
- ដំឡើងមជ្ឈមណ្ឌលការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល ដើម្បីតាមដានសន្តិសុខរបស់ប្រព័ន្ធបច្ចេកវិទ្យាពីការវាយប្រហារនិងជ្រៀតចូលដោយខុសច្បាប់ រួមមានមជ្ឈមណ្ឌលការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល និងបន្ទប់កោសល្យវិច័យបច្ចេកវិទ្យាឌីជីថល សម្រាប់បម្រើការងារស្រាវជ្រាវតាមដាន វិភាគទិន្នន័យ និងការពារសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យា
- ការរៀបចំនិងអនុវត្តយន្តការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបច្ចេកវិទ្យាឌីជីថល ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាពនិងគាំទ្រដល់កិច្ចការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល និងការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា។

**ទី២- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** បន្តពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ តាមរយៈការកំណត់នីតិវិធីសុវត្ថិភាពនិងការបំពាក់សម្ភារៈបរិក្ខារបច្ចេកទេសសម្រាប់តាមដាន ត្រួតពិនិត្យ ការពារ និងការទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត។

**ទី៣- គណៈកម្មាធិការសន្តិសុខឌីជីថល** ធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញមុខងារដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គសង្គម ទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព និងឆ្លើយតបគ្រប់ផ្នែកទាំងបច្ចេកទេសនិងកម្លាំងពាក់ព័ន្ធនឹងការធានានិងការពារសន្តិសុខឌីជីថល។

## ៣.៧.៥- ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ

គោលដៅជាយុទ្ធសាស្ត្រ គឺការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយចាប់យកកាលានុវត្តភាព និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣-២០២៨។ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាពទាំងឡាយ ដែលចង្អុលបង្ហាញដោយផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សំដៅរួមចំណែកដល់ការសម្រេចបានទិសដៅគោលនយោបាយអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១- ការរៀបចំ ការធ្វើវិសោធនកម្ម និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីគតិយុត្តសម្រាប់ការធ្វើនិយ័តកម្ម ការធ្វើសុខដុមនីយកម្មមុខងារ និងការលើកកម្ពស់ភាពជឿទុកចិត្តពីអ្នកប្រើប្រាស់។

ទី២- ការសិក្សានិងការរៀបចំក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុបើកចំហ សម្រាប់ការចែករំលែក និងការបើកចំហទិន្នន័យ ដើម្បីផ្តល់កាលានុវត្តភាពថ្មីៗដល់ការអភិវឌ្ឍ និងការធ្វើនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់សហគ្រាសនិងធុរកិច្ចថ្មី ដែលធ្វើអាជីវកម្មក្នុងវិស័យពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ទី៣- ការបន្តកសាង ការធ្វើទំនើបកម្ម និងការជំរុញការចាប់យកនិងការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះ ក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ។

ទី៤- ការជំរុញការធ្វើទំនើបកម្មនិងការធ្វើសុវត្ថិភាពប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ប្រកបដោយបរិយាបន្ន ឈរលើគោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ី សំដៅជានាអធិបតេយ្យក្នុងប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុជាតិ។

ទី៥- ការអភិវឌ្ឍបច្ចេកវិទ្យានិយ័តកម្មនិងបច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីជួយសម្រួលនិងពង្រឹងប្រសិទ្ធភាពនៃអនុលោមភាពនិយ័តកម្ម ព្រមទាំងបង្កើនសមត្ថភាពវិភាគ តាមដាន និងគាំទ្រដល់ដំណើរការនៃការត្រួតពិនិត្យហានិភ័យ ប្រកបដោយបុរេសកម្មនិងប្រសិទ្ធភាព។

ទី៦- ការបង្កើនការបណ្តុះបណ្តាលចំណេះដឹងនិងជំនាញ ការផ្សព្វផ្សាយ ការធ្វើកិច្ចសហការ និងការពង្រីក ការស្រាវជ្រាវ ការអភិវឌ្ឍ ការធ្វើនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយថ្មីៗក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ទី៧- ការលើកកម្ពស់ការកសាងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ ឱ្យកាន់តែមានលក្ខណៈសម្បូរបែបនិងការពង្រឹងយន្តការដឹកនាំសម្របសម្រួលឱ្យមានភាពប្រទាក់ក្រឡានិងបំពេញឱ្យគ្នារវាងបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## សកម្មភាពនិងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន

ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលខាងលើនេះ ក្រសួង ស្ថាប័នទាំងអស់ត្រូវចូលរួមអនុវត្ត ដោយមានស្ថាប័នចម្បងៗចំនួន៣ សម្របសម្រួលដឹកនាំអនុវត្តសកម្មភាពនិងកម្មវិធីអាទិភាព ដូចតទៅ៖

**ទី១- ធនាគារជាតិនៃកម្ពុជា** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនិងការចែករំលែកទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ
- ប្រយុទ្ធនឹងបទល្មើសហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ពិនិត្យនិងសិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ចេញក្របខ័ណ្ឌធនាគារបើកចំហ(Open Banking Framework)
- ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីនិង/ឬពហុភាគីជាមួយនឹងប្រទេសក្នុងតំបន់ ដើម្បីគាំទ្រដល់ការទូទាត់សងប្រាក់ឬការផ្ទេរប្រាក់ឆ្លងដែន
- អភិវឌ្ឍនិងដាក់ឱ្យប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលសម្រាប់វិស័យហិរញ្ញវត្ថុនិងធនាគារ

- អភិវឌ្ឍនិងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីគាំទ្រដល់សេវា និងលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់សងប្រាក់ឌីជីថល
- រៀបចំវេទិកាសាធារណៈ ព្រឹត្តិការណ៍ កម្មវិធីប្រកួតប្រជែង កម្មវិធីពិព័រណ៍ ឬយុទ្ធនាការផ្សេងៗ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍ ក៏ដូចជាកាលានុវត្តភាពនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយសហការ សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងតួអង្គពាក់ព័ន្ធតាមការចាំបាច់
- សហការជាមួយនឹងគ្រប់តួអង្គសង្គមពាក់ព័ន្ធ ដើម្បីដាក់ចេញកម្មវិធីស្តីពីអក្ខរកម្មហិរញ្ញវត្ថុ អក្ខរកម្មឌីជីថល និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដល់សាធារណជនទូទៅនិងសហគ្រិន
- រៀបចំនិងដាក់ចេញបទប្បញ្ញត្តិនិងគោលការណ៍ណែនាំ សម្រាប់ប្រតិបត្តិការផ្តល់ប្រាក់កម្ចីឌីជីថលប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព
- ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ននិងយន្តការសុវត្ថិភាពក្នុងប្រតិបត្តិការទូទាត់សងប្រាក់ឌីជីថល
- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយទូទាត់សងប្រាក់ឌីជីថលជាមួយនឹងវិស័យសាធារណៈ និងវិស័យឯកជន
- លើកកម្ពស់ផលិតផលនិងសេវាធនាគារឌីជីថល ប្រកបដោយនវានុវត្តន៍
- ជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដាក់ឱ្យប្រើប្រាស់នូវការផ្តល់ប្រាក់កម្ចីឬសន្សំប្រាក់ឌីជីថល។

**ទី២- អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ផ្តោតការអនុវត្តលើសកម្មភាពអាទិភាព៖

- សិក្សានិងរៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ រួមទាំងកិច្ចការពារទិន្នន័យនិងឯកជនភាព ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងចូលរួមរៀបចំផែនការមេកសាងសមត្ថភាពនិងជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំ ការដាក់ឱ្យដំណើរការនិងការអភិវឌ្ឍបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយគិតគូរអំពីការធ្វើសុខដុមនីយកម្មមុខងារនិងការជំរុញការអភិវឌ្ឍនិងនិយ័តកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដែលមានលក្ខណៈនវានុវត្តន៍
- ជំរុញនិងលើកទឹកចិត្តដល់ការអភិវឌ្ឍនិងការប្រើប្រាស់ផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនិងកម្មវិធីវិមជ្ឈការ (dApp)
- លើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ ដើម្បីបង្កើននវានុវត្តន៍សេវានិងផលិតផលនិងធ្វើពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ
- លើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការរៀបចំវេទិកា សិក្ខាសាលានិងកម្មវិធីផ្សេងៗ រួមទាំងកម្មវិធីបណ្តុះបណ្តាល និងពន្លឿនធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យនិងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការបន្តការសិក្សាពីការដាក់ឱ្យប្រើប្រាស់នូវការធ្វើនិយ័តកម្មបច្ចេកវិទ្យាReg Tech និងSup Tech ក៏ដូចជា

ការរៀបចំបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងអាជីវកម្មទ្រព្យឱីជីថលនិងប្រតិបត្តិការហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល ជាដើម។

**ទី៣- គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** សម្របសម្រួលជាមួយក្រសួងពាណិជ្ជកម្មលើការអភិវឌ្ឍនិងការជំរុញការអនុវត្តយន្តការចុះបញ្ជីទ្រព្យបញ្ចាំសម្រាប់ចលនវត្ថុ( Collateral Registry for Movable Assets )។

# ជំពូកទី៤
# តម្រូវការធនធានហិរញ្ញវត្ថុនិងការកំណត់កម្មវិធីចំណាយ

ជំពូកនេះបង្ហាញអំពីតម្រូវការធនធានសម្រាប់ការវិនិយោគ ដើម្បីសម្រេចបានទិសដៅនិងចំណុចដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដោយចែកជា៣ផ្នែកធំៗ គឺ ផ្នែកទី១បង្ហាញអំពីតម្រូវការវិនិយោគសរុប ដោយបានកំណត់តម្រូវការហិរញ្ញវត្ថុពីវិស័យឯកជននិងវិស័យសាធារណៈ ផ្នែកទី២ បង្ហាញអំពីតម្រូវការវិនិយោគសាធារណៈ និងផ្នែកទី៣ បង្ហាញអំពីប្រភពហិរញ្ញប្បទានសក្ដានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ។ រាជរដ្ឋាភិបាលបន្តធ្វើឱ្យប្រសើរឡើងនូវភាពស៊ីចង្វាក់គ្នារវាងការរៀបចំផែនការ (ក្នុងក្របខ័ណ្ឌផ.យ.អ.ជ. និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល) ការរៀបចំថវិកា (ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា) ការគ្រប់គ្រងនិងអនុវត្តថវិកា តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាបាននូវប្រសិទ្ធភាពចំណាយ។

## ៤.១- តម្រូវការវិនិយោគសរុប

ដើម្បីសម្រេចបានគោលនយោបាយអាទិភាព សកម្មភាព និងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន ដែលបានកំណត់ក្នុង**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលត្រូវការវិនិយោគសរុបចំនួន៣០៥ ២១២ ប៊ីលានរៀល (៧៥ ៣៦១លានដុល្លារអាម៉េរិក) ពីវិស័យឯកជននិងវិស័យសាធារណៈ ក្នុងនោះ វិនិយោគឯកជនមានចំនួន២៤០ ៣១៨,៤ប៊ីលានរៀល (៥៩ ៣៣៧,៩លានដុល្លារអាម៉េរិក) ប្រមាណ៧៨,៧% នៃទុនវិនិយោគសរុប និងវិនិយោគសាធារណៈមានចំនួន៦៤ ៨៩៣,៦ប៊ីលានរៀល (១៦ ០២៣,១លានដុល្លារអាម៉េរិក) ប្រមាណ២១,៣% នៃទុនវិនិយោគសរុប។

### តារាងទី៤.១ : តម្រូវការវិនិយោគសរុបសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា

| ប្រភពហិរញ្ញប្បទាន | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប |
|---|---|---|---|---|---|---|
| | គិតជាប៊ីលានរៀល | | | | | |
| **វិនិយោគសាធារណៈសរុប** | ១០ ៧៨៨,២ | ១១ ៣៤០,៩ | ១២ ៤៦៤,៣ | ១៤ ១៤៤,៧ | ១៦ ១៥១,៥ | ៦៤ ៨៩៣,៦ |
| ហិរញ្ញប្បទានក្នុងស្រុក | ៤ ៥៨០,៣ | ៤ ៤៦៩,៧ | ៥ ២១២,០ | ៦ ៤៨៣,៧ | ៧ ៨៨៥,៥ | ២៨ ៦៣១,៥ |
| ហិរញ្ញប្បទានក្រៅប្រទេស | ៦ ២០៧,៩ | ៦ ៨៧១,៣ | ៧ ២៥២,៣ | ៧ ៦៦៥,០ | ៨ ២៦៥,៧ | ៣៦ ២៦២,១ |
| **វិនិយោគឯកជនសរុប** | ៣៨ ៨៨៨,៨ | ៤៦ ៤១៦,៨ | ៤៨ ៣៥៧,៤ | ៤៩ ៣៩៤,២ | ៥៧ ២៦១,១ | ២៤០ ៣១៨,៤ |
| ហិរញ្ញប្បទានក្នុងស្រុក | ២១ ៥៣៦,៨ | ២៧ ៨៧៦,៣ | ២៨ ៥៩៨,៩ | ២៨ ៣៣៧,៧ | ៣៤ ៨០០,៦ | ១៤៧ ១៥០,៣ |
| ហិរញ្ញប្បទានក្រៅប្រទេស | ១៧ ៣៥២,១ | ១៨ ៥៤០,៥ | ១៩ ៧៥៨,៥ | ២១ ០៥៦,៥ | ២២ ៤៦០,៥ | ៩៩ ១៦៨,១ |
| **វិនិយោគសរុប** | ៤៩ ៦៧៧,០ | ៥៧ ៧៥៤,៣ | ៦០ ៨២១,៧ | ៦៣ ៥៤២,៩ | ៧៣ ៤១២,៧ | ៣០៥ ២១២,០ |

| | គិតជាលានដុល្លារអាម៉េរិក | | | | | |
|---|---|---|---|---|---|---|
| **វិនិយោគសាធារណៈសរុប** | **២ ៦៦៣,៧** | **២ ៨០០,២** | **៣ ០៧៧,៦** | **៣ ៩៩៤,៥** | **៣ ៩៨៨,០** | **១៦ ០២៣,១** |
| ហិរញ្ញប្បទានក្នុងស្រុក | ១ ១៣០,៩ | ១ ១០៣,៦ | ១ ២៨៦,៩ | ១ ៦០០,៩ | ១ ៩៤៧,១ | ៧ ០៦៩,៥ |
| ហិរញ្ញប្បទានក្រៅប្រទេស | ១ ៥៣២,៨ | ១ ៦៩៦,៦ | ១ ៧៩០,៧ | ១ ៨៩២,៦ | ២ ០៤០,៩ | ៨ ៩៥៣,៦ |
| **វិនិយោគឯកជនសរុប** | **៩ ៦០២,២** | **១១ ៤៦០,៩** | **១១ ៩៤០,១** | **១២ ១៩៦,១** | **១៤ ១៣៨,៦** | **៥៩ ៣៣៧,៩** |
| ហិរញ្ញប្បទានក្នុងស្រុក | ៥ ៣១៧,៧ | ៦ ៨៨៣,០ | ៧ ០៦១,៥ | ៦ ៩៩៧,០ | ៨ ៥៩២,៧ | ៣៤ ៨៥១,៩ |
| ហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៨២,៥ | ៤ ៥៧៧,៩ | ៤ ៨៧៨,៦ | ៥ ១៩៩,១ | ៥ ៥៤៥,៨ | ២៤ ៤៨៦,០ |
| **វិនិយោគសរុប** | **១២ ២៦៥,៩** | **១៤ ២៦១,២** | **១៥ ០១៧,៧** | **១៥ ៦៨៩,៦** | **១៨ ១២៦,៦** | **៧៥ ៣៦១,០** |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*(ចំណាំ : អត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិកស្មើនឹង៤ ០៥០រៀល)*

## ៤.២- តម្រូវការវិនិយោគសាធារណៈ

រាជរដ្ឋាភិបាលត្រូវការវិនិយោគសាធារណៈសរុបចំនួន៦៤ ៨៩៣,៦ប៊ីលានរៀល(១៦ ០២៣,១ លានដុល្លារអាម៉េរិក) ដែលអាចទទួលបានពីប្រភពហិរញ្ញប្បទានក្នុងស្រុកចំនួន២៨ ៦៣១,៥ប៊ីលានរៀល (៧ ០៦៩,៥លានដុល្លារអាម៉េរិក) និងពីប្រភពហិរញ្ញប្បទានក្រៅស្រុកចំនួន៣៦ ២៦២,១ប៊ីលានរៀល (៨ ៩៥៣,៦លានដុល្លារអាម៉េរិក) សម្រាប់អនុវត្តគម្រោងវិនិយោគសំខាន់ៗ ដើម្បីសម្រេចបាន គោលនយោបាយអាទិភាព សកម្មភាព និងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន ដែលបានកំណត់ក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

## ៤.៣- ប្រភពហិរញ្ញប្បទានសក្តានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ

រាជរដ្ឋាភិបាលបាននិងកំពុងពិនិត្យមើលប្រភពហិរញ្ញប្បទានមួយចំនួនសម្រាប់គាំទ្រចំណាយ វិនិយោគសាធារណៈ រួមមាន ១) ហិរញ្ញប្បទានដោយថវិកាជាតិ ២) ហិរញ្ញប្បទានក្រៅប្រទេស ៣) ហិរញ្ញប្បទានតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ៤) ប្រភពហិរញ្ញប្បទានចម្រុះ ៥) ហិរញ្ញប្បទាន ដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ៦) ហិរញ្ញប្បទានដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត ៧) ហិរញ្ញប្បទាន ដោយឥណទានពាណិជ្ជកម្ម និង ៨) ប្រភពហិរញ្ញប្បទានផ្សេងៗទៀត។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តពង្រីកនូវកិច្ចប្រឹងប្រែងកៀរគរការវិនិយោគមូលធនបន្ថែមទៀត ដោយឈោងចាប់នូវកាលានុវត្តភាពថ្មីៗ តាមរយៈ ១) ការបង្កើនគុណភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ជាអតិបរមា ២) ការបង្កើនជំនួយឥតសំណង ដោយលើកទឹកចិត្តម្ចាស់ជំនួយឱ្យងាកទៅរកការរៀបចំ ថវិកាគាំទ្រវិញ ៣) ការស្វែងរកការបង្កើននូវឥណទានសម្បទាន តាមរយៈការចូលរួមពីដៃគូអភិវឌ្ឍដែល ផ្តល់សេវាឥណទានសម្បទាន និងការផ្តល់អាទិភាពដល់ការវិនិយោគណាដែលផ្តល់ផលចំណេញ

ខ្ពស់រយៈពេលវែង ដូចជាគម្រោងវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធជាដើម និង ៤) ការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន សម្រាប់គម្រោងវិនិយោគសាធារណៈធំៗ ដើម្បីកាត់បន្ថយនូវសម្ពាធលើធនធានមូលធនរបស់ជាតិ និងអាចទទួលបានការចូលរួមពីវិស័យឯកជនក្នុងការផ្តល់នូវសេវាសាធារណៈ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ។ ចំពោះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ការបែងចែកធនធានមូលធនតាមវិស័យនិងអនុវិស័យមានបង្ហាញក្នុងតារាងទី៤.២។

### តារាងទី៤.២ : ការបែងចែកតាមវិស័យនិងអនុវិស័យនៃការវិនិយោគវិស័យសាធារណៈ ក្នុងផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០២៤-២០២៨ | |
|---|---|---|---|
| | | ប៊ីលានរៀល | លានដុល្លារអាម៉េរិក |
| **វិស័យសង្គមកិច្ច** | | | |
| អប់រំ សីលធម៌ និងសាសនា | ១២ | ៧ ៧៨៧,២ | ១ ៩២២,៨ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| សុខាភិបាល | ១២ | ៧ ៧៨៧,២ | ១ ៩២២,៨ |
| កិច្ចគាំពារសង្គម/ការកាត់បន្ថយភាពក្រីក្រ | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| សរុប | ៣២ | ២០ ៧៦៦,០ | ៥ ១២៧,៤ |
| **វិស័យសេដ្ឋកិច្ច** | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| ដំណាំតាមរដូវ : ស្រូវនិងផ្សេងៗ | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៧ ៧៨៧,២ | ១ ៩២២,៨ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| សរុប | ២៤ | ១៥ ៥៧៤,៥ | ៣ ៨៤៥,៥ |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ដឹកជញ្ជូន(ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ៧ ៧៨៧,២ | ១ ៩២២,៨ |
| ទឹកនិងអនាម័យ(មិនគិតនៅជនបទ) | ២ | ១ ២៩៧,៩ | ៣២០,៥ |
| ថាមពលនិងអគ្គិសនី | ២ | ១ ២៩៧,៩ | ៣២០,៥ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៦៤៨,៩ | ១៦០,២ |
| ឌីជីថល | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| សរុប | ២១ | ១៣ ៦២៧,៧ | ៣ ៣៦៤,៩ |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ៩៧៣,៤ | ២៤០,៤ |
| ទេសចរណ៍ | ២ | ១ ២៩៧,៩ | ៣២០,៥ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |

| | | | |
|---|---|---|---|
| សហគមន៍និងសេវាកម្មសង្គម | ៤ | ២ ៥៩៥,៧ | ៦៤០,៩ |
| វប្បធម៌និងសិល្បៈ | ១,៥ | ៩៧៣,៤ | ២៤០,៤ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ៥ ១៩១,៥ | ១ ២៨១,៩ |
| សរុប | ២១ | ១៣ ៦២៧,៧ | ៣ ៣៦៤,៩ |
| មិនទាន់បែងចែក | ២ | ១ ២៩៧,៩ | ៣២០,៥ |
| **សរុបរួម** | **១០០** | **៦៤ ៨៩៣,៦** | **១៦ ០២៣,១** |

# ជំពូកទី៥
# យន្តការអនុវត្ត តាមដានត្រួតពិនិត្យ វាយតម្លៃ និង ការគ្រប់គ្រងហានិភ័យ

ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងជោគជ័យខ្ពស់ អាស្រ័យជាចម្បងលើការចូលរួមក្នុងស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្មបំផុតពីគ្រប់ក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំនិងអនុវត្តវិធានការល្អិតល្អន់ ផែនការសកម្មភាពជាក់លាក់ និងការរៀបចំយន្តការស្ថាប័នសម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃ ឱ្យបានច្បាស់លាស់ ហ្មត់ចត់ និងចំគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន **ក្រសួងផែនការ** ឱ្យបំពេញតួនាទីជាស្ថាប័នបង្គោលក្នុងការដឹកនាំនិងសម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តគោលនយោបាយអាទិភាពសំខាន់ៗ សកម្មភាព និងកម្មវិធីអាទិភាពសម្រាប់ក្រសួង ស្ថាប័ន ព្រមទាំងធ្វើរបាយការណ៍ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ ជូនរាជរដ្ឋាភិបាល។ ក្នុងន័យនេះ ដើម្បីជំរុញការអនុវត្តនេះឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញយន្តការជំរុញការអនុវត្ត យន្តការដឹកនាំសម្របសម្រួល និងយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដូចខាងក្រោម៖

## ៥.១- យន្តការដឹកនាំសម្របសម្រួល

ភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ទាមទារនូវការដឹកនាំសម្របសម្រួលដ៏ប៉ិនប្រសប់ រស់រវើក បុរេសកម្ម និងអន្តរសកម្ម ក្នុងការចាត់វិធានការឆ្លើយតបទាន់ពេល និងបត់បែនតាមការប្រែប្រួលនៃបរិការណ៍ជាក់ស្តែង ព្រមជាមួយនឹងការទទួលខុសត្រូវរួមគ្នាជាតួអង្គតែមួយនៃរាជរដ្ឋាភិបាលផង និងការទទួលខុសត្រូវតាមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗរៀងខ្លួនផង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលចាត់តាំងឱ្យក្រសួងផែនការ ជាសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់ដឹកនាំសម្របសម្រួលលើការបូកសរុបវឌ្ឍនភាព ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ដោយមានកិច្ចសហការពេញលេញពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធស្របតាម «**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**»។ នៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ផ.យ.អ.ជ. ការវាស់វែងលទ្ធផលត្រូវធ្វើឡើង ដោយក្រសួងផែនការនៅក្នុងកម្រិត លទ្ធផល(Outcomes) និងធាតុចេញ(Outputs)។ ដោយឡែក នៅក្នុងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** (គ.យ.ប.) ធ្វើការវាស់វែងលទ្ធផលនៅក្នុងកម្រិតកម្មវិបាក(Impacts) និងលទ្ធផល(Outcomes)។

សូចនាករសមិទ្ធកម្មសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃលើផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ត្រូវបានរៀបចំឡើង ស្របតាមសូចនាកររបស់ក្រសួង ស្ថាប័នដែលបានស្នើឡើង

ផ្អែកតាមស្នូល បរិស្ថានគ្រប់ដណ្តប់ និងបញ្ចកោណយុទ្ធសាស្ត្រទាំង៥ នៃ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដោយគិតគូររៀបចំក្នុងកម្រិតកម្មវិបាក(Impacts) លទ្ធផល(Outcomes) និងធាតុចេញ(Outputs) នៃខ្សែច្រវាក់លទ្ធផលផ្សារភ្ជាប់រវាងផ.យ.អ.ជ. និង**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ក្នុងទម្រង់ជាតារាងសូចនាករសមិទ្ធកម្ម ដោយមានការបញ្ជាក់នូវផ្នែកយុទ្ធសាស្ត្របញ្ចកោណ និងសូចនាករ ឯកតានៃការវាស់វែងសូចនាករគន្លឹះនីមួយៗ បន្ទាត់មូលដ្ឋាន ចំណុចដៅ និងក្រសួង ស្ថាប័នទទួលខុសត្រូវ។

## ៥.២- យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ គឺជាឧបករណ៍សម្រាប់តម្រង់ទិស និងកែសម្រួលការអនុវត្តវិធានការគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីអាទិភាព នៃក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រនានា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពខ្ពស់ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នេះ។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នទាំងអស់ ត្រូវរៀបចំនិងអនុវត្តផែនការសកម្មភាព និងកម្មវិធីអាទិភាពនានា សម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃផ្ទៃក្នុងរបស់ខ្លួន ដើម្បីផ្តិះរកបញ្ហាប្រឈមដែលអាចកើតឡើងជាយថាហេតុនិងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនោះទាន់ពេល សំដៅជំរុញការអនុវត្តផែនការសកម្មភាពនិងកម្មវិធីអាទិភាព ដែលមានវឌ្ឍនភាពយឺតឬមិនមានវឌ្ឍនភាព ឱ្យប្រព្រឹត្តទៅរួមគ្នា ប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងជោគជ័យ។

នៅក្រោមក្របខ័ណ្ឌនៃយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃនេះ ក្រសួង ស្ថាប័នត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ តាមសមត្ថកិច្ចទទួលខុសត្រូវរៀងៗខ្លួន និងដាក់របាយការណ៍នេះជូនក្រសួងផែនការ ដែលជាស្ថាប័នទទួលបន្ទុកដឹកនាំសម្របសម្រួលរួមលើការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទាំងមូលប្រចាំឆ្នាំ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល។ បន្ថែមលើនេះ ក្រសួងផែនការ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់ដឹកនាំសម្របសម្រួល ត្រូវវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ អំពីកម្មវិបាក លទ្ធផល និងធាតុចេញ ដែលជាការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងផ្អែកលើសមិទ្ធកម្មការងារដែលសម្រេចបាន ធៀបនឹងផែនការសកម្មភាពនិងកម្មវិធីអាទិភាព ដែលបានដាក់ចេញនៅក្នុងផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ លទ្ធផលនៃការវាយតម្លៃនេះនឹងត្រូវយកទៅប្រើប្រាស់ជាធាតុចូលដ៏សំខាន់សម្រាប់រៀបចំយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី២ ដើម្បីដោះស្រាយបញ្ហាប្រឈមនិងជំរុញការអនុវត្តឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ និងគ្រប់ជ្រុងជ្រោយ សម្រាប់បង្កើនវិបុលភាពសេដ្ឋកិច្ចសង្គមកម្ពុជា។

ក្រសួងផែនការមានតួនាទីនិងភារកិច្ចសម្របសម្រួលលើទិន្នន័យជំរឿន ការអង្កេត ទិន្នន័យរដ្ឋបាល និងស្ថិតិចាំបាច់នានា ដើម្បីគាំទ្រដល់ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់គ្រប់ក្រសួង ស្ថាប័ន

គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** សម្របសម្រួលនិងក្រើនរំលឹកដល់ក្រសួង ស្ថាប័ន ក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពជាប្រចាំឱ្យបានទាន់ពេល និងប្រកបដោយភាពត្រឹមត្រូវ ដឹកនាំការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្តផ.យ.អ.ជ. និងចូលរួមពង្រឹងសមត្ថភាពក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រដល់ប្រសិទ្ធភាពនៃការអនុវត្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផ.យ.អ.ជ. និងលើកជាអនុសាសន៍ជូនរាជរដ្ឋាភិបាល។ ជាក់ស្តែង ក្រសួងផែនការមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

១) ដឹកនាំនិងសម្របសម្រួលជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីវាស់វែងវឌ្ឍនភាពនៃការអនុវត្តផ.យ.អ.ជ. របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ធៀបនឹងចំណុចដៅនៃសូចនាករសមិទ្ធកម្មដែលបានកំណត់ ហើយនៅក្នុងក្របខ័ណ្ឌការគ្រប់គ្រងសមិទ្ធកម្ម ដឹកនាំ និងសម្របសម្រួលជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការកំណត់នូវនិយមន័យ វិធីសាស្ត្រនៃការគណនា និងប្រភពទិន្នន័យ សម្រាប់សូចនាករសមិទ្ធកម្មនីមួយៗ សំដៅបង្កើតឱ្យមានឧបករណ៍គ្រប់គ្រាន់សម្រាប់ការពិនិត្យលើភាពជាក់លាក់នៃការវាស់វែងសមិទ្ធកម្មនៃការអនុវត្តការងារកន្លងមក។

២) តាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃសមិទ្ធកម្មការងារ ដែលត្រូវបានដាក់ចេញនិងដឹកនាំសម្របសម្រួលជាមួយស្ថាប័នទទួលបន្ទុក ដើម្បីជំរុញការអនុវត្តវិធានការ និងកម្មវិធីអាទិភាពដែលមានវឌ្ឍនភាពយឺតឬមិនមានវឌ្ឍនភាព។

៣) រៀបចំរបាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ វាយតម្លៃពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០២៦ និងវាយតម្លៃចុងអាណត្តិនៅឆ្នាំ២០២៨ ដែលជាការវាយតម្លៃគ្រប់ជ្រុងជ្រោយនិងផ្អែកលើសមិទ្ធកម្មការងារដែលសម្រេចបានជាក់ស្តែង ជូនរាជរដ្ឋាភិបាល។

ជាមួយគ្នានេះ ក្រសួង ស្ថាប័នមានតួនាទីនិងភារកិច្ចដឹកនាំសម្របសម្រួលនិងផ្តួចផ្តើមការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការតាមវិស័យ ផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការថវិការបស់ខ្លួន ដើម្បីគាំទ្រដល់ការអនុវត្តផ.យ.អ.ជ. ឱ្យបានជោគជ័យ ដឹកនាំអនុវត្តផែនការសកម្មភាពដែលគាំទ្រដល់ការសម្រេចបាននូវចំណុចដៅនៃសូចនាករសមិទ្ធកម្មរបស់ខ្លួន ចូលរួមអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើសូចនាករសមិទ្ធកម្មក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងបូកសរុបរបាយការណ៍វឌ្ឍនភាពនិងផ្តល់មតិយោបល់ឱ្យទាន់ពេល ជូនក្រសួងផែនការ។

ជាក់ស្តែងក្រសួង ស្ថាប័នទទួលបន្ទុកនីមួយៗ ត្រូវបំពេញតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

១) រៀបចំផែនការសកម្មភាពនិងផែនការថវិកាជាក់លាក់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តវិធានការដែលត្រូវបានដាក់ចេញក្នុងផ.យ.អ.ជ.។

២) សហការជាមួយក្រសួងផែនការ ក្នុងការរៀបចំក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងការរៀបចំរបាយការណ៍វឌ្ឍនភាព ព្រមទាំងជំរុញការអនុវត្តវិធានការនិងកម្មវិធីអាទិភាព ដែលមានវឌ្ឍនភាពយឺតឬមិនមានវឌ្ឍនភាព។

៣) កំណត់ថ្នាក់ដឹកនាំនិងមន្ត្រីបង្គោលឱ្យបានច្បាស់លាស់ ដើម្បីប្រសិទ្ធភាពនៃការផ្តល់កិច្ចសម្រប សម្រួលជាមួយក្រសួងផែនការ។

## ៥.៣- ការរៀបចំរបាយការណ៍

ក្នុងនាមជាស្ថាប័នដឹកនាំសម្របសម្រួល ក្រសួងផែនការត្រូវរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំរបាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ វាយតម្លៃពាក់កណ្តាលអាណត្តិ និងវាយតម្លៃចុងអាណត្តិ ហើយទម្រង់របាយការណ៍ត្រូវប្រើទម្រង់របាយការណ៍រួម នៃក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៃការអនុវត្តផ.យ.អ.ជ.។ របាយការណ៍ទាំងនេះទាមទារនូវការវាយតម្លៃប្រកបដោយគុណភាពនិងភាពជឿជាក់ ក្នុងនោះត្រូវធានាឱ្យបានការប្រមូលទិន្នន័យ ការវិភាគ និងការផ្តល់ការសន្និដ្ឋានច្បាស់លាស់ ផ្អែកតាមវិធីសាស្ត្រ និងការវិភាគតាមបែបវិទ្យាសាស្ត្រស្ថិតិត្រឹមត្រូវ។ របាយការណ៍តាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានកំណត់ ដូចខាងក្រោម៖

១) របាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ ផ្តោតលើការតាមដានវឌ្ឍនភាពនៃការអនុវត្តផ.យ.អ.ជ. របស់ក្រសួង ស្ថាប័ន សំដៅកំណត់នូវវឌ្ឍនភាពនៃសមិទ្ធកម្មការងារនិង/ឬបញ្ហាប្រឈម ដើម្បីរកដំណោះស្រាយសមស្របនិងទាន់ពេល ក្នុងការជំរុញការអនុវត្តឱ្យសម្រេចបានលទ្ធផល ដែលបានកំណត់។

២) របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ផ្តោតលើការវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. ធៀបនឹងចំណុចដៅដែលបានកំណត់ក្នុងផ.យ.អ.ជ. ដើម្បីពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញនិងផ្តល់ដំណោះស្រាយនិងអនុសាសន៍សម្រាប់តម្រង់ទិស និងកែសម្រួលផែនការសកម្មភាពនិងអាទិភាពតាមវិស័យរបស់ក្រសួង ស្ថាប័នតាមករណីចាំបាច់។

៣) របាយការណ៍វាយតម្លៃចុងអាណត្តិ គ្របដណ្តប់លើការវាយតម្លៃលទ្ធផលនិងសូចនាករសមិទ្ធកម្មទាំងមូល ធៀបនឹងចំណុចដៅដែលបានកំណត់ក្នុងផ.យ.អ.ជ. ដែលលទ្ធផលនៃការវាយតម្លៃនេះ នឹងត្រូវប្រើប្រាស់ជាធាតុចូលដ៏សំខាន់សម្រាប់រៀបចំ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី២** និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានា។

គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវរៀបចំរបាយការណ៍ជូនក្រសួងផែនការ អនុវត្តទៅតាមក្របខ័ណ្ឌពេលនៃការរាយការណ៍ដែលត្រូវបានកំណត់ដូចខាងក្រោម៖

១) របាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវរាយការណ៍យ៉ាងយូរ១៥ថ្ងៃ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ។

២) របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិត្រូវរាយការណ៍យ៉ាងយូរត្រឹមត្រីមាសទី៣ ឆ្នាំ២០២៥។

៣) របាយការណ៍វាយតម្លៃចុងអាណត្តិ ត្រូវរាយការណ៍យ៉ាងយូរត្រឹមត្រីមាសទី៣ ឆ្នាំ២០២៧។

ដោយឡែក ក្រសួងផែនការត្រូវរៀបចំរបាយការណ៍នីមួយៗតាមពេលវេលាដែលបានកំណត់ដូចខាងក្រោម៖

១) របាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវបញ្ចប់យ៉ាងយូរ២ខែបន្ទាប់ពីទទួលបានរបាយការណ៍វឌ្ឍនភាពតាមដាននិងត្រួតពិនិត្យពីគ្រប់ក្រសួង ស្ថាប័នទាំងអស់។

២) របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ត្រូវបញ្ចប់យ៉ាងយូរ៣ខែ បន្ទាប់ពីទទួលបានរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ពីគ្រប់ក្រសួង ស្ថាប័នទាំងអស់។

៣) របាយការណ៍វាយតម្លៃចុងអាណត្តិ ត្រូវបញ្ចប់យ៉ាងយូរ៣ខែ បន្ទាប់ពីទទួលបានរបាយការណ៍វាយតម្លៃចុងអាណត្តិពីគ្រប់ក្រសួង ស្ថាប័នទាំងអស់។

## ៥.៤- ការគ្រប់គ្រងហានិភ័យ

ការអនុវត្តផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា អាចជួបហានិភ័យនិងបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ភាពខុសគ្នានៃសមត្ថភាពនិងធនធានមនុស្ស នៅតាមក្រសួង ស្ថាប័ន ក្នុងការបង្កើតសូចនាករ បានធ្វើឱ្យសូចនាករគន្លឹះរបស់ក្រសួង ស្ថាប័ន មានចំនួនច្រើន ក្នុងនោះវិធានការគោលនយោបាយខ្លះពុំទាន់មានសូចនាករវាស់វែងគ្រប់គ្រាន់ឬពុំអាចវាស់វែងបានល្អ
- ភាពមានកម្រិតនៃការវិភាជថវិកានិងការមិនទាន់ផ្តល់អាទិភាព នៅតាមក្រសួង ស្ថាប័នមួយចំនួន លើការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ បានធ្វើឱ្យការអនុវត្តផ.យ.អ.ជ. អាចមានវឌ្ឍភាពយឺត
- ទិន្នន័យនិងគុណភាពទិន្នន័យដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់គណនាសូចនាករសមិទ្ធកម្មនៃផ.យ.អ.ជ. នៅមានកម្រិត។ ទោះបីជាស្ថិតិនិងទិន្នន័យភាគច្រើនត្រូវបានប្រមូលនិងចងក្រងរួចរាល់ក៏ដោយ ស្ថិតិនិងទិន្នន័យមួយចំនួន មានភាពយឺតយ៉ាវ មិនគ្រប់តាមឆ្នាំ និងពុំទាន់ពេញលេញសម្រាប់ប្រើជាមូលដ្ឋាន ក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ
- ការផ្សារភ្ជាប់គ្នានៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ ទៅនឹងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន នៅមានកម្រិត។

ដើម្បីគ្រប់គ្រងហានិភ័យនិងបញ្ហាប្រឈមខាងលើ ក្រសួងផែនការបានគិតគូរជាវិធានការមួយចំនួនដូចខាងក្រោម៖

- ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន គួរផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរផ្តល់អាទិភាពថវិកាសមស្របជូនក្រសួងស្ថាប័ន សម្រាប់អនុវត្តការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ក៏ដូចជាការរៀបចំនិងការអនុវត្តផែនការអភិវឌ្ឍន៍ទិន្នន័យ ដែលគុណភាពនៃទិន្នន័យបច្ចុប្បន្ន ត្រូវបានរកឃើញថានៅមានកម្រិត និងមិនទាន់គ្រប់គ្រាន់
- ក្រសួងផែនការ ត្រូវផ្តល់ការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីបង្គោលនៅតាមក្រសួង ស្ថាប័នអំពីក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករគន្លឹះ សម្រាប់ការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃ

- ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការអភិវឌ្ឍន៍តាមវិស័យឬផែនការសកម្មភាពនិងផែនការយុទ្ធសាស្ត្រថវិកា ឱ្យអនុលោមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងត្រូវរៀបចំផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ខ្លួនឱ្យបានច្បាស់លាស់ ដើម្បីជំរុញការអនុវត្តតាមវិស័យរបស់ខ្លួនសម្រេចបានជោគជ័យខ្ពស់។

ជារួម ការកំណត់សូចនាករសមិទ្ធកម្មសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើផ.យ.អ.ជ. នេះឆ្លុះបញ្ចាំងនូវឆន្ទៈ កិច្ចខិតខំប្រឹងប្រែង និងការតាំងចិត្តមោះមុតរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ យ៉ាងណាមិញ ការអនុវត្តសូចនាករសមិទ្ធកម្មទាំងនេះអាចជួបនូវបញ្ហាប្រឈម ហានិភ័យនិងភាពមិនប្រាកដប្រជាខ្ពស់ ដូចជាការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច សង្គ្រាមពាណិជ្ជកម្ម ការគាំពារនិយម និងពហុវិបត្តិនានា ដែលពិបាកប៉ាន់ស្មាន។ ការណ៍នេះអាចមានការកែសម្រួលវិធានការ ផែនការសកម្មភាព និងកម្មវិធីអាទិភាពមួយចំនួននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ តាមការចាំបាច់។

# សេចក្តីសន្និដ្ឋាន

បច្ចុប្បន្ននិងក្នុងរយៈពេលប្រាំឆ្នាំទៅមុខ កម្ពុជា ក៏ដូចជាសកលលោកទាំងមូល បាននិងកំពុងជួបនូវបញ្ហាប្រឈមសកលមួយចំនួន ដូចជាភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ការគាំពារនិយម និងសង្គ្រាមពាណិជ្ជកម្មជាដើម និងការលេចឡើងនូវបញ្ហាប្រឈមថ្មីៗ ដែលបង្កឱ្យមានភាពមិនប្រាកដប្រជា និងហានិភ័យ និងមានកម្មវិបាកជាអវិជ្ជមានដោយផ្ទាល់និងប្រយោលលើកម្ពុជា។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងជំរុញការដ្ឋានកែទម្រង់ឱ្យកាន់តែស៊ីជម្រៅតាមវិស័យទាំងអស់ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ព្រមទាំងបន្សុីគ្នានូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទាំងឡាយ ដើម្បីបង្កើតជាកម្លាំងចលកររួមសម្រាប់កសាងមូលដ្ឋានគ្រឹះរឹងមាំនិងភាពធន់ ក្នុងការជំរុញវឌ្ឍនភាពសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព និងការលើកកម្ពស់វិបុលភាពសង្គមមួយកម្រិតថ្មីទៀត សម្រាប់ជាឧត្តមប្រយោជន៍ដល់ជាតិនិងប្រជាជនកម្ពុជា។

ដោយមាន **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ជាមគ្គុទ្ទេសក៍ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដោយបានគិតគូរយ៉ាងច្បាស់លាស់គ្រប់ជ្រុងជ្រោយលើគ្រប់ទិដ្ឋភាព និងមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នទាំងអស់ និងកិច្ចប្រជុំជាច្រើនដង ដើម្បីសម្រួចផែនការយុទ្ធសាស្ត្រនេះ ឱ្យខ្លីសមរម្យ ខ្លឹម និងអាចអនុវត្តបានដោយជោគជ័យតាមក្របខ័ណ្ឌពេលកំណត់។ ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះបានដាក់ចេញវិធានការ ផែនការសកម្មភាព កម្មវិធីអាទិភាពតាមវិស័យ និងសូចនាករសមិទ្ធកម្មច្បាស់លាស់ សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បី***ម្ខាង*** ជំរុញការអនុវត្តឱ្យសម្រេចបានជោគជ័យ និង***ម្ខាងទៀត*** ជំរុញការអនុវត្តវិធានការ ផែនការសកម្មភាព និងកម្មវិធីអាទិភាព**តាមវិស័យ** ដែលមានវឌ្ឍនភាពយឺតឬមិនមានវឌ្ឍនភាព សំដៅធានាការអនុវត្តអាចប្រព្រឹត្តទៅរួមគ្នា ប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

ជាមួយនឹងការត្រូវជម្នះនូវបញ្ហាប្រឈម ហានិភ័យ និងវិបត្តិទាំងឡាយ ព្រមទាំងចលនការនៃការខិតខំប្រឹងប្រែងជាប្រចាំជាប់មិនដាច់ និងការត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយតបទាន់ពេលពីគ្រប់ក្រសួង ស្ថាប័ន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះនឹងត្រូវបានអនុវត្តដោយជោគជ័យ ប្រកបដោយភាពបត់បែននិងស្របតាមកាលៈទេសៈនៃការប្រែប្រួលជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចនិងសង្គម ដើម្បីជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វឌ្ឍនភាព និងវិបុលភាពសង្គមកម្ពុជាកាន់តែថ្កើងថ្កានឡើងបន្ថែមទៀត ក៏ដូចជាដាក់កម្ពុជាលើវិថីលឿនប្រកបដោយភាពប្រាកដប្រជា និងមោះមុត ឆ្ពោះដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់មានអារ្យធម៌រុងរឿង។

# ឧបសម្ព័ន្ធទី១ : តារាងសូចនាករសមិទ្ធកម្មសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

| ផែនកយុទ្ធសាស្ត្របញ្ចកោណនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| **ស្នូលនៃយុទ្ធសាស្ត្រ : ការកែទម្រង់និងការពង្រឹងអភិបាលកិច្ច** | | | | | | | | | |
| **មុំទី១** | **ការពង្រឹងនិងការកែទម្រង់ស្ថាប័ន** | | | | | | | | |
| ១ | ចំនួនរដ្ឋបាលឃុំ សង្កាត់ ដែលអនុវត្តយន្តការច្រកចេញ-ចូលតែមួយ លើសេវាអត្តសញ្ញាណកម្ម | ឃុំ សង្កាត់ | ២៤ | ៥០០ | ១ ០០០ | ១ ៦៥២ | ១ ៦៥២ | ១ ៦៥២ | គ.ជ.អ.ប. |
| ២ | ច្បាប់និងលិខិតបទដ្ឋានគតិយុត្តបង្កើតថ្មីនិងកែសម្រួល | ចំនួន | ២៨ | ៤១ | ២៩ | ១៩ | ១១ | ៩ | ម.ស. |
| ៣ | ចំនួនក្រសួង ស្ថាប័នដែលបានកែសម្រួលរចនាសម្ព័ន្ធចប់សព្វគ្រប់ | ក្រសួង / ស្ថាប័ន | - | ៦ | ១០ | ១០ | ៣ | - | ម.ស. |
| **មុំទី២** | **ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ** | | | | | | | | |
| ១ | ចំនួនបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលការបណ្តុះបណ្តាល ដោយសាលាជាតិរដ្ឋបាលមូលដ្ឋានបន្ថែម | នាក់ | ៧០០ | ៧៥០ | ៨៥០ | ១ ១០០ | ១ ៥០០ | ២ ០០០ | គ.ជ.អ.ប. |
| ២ | ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលពីសាលាភូមិន្ទរដ្ឋបាល | នាក់ | ៣ ៧៨៥ | ៤ ៥៩៧ | ៥ ៥៨៣ | ៦ ៧៨០ | ៨ ២៣៤ | ១០ ០០០ | ម.ស. |
| **មុំទី៣** | **ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ** | | | | | | | | |
| ១ | ចំនួនក្រសួង ស្ថាប័ន ដែលអនុលោមបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្ត | ស្ថាប័ន អង្គភាព | ៣២៦ | ៧៨៥ | ៥៩៣ | ៦០៦ | ៦១៨ | ៦៣១ | អ.ធ.ក. |
| ២ | ចំនួនពាក្យបណ្តឹងដែលបានដោះស្រាយ | ករណី | ៨១ | ១៧០ | ១៧៥ | ១៨០ | ១៨៥ | ១៩០ | អ.ធ.ក. |
| ៣ | សន្ទស្សន៍នៃការបើកចំហថវិកា | ពិន្ទុ | ៤៣ | - | ៥០ | - | ៦០ | - | ស.ហ.វ. |
| **មុំទី៤** | **ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌** | | | | | | | | |
| ១ | សំណុំរឿងដែលត្រូវបានចាត់ការតាមសាលាជម្រះក្តី | ករណី | ៧០ ០០០ | ៩០ ០០០ | ៩៦ ៣០០ | ១០៣ ០៤១ | ១១០ ២៥៤ | ១១៧ ៩៧២ | ក.យ. |
| ២ | សំណុំរឿងវិវាទដែលត្រូវបានចាត់ការនៅក្រៅប្រព័ន្ធតុលាការ | ចំនួន | ៥០ | ៣០០ | ៥០០ | ៦០០ | ៧០០ | ៨០០ | ក.យ. (អ.ជ.ក.) |
| ៣ | ពាក្យស្នើសុំពន្លឿននិងពិនិត្យភាពមិនប្រក្រតីដែលត្រូវបានដោះស្រាយ | ចំនួន | ២០០ | ១០០០ | ៧០០ | ៥០០ | ៣០០ | ២០០ | ក.យ. |
| **មុំទី៥** | **ការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច** | | | | | | | | |
| ១ | ការពង្រឹងអនុលោមភាពនៃការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលទំនិញនិងសេវា ច្បាប់កិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ | % | ៥០ | ៥៣ | ៥៦ | ៦០ | ៦៥ | ៧០ | ព.ណ. |
| **បរិស្ថានគ្របដណ្តប់** | | | | | | | | | |
| **មុំទី១** | **ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | | |
| ១ | ចំនួនគ្រោះថ្នាក់ចរាចរណ៍ប្រចាំឆ្នាំ | ករណី | ៣ ២៤០ | ៣ ២១០ | ៣ ១៧៨ | ៣ ១៤៦ | ៣ ១១៥ | ៣ ០៨៤ | ម.ផ. |
| | | % | - | ០,៩២ | ០,៩៩ | ១,០ | ០,៩៨ | ០,៩៩ | |
| ២ | ចំនួនឃុំ សង្កាត់ ស គ្មានគ្រឿងញៀនដែលបានរៀបចំ(ថ្មី) | ឃុំ សង្កាត់ | - | ៥ | ៤១១ | ៤១១ | ៤១១ | ៤១៤ | អ.ជ.ប.គ.ញ. |
| ៣ | ផ្ទៃដីបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ | ហិកតា | ៤៤ ៤១៨ | ២៧ ៣៤៩ | ២២ ០៣៤ | ២១ ៦០០ | ១៣ ១៨៧ | ១៣ ១៨៧ | អ.ធ.ម. |
| ៤ | ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅដោយគ្រោះមហន្តរាយទឹកជំនន់ និងខ្យល់ព្យុះ មានទីជម្រក សេវាសុខភាព អាហារ និងទឹកស្អាតបរិភោគគ្រប់គ្រាន់ | % | ៩ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៥ | គ.ជ.គ.ម. |
| **មុំទី៣** | **ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | | | | | | | |
| ១ | ផ.ស.ស. តម្លៃបច្ចុប្បន្ន | ប៊ីលានរៀល | ១៧៧ ៣៥១ | ១៩១ ៨៦២ | ២០៨ ០០១ | ២២៦ ២០៣ | ២៤៦ ៧៨១ | ២៦៩ ៣១៧ | ស.ហ.វ. |
| | | លានដុល្លារអាម៉េរិក | ៤៣ ១៥១ | ៤៧ ១៣៧ | ៥១ ៣០៧ | ៥៥ ៨២៨ | ៦០ ៩៣៩ | ៦៦ ៥០៦ | |
| ២ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ | ដុល្លារ អាម៉េរិក/ម្នាក់ | ២ ៥២៥ | ២ ៧១៩ | ២ ៩១៩ | ៣ ១៣៤ | ៣ ៣៧៦ | ៣ ៦៣៧ | ស.ហ.វ. |
| ៣ | អត្រាកំណើនពិត នៃ ផ.ស.ស. | % | ៥,០ | ៦,០ | ៦,៣ | ៦,៣ | ៦,៥ | ៦,៥ | ស.ហ.វ. |
| ៤ | ចំណូលថវិកាសរុប ធៀបនឹង ផ.ស.ស. | % | ១៩,៨ | ១៥,០ | ១៥,២ | ១៥,២ | ១៥,៤ | ១៥,៦ | ស.ហ.វ. |
| ៥ | ចំណាយថវិកាសរុប ធៀបនឹង ផ.ស.ស. | % | ២១,១ | ១៨,០ | ១៨,២ | ១៧,៣ | ១៧,៤ | ១៧,៨ | ស.ហ.វ. |
| ៦ | អត្រាអតិផរណា( ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ) | % | ២,១ | ០,៨ | ៣,០ | ២,១ | ២,៥ | ២,៥ | ធ.ជ.ក. |
| ៧ | អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ( មធ្យមប្រចាំឆ្នាំ ) | រៀល/ដុល្លារ អាម៉េរិក | ៤ ១១០ | ៤ ០៧០ | ៤ ០៦០ | ៤ ០៥០ | ៤ ០៥០ | ៤ ០៥០ | ធ.ជ.ក. |
| **មុំទី៤** | **ការបន្តកសាងភាពជាដៃគូ ប្រកបដោយបរិយាបន្ន និងសក្តិសិទ្ធិភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** | | | | | | | | |
| ១ | ទំហំនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំ | លានដុល្លារ អាម៉េរិក | ១ ៧៩៥ | ១ ៨២០ | ១ ៨៥០ | ១ ៨៨៥ | ១ ៩២០ | ១ ៩៦០ | ក.អ.ក.(គ.សអ.ក.) |

| ផ្នែកយុទ្ធសាស្រ្តបញ្ហាកោណនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួងស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| ២ | ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផល ដោយដៃគូអភិវឌ្ឍ | % | ៨៤ | ៨៩ | ៨៩ | ៨៩ | ៨៩ | ៨៩ | ក.អ.ក.(គ.ស.អ.ក.) |
| **មុំទី៥** | **ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងសកលលោក** | | | | | | | | |
| ១ | មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស | ចំនួន | ១១ | ១៣ | ១៥ | ១៧ | ១៩ | ២១ | ព.ណ. |
| ២ | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី | ចំនួន | ៤ | ៦ | ៨ | ១០ | ១២ | ១៤ | ព.ណ. |
| ៣ | ទំហំនៃការនាំចេញទៅទីផ្សារពិភពលោក | លានដុល្លារ | ៤៨ ០១១ | ៥០ ៨៥៣ | ៥៤ ២៥៩ | ៥៧ ៦៦៣ | ៦១ ០៦៩ | ៦៤ ៤៧៣ | ព.ណ. |
| **បញ្ហាកោណទី១ : ការអភិវឌ្ឍមូលធនមនុស្ស** | | | | | | | | | |
| **មុំទី១** | **ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** | | | | | | | | |
| ១ | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ សរុប | % | ៦៤,៨ | ៦៥,៤ | ៦៦,៨ | ៦៨,២ | ៦៩,៦ | ៧១,០ | អ.យ.ក. |
| ២ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា សរុប | % | ៩៥,៨ | ៩៦,២ | ៩៦,៦ | ៩៧,០ | ៩៧,៤ | ៩៧,៨ | អ.យ.ក. |
| ៣ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សរុប | % | ៦៤,៨ | ៧៥,២ | ៧៥,៥ | ៧៦,០ | ៧៦,៥ | ៧៧,០ | អ.យ.ក. |
| ៤ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ សរុប | % | ៤៤,២ | ៤៤,៣ | ៤៤,៨ | ៤៥,៣ | ៤៥,៨ | ៤៦,៣ | អ.យ.ក. |
| ៥ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ)សរុប | % | ១៧,៩ | ១៨,៩ | ១៩,៩ | ២១,០ | ២២,០ | ២៣,០ | អ.យ.ក. |
| ៦ | អត្រាអក្ខរកម្មមនុស្សពេញវ័យ(១៥ឆ្នាំឡើង) | % | ៨៤,៧ | ៨៦,៥ | ៨៧,៤ | ៨៨,៨ | ៩០,០ | ៩១,៥ | អ.យ.ក. |
| ៧ | ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | នាក់ | ៣ ២៥៩ | ៣ ៨០៧ | ៤ ៣៥៥ | ៤ ៩០៤ | ៥ ៤៥២ | ៦ ០០០ | អ.យ.ក. |
| ៨ | ចំនួននិស្សិតជំនាញក្នុងផ្នែកបច្ចេកវិទ្យាឌីជីថល សរុប | នាក់ | ៧៣៧ | ៧៧៧ | ៨១៧ | ៨៥៧ | ៨៩៧ | ៩៣៧ | អ.យ.ក. |
| ៩ | ចំនួនមេដាយពីការប្រកួតកម្រិតតំបន់និងអន្តរជាតិក្នុងមួយឆ្នាំ | មេដាយ | ១០០ | ១០៤ | ១៣៩ | ១១០ | ១៤៦ | ១៥០ | អ.យ.ក. |
| ១០ | សាលារៀនគំរូ | ចំនួន | ១២០ | ២៥០ | ៣៦០ | ៤៧០ | ៥៨០ | ៧០០ | អ.យ.ក. |
| ១១ | ចំនួនសមណសិស្សប្រឡងជាប់ពុទ្ធិកបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ | អង្គ/នាក់ | ៣ ៩៥៩ | ៥ ៤៥៦ | ៥ ៦៥០ | ៥ ៧៥០ | ៥ ៨៥០ | ៥ ៩៥០ | ធ.ស. |
| | | % | ៧៧ | ៩៣ | ៩១ | ៩០ | ៨៩ | ៨៩ | |
| ១២ | ចំនួនសមណសិស្សប្រឡងជាប់ពុទ្ធិកទុតិយភូមិ | អង្គ/នាក់ | ៥២២ | ៥៤៩ | ៥៧០ | ៦០០ | ៦៣០ | ៦៤០ | ធ.ស. |
| | | % | ៩៤ | ៩៣ | ៩៥ | ៩២ | ៩០ | ៨១ | |
| ១៣ | ចំនួនសមណនិស្សិតប្រឡងជាប់ពុទ្ធិកឧត្តមសិក្សា និងក្រោយឧត្តមសិក្សា | អង្គ/នាក់ | ៩២៧ | ១ ១០៣ | ១ ៥១៤ | ២ ១៤៧ | ២ ៤៧៧ | ២ ៦៤០ | ធ.ស. |
| | | % | ៣៣ | ៣២ | ៤២ | ៥៦ | ៦២ | ៦៣ | |
| **មុំទី២** | **ការបណ្តុះបណ្តាលជំនាញបច្ចេកទេស** | | | | | | | | |
| ១ | ចំនួនគុណវុឌ្ឍិសម្រាប់កញ្ចប់ស្តង់ដាបណ្តុះបណ្តាល (ស្តង់ដាសមត្ថភាព, កម្មវិធីសិក្សា និងកញ្ចប់វាយតម្លៃ) ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ | គុណវុឌ្ឍិ | ១៨៨ | ២២៨ | ២៧១ | ៣១៧ | ៣៦៦ | ៤១៨ | ក.ប. |
| ២ | ចំនួនសិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ(គ្រឹះស្ថាន អ.ប.វ. សាធារណៈ ឯកជន អង្គការ/សមាគម ទាំងអស់ ដែលចុះបញ្ជីជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) | នាក់/ឆ្នាំ | ៨៥ ៩៨៧ | ១២៧ ៥៧៥ | ១៧៧ ០០០ | ២២០ ០០០ | ២៦៣ ០០០ | ៣០៦ ០០០ | ក.ប. |
| ៣ | អត្រាសិក្ខាកាម សិស្ស និស្សិតក្នុងកម្មវិធី អ.ប.វ. ក្រោយបញ្ចប់ការសិក្សា៣ខែ មានការងារឬមុខរបរដែលមានចំណូលខ្ពស់ជាងមុន | % | ៨០,០ | ៨០,៥ | ៨១,០ | ៨១,៥ | ៨២,០ | ៨២,៥ | ក.ប. |
| ៤ | អត្រានៃការពេញចិត្តរបស់និយោជក ចំពោះសិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថាន អ.ប.វ. | % | ៧០,០ | ៧២,៥ | ៧៥,០ | ៧៧,៥ | ៨០,០ | ៨២,៥ | ក.ប. |
| ៥ | អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃជនមានពិការភាពទទួលបានសេវាស្តារលទ្ធភាពពលកម្ម | នាក់ | ៦០ ៧៣៧ | ៦៣ ០០០ | ៦៣ ០៥០ | ៦៣ ១០០ | ៦៣ ១៥០ | ៦៣ ២០០ | ស.អ.យ. |
| | | % | | ៣,៧២ | ០,០៨ | ០,០៨ | ០,០៨ | ០,០៨ | |
| **មុំទី៣** | **ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន** | | | | | | | | |
| ១ | អត្រាមរណភាពមាតា | ក្នុង១០០ពាន់កំណើតរស់ | ១៧០ (CDHS 2014) | ១៥៤ (CDHS 2021-2022) | ១០០ | | | ៧០ | ស.ខ.ល. |
| ២ | ភាគរយនៃមណ្ឌលសុខភាពទទួលបានពិន្ទុគុណភាពលើសពី៥០% | % | ៤,៦១ | ១០,០០ | ៤០,០០ | ៦០,០០ | ៧០,០០ | ៨០,០០ | ស.ខ.ល. (PS1) |
| ៣ | ភាគរយនៃអ្នកជំងឺអាយុ៤០ឆ្នាំឡើងមានជំងឺទឹកនោមផ្អែម ដែលបានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ស្របតាមពិធីសារនៃការព្យាបាល | % | ១០ | ១១ | ១៥ | ២០ | ២៥ | ៣០ | ស.ខ.ល. |
| ៤ | ភាគរយនៃអ្នកជំងឺអាយុ៤០ឆ្នាំឡើងមានជំងឺឡើងសម្ពាធឈាម ដែលបានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ស្របតាមពិធីសារនៃការព្យាបាល | % | ១០ | ១១ | ១៥ | ២០ | ២៥ | ៣០ | ស.ខ.ល. |
| ៥ | ករណីឆ្លងថ្មីនៃជំងឺរបេងគ្រប់សណ្ឋាន | ក្នុងប្រជាជន ១០០ ពាន់នាក់ | ៣៣៥ | ២៧៨ | ២៦៨ | ២៥៩ | ២៥០ | ២៤០ | ស.ខ.ល. |
| ៦ | មន្ទីរពេទ្យបង្អែកកម្រិត១ ទទួលបានពិន្ទុគុណភាពលើសពី៥០% | % | ៦,៦៧ | ១០,០០ | ៦០,០០ | ៧០,០០ | ៨០,០០ | ៩០,០០ | ស.ខ.ល. (PS1) |
| | មន្ទីរពេទ្យបង្អែកកម្រិត២ ទទួលបានពិន្ទុគុណភាពលើសពី៥០% | % | ១៣,១៦ | ២៥,០០ | ៦០,០០ | ៧០,០០ | ៨០,០០ | ៩០,០០ | |
| | មន្ទីរពេទ្យបង្អែកកម្រិត៣ ទទួលបានពិន្ទុគុណភាពលើសពី៥០% | % | ៣៣,៣៣ | ៥០,០០ | ៧០,០០ | ៨០,០០ | ៨៥,០០ | ៩០,០០ | |

| ផ្នែកយុទ្ធសាស្ត្របញ្ចកោណនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួង ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| ៧ | សន្ទស្សន៍គ្របដណ្តប់សេវាសុខាភិបាលនៃការគ្របដណ្តប់សុខភាពជាសកល | រង្វាស់ពី 0-១០០ | ៥៨ (2021) | ៦០.១ | ៦៤ | ៦៨ | ៧០ | ៧២ | ស.ខ.ល |
| ៨ | អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុ១៥ ដល់៤៩ឆ្នាំ | % | ០,៥ (២០២២) | ០,៥ | ០,៥ | ០,៤ | ០,៤ | ០,៤ | អ.ជ.ប.ជ.អ. |
| ៩ | ភាគរយនៃអ្នកដែលទទួលការព្យាបាល ដោយថ្នាំប្រឆាំងនឹងមេរោគ មានមេរោគអេដស៍នៅក្នុងឈាមកម្រិតទាបបំផុត | % | ៩៨ (២០២២) | ៩៨ | ៩៨ | ៩៩ | ៩៩ | ៩៩ | អ.ជ.ប.ជ.អ. |
| ១០ | អត្រានៃគ្រួសារនៅតំបន់ជនបទដែលទទួលបានសេវាអនាម័យជាមូលដ្ឋាន | % | ៨៦,៦ | ៨៨,៦ | ៩០,០ | ៩៣,០ | ៩៥,០ | ៩៧,០ | ក.អ.ជ. |
| ១១ | អត្រានៃគ្រួសារនៅតំបន់ជនបទដែលទទួលបានសេវាអនាម័យគ្រប់គ្រងដោយសុវត្ថិភាព | % | ៣៥,០ | ៣៦,០ | ៣៨,០ | ៤២,០ | ៤៥,០ | ៤៨,០ | ក.អ.ជ. |
| ១២ | អត្រាប្រេវ៉ាឡង់នៃបញ្ហាគ្រិសគ្រិន ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ | % | ៣២,៤ (CDHS 2014) | ២១,៩ (CDHS 2021-2022) | ២០ | | | ១៥ | ក.ក.ជ. |
| ១៣ | អត្រាប្រេវ៉ាឡង់នៃបញ្ហាស្គមស្គាំង ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ | % | ៩,៦ (CDHS 2014) | ៩,៦ (CDHS 2021-2022) | ៥ | | | ៥ | ក.ក.ជ. |
| **មុំទី៤** | **ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង** | | | | | | | | |
| ១ | អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃចំនួនសមាជិក ប.ស.ស. | នាក់ | ៣០៣ ៨៧៤ | ៣៤០ ០០០ | ៣៥០ ០០០ | ៣៦០ ០០០ | ៣៧០ ០០០ | ៣៨០ ០០០ | ក.ប. |
| ២ | ចំនួនសហគ្រាសគ្រឹះស្ថានចុះបញ្ជីកាថ្មីប្រចាំឆ្នាំជាមួយ ប.ស.ស. | សហគ្រាស | ៤ ៩៥៧ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ក.ប. |
| ៣ | គ្រួសារដែលមានបណ្ណសមធម៌ទទួលបានប្រាក់ឧបត្ថម្ភគោល ពីកម្មវិធីជាតិជំនួយសង្គម | គ្រួសារ | ៧០៥ ៧១៦ | ៦៥៨ ០២១ | ៦៦០ ០០០ | ៦៧០ ០០០ | ៦៨០ ០០០ | ៦៨៥ ០០០ | ស.អ.យ. |
| ៤ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារមានប័ណ្ណសមធម៌ទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម | នាក់ | ៤៩ ៦៨៨ | ៤១ ៣៨១ | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ | ស.អ.យ. |
| ៥ | ជនចាស់ជរាមកពីគ្រួសារមានប័ណ្ណសមធម៌ទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម | នាក់ | - | ៣២៨ ២២៨ | ៣៣៥ ០០០ | ៣៤០ ០០០ | ៣៤៥ ០០០ | ៣៥០ ០០០ | ស.អ.យ. |
| ៦ | ជនមានពិការភាពមកពីគ្រួសារមានប័ណ្ណសមធម៌ទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម | នាក់ | - | ៣៥ ២៤៧ | ៣៨ ០០០ | ៤០ ០០០ | ៤២ ០០០ | ៤៤ ០០០ | ស.អ.យ. |
| ៧ | សិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សាមកពីគ្រួសារមានប័ណ្ណសមធម៌ទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម | នាក់ | - | ២៦៣ ៧៥១ | ៤០០ ០០០ | ៤១០ ០០០ | ៤២០ ០០០ | ៤៣០ ០០០ | ស.អ.យ. |
| ៨ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | គ្រួសារ | ៨៧ ៥៥៧ | ៨៨ ០៥៧ | ៨៨ ៥៥៧ | ៨៩ ០៥៧ | ៨៩ ៥៥៧ | ៩០ ០៥៧ | ដ.ន.ស. |
| ៩ | ផ្ទះដែលបានសាងសង់ជូនកងកម្លាំងឈរជើងតាមព្រំដែន និងគ្រួសារកងទ័ព នគរបាលជាតិ និងអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ | ខ្នងផ្ទះ | ៨ ១៤១ | ៨ ៦៤១ | ៩ ១៤១ | ៩ ៦៤១ | ១០ ១៤១ | ១០ ៦៤១ | ដ.ន.ស. |
| **មុំទី៥** | **ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន** | | | | | | | | |
| ១ | អត្រាកំណើននៃចំនួនព្រះសង្ឃ | អង្គ | ៧១ ១៧៩ | ៧៥ ៥៥៦ | ៧៥ ៧៥៦ | ៧៥ ៩៥៦ | ៧៦ ១៥៦ | ៧៦ ៣៥៦ | ធ.ស. |
| | | % | | ៦ | ៦ | ៧ | ៧ | ៧ | |
| **បញ្ចកោណទី២ : ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង** | | | | | | | | | |
| **មុំទី១** | **ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច** | | | | | | | | |
| ១ | ទុននិយោគក្នុងវិស័យឧស្សាហកម្ម ដែល ក.អ.ក. បានអនុម័ត | លាន ដុល្លារ | ២ ២៦០ | ២ ៥១០ | ២ ៨០០ | ៣ ១១០ | ៣ ៤៦០ | ៣ ៨៥០ | ក.អ.ក.(គ.វ.ក.) |
| ២ | ទេសចរអន្តរជាតិ | លាននាក់ | ៥,៤៥ | ៦,៧០ | ៧,២៤ | ៧,៦៧ | ៨,១៣ | ៨,៥៤ | ក.ទ.ច. |
| ៣ | ទេសចរជាតិ | ពាន់នាក់ | ១៨,៧៤ | ២២,៥២ | ២២,៦៣ | ២២,៧២ | ២២,៧៦ | ២៣,០០ | ក.ទ.ច. |
| ៤ | មូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ និងមណ្ឌលកម្សាន្តមេណីយដ្ឋាន | | | | | | | | ក.ទ.ច. |
| | សេវាកម្មស្នាក់នៅ | បន្ទប់ | ៨០ ១៤៨ | ៨៣ ៣៨៧ | ៨៥ ៤៦៣ | ៨៧ ១៧២ | ៨៨ ៩១៥ | ៩០ ៦៩៤ | |
| | ភោជនីយដ្ឋាន និងអាហារដ្ឋាន | កៅអី | ១៧៥ ៥១១ | ១៥៤ ៩២៣ | ១៥៨ ០២១ | ១៦១ ១៨២ | ១៦៤ ៤០៦ | ១៦៧ ៦៩៤ | |
| | មេណីយដ្ឋានទេសចរណ៍ | អាជ្ញាបណ្ណ | ៦២ | ៥៧ | ៥៧ | ៥៨ | ៥៩ | ៦០ | |
| ៥ | ចំណូលទេសចរណ៍អន្តរជាតិ | លានដុល្លារ អាម៉េរិក | ៣ ០៨៣ | ៣ ៦៣៧ | ៥ ១០០ | ៥ ៧៥០ | ៦ ៧០០ | ៧ ៥០០ | ក.ទ.ច. |
| **មុំទី២** | **ការលើកកម្ពស់ការតភ្ជាប់និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល** | | | | | | | | |
| ១ | ចំនួនខ្សែរថយន្តដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងទៀត | ខ្សែ | ១៣ | ១៧ | ២៣ | ៣០ | ៣៨ | ៤៦ | ស.ក. |
| ២ | អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃបរិមាណដឹកជញ្ជូនទំនិញសរុបតាមផែស្វយ័តក្រុងព្រះសីហនុ | ពាន់តោន | ៧ ៨៩៣ | ៩ ៧៩៧ | ១០ ៩៧៣ | ១២ ២៨៩ | ១៣ ៧៦៤ | ១៥ ៤១៦ | ស.ក. |
| | | % | | ២៤,១២% | ១២% | ១២% | ១២% | ១២% | |
| ៣ | អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃបរិមាណដឹកជញ្ជូនទំនិញសរុបតាមផែស្វយ័ត ភ្នំពេញ | ពាន់តោន | ៤ ២០៣,៦ | ៤ ៨៥៦,៤ | ៥ ០០៨ | ៥ ២៥៨ | ៥ ៥២១ | ៥ ៧៩៧ | ស.ក. |
| | | % | | ១៥,៥៣% | ៣,១២% | ៤,៩៩% | ៥% | ៥% | |
| ៤ | អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃបរិមាណដឹកជញ្ជូនទំនិញសរុប តាមផ្លូវដែក | ពាន់តោន | ១ ០៧៩,២ | ១ ១៦៨,៧ | ១ ១៩២,១ | ១ ២១៥,៩ | ១ ២៤០,៣ | ១ ២៦៥,១ | ស.ក. |
| | | % | | ៨,២៥% | ២% | ២% | ២% | ២% | |
| ៥ | ចំនួនអ្នកធ្វើដំណើរតាមផ្លូវអាកាស | ពាន់នាក់ | ៥ ១១១ | ៦ ២៤១ | ៧ ៤៨៩ | ៨ ៦១៣ | ៩ ៩០៤ | ១១ ៣៩០ | រ.ល.អ.ស. |

| ផ្នែកយុទ្ធសាស្ត្របញ្ហាគោលនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួងស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនអ្នកធ្វើដំណើរក្នុងស្រុក | ពាន់នាក់ | ១៩៥ | ៣១១ | ៣៧៣ | ៤២៩ | ៤៩៤ | ៥៦៨ | |
| | ចំនួនអ្នកធ្វើដំណើរអន្តរជាតិ | ពាន់នាក់ | ៤ ៩១៦ | ៥ ៩៣០ | ៧ ១១៦ | ៨ ១៨៣ | ៩ ៤១១ | ១០ ៨២៣ | |
| ៦ | អត្រាអ្នកប្រើប្រាស់ទូរសព្ទចល័តសរុប | ក្នុងប្រ/ជ ១០០នាក់ | ១២២,៨៨ | ១១៨,១២ | ១២១,៣៧ | ១២១,៩៥ | ១២២,៥៣ | ១២៣,១១ | ក.ប.ទ. |
| ៧ | អត្រាអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតសរុប | | | | | | | | ក.ប.ទ. |
| | អ៊ីនធឺណិតចល័ត | ក្នុងប្រ/ជ ១០០នាក់ | ១១១,០៩ | ១០៥,៨៧ | ១០៧,២៧ | ១០៨,៦៥ | ១១០,០៣ | ១១១,៤១ | |
| | អ៊ីនធឺណិតអចល័ត | ក្នុងប្រ/ជ ១០០នាក់ | ៣,៧០ | ៤,២២ | ៤,៥៩ | ៥,១៣ | ៥,៦៧ | ៦,២១ | |
| ៨ | ភាគរយនៃខ្នងផ្ទះប្រជាពលរដ្ឋ ដែលបានទទួលសេវាផ្គត់ផ្គង់អគ្គិសនីដូចគ្នា គិតទាំងគុណភាព ថ្លៃ ការតភ្ជាប់ចរន្ត និងសេវាផ្សេងៗ[១] | % | ៩៤,០២ | ៩៥,២៤ | ៩៦,៣៩ | ៩៧,៤៩ | ៩៨,៥៣ | ៩៩,៥២ | រ.ថ. |
| ៩ | សន្ទស្សន៍នៃការសន្សំសំចៃការប្រើប្រាស់ថាមពលតាមរយៈវិធានការប្រសិទ្ធភាពថាមពល ដោយធៀបនឹងសេណារីយ៉ូធុរកិច្ចធម្មតា | % | ៧ | ៩ | ១០ | ១២ | ១៤ | ១៦ | រ.ថ. |
| ១០ | ស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈមានច្បាប់ | % | ៨០ | ៨២ | ៨៤ | ៨៦ | ៨៨ | ៩០ | រ.ថ |
| ១១ | ភាគរយនៃខ្នងផ្ទះប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាតជាមូលដ្ឋាន | % | ៨១,២ | ៨៧ | ៨៩,៦ | ៩២,២ | ៩៤,៨ | ៩៧,៤ | ក.អ.ជ. |
| ១២ | អត្រានៃគ្រួសារនៅតំបន់ជនបទដែលទទួលបានសេវាទឹកស្អាតគ្រប់គ្រងដោយសុវត្ថិភាព | % | ១៩ | ២១ | ២៥ | ៣០ | ៣៥ | ៤០ | ក.អ.ជ. |
| **មុំទី៣** | **ការកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ** | | | | | | | | |
| ១ | ទុនវិនិយោគសរុប ដែល ក.អ.ក. បានការអនុម័ត | លានដុល្លារ | ៤ ៩៣០ | ៥ ១២០ | ៥ ៣១០ | ៥ ៥១០ | ៥ ៧២០ | ៥ ៩៤០ | ក.អ.ក.(គ.វ.ក.) |
| **មុំទី៤** | **ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក** | | | | | | | | |
| ១ | ទុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស | លានដុល្លារ | ៧៤០ | ៨៨០ | ១ ០៤០ | ១ ២៣០ | ១ ៤៥០ | ១ ៧១០ | ក.អ.ក.(គ.វ.ក.) |
| **មុំទី៥** | **ការធ្វើនវានុវត្តន៍ យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ** | | | | | | | | |
| ១ | គណនីឥណទាន | ចំនួន | ៣ ៨៥៦ ៨៩៩ | ៤ ០០៤ ២៤៩ | ៤ ២០៦ ៦៦៥ | ៤ ៤០៣ ៥៤០ | ៤៦០២៧៣៧ | ៤ ៨០៤ ០១១ | ធ.ជ.ក |
| **បញ្ហាគោលទី៣ : ការអភិវឌ្ឍវិស័យឯកជននិងការងារ** | | | | | | | | | |
| **មុំទី១** | **ការអភិវឌ្ឍទីផ្សារការងារ** | | | | | | | | |
| ១ | អត្រាកំណើនប្រចាំឆ្នាំនៃចំនួនការងារនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ | លាននាក់ | ១,៧ | ១,៩ | ២,១ | ២,៣ | ២,៥ | ២,៧ | ក.ប. |
| | | % | | ១១,៧៦ | ១០,៥៣ | ៩,៥២ | ៨,៦៩ | ៨,០០ | |
| ២ | កំណើនចំណែកនៃចំនួនការងារនៅក្នុងវិស័យកម្មន្ត-សាលមិនមែនកាត់ដេរ ធៀបនឹងចំនួនការងារសរុបនៅក្នុងវិស័យកម្មន្តសាលនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ | % | ១៧,៨ | ១៨,៥ | ១៩,០ | ១៩,៥ | ២០,០ | ២០,៥ | ក.ប. |
| ៣ | ចំនួនឱកាសការងារដែលបានប្រមូល និងផ្សព្វផ្សាយ | កន្លែង | ១៦៤ ៧០២ | ១៧០ ០០០ | ១៨០ ០០០ | ១៩០ ០០០ | ២០០ ០០០ | ២១០ ០០០ | ក.ប. |
| ៤ | អត្រាអ្នកទទួលបានការងារធ្វើតាមរយៈសេវាការងារសាធារណៈ | % | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ក.ប. |
| ៥ | ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាមានជំនាញ ដែលទៅធ្វើការនៅប្រទេសអភិវឌ្ឍន៍ | នាក់/ឆ្នាំ | ៧១ ០២៦ | ៧៥ ០០០ | ៨០ ០០០ | ៨៥ ០០០ | ៩០ ០០០ | ៩៥ ០០០ | ក.ប. |
| ៦ | ចំនួនសាកលវិទ្យាល័យនៅទូទាំងប្រទេសដែលមានការិយាល័យភ្ជាប់ទំនាក់ទំនងជាមួយសាកលវិទ្យាល័យនិងសហគ្រាស | % | ១ | ១ | ៦ | ១១ | ១៧ | ២២ | ក.វ.ប.ន. |
| ៧ | អត្រាគ្រួសារនៅជនបទមានការងារនិងមុខរបរបន្ថែមលើសពីកសិកម្មបន្ទាប់ពីការបណ្តុះបណ្តាលជំនាញបំណិនជីវិត | % | ១១,៣៤ | ១៣,៦០ | ១៥,៨៧ | ១៨,១៤ | ២០,៤១ | ២២,៦៨ | ក.អ.ជ. |
| **មុំទី២** | **ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** | | | | | | | | |
| ១ | ចំនួនកំណើនក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម | ក្រុមហ៊ុន/សហគ្រាស | ៤ ៧១៩ | ៤ ៧២២ | ៤ ៧០៧ | ៤ ៦៩១ | ៤ ៦៧៦ | ៤ ៦៦០ | ព.ណ. |
| ២ | ចំនួនម៉ាកសញ្ញាផលិតផលកម្ពុជាដែលបានចុះបញ្ជី | ម៉ាក | ៨ ១៩២ | ៨ ៤៣៨ | ៨ ៦៩១ | ៨ ៩៥២ | ៩ ២២០ | ៩ ៤៩៧ | ព.ណ. |
| **មុំទី៣** | **ការពង្រឹងភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន** | | | | | | | | |
| ១ | ចំនួនគម្រោងសរុប ដែលត្រូវបានបង្កើតឡើងក្រោមយន្តការភាពជាដៃគូវិស័យសាធារណៈនិងឯកជន | គម្រោង | ០ | ០ | ៥ | ៩ | ១០ | ១១ | ស.ហ.វ. |
| **មុំទី៤** | **ការពង្រឹងការប្រកួតប្រជែង** | | | | | | | | |
| ១ | ការយល់ឃើញរបស់ធុរជន និងសាធារណជនលើការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ | % | ៦០ | ៦៣ | ៦៥ | ៧០ | ៧៥ | ៨០ | ព.ណ. (PS1) |

[១] **សេវាផ្សេងៗ:** សំដៅដល់ការផ្តល់សេវាពាក់ព័ន្ធជាមួយការផ្គត់ផ្គង់អគ្គិសនីដែលរួមមាន ការស្នើសុំ ការផ្តល់សេវា ការផ្តល់ព័ត៌មាន ការផ្តល់វិក្កយបត្រ ការទូទាត់ ការទំនាក់ទំនងរបស់អ្នកប្រើប្រាស់អគ្គិសនីអាចធ្វើតាមប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធទូរស័ព្ទដៃ។

| ផ្នែកយុទ្ធសាស្ត្របញ្ហាគោលនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួង ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| ២ | អត្រាកំណើនប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកដែលបានដាក់តាំងបង្ហាញនៅក្នុងពិព័រណ៍ភូមិមួយផលិតផលមួយ | ប្រភេទ | ៣៥០ | ៤៣៨ | ៥៤៨ | ៦៨៥ | ៨៥៦ | ១ ០៧០ | ព.ណ. |
| | | % | - | ២៥,១៤ | ២៥,១១ | ២៥,០០ | ២៤,៩៦ | ២៥,០០ | |
| ៣ | ព្យាសកម្មនិងត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ | គ្រឿង/មុខ | ៤០ ២០៩ | ៤១ ៤៤៩ | ៤៣ ៥៨៤ | ៤៥ ៨០៦ | ៤៨ ១៣១ | ៥០ ៥៦៧ | ឧ.វ.ប.ន. |
| **មុំទី៥** | **ការពង្រឹងប្រព័ន្ធធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ** | | | | | | | | |
| ១ | ទុនបម្រុងអន្តរជាតិ | លានដុល្លារអាម៉េរិក | ១៩ ៩៩៨ | ២១ ២៥៩ | ២២ ៣៦៤ | ២៣ ០៣៥ | ២៣ ៧២៦ | ២៤ ៤៣៨ | ធ.ជ.ក. |
| | | ចំនួនខែនាំចូល | ៧,៥ | ៧,១ | ៦,៩ | ៦,៨ | ៦,៧ | ៦,៨ | |
| ២ | ទ្រព្យសកម្ម | ទ្រីលានរៀល | ៣៤៥ | ៣៦៩ | ៣៩៦ | ៤២៤ | ៤៥៦ | ៤៩៤ | ធ.ជ.ក. |
| ៣ | ប្រាក់បញ្ញើជារៀល | ទ្រីលានរៀល | ២២ | ២៧ | ២៩ | ៣១ | ៣៣ | ៣៥ | ធ.ជ.ក. |
| ៤ | ប្រាក់បញ្ញើជារូបិយបណ្ណ | ទ្រីលានរៀល | ១៧៥ | ២០៤ | ២២៥ | ២៤២ | ២៥៥ | ២៦៦ | ធ.ជ.ក. |
| **បញ្ហាគោលទី៤ : ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** | | | | | | | | | |
| **មុំទី១** | **ការធ្វើសុកបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ** | | | | | | | | |
| ១ | សន្ទស្សន៍វិសមភាពយេនឌ័រ(ពិន្ទុ ០-១) | សន្ទស្សន៍ | ០,៤៨៦ | ០,៤៨៥ | ០,៤៨៤ | ០,៤៨៣ | ០,៤៨២ | ០,៤៨១ | ក.ក.ន. |
| ២ | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ(១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារ បានពេញចិត្តនឹងមធ្យោបាយពន្យារកំណើតទំនើប | % | ៦០,៦ | | ៦៥,០ | | | ៦៨ | ស.ខ.ល. |
| ៣ | អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបមួយក្នុងចំណោមស្ត្រីបានរៀបការអាយុ១៥-៤៩ឆ្នាំ | % | ១៤,១៤ | ២៤,០០ | ២៥,០០ | ២៦,០០ | ២៧,០០ | ២៨,០០ | ស.ខ.ល. |
| ៤ | ភាគរយនៃស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលីក៩០គ្រាប់ | % | ៨៧,២៩ | ៨៨,០០ | ៨៩,០០ | ៩០,០០ | ៩០,០០ | ៩១,០០ | ស.ខ.ល. |
| ៥ | សមាមាត្រនៃការសម្រាលដោយបុគ្គលិកសុខាភិបាល | % | ៩០,៦២ | ៩០ | ៩១ | ៩២ | ៩៣ | ៩៤ | ស.ខ.ល. |
| ៦ | ការកសាងច្បាប់ និងគោលនយោបាយដែលដោះស្រាយ និងទទួលស្គាល់នូវតុល្យភាពជីវិតនិងការងារ និងការលើកកម្ពស់សេដ្ឋកិច្ច ដែលគិតគូរសុខុមាលភាព និងថែទាំ | ចំនួន | ១០ | ១១ | ១២ | ១៤ | ១៥ | ១៦ | ក.ក.ន. |
| ៧ | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងជីវិត | % | ២៩ (CDHS 2014) | ២១ (CDHS 2021-2022) | - | - | - | ១៨ | ក.ក.ន. |
| ៨ | សមាមាត្រស្ត្រីនៅក្នុងរដ្ឋសភា | % | ១៣,៦ | - | - | - | - | ២៥,០ | ក.ក.ន. |
| ៩ | សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | % | ២២ | - | - | - | ២៥ | ២៥ | ក.ក.ន. |
| ១០ | សមាមាត្រស្ត្រីមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈ | % | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ៣១ | ក.ក.ន. |
| ១១ | ភាគរយនៃចំនួនស្ត្រីពេញវ័យដែលប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ | % | ៥២ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ក.ក.ន. |
| **មុំទី២** | **ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព** | | | | | | | | |
| ១ | ទំហំផ្ទៃដីព្រៃឈើត្រូវបានស្តារឡើងវិញ | ពាន់ហិកតា | ១០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ក.ស.ក., ប.ស្ថ. |
| ២ | ផ្ទៃដីតំបន់ការពារធម្មជាតិ ត្រូវបានចុះបញ្ជិកាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ តំបន់ការពារធម្មជាតិ | ពាន់ហិកតា | ២៧៣,៥២ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ប.ស្ថ. |
| ៣ | អត្រានៃការបាត់បង់ព្រៃឈើប្រចាំឆ្នាំ | % | ២ | ១,៩០ | ១,៨៥ | ១,៧០ | ១,៥៥ | ១,៤០ | ប.ស្ថ. |
| ៤ | ចំនួនសំណង់បេតិកភណ្ឌដែលត្រូវបានជួលជុសនិងអភិរក្ស | ទីតាំង/ផ្នែក/ចំណុច | ២១៦ (២០២២) | ២២០ | ២២៥ | ២៣០ | ២៣៥ | ២៤០ | ក.វ.វ.ស. |
| ៥ | អភិរក្សបណ្ណសារបេតិកភណ្ឌ | % | ១៥ | ១៨ | ២១ | ២៤ | ២៧ | ៣០ | គ.រ.ម. |
| **មុំទី៣** | **ការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ** | | | | | | | | |
| ១ | តម្លៃសរុបផលិតផលកសិកម្ម(តម្លៃនៅកសិដ្ឋាន) | លានដុល្លារ | ៧ ៦២៥ | ៩ ១៥០ | ៩ ៤២៥ | ៩ ៧០៧ | ៩ ៩៩៩ | ១០ ១៩៨ | ក.ស.ក. |
| | | % | - | ២០ | ៣,០១ | ២,៩៩ | ៣,០១ | ១,៩៩ | |
| ២ | តម្លៃនាំចេញផលិតផលកសិកម្ម(ដំណាំ) | លានដុល្លារ | ៤ ៥៧០ | ៤ ៥៩៩ | ៤ ៦៨៨ | ៤ ៧៧៨ | ៤ ៨៧១ | ៤ ៩៦៥ | ក.ស.ក. |
| | | % | - | ០,៦៣ | ១,៩៤ | ១,៩២ | ១,៩៥ | ១,៩៣ | |
| ៣ | តម្លៃនាំចេញសត្វ និងផលិតផលសត្វ | លានដុល្លារ | ១២២ | ១២៥ | ១២៦ | ១២៨ | ១២៩ | ១៣០ | ក.ស.ក. |
| | | % | - | ២,៤ | ០,៨ | ១,៦ | ០,៨ | ០,៨ | |
| ៤ | តម្លៃផលិតផលជលផល (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | លានដុល្លារ | ១ ៩៧១ | ១ ៩៩៧ | ២ ០២១ | ២ ០៤៦ | ២ ០៧៣ | ២ ១០១ | ក.ស.ក. |
| | | % | - | ១,៣២ | ១,២០ | ១,២៤ | ១,៣២ | ១,៣៥ | |
| ៥ | ចំនួនសហគមន៍កសិកម្មទំនើបត្រូវបានបង្កើត និងដំណើរការ | ចំនួន | - | ៣ | ៣ | ៣ | ៣ | ៣ | ក.ស.ក. |
| ៦ | មន្ត្រីកសិកម្មឃុំត្រូវបានដាក់ពង្រាយ | នាក់/ឃុំ សង្កាត់ | ២៥០ | ១ ០០០ | ៣៥០ | - | - | - | ក.ស.ក. |

| ផ្នែកយុទ្ធសាស្ត្របញ្ហាគោលនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួងស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| ៧ | កំណើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវ (ប្រាំង និងវស្សា) | ហិកតា | ១ ៩៤៨ ៦៩៧ | ១ ៩៦៤ ៨៤៣ | ២ ០០៨ ៦៩៧ | ២ ០៣៨ ៦៩៧ | ២ ០៦៨ ៦៩៧ | ២ ០៩៨ ៦៩៧ | ធ.ទ.ឧ. |
| | | % | | ០,៨៣ | ៣,០៨ | ៤,៦២ | ៦,១៦ | ៧,៧០ | |
| ៨ | កំណើនលទ្ធភាពស្រោចស្រពដំណាំរួមផ្សំ | ហិកតា | ១៨ ៨៦៦ | ១៩ ១៤១ | ១៩ ៨៦៦ | ២០ ៣៦៦ | ២០ ៨៦៦ | ២១ ៣៦៦ | ធ.ទ.ឧ. |
| | | % | | ១,៤៦ | ៥,៣០ | ៧,៩៥ | ១០,៦០ | ១៣,២៥ | |
| ៩ | ភូមិគំរូដែលត្រូវបានទទួលស្គាល់ | ចំនួន | ៣០ | ៣០ | ៨០ | ១៣០ | ១៨០ | ២៣០ | ក.អ.ជ. |
| ១០ | ប្រវែងនិងភាគរយផ្លូវជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុ | គ.ម. | ៤ ៣៩៦ | ៤ ៦០៣ | ៤ ៨៣៣ | ៥ ១២៣ | ៥ ៤១៣ | ៥ ៧២៣ | ក.អ.ជ. |
| | | % | | ៤,៧០ | ៥,០០ | ៦,០០ | ៥,៦៦ | ៥,៧២ | |
| ១១ | អត្រាកំណើនប្រចាំឆ្នាំនៃប្រវែងផ្លូវជនបទត្រូវបានថែទាំ | គ.ម. | ៣ ៩១៨ | ៤ ២០០ | ៤ ៨០០ | ៥ ៣០០ | ៦ ០០០ | ៦ ៣០០ | ក.អ.ជ. |
| | | % | | ៧,២០ | ១៤,២៨ | ១០,៤១ | ១៣,២០ | ៥,០០ | |
| ១២ | ផលិតផលខ្មែរត្រូវបានបញ្ចូលជាផលិតផលភូមិមួយផលិតផលមួយ(២៥ រាជធានី ខេត្ត) | ប្រភេទ | ៥៥៩ | ៣៧០ | ៤០០ | ៤០០ | ៤០០ | ៤០០ | គ.ជ.ភ.១ ផ.១. |
| ១៣ | ចំនួនកសិករខ្នាតតូចដែលទទួលបានអត្ថប្រយោជន៍ពីគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច | គ្រួសារ | ៧៨ ២៨០ | ៧៨ ៧៩០ | ៨៨ ៧៩០ | ៩២ ២៩០ | ៩៥ ៧៩០ | ៩៩ ២៩០ | ព.ណ. |
| **មុំទី៤** | **ការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម** | | | | | | | | |
| ១ | អត្រាចុះបញ្ជីដីធ្លី(ចេញបណ្ណកម្មសិទ្ធិ) ជំហានទី២ លើក្បាលដីប៉ាន់ស្មាន ៥លានក្បាលដីបន្ថែម | % | - | ២០ | ៤០ | ៦០ | ៨០ | ១០០ | ដ.ន.ស. |
| ២ | ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | សហគមន៍ | ៤២ | ៥២ | ៦២ | ៧២ | ៨២ | ៩០ | ដ.ន.ស. |
| ៣ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ផែនការ | ២០១ | ២០៧ | ២១៧ | ២២៧ | ២៣៧ | ២៤៧ | ដ.ន.ស. |
| ៤ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ | ប្លង់គោល | ៩ | ១១ | ១៣ | ១៥ | ១៧ | ១៩ | ដ.ន.ស. |
| ៥ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងនិងទីប្រជុំជន | ប្លង់គោល | ១៨ | ១៩ | ២៣ | ២៧ | ៣០ | ៣៣ | ដ.ន.ស. |
| ៦ | ផែនការរៀបចំដែនដីថ្នាក់ខេត្ត/ប្លង់គោលប្រើប្រាស់ដីរាជធានី | ផែនការ/ប្លង់គោល | ៤ | ៧ | ១១ | ១៥ | ២០ | ២៥ | ដ.ន.ស. |
| ៧ | ផែនការរៀបចំដែនដីតាមតំបន់ | ផែនការ | - | ០ | ១ | ៣ | ៦ | ៨ | ដ.ន.ស. |
| ៨ | ផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រតាមក្រុង ស្រុក នៅតំបន់ឆ្នេរសមុទ្រកម្ពុជា | ក្រុង/ស្រុក | ២ | ៤ | ៦ | ៨ | ១០ | ១២ | ដ.ន.ស. |
| ៩ | កសាងផែនទីប្រើប្រាស់ដីកោះនៅតំបន់ឆ្នេរសមុទ្រកម្ពុជា | ចំនួនកោះ | - | ៣ | ៦ | ៩ | ១២ | ១៥ | ដ.ន.ស. |
| **មុំទី៥** | **ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង** | | | | | | | | |
| ១ | បរិមាណសរុបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | $MtCO_{2e}$ | ១២៩,២ | ១២៣,២ | ១១៧,១ | ១១០,៩ | ១០៤,៦ | ៩៨,២ | ប.ស្ត. (PS1) |
| ២ | ភាគរយនៃទីតាំងប្រភពបំពុលដែលមានការគ្រប់គ្រងសំណល់រឹង រាវ សំណល់គ្រោះថ្នាក់ សារធាតុបំពុលខ្យល់ សំឡេង និងរំញ័រ អនុលោមតាមបទប្បញ្ញត្តិបរិស្ថាន | % | ៥២ | ៦៥ | ៧៥ | ៨០ | ៨៥ | ៩០ | ប.ស្ត. |
| ៣ | ចំនួនស្ថានីយឧតុនិយម | ស្ថានីយ៍ | ៩៨ | ១០៣ | ១០៨ | ១១៣ | ១១៨ | ១២៣ | ធ.ទ.ឧ. |
| ៤ | ចំនួនស្ថានីយជលសាស្ត្រវាស់កម្ពស់ទឹក | ស្ថានីយ៍ | ៥៦ | ៦១ | ៦៦ | ៧១ | ៧៦ | ៨១ | ធ.ទ.ឧ. |
| ៥ | ចំនួនសហគមន៍កសិករប្រើប្រាស់ទឹក | កន្លែង | ៦១២ | ៦១៩ | ៦២៦ | ៦៣៣ | ៦៤០ | ៦៤៧ | ធ.ទ.ឧ. |
| ៦ | ភាគរយនៃអានុភាពប្រភពថាមពលកកើតឡើងវិញធៀបនឹងអានុភាពនៃប្រភពផ្គត់ផ្គង់ក្នុងស្រុក | % | ៥៧,២៥ | ៥៨,៩៥ | ៦០,៧៥ | ៦២,៣៧ | ៦៦,៥២ | ៦៨,៨១ | រ.ថ. |
| **បញ្ហាគោលទី៥ : ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល** | | | | | | | | | |
| **មុំទី១** | **ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល** | | | | | | | | |
| ១ | អត្រានៃការផ្តល់សេវាសាធារណៈក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម | % | ៧៥ | ៧៨ | ៨០ | ៩៣ | ៩៥ | ១០០ | ព.ណ. |
| ២ | រៀបចំនិងធ្វើឱ្យប្រសើរឡើងប្រព័ន្ធព័ត៌មានគ្រប់គ្រងមន្ត្រីរាជការ | ប្រព័ន្ធ | ២ | ២ | ៣ | ៣ | ៣ | ២ | ម.ស. |
| ៣ | ការពង្រីកការប្រើប្រាស់ថ្នាលឌីជីថលរបស់រាជរដ្ឋាភិបាល | ចំនួនថ្នាល | ១ | ៥ | ៦ | ៧ | ៨ | ៩ | ក.ប.ទ. |
| **មុំទី២** | **ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តឌីជីថល** | | | | | | | | |
| ១ | ជំរុញការរៀបចំ និងប្រើប្រាស់ថ្នាលឌីជីថលក្នុងវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម | សហគ្រាសឯកជន | ១២០ | ១២០ | ១២០ | ១២០ | ១២០ | ១២០ | ឧ.វ.ប.ន. |
| **មុំទី៣** | **ការកសាងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល** | | | | | | | | |
| ១ | ការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ពីអាណាឡូកទៅឌីជីថល | % | ៨៥ | ៨៨ | ៩០ | ៩២ | ៩៣ | ៩៥ | ព.ម. |
| ២ | ស្ថានីយ៍អង់តែនទូរគមនាគមន៍ | ចំនួន | ១២ ៨៤១ | ១៣ ៤៩៨ | ១៣ ៩០២ | ១៤ ៣២០ | ១៤ ៧៤៩ | ១៥ ១៩២ | ក.ប.ទ |
| ៣ | សេវាទូរសព្ទចល័ត(4G) គ្របដណ្តប់នៃប្រជាជនសរុប | % | ៩៣,១ | ៩៣,២ | ៩៣,៣ | ៩៣,៣ | ៩៣,៣ | ៩៣,៣ | ក.ប.ទ. |
| ៤ | បណ្តាញខ្សែកាបទូរគមនាគមន៍ | គីឡូម៉ែត្រ | ៣២ ៥៥០ | ៣៩ ៣០៩ | ៤៣ ២៤១ | ៤៧ ៥៦៥ | ៥២ ៣២២ | ៥៧ ៥៥៤ | ក.ប.ទ. |
| **មុំទី៤** | **ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល** | | | | | | | | |
| ១ | យន្តការសហប្រតិបត្តិការក្រុមការងារឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ(CERT)ក្នុងប្រទេសជាមួយវិស័យសាធារណៈនិងឯកជន | ចំនួន | ៣ | ៥ | ១០ | ១៥ | ២០ | ២៥ | ក.ប.ទ |
| ២ | យន្តការសហប្រតិបត្តិការក្រុមការងារឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ(CERT)ជាមួយអន្តរជាតិ | ចំនួន | ១០ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ក.ប.ទ |

| ផ្នែកយុទ្ធសាស្ត្របញ្ហាគោលនិងសូចនាករ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ក្រសួងស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| មុំទី៥ | ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ | | | | | | | | |
| ១ | ចំនួនប្រតិបត្តិការទូទាត់តាមឌីជីថល | លាន ប្រតិបត្តិការ | ១ ៧៨៦ | ២ ៧១២ | ២ ៩៨៣ | ៣ ២៨២ | ៣ ៦១០ | ៣ ៩៧១ | ធ.ជ.ក. |
| ២ | ទំហំទឹកប្រាក់ប្រតិបត្តិការទូទាត់តាមឌីជីថល | ប៊ីលានដុល្លារ អាម៉េរិក | ៤៩២ | ៦៣២ | ៦៦៣ | ៦៩៦ | ៧៣១ | ៧៦៨ | ធ.ជ.ក. |
| ៣ | ទំហំទឹកប្រាក់ប្រតិបត្តិការទូទាត់ឆ្លងដែន | ប៊ីលានរៀល | ២៣ | ៤០ | ៤២ | ៤៤ | ៤៦ | ៤៩ | ធ.ជ.ក. |

# ឧបសម្ព័ន្ធទី២ : ពាក្យបំព្រួញ

| | |
|---|---|
| គ.រ.ម. | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ម.ផ. | ក្រសួងមហាផ្ទៃ |
| កបទ.សអ. | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |
| ស.ហ.វ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ស.ក. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ព.ណ. | ក្រសួងពាណិជ្ជកម្ម |
| ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| ផ.ក. | ក្រសួងផែនការ |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ប.ស្ថ. | ក្រសួងបរិស្ថាន |
| ធ.ទ.ឧ. | ក្រសួងធនធានទឹកនិងឧតុនិយម |
| ព.ម. | ក្រសួងព័ត៌មាន |
| ក.យ. | ក្រសួងយុត្តិធម៌ |
| អ.ធ.ក. | ក្រសួងអធិការកិច្ច |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ស.ខ.ល. | ក្រសួងសុខាភិបាល |
| ស.ក. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ក.វ.វ.ស. | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ធ.ស. | ក្រសួងធម្មការនិងសាសនា |
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ប. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ម.ស. | ក្រសួងមុខងារសាធារណៈ |
| រ.ល.អ.ស. | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| រ.ក.ព. | រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន |
| អ.ប.ព. | អង្គភាពប្រឆាំងអំពើពុករលួយ |

| | |
|---|---|
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| ក.ប.ស. | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.ស.អ.ក. | គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| គ.វ.ក. | គណៈកម្មាធិការវិនិយោគនៃកម្ពុជា |
| ក.ក.ជ. | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| អ.ជ.ប.គ.ញ. | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| អ.ជ.ប.ជ.អ. | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| អ.ជ.ក. | អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ |
| អ.ធ.ម. | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ជ.គ.ម. | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| គ.ជ.ភ.១ ផ.១. | គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ |
| គ.ជ.ទ.ម.ក. | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| គ.អ.ច.ក. | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| អ.ប.វ. | អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| គ.ម. | គីឡូម៉ែត្រ |

ក្រសួងផែនការ

អាសយដ្ឋាន ៖ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
គេហទំព័រ ៖ www.mop.gov.kh